01667265


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire


ឯកសារលេខ D266/27 និង D267/35

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៥)

**អង្គបុរេជំនុំជម្រះ**

| | | |
|---|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គឹមសាន** | **ជាប្រធាន** |
| | **ចៅក្រម** Olivier BEAUVALLET | |
| | **ចៅក្រម ន៉ីយ ថុល** | |
| | **ចៅក្រម** Kang Jin BAIK | |
| | **ចៅក្រម ហួត វុទ្ធី** | |
| កាលបរិច្ឆេទ: | **០៧ មេសា ២០២១** | |
| ភាសាដើម: | **ខ្មែរ/អង់គ្លេស/បារាំង** | |
| ចំណាត់ថ្នាក់: | **សាធារណៈ** | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 04 / 2021
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Brenda J. Hollis

**<u>សហមេធាវីការពារក្តី មាស មុត</u>**

អាង ឧត្តម
Michael G. KARNAVAS

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រ៊ីនណា
វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

# មាតិកា

I. ប្រវត្តនីតិវិធី ........ 2

II. ការបញ្ចូលគ្នាក្នុងសំណុំរឿងតែមួយ ........ 13

III. បទដ្ឋាននៃការពិនិត្យឡើងវិញ ........ 14

IV. ភាពអាចទទួលយកបាន ........ 18

ក .ភាពអាចទទួលយកបានជាផ្លូវការ ........ 18

ខ .បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ........ 18

គ .បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ........ 19

ឃ .បណ្តឹងឧទ្ធរណ៍របស់សហមេធាវី ........ 19

១ .សារណា ........ 20

២ .ការពិភាក្សា ........ 24

ក .មូលដ្ឋាន ក ........ 32

ខ .មូលដ្ឋាន ខ ........ 33

V. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នា ........ 35

ក .ច្បាប់ជាធរមាន ........ 36

ខ .សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយផ្ទុយគ្នា ........ 40

គ .ការពិភាក្សា ........ 45

១ .គោលការណ៍ជាសារវន្ត គ្រប់គ្រងលើការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ........ 46

២ .ការដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ........ 48

៣ .សេចក្តីសង្កេតទាក់ទងនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា ........ 52

VI. អង្គសេចក្តី ........ 55

VII. សេចក្តីសម្រេច ..... 57

VIII. យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ធុល និងចៅក្រម ហួត វុទ្ធី ..... 58

IX. យោបល់របស់ចៅក្រម OLIVIER BEAUVALLET និងចៅក្រម KANG JIN BAIK ..... 61

ក .បញ្ហាបឋម ..... 61

១ .សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ ..... 62

ក .ប្រភពនៃសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ ..... 62

ខ .លក្ខណៈនៃយុត្តាធិការរបស់អង្គបុរេជំនុំជម្រះនៅដំណាក់កាល នៃកិច្ចដំណើរការនីតិវិធីចេញដីកាដំណោះស្រាយ ..... 63

គ .អន្តរាគមន៍ខុសៗគ្នា ដែលអង្គបុរេជំនុំជម្រះអាចធ្វើឡើង ..... 66

i . ការពិនិត្យលើបណ្តឹងឧទ្ធរណ៍ដែលភាគីបានដាក់ ..... 66

ii . ការពិនិត្យលើសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត ..... 67

iii . អំណាចបំពេញកិច្ចបន្ថែមទៀត ..... 69

ឃ .ការរម្លឹកពីសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ៖ ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបង្គាប់ឲ្យបោះត្រា និងបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ..... 70

២ .ការពន្យារពេលហួសហេតុក្នុងការចេញដីកាដំណោះស្រាយ ..... 72

ក .ការពន្យារពេលបញ្ចប់ការស៊ើបអង្កេត ..... 73

ខ .ការពន្យារពេលយូរហួសហេតុក្នុងការចេញដីកាដំណោះស្រាយ ..... 77

គ .ការពន្យារពេលផ្សេងៗទៀតដែលអាចចៀសវាងបាន ..... 78

ឃ .សេចក្តីសន្និដ្ឋាន ..... 79

៣ .សេចក្តីពិចារណាលើភស្តុតាង ..... 79

ក .ការវាយតម្លៃលើភស្តុតាង ..... 80

i. គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង ..... 80

ii .ការពិចារណាលើភស្តុតាងផ្តល់ជូនដោយជនរងគ្រោះ ..... 85

ខ .បទដ្ឋានភស្តុតាង ........ 87

គ .ចំនួនជនរងគ្រោះ ........ 90

ឃ .សេចក្តីសន្និដ្ឋាន ........ 91

៤ .តួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា និងអានុភាពនៃសេចក្តីសម្រេចរបស់តុលាការនេះដែលសន្និដ្ឋានថាពុំមានយុត្តាធិការបុគ្គល ........ 92

ខ. អង្គសេចក្តី ........ 97

១. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ........ 97

ក. សារណា ........ 97

ខ. ការពិភាក្សា ........ 106

២ .បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ........ 113

ក. សារណា ........ 113

i. មូលដ្ឋាន ក៖ កំហុសផ្នែកអង្គច្បាប់ស្តីពីការខកខានមិនបានធ្វើសំអាងហេតុ និងសំអាងច្បាប់ទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត និង ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងនោះ ........ 113

ii. មូលដ្ឋាន ខ៖ កំហុសផ្នែកអង្គច្បាប់ស្តីពីការខកខានមិនពិចារណាភស្តុតាងដែលបានដាក់នៅក្នុង សំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ........ 114

iii. មូលដ្ឋាន គ៖ កំហុសផ្នែកអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់ក្នុងវិសាលភាពនៃសំណុំរឿង ០០៣ ........ 116

iv. មូលដ្ឋាន ឃ៖ កំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ពាក់ព័ន្ធនឹងការពិចារណាទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ នៅពេលធ្វើការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ........ 117

v. មូលដ្ឋាន ង៖ កំហុសផ្នែកអង្គច្បាប់ និងអង្គហេតុនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ពាក់ព័ន្ធនឹងការពិនិត្យទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅពេលកំណត់កម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ........ 119

vi. មូលដ្ឋាន ច៖ សំអាងហេតុដោយខុសឆ្គង មានផលប៉ះពាល់ក្នុងការសម្រេចទៅលើបញ្ញាយុត្តាធិការបុគ្គល ........ 121

vii. មូលដ្ឋាន ឆ៖ កំហុសផ្នែកអង្គហេតុ នៅក្នុងផ្នែកនៃការពិនិត្យទៅលើជនរងគ្រោះក្នុងដីកាសម្រេចលើកលែងចោទប្រកាន់........ 121

viii. មូលដ្ឋាន ជ៖ កំហុសផ្នែកអង្គច្បាប់ដោយសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលត្រូវជាន់ខ្ពស់តែម្នាក់គត់ ........ 123

ix. អំណះអំណាងពាក់ព័ន្ធនឹងដីកាដំណោះស្រាយផ្ទុយគ្នា ........ 124

ខ. ការពិភាក្សា ........ 127

i. មូលដ្ឋាន ខ និង គ ........ 127

(ក) មូលដ្ឋាន (ខ) ........ 127

(i) សាវតារ ........ 128

(ii) សេចក្តីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) និងអានុភាពរបស់វាទៅលើការបញ្ចប់កិច្ចស៊ើបសួរ........ 129

(iii) ការស៊ើបអង្កេតពេញលេញក្នុងសំណុំរឿង ០០៣ ត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១..... 134

(ខ) មូលដ្ឋាន គ ........ 137

(គ) សេចក្តីសន្និដ្ឋាន ........ 140

ii. មូលដ្ឋាន ក, ឃ, ង, ច, ឆ និង ជ ........ 141

គ. សេចក្តីសន្និដ្ឋានអំពីសុពលភាព នៃដីកាដំណោះស្រាយ ........ 142

១. ច្បាប់ពាក់ព័ន្ធ និងការអនុវត្តក្នុងសំណុំរឿងបច្ចុប្បន្ន........ 143

ក. អត្ថន័យនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្ត" មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ........ 143

ខ. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០៤/២ មិនមានអានុភាពទៅលើសំណុំរឿងបច្ចុប្បន្នឡើយ ........ 147

i. ការបែងចែកគ្នានូវសមត្ថកិច្ចតុលាការ នៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ........................... 150

ii. ការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើគោលជំហរជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ................................................................................................................................ 152

iii. អង្គជំនុំជម្រះតុលាការកំពូល មិនអាចបិទបញ្ចប់សំណុំរឿង ០០៤/២ ដោយមិនមានដីកាដំណោះស្រាយដែលមានសុពលភាពឡើយ ............................................................................ 156

iv. ការសន្និដ្ឋានពាក់ព័ន្ធនឹងការបកស្រាយដោយភាន់ច្រឡំ របស់អង្គជំនុំជម្រះតុលាការកំពូល ....... 158

២. ការសម្រេចលើសុពលភាព នៃដីកាដំណោះស្រាយ ................................................... 160

ឃ. សេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល ............................................................ 160

១. ការវាយតម្លៃពីឧក្រិដ្ឋកម្មដែលបានចោទ ឬត្រូវបានចោទប្រកាន់........................................ 162

ក. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត.......................................................... 162

i. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ................................................ 163

ii. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតជាតិ ................................................... 164

ខ. ការពិភាក្សា ................................................................................... 165

i. ការពិនិត្យលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬត្រូវបានចោទប្រកាន់ .................................................................. 165

ii. ការពិនិត្យឡើងវិញលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតជាតិលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់ ............................................................. 169

២. ការវាយតម្លៃអំពីតួនាទី និងការទទួលខុសត្រូវរបស់ មាស មុត.......................................... 171

ក. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតលើតួនាទីរបស់ មាស មុត ................................ 171

i. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ................................................. 171

ii. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតជាតិ .................................................... 173

ខ. ពិភាក្សា........................................................................................ 176

i. សារៈសារនិងតួនាទីរបស់ មាស មុត .................................................................. 176

(ក) សមាជិកគណៈកម្មាធិការមជ្ឈិម ........ 178

(ខ) មេបញ្ជាការកងពលធំលេខ១៦៤ ........ 180

(i) ចាប់ផ្តើមពីមេបញ្ជាការកងពលធំលេខ៣ ........ 180

(ii) ការបង្កើតកងពលធំលេខ១៦៤ និងតួនាទីរបស់ មាស មុត ........ 181

(គ) លេខាតំបន់ស្វយ័តកំពង់សោម ........ 186

(ឃ) តួនាទីនៅក្នុងគណៈកម្មាធិការនៃអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា ........ 191

(ង) តួនាទីនៅភូមិភាគបូព៌ា និងខេត្តក្រចេះ ........ 193

ii. សេចក្តីសន្និដ្ឋានអំពីកម្រិតនៃការទទួលខុសត្រូវរបស់ លោក មាស មុត ........ 195

៣. សេចក្តីសន្និដ្ឋាន ........ 199

ង. សេចក្តីសន្និដ្ឋានចុងក្រោយ ........ 200

១ .ការយល់ឃើញនានាលើបណ្តឹងឧទ្ធរណ៍ និងអានុភាពនៃសេចក្តីពិចារណានេះ ........ 200

២. វិធានការសន្តិសុខ ........ 201

ក. ច្បាប់ជាធរមាន ........ 202

ខ. ការពិភាក្សា ........ 203

# តារាងអក្សរកាត់

| ពាក្យ | ពាក្យបំព្រួញ/អក្សរកាត់ |
|---|---|
| កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ | កិច្ចព្រមព្រៀង អ.វ.ត.ក |
| ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | អ.វ.ត.ក |
| ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់ទោសបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ដែលបានធ្វើវិសោធនកម្ម) | ច្បាប់ អ.វ.ត.ក |
| មជ្ឈមណ្ឌលឯកសារកម្ពុជា | DC-CAM |
| អង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក | តុលាការ EAC |
| គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ | ICCPR |
| រាជរដ្ឋាភិបាលកម្ពុជា | រាជរដ្ឋាភិបាល |
| បក្សកុម្មុយនីស្តកម្ពុជា | ប.ក.ក |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា | តុលាការ ICTR |
| តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន | តុលាការ SCSL |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូ ហ្គោស្លាវី | តុលាការ ICTY |

| | |
|---|---|
| យន្តការអន្តរជាតិជាសកលសម្រាប់តុលាការព្រហ្មទណ្ឌ | IRMCT |
| គណៈកម្មាធិការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ | គណៈកម្មាធិការសិទ្ធិមនុស្ស |
| លក្ខន្តិកៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងទីបអាហ្វ្រិកនៃតុលាការ សេនេហ្គាល់ ដើម្បីកាត់ទោសបទឧក្រិដ្ឋអន្តរជាតិដែលបានប្រព្រឹត្តនៅប្រទេសឆាត រវាងថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៨២ និង ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩០ | លក្ខន្តិកៈ EAC |
| សាលាក្តីពិសេសសម្រាប់ LEBANON | តុលាការ STL |
| អង្គការសហប្រជាជាតិ | UN |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធី |
| កងទ័ពបដិវត្តន៍កម្ពុជា | ក.ប.ក |
| គណៈកម្មាការច្បាប់អន្តរជាតិ | ILC |
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ | កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| អនុសញ្ញាស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ | អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ |
| គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ | គណៈកម្មាធិការសិទ្ធិមនុស្ស |
| អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា | អនុសញ្ញាវីយែន |
| កម្ពុជាប្រជាធិបតេយ្យ | DK |

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងឧទ្ធរណ៍ចំនួនបីប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរ ពោលគឺ ដីកាសម្រេចលើកលែងចោទ**ប្រកាន់** មាស មុត របស់សហចៅក្រមស៊ើបអង្កេតជាតិ ("ដីកាសម្រេចលើកលែងចោទប្រកាន់")[1] និងដីកាបញ្ជូនមាស មុត ទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[2]។ បណ្តឹងឧទ្ធរណ៍ទាំងបីមានដូចខាងក្រោម៖

(១) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៣ ដាក់នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ")[3]

(២) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ខែមេសា ឆ្នាំ ២០១៩ ដាក់នៅថ្ងៃទី ០៨ (បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ) [4]

និង

(៣) បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ (បណ្តឹងឧទ្ធរណ៍របស់ មាស មុត)[5]។

[1] សំណុំរឿង ០០៣ស.ច.ស.ក/ក.ត.វ.អ-២០០៩-០៩-០៧/"សំណុំរឿង ០០៣" ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 )"ដីកាសម្រេចលើកលែងចោទប្រកាន់ (D266)")។

[2] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 )"ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)"។

[3] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងទៅនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ (D267/3) "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3)"។

[4] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2 )"បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2)")។

[5] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ (D267/4 )"បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4)"។

## I. ប្រវត្តនីតិវិធី

១. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានចុះហត្ថលេខាលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ”) ដោយស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការទាក់ទងនឹងការទទួលខុសត្រូវរបស់ ស៊ូ ម៉េត និង មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[6]។

២. នៅថ្ងៃដដែលនេះដែរ អនុលោមតាមវិធានផ្ទៃក្នុង ៧១(២)[7] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិពុំយល់ស្របនឹងការចោទប្រកាន់លើបទល្មើសថ្មីៗ ដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ[8]។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនចំពោះការខ្វែងយោបល់គ្នានេះ[9]។

៣. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងបានដាក់សំណុំរឿងនេះជូនសហចៅក្រមស៊ើបអង្កេត[10]។ ការចោទប្រកាន់បន្ថែមត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលបានដាក់កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ

---

[6] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿឱ្យស៊ើបសួរទី២ ទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

[7] *វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (វិ.លើកទី៩) ត្រូវបានធ្វើវិសោធនកម្មថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង”) វិធាន ៧១(២)។

[8] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីប្រកាសជាលាយលក្ខណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីអង្គហេតុ និងសំអាងហេតុសម្រាប់ករណីខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ ១។

[9] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។

[10] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")[11]។

៤. ការខ្វែងយោបល់គ្នាជាសម្ងាត់ រវាងសហចៅក្រមស៊ើបអង្កេត ត្រូវបានកត់ត្រាក្នុងបញ្ជីកាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨។[12] ការខ្វែងយោបល់គ្នាទាំងនេះ មិនត្រូវបានដាក់ជូនទៅចំពោះមុខអង្គបុរេជំនុំជម្រះនោះទេ។

៥. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា ពួកគាត់បានសម្រេចថា កិច្ចស៊ើបសួរតាមផ្លូវតុលាការលើសំណុំរឿង ០០៣ បានបញ្ចប់ហើយ ("សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ឆ្នាំ២០១១")[13]។ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ លោកចៅក្រម Blunk បានលាលែងពីតំណែង ហើយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ[14] បានចេញដីកាសម្រេចស្តីអំពីការបើកកិច្ចស៊ើបអង្កេតបឋមឡើងវិញ[15]។

៦. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានជូនដំណឹងដល់ ស៊ូ ម៉េត និង មាស មុត ថា ពួកគេគឺជាជនសង្ស័យក្នុងសំណុំរឿង ០០៣ និងបានជូនដំណឹងស្តីពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានតំណាងផ្លូវច្បាប់ តាមជម្រើសរបស់ពួកគេ ហើយពួកគេមានសិទ្ធិចូលមើលសំណុំរឿងបាន[16]។

---

[11] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120។

[12] ដីកាសម្រេចលើកលែងចោទ (D267) កថាខណ្ឌ ៥,៧,១៥,២៧

[13] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីការបិទការស៊ើបសួរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D13 "សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ឆ្នាំ២០១១ (D13)"។

[14] សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-international-co-investigating-judge (៧ មេសា ២០២១)

[15] សំណុំរឿង ០០៣ ដីកាសម្រេចអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D28។

[16] សំណុំរឿង ០០៣ ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D30 (ទាក់ទងនឹង មាស មុត)។ សំណុំរឿង ០០៣ ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D31 (ទាក់ទងនឹង ស៊ូ ម៉េត)។

៧. នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីទាំងអស់ថា ស៊ូ ម៉េត បានស្លាប់ហើយ[17] ហើយបន្ទាប់មក កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានបញ្ចប់នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥[18]។

៨. នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខ អ.វ.ត.ក ដែលបានកំណត់ពេលឱ្យបង្ហាញខ្លួននៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤[19] ដែលសហមេធាវីការពារក្តីរបស់ មាស មុត ("សហមេធាវី") បានជំទាស់តវ៉ានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[20]។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ អង្គបុរេជំនុំជម្រះបានទទួលស្គាល់សុពលភាពនៃដីកាកោះនេះ[21]។

៩. ដោយការខកខានរបស់ មាស មុត ចំពោះការអនុវត្តតាមដីកាកោះនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ឱ្យនាំខ្លួនចំនួនពីរច្បាប់ប្រឆាំងនឹងគាត់ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ [22] និងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥[23]។

១០. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ មាស មុត *ដោយកំបាំងមុខ* ("ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ*)[24] និងបាន

---

[17] សំណុំរឿង ០០៣ ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់ នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ឯកសារ D86។

[18] សំណុំរឿង ០០៣ ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D86/3។

[19] សំណុំរឿង ០០៣ ដីកាកោះដើម្បីបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ A66។

[20] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤ និង ឯកសារ ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ A67/1.1។

[21] សំណុំរឿង ០០៣ (អបជ១៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D117/1/1/2។

[22] សំណុំរឿង ០០៣ ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ និងដាក់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ C1

[23] សំណុំរឿង ០០៣ ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ និងដាក់នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ C2។

[24] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។

បញ្ជាក់កម្រិតពីបទចោទនៅក្នុងឧបសម្ពន្ធភ្ជាប់ទៅនឹងដីកាសម្រេចស្ដីពី ("ការជូនដំណឹងអំពីបទចោទប្រកាន់")[25] ដែលសហមេធាវីបានប្ដឹងឧទ្ធរណ៍ជំទាស់តវ៉ា នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥[26] និងនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ដោយឡែកៗពីគ្នា[27]។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេច និងសេចក្ដីពិចារណារបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ទាំងនេះ[28]។

១១. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ក្នុងពេលបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលុបចោលបទចោទប្រកាន់មួយចំនួន និងទម្រង់នៃការទទួលខុសត្រូវប្រឆាំងនឹងគាត់[29] បានជូនដំណឹងគាត់ពីការកំណត់លក្ខណៈផ្លូវច្បាប់បន្ថែមទៀត ចំពោះអំពើប្រល័យពូជសាសន៍ និង

---

[25] សំណុំរឿង ០០៣ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចចោទប្រកាន់ មាស មុត ឯកសារ (D128) ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ និងបានដាក់ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៨ លេខ (D12.1) ។

[26] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128/1/3។

[27] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128.1/1/3។

[28] សំណុំរឿង ០០៣ (អបជ២២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D128.1/1/11។ សំណុំរឿង ០០៣ (អបជ២១) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រម ស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D128/1/9 ("សេចក្ដីពិចារណាលើការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (D128/1/9)")។

[29] សូមមើល សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ D174 ("កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (D174)") ទំព័រ ១៥-១៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រកាសថា បទចោទប្រកាន់អំពី ១) ការធ្វើទារុណកម្មនៅវត្តឥន្ទញាណ យោងតាមមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ២) មនុស្សឃាតដោយចេតនា ទាក់ទងនឹងកម្មាភិបាលស៊ីវិលនៅតំបន់ ៥០៥ ខេត្តក្រចេះ ៣) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងកម្មាភិបាលស៊ីវិលនៅតំបន់ ៥០៥ ខេត្តក្រចេះ ៤) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការបោសសម្អាតជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជាជនក្បត់ នៅកំពង់សោម ៥) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងកម្មាភិបាលកងពលលេខ ១១៧ និងកម្មាភិបាលតំបន់ ៥០៥ ខេត្តក្រចេះ ៦) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងជនបរទេស ក្រៅពីជនជាតិវៀតណាម និងថៃ និង ៧) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ "ជាតិពន្ធុ"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រកាសបន្ថែមទៀតថា ទម្រង់នៃការទទួលខុសត្រូវតាមរយៈការញុះញង់ ឬការជួយ និងជំរុញឲ្យមានឧក្រិដ្ឋកម្ម ត្រូវបានលុបចោលចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិទាំងអស់ ដែលជាបទចោទប្រកាន់នៅក្នុងដីកាសម្រេចថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥)។

ការរំលោភសេពសន្ថវៈ ហើយបានចោទប្រកាន់គាត់បន្ថែមចំពោះបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[30]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រកាសថា (១) ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ លែងមានសុពលភាព ហើយដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ត្រូវលុបចោល និង (២) បទចោទប្រកាន់នានានៅក្នុងដីកាសម្រេច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ដែលបានដាក់គាត់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ*លែងមានសុពលភាព ហើយបទចោទដែលបានធ្វើឡើងនៅក្នុងការបង្ហាញខ្លួនលើកដំបូងនេះ គឺជាបទចោទប្រកាន់ស្ថាពរប្រឆាំងនឹង មាស មុត[31]។

១២. នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានចេញដីកាស្តីពីការអនុវត្តតាមការធានាអះអាងដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្ត នៅពេលបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥[32]។

១៣. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងលើកទី១ នៃការបញ្ចប់កិច្ចស៊ើបសួរ ("សេចក្តីជូនដំណឹងលើកទី១ យោងតាមវិធាន ៦៦(១)")[33]។

១៤. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកអង្គហេតុនានាដែលបានចោទប្រកាន់ចេញ យោងតាមវិធាន ៦៦*ស្ទួន* ("ដីកាសម្រេចយោងតាមវិធាន *៦៦ស្ទួន*")[34]។

១៥. នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីជូន

---

[30] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (D174) ទំព័រ ២-៩។

[31] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (D174) ទំព័រ ១៥-១៦។

[32] សំណុំរឿង ០០៣ ដីកាស្តីពីការអនុវត្តតាមការធានាអះអាងដែល មាស មុត បានស្នើឡើងដោយស្ម័គ្រចិត្ត នៅពេលបង្ហាញខ្លួនលើកដំបូងចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D174/2 ("ដីកាស្តីពីការអនុវត្តតាមការធានាអះអាងដោយស្ម័គ្រចិត្ត (D174/2)")។

[33] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D225 ("សេចក្តីជូនដំណឹងលើកទី១ យោងតាមវិធាន ៦៦(១) (D225)")។

[34] សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226 ("ដីកាសម្រេចយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* (D226)")។

ដំណឹងលើកទី២ ស្ដីពីការបិទកិច្ចស៊ើបសួរ ("សេចក្ដីជូនដំណឹងលើកទីពីរ យោងតាមវិធាន ៦៦(១)")[35]។

១៦. នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ អនុលោមតាមវិធាន ៦៦(៤) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជូនសំណុំរឿងទៅឲ្យសហព្រះអាជ្ញាពិនិត្យ ដោយស្នើឲ្យពួកគាត់ដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនក្នុងរយៈពេលបីខែ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[36]។ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យនេះ ត្រូវបានចេញតែជាភាសាអង់គ្លេសប៉ុណ្ណោះ។

១៧. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើឲ្យសហចៅក្រមស៊ើបអង្កេត (១) ផ្ដល់យោបល់ថាតើសំណៅបកប្រែជាភាសាខ្មែរ នៃដីកាបញ្ជូនរឿងទៅពិនិត្យ នឹងត្រូវជូនដំណឹងនៅពេលណា និង (២) កែប្រែកាលបរិច្ឆេទកំណត់ពេលវេលាសម្រាប់ការដាក់ដីកាសន្និដ្ឋានស្ថាពររបស់គាត់[37]។

១៨. នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧ សំណៅបកប្រែជាភាសាខ្មែរ នៃដីកាបញ្ជូនរឿងទៅពិនិត្យត្រូវបានជូនដំណឹង។

១៩. ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេច ("ដីកាសម្រេចលើកាលបរិច្ឆេទ") ដោយបង្គាប់ឲ្យ (១) សហព្រះរាជអាជ្ញាអន្តរជាតិដាក់ដីកាសន្និដ្ឋានស្ថាពររបស់គាត់តែជាភាសាអង់គ្លេស នៅក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាបញ្ជូនសំណុំរឿងទៅពិនិត្យទាំងជាភាសាអង់គ្លេស និងភាសាខ្មែរ និង (២) សហមេធាវីដាក់ចម្លើយតបរបស់ខ្លួនតែជាភាសាអង់គ្លេស នៅក្នុងរយៈពេលប្រាំមួយសប្ដាហ៍ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែរួចរាល់ពេញលេញនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[38]។

---

[35] សំណុំរឿង ០០៣ សេចក្ដីជូនដំណឹងលើកទី ២ ស្ដីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D252 ("សេចក្ដីជូនដំណឹងលើកទី ២ ស្ដីពីការបិទកិច្ចស៊ើបសួរ (D252)")។

[36] សំណុំរឿង ០០៣ ដីកាបញ្ជូនរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D256។

[37] សំណុំរឿង ០០៣ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំព័ត៌មានអំពីកាលបរិច្ឆេទរំពឹងទុកនៃការជូនដំណឹងអំពីសំណៅជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅពិនិត្យ និងសំណើសុំកែប្រែកាលវិភាគសម្រាប់ដាក់ដីកាសន្និដ្ឋានស្ថាពរ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D256/1។

[38] សំណុំរឿង ០០៣ ដីកាសម្រេចលើកាលបរិច្ឆេទដើម្បីដាក់ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់មេធាវីការពារក្ដី ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D256/3។

២០. នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា ពួកគាត់បានពិចារណាលើដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នា ដោយសំអាងលើការមិនចុះសម្រុងគ្នារវាងពួកគាត់ ដែលអនុញ្ញាតនៅក្រោមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក និងផលវិបាកទំនងជាកើតឡើងសម្រាប់ដំណើរការបណ្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧(១៣)[39]។

២១. នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ សហមេធាវីបានស្នើឲ្យសហចៅក្រមស៊ើបអង្កេត ពិចារណាឡើងវិញលើដីកាសម្រេចស្ដីពីការកំណត់កាលវិភាគ[40] ហើយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្គាប់ឲ្យសហមេធាវីដាក់ចម្លើយតបរបស់ពួកគេតែជាភាសាអង់គ្លេស ក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែរួចរាល់ពេញលេញនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[41]។

២២. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនដោយស្នើសុំឲ្យបដិសេធបទចោទប្រកាន់ទាំងអស់ចោល[42] ហើយនៅថ្ងៃដដែលនេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើសុំឲ្យចោទប្រកាន់ មាស មុត និងបញ្ជូនគាត់ទៅជំនុំជម្រះ[43] (“ដីកាសន្និដ្ឋានស្ថាពរ”)។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ សហមេធាវីបានដាក់ចម្លើយរបស់ពួកគេតបទៅនឹង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[44]។

---

[39] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D262។

[40] សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើដីកាសម្រេចស្ដីពីកាលវិភាគនៃការដាក់ដីកាសន្និដ្ឋានស្ថាពររបស់អយ្យការ និងចម្លើយរបស់មេធាវីការពារក្ដី ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D256/4។

[41] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំពិចារណាឡើងវិញលើកាលបរិច្ឆេទនៃការដាក់ចម្លើយតបរបស់មេធាវីការពារក្ដី ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ឯកសារ D256/5។

[42] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/6។

[43] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/7។

[44] សំណុំរឿង ០០៣ ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ (កំណែត្រូវបានដាក់នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨) ឯកសារ D256/11 (សហមេធាវីស្នើសហចៅក្រមស៊ើប

01667282



២៣. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំង មាស មុត[45] ចំណែកសហចៅក្រមស៊ើបអង្កេតជាតិវិញបានចេញ ដីកាសម្រេចលើកលែងចោទប្រកាន់[46] (ហៅជារួមថា "ដីកាដំណោះស្រាយ")។ ដីកាដំណោះស្រាយត្រូវបានដាក់ជូនដាច់ដោយឡែកពីគ្នា ជាភាសាអង់គ្លេស និងភាសាខ្មែរតែប៉ុណ្ណោះ ឯសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ។

២៤. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ សហមេធាវីបានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត[47]។ សំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរនេះមិនទាន់បានជូនដំណឹងនៅឡើយទេ។

២៥. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យភាគីដាក់សារណាស្តីពីបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីពេលជូនដំណឹងអំពីការបកប្រែដីកាដំណោះស្រាយទាំងពីរ និងដាក់សារណានានាកម្រាស់ត្រឹម ១០០ ទំព័រ[48]។

២៦. ការបកប្រែជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានជូនដំណឹងនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩។

---

អង្កេតឱ្យផ្អាកកិច្ចដំណើរការនីតិវិធីទាំងស្រុងជាអចិន្ត្រៃយ៍ ឬជាជម្រើសម្យ៉ាងទៀត ចេញដីកាលើកលែងការចោទប្រកាន់)។ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមសំណើរបស់សហមេធាវីការពារក្តីម្តងទៀត (សូមមើល សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ផ្តល់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដំបូងដាក់នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ និងកែតម្រូវនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/8) សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្តល់ជូនមេធាវីការពារក្តីនូវពេលវេលាបន្ថែមចំនួន ២០ ថ្ងៃទៀត ដើម្បីដាក់ចម្លើយតប (សូមមើល សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំពន្យារពេលកំណត់ឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/9)។

[45] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)។

[46] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266)។

[47] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរបសរបស់ មាស មុត ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D267/1។

[48] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ សម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសុំដាក់បណ្តឹងឧទ្ធរណ៍របស់គាត់ជាភាសាអង់គ្លេសសិន ឯសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ឯកសារ D267/1/3 ("សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ (D267/1/3)")។

២៧. នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ[49]។

២៨. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[50]។

២៩. ការបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវនៃដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

៣០. នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់សារណាលើបណ្ដឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[51] ជាភាសាខ្មែរ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីបានដាក់សារណាស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ពួកគាត់រៀងៗខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[52] និងជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[53] ជាភាសាអង់គ្លេស។

៣១. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យភាគីដាក់ចម្លើយតបរបស់ពួកគេកម្រាស់ ៥០ ទំព័រ ក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែបណ្ដឹងឧទ្ធរណ៍នីមួយៗ និងដាក់ការឆ្លើយតបកម្រាស់ ៣០ ទំព័រ ក្នុងរយៈពេល ២៥ ថ្ងៃ គិតចាប់ពីពេលជូនដំណឹងអំពីការបកប្រែចម្លើយតបនីមួយៗរួចរាល់[54]។

---

[49] សំណុំរឿង ០០៣ សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D266/1។

[50] សំណុំរឿង ០០៣ សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D267/2។

[51] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3)។

[52] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2)។

[53] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត (D267/4)។

[54] សំណុំរឿង ០០៣ សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់ចម្លើយតប និងការឆ្លើយតបនានា ទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយសំណុំរឿង ០០៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ឯកសារ

៣២. ការបកប្រែជាភាសាអង់គ្លេស នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ត្រូវបានជូនដំណឹងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ចំណែកការបកប្រែជាភាសាខ្មែរ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ត្រូវបានជូនដំណឹងនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ និងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ រៀង១ខ្លួន។

៣៣. នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ សហមេធាវីបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ចម្លើយតបរបស់ មាស មុត")[55] ជាភាសាអង់គ្លេស ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ")[56] និងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត")[57] ជាភាសាអង់គ្លេសនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ និងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ដោយឡែក១ពីគ្នា។ សហព្រះរាជអាជ្ញាជាតិពុំបានដាក់ចម្លើយតបណាមួយទេ។

៣៤. ការបកប្រែជាភាសាខ្មែរ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ និងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ និងនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ដោយឡែក១ពីគ្នា ចំណែកការបកប្រែជាភាសាខ្មែរ នៃចម្លើយតបរបស់ មាស មុត ត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩។

៣៥. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានឆ្លើយតបទៅនឹងចម្លើយតប

---

D266/4 និងឯកសារ D267/6 ("សេចក្តីសម្រេចលើកទី ២ លើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ (D266/4 និង D267/6)")។

[55] សំណុំរឿង ០០៣ ចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D266/5 ("ចម្លើយតបរបស់ មាស មុត (D266/5)")។

[56] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/9 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/9)")។

[57] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/10 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10)")។

របស់ មាស មុត ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")[58] ជាភាសាអង់គ្លេស ហើយនៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩ សហមេធាវីបានឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តប ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ("ការឆ្លើយតបរបស់ មាស មុត")[59] ជាភាសាអង់គ្លេស។ ការបក ប្រែជាភាសាខ្មែរ នៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងការឆ្លើយតបរបស់ មាស មុត ត្រូវ បានជូនដំណឹងនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ និងនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាម២០១៩ ដោយឡែកៗពីគ្នា។

៣៦. នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ក្រោយពីបានស្តាប់ភាគីទាំងអស់រួចមក[60] អង្គបុរេជំនុំជម្រះ បានចេញដីកាកំណត់កាលវិភាគសម្រាប់សវនាការលើបណ្តឹងឧទ្ធរណ៍[61]។ បន្ទាប់ពីការអានរបាយការណ៍នៃ សំណុំរឿង និងបណ្តឹងឧទ្ធរណ៍ជាសាធារណៈក្នុងនាមអង្គបុរេជំនុំជម្រះទាំងមូល[62] រួចមក អង្គជំនុំជម្រះបាន ដំណើរការស្តាប់អំណះអំណាងផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍*ជាអសាធារណៈ* នៅថ្ងៃទី២៧, ២៨ និង ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩[63]។

---

[58] សំណុំរឿង ០០៣ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ និងដាក់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/11 ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11)")។

[59] សំណុំរឿង ០០៣ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍ របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D266/7 និង ឯកសារ D267/12 ("ការឆ្លើយតបរបស់ មាស មុត (D266/7 និង D267/12)")។

[60] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះដល់ភាគីតាមអ៊ីមែល ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D266/9.1.1។

[61] សំណុំរឿង ០០៣ ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះ ស្រាយ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D266/12 និង ឯកសារ D267/17។

[62] សំណុំរឿង ០០៣ របាយការណ៍នៃសំណុំរឿង និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/15 និង ឯកសារ D267/20 ("របាយការណ៍សំណុំរឿង")។

[63] សវនាការជាសាធារណៈរួមមាន សេចក្តីផ្តើម និង ការអានរបាយការណ៍សំណុំរឿង នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ព្រមទាំង ការតាំងសំណួរពីចៅក្រមដល់ភាគី នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ *សូមមើល* សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការ នីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ (CS) ឯកសារ D266/16.1 និង ឯកសារ D267/21.1 ("ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ (D266/16.1 និង D267/21.1)")។ សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើប ណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ (CS) ឯកសារ

## II. ការបញ្ចូលគ្នាក្នុងសំណុំរឿងតែមួយ

៣៧. ដូចដែលបានកត់សម្គាល់ខាងលើ[64] បច្ចុប្បន្ននេះ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ចំនួនបី ប្រឆាំងទៅនឹងដីកាដំណោះស្រាយចំនួនពីរដែលបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣។

៣៨. មាត្រា ១២នៃកិច្ចព្រមព្រៀង[65] (១) និងវិធាន ២ នៃវិធានផ្ទៃក្នុង ចែងថា ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងអត្ថបទច្បាប់ អ.វ.ត.ក អង្គជំនុំជម្រះត្រូវធ្វើការសម្រេចដោយអនុលោមទៅតាមច្បាប់កម្ពុជា។ ត្រង់ចំណុចនេះ អង្គបុរេជំនុំជម្រះរម្លឹកថា[66] មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថាក“៌លណាតុលាការបានទទួលនីតិវិធីច្រើនដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឲ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន[67]”។

៣៩. នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះមិនបានទទួលសំណុំរឿងច្រើនជាប់ទាក់ទងគ្នាទេ។ ផ្ទុយទៅវិញអង្គបុរេជំនុំជម្រះបានទទួលសំណុំរឿងចំនួនមួយ ដែលកំណត់ដោយការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរ ដែលនាំឲ្យមាននីតិវិធីបណ្តឹងឧទ្ធរណ៍ខុសគ្នា ប៉ុន្តែទាក់ទងគ្នា។ ដោយពិចារណាលើ សិទ្ធិអំណាចរបស់អង្គជំនុំជម្រះ ក្នុងការបង្គាប់ឲ្យបញ្ចូលគ្នានូវសំណុំរឿងច្រើនជាប់ទាក់ទងគ្នា កាតព្វកិច្ចរបស់ខ្លួនក្នុងការធានាឲ្យមានដំណើរការស្វែងរក

---

D266/17.1 និង ឯកសារ D267/22.1។ សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ (CS) ឯកសារ D266/18.1 និង ឯកសារ D267/23.1។ សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D266/18.2 និង ឯកសារ D267/23.2 (“ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ (D266/18.2 និង D267/23.2)”)។

[64] សូមមើលខាងលើ ទំព័រ ១ កថាខណ្ឌ ៣០។

[65] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្នុងច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ *ចូលជាធរមាននៅ*ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ )“កិច្ចព្រមព្រៀង អ”ក.ត.វ.) មាត្រា ១២។(១)

[66] សំណុំរឿង ០០៤) ស.ច.ស.ក/ក.ត.វ.អ-២០០៩-០៩-០៧/២/“សំណុំរឿង ០០៤”២/) (អបជ ៦០សេចក្តីពិចារណាលើប ( ណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(D266/24 & D266/33) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 )“សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ២/(D359/24 & D360/33)”) កថាខណ្ឌ ២៥។

[67] *ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* ខែមិថុនា ឆ្នាំ២០០៧ ថ្ងៃទី០៧)) (”ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា“) មាត្រា ២៩៩។

យុត្តិធម៌ឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស និងវិធីសាស្ត្រដែលបានប្រកាន់យកកន្លងមកក្នុងសំណុំរឿង០០៤/០២[68] អង្គបុរេជំនុំជម្រះយល់ឃើញថា ការបញ្ចូលគ្នាក្នុងសំណុំរឿងតែមួយ គឺតម្រូវឱ្យមានជាចាំបាច់ក្នុងសំណុំរឿង០០៣។

៤០. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបង្គាប់ឱ្យបញ្ចូលនីតិវិធីបណ្ដឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះជាមួយគ្នា ហើយនឹងដោះស្រាយជារួមទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរនៅក្នុងសេចក្ដីពិចារណាទាំងនេះ។

## III. បទដ្ឋាននៃការពិនិត្យឡើងវិញ

៤១. នៅក្នុងផ្នែកនេះ អង្គបុរេជំនុំជម្រះសូមបញ្ជាក់សាជាថ្មី អំពីបទដ្ឋានសម្រាប់ការត្រួតពិនិត្យឡើងវិញរបស់ខ្លួនទៅលើមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ ដែលភាគីបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ។ អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា បទដ្ឋានដែលលើកយកមកពិភាក្សានៅពេលនេះ គ្របដណ្ដប់តែទៅលើការត្រួតពិនិត្យឡើងវិញ នូវបណ្ដឹងឧទ្ធរណ៍ដែលដាក់ជូនអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ ហើយមិនរារាំងតាមមធ្យោបាយណាមួយ ដល់អំណាចផ្សេងទៀត ដែលអង្គជំនុំជម្រះអាចយល់ឃើញថា ចាំបាច់ត្រូវអនុវត្តនោះទេ។

៤២. វិធាន ៧៥(៤) កំណត់ថា ការដាក់សារណាបណ្ដឹងឧទ្ធរណ៍ ត្រូវមានបញ្ជាក់អំពី "អំណះអំណាងអង្គហេតុ និង អង្គច្បាប់ ដែលជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍"។ ការបង្ហាញភស្តុតាងពិតប្រាកដ ដែលតម្រូវឱ្យភាគីលើកឡើង គឺអាស្រ័យទៅតាមប្រភេទនៃកំហុសទាំងឡាយ ដូចបានលើកឡើង។

៤៣. ក្នុងករណីនេះ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ[69] ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលសម្រេចថា មាស មុត មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អវ.ត.ក[70]. ទេ ហើយក៏ដូចជាបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ[71] និងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារ

---

[68] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ២/(D359/24 & D360/33) កថាខណ្ឌ ២៤២៧។-

[69] *សូមមើល* បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D266/2។

[70] ដីកាសម្រេចលើកលែងចោទប្រកាន់ ឯកសារD266 កថាខណ្ឌ ៤២៩។

[71] *សូមមើល* បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ឯកសារ D267/3។

ក្តី មាស មុត[72] ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានកំណត់បទចោទប្រកាន់បានគ្រប់គ្រាន់ និងសន្និដ្ឋានថា អវ.ត.ក អាច. អនុវត្តយុត្តាធិការបុគ្គលទៅលើគាត់ ដែលជាបុគ្គលម្នាក់នៅក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ទៅលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម។[73]

៤៤. អង្គបុរេជំនុំជម្រះ បានសម្រេចរួចមកហើយថា ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត ថាតើបុគ្គលណាម្នាក់ស្ថិតក្នុងចំណោម ជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុតឬយ៉ាងណានោះ គឺជា " សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[74] ដែលត្រូវបានពិនិត្យស្របតាមបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលអាចអនុវត្តបានចំពោះសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[75]។

៤៥. អង្គបុរេជំនុំជម្រះ បានសម្រេចយ៉ាងស្របគ្នាថា ឆន្ទានុសិទ្ធិដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ នៅក្នុងការពិចារណាលើយុត្តាធិការបុគ្គលរបស់ អវ.ត.ក គឺជាឆន្ទានុសិទ្ធិតុលាការ ដែលមិន. អនុញ្ញាតឲ្យបំពេញតាមអំពើចិត្តទេ ប៉ុន្តែ ត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ ដែលមានចែង

---

[72] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ឯកសារD267/4។

[73] ដីកាដំណោះស្រាយ ឯកសារD267 កថាខណ្ឌ ៤៥៦។

[74] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤/២) ឯកសារ D359/24 & D360/33 កថាខណ្ឌ ២៨ ,។ សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស" ,សំណុំរឿង ០០៤/១ អបជ៥០ ,សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ )សំអាងហេតុ (ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ឯកសារ ឯកសារ D308/3/1/20 កថាខណ្ឌ ២០។

[75] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤/២) ឯកសារ D359/24 & D360/33 កថាខណ្ឌ ២៨-២៩។ *សូមមើល*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១) ឯកសារ D308/3/1/20 (កថាខណ្ឌ ២០-២១ *ដែលក្នុងនោះ ក៏មានយោងទៅលើ*សំណុំរឿង ០០៤ )អបជ៥២ ,(សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5") សាលដីកាលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ ក្នុងសំណុំរឿង ០០៤ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។

[76] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤ ២ ឯកសារ/D359/24 & D360/33 កថាខណ្ឌ ២៨។*សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤១ ឯកសារ/ D308/3/1/20 កថាខណ្ឌ ២០ (*ដែលយោងទៅលើ*តុលាការយោធាអន្តរជាតិជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមចម្បង១ នៅចំពោះ

បំផុត" គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលក្នុងនោះ ការពិចារណាតាមផ្លូវច្បាប់ គឺអាស្រ័យលើស្ថាប័នតុលាការរបស់ អ.វ.ត.ក។[77]

៤៦. ដូចដែលអង្គបុរេជំនុំជម្រះ បានសម្រេចរួចហើយថា ទោះបីជាសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិខ្លះក្នុងការកំណត់អំពីយុត្តាធិការបុគ្គលរបស់ អវ.ត.ក ក្តី ក៏ឆន្ទានុសិទ្ធិរបស់ពួកគាត់ ក្នុងការពិចារណា. ឬអត់នោះ គឺមិនមែនគ្មានព្រំដែន និងអាចចៀសផុតពីការពិនិត្យឡើងវិញ ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះទេ។[78] អង្គបុរេជំនុំជម្រះពិនិត្យឡើងវិញ ថាតើនៅក្នុងបរិបទ អ.វ.ត.ក នេះ សហចៅក្រមស៊ើបអង្កេតបានផ្តល់អានុភាពផ្លូវច្បាប់សមស្រប ចំពោះលក្ខខណ្ឌតម្រូវអំពីយុត្តាធិការបុគ្គលដែរឬយ៉ាងណា។

៤៧. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះបានពិចារណាថា ការសម្រេចរបស់សហចៅក្រមស្រមស៊ើបអង្កេតថា បុគ្គលណាម្នាក់ស្ថិត ឬមិនស្ថិតក្នុងយុត្តាធិការរបស់ អវ.ត.ក អាចត្រូវបានច្រានចោលតាម. សំណើរបស់ភាគី នៅពេលដែលភាគីបង្ហាញថា ការសម្រេចបែបនោះគឺ៖ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (គឺកំហុសអង្គច្បាប់) ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព និង/ឬ (២) ផ្អែកលើការសន្និដ្ឋានអំពីអង្គហេតុមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត (គឺកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌) និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋានថា ចៅក្រមទាំងនោះមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែងទេ។[79]

---

មុខតុលាការយោធាអន្តរជាតិ វ៉ុល ,I សាលក្រម") សាលក្រម ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ ,IMT វ៉ុល ,I ទំព័រ ១៧១-៣៦៧ ត្រង់លេខ ២៥៦។

[77] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុសំណុំរឿង ០០៤/២ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ២៨។ សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០ ដែលយោងទៅលើកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផ្នែកទី ២ (ថ្មី)។

[78] សំណុំរឿង ០០៤/២, សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ២៨។ សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០។

[79] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤/២ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ២៩។ សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯក

៤៨. ចុងបញ្ចប់ អង្គបុរេជំនុំជម្រះបញ្ជាក់ឡើងវិញថា ក្រោយការពិនិត្យឡើងវិញតាមផ្លូវឧទ្ធរណ៍របស់ខ្លួនទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា កំហុស និងឬ ការរំលោភបំពានទាំងឡាយ ដែលភាគីបានចោទប្រកាន់នោះ គឺពិតជាត្រូវបានប្រព្រឹត្តឡើង/ដោយសហចៅក្រមស៊ើបអង្កេតមែន នោះអង្គជំនុំជម្រះអាចនឹងបញ្ជូនសេចក្តីសម្រេចនេះឱ្យទៅសហសម្រេចនេះ[81] និងចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែសម្រួល។[82]

---

សារ D308/3/1/20) កថាខណ្ឌ ២១ ដែលក្នុងនោះ បានសំអាងទៅលើដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ (ឯកសារ D365/3/1/5) កថាខណ្ឌ ១៥។

[80] *សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤/២ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៣០។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២២។ សូមមើល ឧទា. សំណុំរឿង ០០២ (អបជ៥២), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ (អបជ៤៦), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174 D178 និង D284 ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៩, ២៦។*

[81] *សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៣០។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២២ ដែលសំអាងលើសំណុំរឿង ០០២ (អបជ៦៧), សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ឯកសារ D365/2/17 ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៦៧។*

[82] *សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៣០ ដែលសំអាងលើសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២២ ដែលយោងទៅលើសំណុំរឿង ០០១ (អបជ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ឯកសារ D99/3/42 ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨។*

## IV. ភាពអាចទទួលយកបាន

### ក. ភាពអាចទទួលយកបានជាផ្លូវការ

៤៩. ដោយពិចារណា ជាបឋម ទៅលើវិធាន ៧៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការដាក់បណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងទីពីរលើសេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍ និងសារណាដែលបានដាក់នៅក្នុងពេលវេលាកំណត់ដែលបានតម្រូវ ហើយស្របទៅតាមការណែនាំរបស់អង្គជំនុំជម្រះ នៅក្នុងសំណុំរឿងនេះ ទើបអង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍ទាំងបី ដែលបានដាក់ប្រឆាំងដីកាដំណោះស្រាយទាំងពីរ គឺអាចទទួលយកបានជាផ្លូវការ[83]។ នាពេលនេះ អង្គជំនុំជម្រះ នឹងវាយតម្លៃថាតើបណ្ដឹងឧទ្ធរណ៍នីមួយៗ ស្ថិតនៅក្នុងវិសាលភាពរបស់អង្គជំនុំជម្រះ ក្នុងការត្រួតពិនិត្យលើបណ្ដឹងឧទ្ធរណ៍ ដែរឬយ៉ាងណា។

### ខ. បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ

៥០. សហព្រះរាជអាជ្ញាជាតិ បានប្ដឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមវិធាន ៦៧(៥) ៧៣(ក) និង ៧៤(២)[84] នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានជំទាស់ចំពោះភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះទេ[85]។

៥១. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ៦៧(៥) ៧៤(២) និង ៧៣(ក) នៃវិធានផ្ទៃក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ហើយសហព្រះរាជអាជ្ញា មានសិទ្ធិជាទូទៅក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងគ្រប់ដីកាទាំងអស់របស់សហចៅក្រស៊ើបអង្កេត ហើយអង្គបុរេជំនុំជម្រះ មាន

[83] សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ (D267/1/3)។ សេចក្ដីសម្រេចលើកទី ២ លើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ (D266/4 និង D267/6)។

[84] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦។

[85] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/9)។ សហមេធាវីមិនបានដាក់ការឆ្លើយតបទេ។

យុត្តាធិការទៅលើបណ្តឹងឧទ្ធរណ៍បែបនេះ។ ហេតុដូច្នេះ ទើបអង្គជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ អាចទទួលយកបាន។

### គ. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ

៥២. សហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍ប្រឆាំង ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ អនុលោមតាមវិធាន ៦៧(៥) និង ៧៤(២) នៃវិធានផ្ទៃក្នុង[86]។ សហមេធាវី មិនជំទាស់ចំពោះ ភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍នេះទេ[87]។

៥៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ៦៧(៥) ៧៤(២) និង ៧៣(ក) នៃវិធានផ្ទៃក្នុង ដីកាសម្រេចលើកលែងចោទប្រកាន់ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ហើយសហព្រះរាជអាជ្ញា មានសិទ្ធិជាទូទៅ ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងគ្រប់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត ហើយអង្គបុរេជំនុំជម្រះ មានយុត្តាធិការទៅលើបណ្តឹងឧទ្ធរណ៍បែបនេះ។ ហេតុដូច្នេះទើបអង្គជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ អាចទទួលយកបាន។

### ឃ. បណ្តឹងឧទ្ធរណ៍របស់សហមេធាវី

៥៤. សហមេធាវីបានប្តឹងឧទ្ធរណ៍ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធាន ៧៤(៣)(ក) និងវិធាន ២១ នៃវិធានផ្ទៃក្នុង[88]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន អនុលោមតាមវិធានទាំងអស់នេះទេ[89] ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានជំទាស់ចំពោះ មាស មុត ក្នុងការដាក់សារណាស្តីពីបញ្ហា ដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ឡើយ[90]។

---

[86] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៣, ៥។

[87] ចម្លើយតបរបស់ មាស មុត (D266/5)។ សហព្រះរាជអាជ្ញាជាតិមិនបានដាក់ចម្លើយតបទេ។

[88] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ១។

[89] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៧។

[90] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៦។ សហព្រះរាជអាជ្ញាជាតិមិនបានដាក់ចម្លើយតបទេ។

៥៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ហើយអង្គបុរេជំនុំជម្រះ មានយុត្តាធិការទៅលើបណ្តឹងឧទ្ធរណ៍ ដែលបានដាក់អនុលោមតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា វិធាន ៧៤ (៣) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យជនត្រូវចោទ ឬជនជាប់ចោទ ដាក់ប្រភេទជាក់លាក់មួយចំនួន នៃបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលបុរេជំនុំជម្រះ[91] ដូចជាបណ្តឹងឧទ្ធរណ៍ ដែលដាក់អនុលោមតាមអនុវិធាន ៧៤(៣)(ក) ប្រឆាំងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត "បញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។ អង្គជំនុំជម្រះសម្រេចថា ការពង្រីកសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នេះ តាមរយៈវិធាន២១ នៃវិធានផ្ទៃក្នុង គឺអាចធ្វើទៅបាន តាមករណីជាក់ស្តែង[92] ហើយអាចអនុញ្ញាតបាន តែក្នុងករណីពិសេសតែប៉ុណ្ណោះ[93] ។ ហេតុដូច្នេះ អង្គជំនុំជម្រះ នឹងធ្វើការសម្រេចថាតើ បណ្តឹងឧទ្ធរណ៍របស់ មាស មុត អាចទទួលយកបានដែរឬអត់។

---

[91] ភាពខុសគ្នារវាងសិទ្ធិរបស់អយ្យការ និងសិទ្ធិរបស់មេធាវីការពារក្តី ក្នុងការប្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ ត្រូវបានបញ្ជាក់នៅក្នុងបរិបទខុសៗគ្នា។ *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ១០៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/15 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15)") កថាខណ្ឌ ១៤។ សំណុំរឿង ០០២ (អបជ ៤៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D313/2/2 កថាខណ្ឌ ១៣។

[92] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ១៤៧។ សំណុំរឿង ០០២ (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

[93] *សូមមើល* សំណុំរឿង ០០៤/១ (អបជ ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 ("សេចក្តីពិចារណាលើការចោទប្រកាន់ *ដោយកំបាំងមុខ* ក្នុងសំណុំរឿង ០០៤ (D239/1/8)") កថាខណ្ឌ ១៧។ សំណុំរឿង ០០៣ (អបជ ២៣) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ C2/4 មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ៩។

១. សារណា

៥៦. សហមេធាវីបានលើកមូលដ្ឋានពីរ ក្នុងការប្តឹងឧទ្ធរណ៍ ពាក់ព័ន្ធទស្សនៈរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានលើកឡើងនៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ដែលថា ប្រសិនបើមិនមានសម្លេងភាគច្រើនលើសលប់ នៅក្នុងអង្គបុរេជំនុំជម្រះ ដើម្បីតម្កល់ដីកាដំណោះស្រាយណាមួយ ក្នុងចំណោមដីកាដំណោះស្រាយដែលផ្ទុយគ្នា ពេលនោះដីកាដំណោះស្រាយទាំងពីរ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយ ត្រូវមានអនុភាពតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[94]។ ជាបឋម សហមេធាវីបញ្ជាក់បំភ្លឺនូវសំអាងហេតុដែលខ្លួនពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍របស់ខ្លួនអាចទទួលយកបាន មុននឹងពន្យល់លម្អិតទៅលើអង្គសេចក្តីនៃមូលដ្ឋាននានានៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន (មូលដ្ឋាន ក និង ខ)។

៥៧. ទាក់ទិននឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជាបឋម សហមេធាវីបានលើកទទ្បីករណ៍ថា បើតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង សំណើរបស់ខ្លួនជំទាស់យ៉ាងត្រឹមត្រូវទៅលើការបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទៅលើ មាស មុត[95]។ ពួកគេបានផ្តល់សំអាងហេតុថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទៅលើ មាស មុត ដោយលើកឡើងជាដំបូង តាមរយៈការបកស្រាយរបស់គាត់ ទៅលើវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងថា ដីកាដំណោះស្រាយទាំងពីរ ឬមានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ដែលមានអានុភាព លើកលែងតែអង្គបុរេជំនុំជម្រះ សម្រេចតម្កល់ដីកាដំណោះស្រាយណាមួយ ដោយសម្លេងភាគច្រើនលើសលប់។ សហមេធាវីអះអាងថា ការបញ្ជាក់បែបនេះ គឺត្រូវបានធ្វើឡើងផងដែរ ជាលើកទីពីរ ដោយការមិនបានសន្និដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់ គួរមានអនុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមគោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ លើកលែងតែអង្គជំនុំជម្រះនេះ សម្រេចដោយសម្លេងភាគច្រើនលើសលប់ថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសឆ្គង ឬរំលោភបំពានទៅលើកត្តាសម្រេចកំណត់ជាសារវ័ន្ត

---

94 *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ២, ៣២ ជើងទំព័រ ១៧៩, ២៣៣ *យោងទៅ* ដីកាដំណោះបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៩ ជើងទំព័រ ២៦ *ដកស្រង់ពី* ដីកាសម្រេចលើការដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ក្នុងសំណុំរឿង ០០៤/២ (D355/1) កថាខណ្ឌ ១៦ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៧៩។

95 បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ២។

01667295



ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ ក្នុងការសម្រេចថា មាស មុត មិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក[96]។

៥៨. ដើម្បីគាំទ្របន្ថែមទៀតដល់ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានអះអាងថា វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវថា ក្របខណ្ឌ អ.វ.ត.ក ត្រូវតែបកស្រាយក្នុងន័យការពារដល់ផលប្រយោជន៍របស់ មាស មុត ហើយជាលទ្ធផលតម្រូវឱ្យមាន ការបកស្រាយក្នុងន័យទូលាយ ចំពោះសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ សហមេធាវីអះអាងថា កាលៈទេសៈពិសេស ដែលតម្រូវឱ្យមានការបកស្រាយក្នុងន័យទូលាយបែបនេះ ក្នុងសំណុំរឿងនេះគឺ៖ (១) វិធានផ្ទៃក្នុងមិនបានប្រមើលមើល អំពីសេណារីយ៉ូដែលមាន ដីកាដំណោះស្រាយផ្ទុយគ្នាដូចបច្ចុប្បន្នឡើយ (២) បណ្តឹងឧទ្ធរណ៍របស់ខ្លួន បានលើកឡើងពីបញ្ហាដែល អង្គជំនុំជម្រះសាលាដំបូង មិនអាចកែសម្រួលបាន និង (៣) ការរារាំងមិនឱ្យ មាស មុត ប្តឹងឧទ្ធរណ៍ទៅលើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺដកហូតពីគាត់ដោយមិនអាចជួសជុលបាន នូវសិទ្ធិដែលមានការធានាការពារ ក្នុងការទទួលបាន ការជំនុំជម្រះប្រកបដោយយុត្តិធម៌[97]។

៥៩. ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានជំទាស់នៅក្នុងមូលដ្ឋាន កថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ ដោយបកស្រាយវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងអះអាងថា ដីកាដំណោះស្រាយទាំងពីរ ឬមានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះដែលមានសុពលភាព លុះត្រាតែអង្គបុរេជំនុំជម្រះតម្កល់ដីកាដំណោះស្រាយណាមួយក្នុងចំណោមនោះ ដោយសំឡេងគាំទ្រភាគច្រើនលើសលុប។ ទីមួយ សហមេធាវីលើកជាទឡ្ហីករណ៍ថា រាជរដ្ឋាភិបាល និង អ.ស.ប ពុំមានបំណងបញ្ជូនសំណុំរឿងទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលចេញដីកាសម្រេចលើកលែងចោទប្រកាន់មួយផ្ទុយ ក្នុងពេលដំណាលគ្នានោះឡើយ[98]។ ទីពីរ សហមេធាវីអះអាងថា ការអនុវត្តវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចំពោះដីកាដំណោះស្រាយដែលផ្ទុយគ្នា នឹងបង្កឱ្យមានលទ្ធផលមិនត្រឹមត្រូវ

---

[96] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ២។

[97] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៣-៥។

[98] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៣៣-៤០។

ដែលនឹងប៉ះពាល់ដល់សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងរំលោភបំពានដល់រដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក[99]។

៦០. នៅក្នុងមូលដ្ឋាន ខ សហមេធាវីចោទប្រកាន់ថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅក្នុងច្បាប់ព្រហ្មទណ្ឌអះអាងថា វិមតិសង្ស័យពាក់ព័ន្ធនឹងអង្គហេតុ និងអង្គច្បាប់ត្រូវផ្តល់ជាប្រយោជន៍ដល់ចុងចោទ មាស មុត លុះត្រាតែកំហុសឆ្គង និងការរំលោភបំពានដែលជាកត្តាកំណត់ជាសារវ័ន្តទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួន ត្រូវបានសន្និដ្ឋានដោយសំឡេងភាគច្រើនលើសលុប ពីអង្គបុរេជំនុំជម្រះ[100]។ ជាងនេះទៀត សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតទាំងពីររូបបានស៊ើបអង្កេតទៅការចោទប្រកាន់អង្គហេតុដែលពួកគាត់បានទទួល និងធ្វើសេចក្តីសន្និដ្ឋានអង្គច្បាប់ដែលចាំបាច់ នៅក្នុងដីកាដំណោះស្រាយដែលមានសំអាងហេតុ[101]។ ហេតុនេះ សហមេធាវីអះអាងថា ដោយសារពុំមានកំហុស ឬការរំលោភបំពាននានាដូចបានលើកឡើងខាងលើ ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវមានឧត្តមភាព ដោយសារការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*[102]។

៦១. ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានជំទាស់ចំពោះ មាស មុត ក្នុងការដាក់សារណាអំពីផលវិបាកនៃការចេញដីកាដំណោះស្រាយផ្ទុយគ្នាក្តី[103] តែសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា បណ្តឹងឧទ្ធរណ៍របស់ មាស មុត មិនអាចទទួលយកបានឡើយ តាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[104] ហើយមិនបានស្នើសុំឱ្យមានការបកស្រាយក្នុងន័យទូលាយ តាមរយៈវិធាន ២១ នៃវិធានផ្ទៃក្នុង[105]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍ស្ថិតក្រៅដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសារតែសហមេធាវី មិនបានលើកឡើងពីកំហុសឆ្គង ឬការរំលោភបំពានទៅលើឆន្ទានុសិទ្ធិ របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ[106]។ សហ

[99] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៤១-៤៦។

[100] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៥០-៥១។

[101] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៥២-៦១។

[102] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៦២-៦៥។

[103] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៦។

[104] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៧។

[105] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៨។

[106] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៧-៨។

ព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទាក់ទងតែជាមួយផលវិបាកនៃការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា ជាបញ្ហាមួយដែលអាចមានដោយចៃដន្យ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយអាស្រ័យទាំងស្រុងទៅលើអង្គបុរេជំនុំជម្រះ[107]។

៦២. សហមេធាវីឆ្លើយតបវិញថា សហព្រះរាជអាជ្ញាអន្តរជាតិ យល់ខុសទៅលើវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង គឺថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ដោយប្រយោល ទៅលើយុត្តាធិការរបស់ អ.វ.ត.ក លើ មាស មុត ដោយការបកស្រាយដោយមិនត្រឹមត្រូវទៅលើវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[108]។ សហមេធាវីបានបន្ថែមថា បណ្តឹងឧទ្ធរណ៍របស់ខ្លួន បានព្យាយាមដោយចេតនា មិនជំទាស់ចំពោះការសម្រេចលើយុត្តាធិការបុគ្គលរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយសារមូលហេតុសេដ្ឋកិច្ចតុលាការ ហើយថាសហមេធាវីសូមរក្សាសិទ្ធិរបស់ មាស មុត ក្នុងការជំទាស់ចំពោះការសម្រេចលើអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធនានា ប្រសិនបើសំណុំរឿងត្រូវបន្តទៅដំណាក់កាលជំនុំជម្រះ[109]។ សហមេធាវីបានលើកឡើងបន្ថែមថា ការណ៍ដែលសហព្រះរាជអាជ្ញាអន្តរជាតិ ដោយអះអាងជាទូទៅថា ជំនួយក្នុងការបកស្រាយទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង គឺមិនមានភាពចាំបាច់ ដោយសារតែមិនមានវិមតិសង្ស័យឡើយថា បណ្តឹងឧទ្ធរណ៍របស់ មាស មុត គឺមិនអាចទទួលយកបាន តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង គឺជាការគេចវេសពីការពិភាក្សា អំពីកាលៈទេសៈពិសេស ដែលតម្រូវឱ្យមានការបកស្រាយ ក្នុងន័យទូលាយចំពោះសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ មាស មុត[110]។ ជាចុងក្រោយ សហមេធាវីបានលើកឡើងករណីថា ផលប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវនៃនីតិវិធី គាំទ្រដល់ការទទួលយកបណ្តឹងឧទ្ធរណ៍របស់ មាស មុត នៅក្នុងសំណុំរឿងនេះ[111]។

## ២. ការពិភាក្សា

៦៣. សិទ្ធិរបស់ភាគី ក្នុងការប្តឹងឧទ្ធរណ៍ និងមូលដ្ឋានដែលអាចទទួលយកបាន សម្រាប់បណ្តឹងឧទ្ធរណ៍នៅដំណាក់កាលបុរេជំនុំជម្រះ គឺស្ថិតក្រោមវិធាន ៧៤ នៃវិធានផ្ទៃក្នុង។ ដូចដែលបានបង្ហាញនៅផ្នែកខាង

[107] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/10) កថាខណ្ឌ ៨។

[108] ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ៩-១១។

[109] ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ៨។

[110] ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ១២។

[111] ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ១៣។

ក្រោម អង្គបុរេជំនុំជម្រះប្រកាសថា បណ្តឹងឧទ្ធរណ៍ដែលបានដាក់ដោយជនត្រូវចោទ ឬជនជាប់ចោទ គឺអាចទទួលយកបាន ប្រសិនបើបណ្តឹងឧទ្ធរណ៍នោះពាក់ព័ន្ធដូចជា៖ (១) យុត្តាធិការលើរឿងក្តី តាមអនុវិធាន ៧៤(៣)(ក), (២) យុត្តាធិការបុគ្គលតាមអនុវិធាន ៧៤(៣)(ក) និង/ឬ(៣) បញ្ហាពិសេសនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវត្រួតពិនិត្យតាមករណីជាក់ស្តែង ដែលអាចតម្រូវឱ្យមានការពង្រីក សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ តាមការចែងក្នុងអនុវិធាន ៧៤(៣)(ក) និងអនុលោមទៅតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ នៅក្នុងសំណុំរឿងនេះ សហមេធាវីព្យាយាមប្តឹងឧទ្ធរណ៍ ដោយអនុលោមទៅតាមវិធាន ៧៤(៣)(ក) និងវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយដែលវិសាលភាពទាំងនេះ ត្រូវបានអង្គជំនុំជម្រះត្រួតពិនិត្យនាពេលនេះ។

៦៤. ទីមួយ សញ្ញាណនៃបណ្តឹងជំទាស់លើយុត្តាធិការ ត្រូវបានគេយល់ជាទូទៅថា ជាការតវ៉ាចំពោះសមត្ថកិច្ចរបស់ អ.វ.ត.ក *លើបុគ្គល លើរឿងក្តី តាមពេលវេលា និង/ឬ ទីកន្លែង*[112] ដូចដែលបានកំណត់ក្នុងមាត្រា ២ថ្មី ដល់មាត្រា៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[113]។ ដូចដែលបានបញ្ជាក់កន្លងមក វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ផ្តល់ដល់ជនត្រូវចោទ និងជនជាប់ចោទ នូវសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ តែចំពោះដីកាសម្រេច និងសេចក្តីសម្រេចទាំងឡាយណា ដែលមានចែងកំណត់ក្នុងបទប្បញ្ញត្តិនេះ[114]។ ដីកាសម្រេច និងសេចក្តីសម្រេចទាំងនោះ ដោយអនុលោមតាមអនុវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងរួមមាន ដីកាសម្រេចឬសេចក្តីសម្រេច របស់សហចៅក្រមស៊ើបអង្កេត "បញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[115]។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺ "ត្រូវតែអាចប្តឹងឧទ្ធរណ៍ ពាក់ព័ន្ធទៅនឹងបញ្ហាស្តីពីយុត្តាធិការ ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត"[116]។

---

[112] សេចក្តីពិចារណាលើការចោទប្រកាន់*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤ (D239/1/8) កថាខណ្ឌ ២២។

[113] ច្បាប់ អ.វ.ត.ក ជំពូកទី II មាត្រា ២*ថ្មី*-៨។ សំណុំរឿង ០០២ (អបជ ១៤៥ និង ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 និង D427/3/15 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15)") កថាខណ្ឌ ៦៣។ *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១, ៩។

[114] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15) កថាខណ្ឌ ១៤។

[115] វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

[116] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15) កថាខណ្ឌ ១៤ (លុបជើងទំព័រ)។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង

៦៥. ចំពោះបណ្ដឹងជំទាស់យុត្តាធិការបុគ្គល អង្គបុរេជំនុំជម្រះសូមរំឭកថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក កម្រិតត្រឹម "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក[117]។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ទោះបីជាពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" មិនត្រូវបានកំណត់និយមន័យ ដោយកិច្ចព្រមព្រៀង ឬច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ក្ដី តែគោលការណ៍ណែនាំសម្រាប់ការបកស្រាយ អាចទាញចេញដោយការពិនិត្យមើលផងដែរ ទៅលើយុត្តិសាស្ត្រអន្តរជាតិ ដោយផ្អែកលើកម្មវត្ថុនិងគោលបំណង នៃលិខិតុបករណ៍បង្កើតតុលាការ[118]។ ដូចដែលអង្គជំនុំជម្រះជាច្រើនរបស់ អ.វ.ត.ក បានសម្រេចកន្លងមក យុត្តិសាស្ត្រអន្តរជាតិបានកំណត់ថា អត្តសញ្ញាណរបស់បុគ្គលដែលស្ថិតក្នុងប្រភេទទទួលខុសត្រូវខ្ពស់បំផុត រួមមានការវាយតម្លៃជាបរិមាណ និងគុណភាព ទៅលើទាំង

---

សារី) (D427/1/30) កថាខណ្ឌ ៤៤-៤៥។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ ៥៩-៦០។ សំណុំរឿង ០០២ (អបជ ៣៨) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្ម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 ("សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9)") កថាខណ្ឌ ១៩, ២១។

[117] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(១)។ ច្បាប់ អ.វ.ត.ក មាត្រា ២*ថ្មី*។

[118] *សូមមើល អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា* ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ 1155 U.N.T.S. 331 *ចូលជាធរមាន*នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០ ("អនុសញ្ញាទីក្រុងវីយែន") មាត្រា ៣១(១)(២) (ចែងថា ពាក្យពេចន៍នៅក្នុងលិខិតុបករណ៍ត្រូវបកស្រាយជាចម្បងនៅក្នុងបរិបទរបស់វា ដែលរួមមានអត្ថបទរបស់លិខិតុបករណ៍នោះ ទាក់ទិននឹងកម្មវត្ថុ និងគោលបំណងរបស់វា)។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១) (ចែងថា នៅពេលមានភាពមិនច្បាស់លាស់នៅក្នុងច្បាប់ជាធរមាន "គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ")។ ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី* (ចែងថា សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ)។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 ("បណ្ដឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបានជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D404/2/4)") កថាខណ្ឌ ៥៨-៦០។

ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម (ដែលរងការចោទ ឬត្រូវបានចោទប្រកាន់) និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[119] ដែលពាក់ព័ន្ធជាសំខាន់ជាមួយបញ្ហាអង្គច្បាប់ និងអង្គហេតុ[120]។

៦៦. ដូចដែលសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់[121] អង្គបុរេជំនុំជម្រះគឺជាស្ថាប័នតុលាការតែមួយ ដែលមានសិទ្ធិស្របច្បាប់ ក្នុងការត្រួតពិនិត្យដោយផ្ទាល់ ទៅលើដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេត ព្រមទាំងទៅលើផលវិបាកផ្លូវច្បាប់ នៃដីកាដំណោះស្រាយនោះ។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះពិចារណាថា ផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលរងការជំទាស់ គឺត្រង់ផ្នែកដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ការកត់សម្គាល់របស់គាត់ ទៅលើសុពលភាពនៃកិច្ចខុសច្បាប់ដែលមិនធ្លាប់មានពីមុនមករបស់គាត់ផ្ទាល់[122]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា ទាំងអស់នេះគឺគ្រាន់តែជាការទាយស្មាន ដែលលើកឡើងហួសពីអាណត្តិសមត្ថកិច្ច តាមផ្លូវតុលាការរបស់គាត់ ហើយមិនមានអានុភាពផ្លូវតុលាការឡើយ។ ដូច្នេះ នេះមិនមែនជាសេចក្តីសម្រេច ឬដីកាសម្រេចតាមផ្លូវតុលាកា ដែលអាចប្តឹងឧទ្ធរណ៍បាន តាមវិធាន ៧៤ នៃវិធានផ្ទៃក្នុងឡើយ។

៦៧. បន្ថែមលើនេះអង្គបុរេជំនុំជម្រះ កត់សម្គាល់ថា សហមេធាវីបានរក្សាសិទ្ធិរបស់ មាស មុត ក្នុងការជំទាស់ចំពោះការសម្រេច លើអង្គហេតុនិងអង្គច្បាប់ របស់សហចៅក្រមស៊ើបអង្កេត នៅដំណាក់កាលជំនុំជម្រះទៀត ប្រសិនបើសំណុំរឿងនេះបន្តដំណើរការនីតិវិធីទៅមុខ[123]។ ក្នុងន័យនេះ អង្គជំនុំជម្រះកត់

---

[119] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ("សាលក្រមនៃសំណុំរឿង ០០១ (E188)") កថាខណ្ឌ ២២ និង ជើងទំព័រ ២៨-៣០។ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ("សាលដីកានៃសំណុំរឿង ០០១ (F28)") កថាខណ្ឌ ៧១។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយនៃការស៊ើបអង្កេតពាក់ព័ន្ធនឹងជនសង្ស័យ មាស មុត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 ("សេចក្តីសម្រេចលើយុត្តាធិការបុគ្គលក្នុងសំណុំរឿង ០០៣ (D48)") កថាខណ្ឌ ១៥ និង ជើងទំព័រ ២៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[120] សាលដីកានៃសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៧។

[121] ដីកាសម្រេចលើការដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ក្នុងសំណុំរឿង ០០៤/២ (D355/1) កថាខណ្ឌ ១៦។

[122] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៣២, ៤៩ *យោងទៅ*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៩ ជើងទំព័រ ២៦ និង កថាខណ្ឌ ៥៧៩។

[123] ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ៨។

សម្គាល់ថា ទោះបីជាតាមគោលការណ៍ទូទៅ បញ្ហារួមគ្នានៃអង្គហេតុនិងអង្គច្បាប់ មិនមានលក្ខណៈជាបញ្ហាយុត្តាធិការ ហើយដែលត្រូវដោះស្រាយជាដំបូងនៅ ដំណាក់កាលជំនុំជម្រះក្តី[124] យុត្តាធិការបុគ្គលគឺជា "ធាតុផ្សំចាំបាច់នៃយុត្តាធិការ"[125] ដែលគួរតែជាកម្មវត្ថុនៃ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ នៅដំណាក់កាលបុរេជំនុំជម្រះ ប្រកបដោយប្រសិទ្ធិភាព។ ក្នុងករណីបច្ចុប្បន្ននេះ ប្រសិទ្ធិភាពនៃសិទ្ធិនេះគឺ ជាប់ពាក់ព័ន្ធជាមួយហេតុផលដែលនៅពីក្រោយ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងអនុវិធាន ៧៤(៣)(ក) ដែលមានគោលដៅលើកកម្ពស់ រដ្ឋបាលតុលាការប្រកបដោយរបៀបរៀបរយ និងប្រសិទ្ធិភាព តាមរយៈការអនុញ្ញាតឲ្យមេធាវីការពារក្តី អាចជៀសផុតពីការជំនុំជម្រះ ដែលតុលាការមិនមានយុត្តាធិការ និងដើម្បីជៀសវាងការខ្ជះខ្ជាយធនធាន[126]។

៦៨. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា ដោយពិចារណាទៅលើផលប្រយោជន៍របស់ជនជាប់ចោទ និងជនរងគ្រោះ ព្រមទាំងភាពចាំបាច់នៃសច្ចភាព និងតម្លាភាពគតិយុត្តិ នៃកិច្ចដំណើរការនីតិវិធី[127] ការអនុញ្ញាតឲ្យមានបណ្តឹងជំទាស់ ចំពោះយុត្តាធិការលើរឿងក្តី តែត្រង់ចំណុចអង្គច្បាប់ ដូចបានកំណត់នៅក្នុងសេចក្តីសម្រេចកន្លងមក[128] គឺគ្រប់គ្រាន់ក្នុងការធានាដល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ប្រកបដោយប្រសិទ្ធិភាពរបស់ជនជាប់ចោទ នៅដំណាក់កាលបុរេជំនុំជម្រះ គឺធានាថាជនជាប់ចោទ នឹងមិនត្រូវបញ្ជូនទៅជំនុំជម្រះឡើយ ចំពោះឧក្រិដ្ឋកម្មដែលតុលាការមិនមានយុត្តាធិការនោះ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះយល់ឃើញថា ដោយសារតែការសម្រេចលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ពាក់ព័ន្ធផ្ទៃក្នុងជាមួយបញ្ហារួមគ្នា នៃអង្គហេតុនិងអង្គច្បាប់នោះ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចដែលសម្រេច អំពីបញ្ហាមួយនេះ អាច

---

124 *សូមមើល ឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៦។

125 សាលដីកានៃសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣១។

126 ដោយការប្រៀបធៀប (analogy) ជាមួយវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ដែលមានគោលបំណងដូចគ្នា *សូមមើល* សាលដីកានៃសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៨។

127 វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

128 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ១៣៧ និង ជើងទំព័រ ២២៤ *យោងទៅ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ ៦០។ សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ២៣-២៤។

ធ្វើឡើងដោយប្រសិទ្ធិភាព តែក្នុងករណីដែលមេធាវីការពារក្តី ចូលរួមពាក់ព័ន្ធជាមួយបញ្ហារួមគ្នាទាំងអស់នេះ នៅក្នុងបណ្តឹងឧទ្ធរណ៍ដែលដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ។

៦៩. ក្នុងន័យនេះ អង្គបុរេជំនុំជម្រះសូមរំឭកថា នៅពេលប្រឈមមុខជាមួយបណ្តឹងជំទាស់យុត្តាធិការបុគ្គលពាក់ព័ន្ធ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អង្គជំនុំជម្រះនឹងកម្រិតកំណត់ ការវាយតម្លៃរបស់ខ្លួនទៅលើតែបញ្ហាដែលសំខាន់ សម្រាប់ការសម្រេចនិងការវាយតម្លៃ ទៅលើយុត្តាធិការបុគ្គលប៉ុណ្ណោះ គឺភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និង/ឬកម្រិតនៃការទទួលខុសត្រូវ របស់ជនជាប់ចោទ[129]។ ហេតុដូច្នេះអង្គជំនុំជម្រះ បានសម្រេចរួចហើយថា បណ្តឹងជំទាស់ចំពោះយុត្តាធិការបុគ្គល ពាក់ព័ន្ធអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត គឺអាចទទួលយកបានប្រសិនបើ មានការកំណត់គោលដៅចំពោះ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និង/ឬកម្រិតនៃការទទួលខុសត្រូវ របស់ជនជាប់ចោទ[130]។ អង្គជំនុំជម្រះសូមបញ្ជាក់សារជាថ្មីថា ការជំទាស់ដែលពាក់ព័ន្ធជាមួយបញ្ហា ដែលស្ថិតក្រៅការកម្រិតកំណត់នេះ គឺមិនអាចរួមបញ្ចូលថាជាបណ្តឹងជំទាស់ចំពោះយុត្តាធិការបុគ្គលឡើយ ដូច្នេះហើយគឺមិនអាចទទួលយកបានឡើយ ដោយផ្អែកលើមូលដ្ឋានបែបនេះ អនុលោមតាមតែវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងតែមួយនោះ[131]។

៧០. បើពិនិត្យទៅលើទំនាក់ទំនងរវាងសិទ្ធិ ក្នុងការប្តឹងឧទ្ធរណ៍នៅដំណាក់កាលបុរេជំនុំជម្រះ ជាមួយវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានសម្រេចកន្លងមកថា ដោយផ្អែកលើមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងថា "ការជំនុំជម្រះក្តីត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ" និងប្រព្រឹត្តទៅ "ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ" ហើយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ICCPR")[132] ដែលអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់ នៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក "ការពិចារណាសំខាន់ជាងគេ នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺជាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាន ២១(១)(ក)

---

[129] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ១៥៤។

[130] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ១៥៥។

[131] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ១៥៥។

[132] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ លេខ 999 U.N.T.S. 171 និង 1057 U.N.T.S 407 ចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ("ICCPR") មាត្រា ១៤។

នៃវិធានផ្ទៃក្នុង”[133]។ ហេតុដូច្នេះ អង្គជំនុំជម្រះកត់សម្គាល់ថា “នៅពេលដែលអង្គហេតុ និងកាលៈទេសៈនានានៃបណ្តឹងឧទ្ធរណ៍តម្រូវ” អង្គបុរេជំនុំជម្រះ “មានសមត្ថកិច្ចធ្វើការពិចារណា អំពីមូលដ្ឋាននានាដែលបានលើកឡើង ដោយ[ជនជាប់ចោទ] ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ ស្របតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង តាមរយៈការបកស្រាយដែលមានគំនិតច្រើន អំពីសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្តឹងឧទ្ធរណ៍ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង”[134]។

៧១. ដោយមានភាពពាក់ព័ន្ធ និងដោយផ្ទុយពីការអះអាង របស់សហមេធាវីនៅក្នុងសំណុំរឿងនេះ[135] អង្គបុរេជំនុំជម្រះសម្រេចថា ភាពខុសគ្នាផ្នែកនីតិវិធី រវាងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ របស់ជនជាប់ចោទ និង

---

[133] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៩ *ដកស្រង់ពី* សាលដីកាលើការរំលោភនីតិវិធីក្នុងសំណុំរឿង ០០២ (D264/2/6) កថាខណ្ឌ ១៣-១៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ ៧១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង ធីរិទ្ធ) (D427/3/15) កថាខណ្ឌ ៧១ *យោងទៅ* សាលដីកាលើការរំលោភនីតិវិធីក្នុងសំណុំរឿង ០០២ (D264/2/6) កថាខណ្ឌ ១៣-១៤។ *សូមមើល ផងដែរ* សំណុំរឿង ០០២ (អបជ ៥៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D273/3/5 កថាខណ្ឌ ១០។

[134] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ ៧១។ *សូមមើលផងដែរ* សាលដីកាលើសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ៣០។ សំណុំរឿង ០០៣ (អបជ ២៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ដោយ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ឯកសារ D174/1/4 (“សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចចោទប្រកាន់ក្នុងសំណុំរឿង ០០៣ (D174/1/4)”) មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៩។ សំណុំរឿង ០០៤ (អបជ ០៥) ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ឯកសារ D121/4/1/4 (“ការពិចារណាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការពិនិត្យមើលសំណុំរឿង ក្នុងសំណុំរឿង ០០៤ (D121/4/1/4)”) មតិយោបល់របស់ចៅក្រម CHUNG និងចៅក្រម DOWNING កថាខណ្ឌ ៤។

[135] ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ១៣។ *សូមមើល ផងដែរ* ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/18.2 និង D367/23.2, ERN 01639987-01639988 (ភាសាអង់គ្លេស) ទំព័រ ១៦:២០ ដល់ ១៧:០៤។

សហព្រះរាជអាជ្ញា គឺមិនបានបង្កើតជាការរំលោភបំពាន ទៅលើភាពយុត្តិធម៌ឡើយ។ ទីមួយ បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី បើតាមទស្សនៈរបស់អង្គជំនុំជម្រះ មិនបានជំទាស់ចំពោះសំអាងហេតុ ដែលនាំទៅដល់ការចោទប្រកាន់ បញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ។ ហេតុដូច្នេះអង្គជំនុំជម្រះមិនជឿជាក់ អំពីភាពអាចទទួលយកបាន នៃបណ្ដឹងឧទ្ធរណ៍បែបនេះទេ ប្រសិនបើបណ្ដឹងបែបនេះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា តាមសិទ្ធិជាទូទៅរបស់ពួកគេក្នុងការប្ដឹងឧទ្ធរណ៍។ សំខាន់ជាងនេះទៅទៀត នៅ អ.វ.ត.ក វិធានជាធរមានបានកំណត់ពីសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍តាមនីតិវិធីខុសៗគ្នាសម្រាប់ភាគីនីមួយៗ ហើយ "ចំពោះភាពអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ការត្រួតពិនិត្យបណ្ដឹងឧទ្ធរណ៍ ទៅតាមករណីនីមួយៗ មានគោលបំណងដើម្បីធានាសិទ្ធិ របស់ភាគីទាំងអស់"[136]។ អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ម្ដងហើយម្ដងទៀតថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានបើកផ្លូវដោយស្វ័យប្រវត្តិ សម្រាប់ការប្ដឹងឧទ្ធរណ៍ បើទោះបីជាក្នុងករណីដែលបណ្ដឹងឧទ្ធរណ៍ លើកឡើងពីបញ្ហាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្ដី[137]។ ភាគីប្ដឹងឧទ្ធរណ៍ ចាំបាច់ត្រូវបង្ហាញ ថាកាលៈទេសៈជាក់លាក់នៃសំណុំរឿងរបស់ខ្លួន តម្រូវឲ្យមានការជួយអន្តរាគមន៍ ពីអង្គជំនុំជម្រះ នៅដំណាក់កាលដែលដាក់បណ្ដឹងឧទ្ធរណ៍ ដើម្បីជៀសវាងពីព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិជាសារវន្តក្នុងការទទួលបាន ការជំនុំជម្រះប្រកបដោយយុត្តិធម៌[138]។ ក្នុងករណីនេះ អង្គជំនុំជម្រះចាំបាច់ត្រូវវាយតម្លៃថាតើ សហមេធាវីបានបំពេញតាមបន្ទុកនេះដែរឬយ៉ាងណា ក្នុងការបង្ហាញថា កាលៈទេសៈជាក់លាក់តម្រូវ ឲ្យមានការបកស្រាយក្នុងន័យទូលាយ ទៅលើវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

---

[136] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ (D361/4/1/10) កថាខណ្ឌ ១៩។

[137] *សូមមើល ឧទាហរណ៍* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ ៧៣។ សេចក្ដីពិចារណាលើការចោទប្រកាន់*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤ (D239/1/8) កថាខណ្ឌ ១៧។ សេចក្ដីពិចារណាលើការចោទប្រកាន់*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៣ (D128/1/9) កថាខណ្ឌ ២០។

[138] *សូមមើល ឧទាហរណ៍* សេចក្ដីពិចារណាលើការចោទប្រកាន់*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤ (D239/1/8) កថាខណ្ឌ ១៧។ សេចក្ដីពិចារណាលើការចោទប្រកាន់*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៣ (D128/1/9) កថាខណ្ឌ ២០។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងសេចក្ដីសម្រេចចោទប្រកាន់ក្នុងសំណុំរឿង ០០៣ (D174/1/4) មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៩។

៧២. ចំពោះបញ្ហានេះ អង្គបុរេជំនុំជម្រះសូមរំឭកថា នៅពេលដែលបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង បានលើកឡើងអំពីបញ្ហា ដែលមិនអាចកែតម្រូវបានដោយ អង្គជំនុំជម្រះសាលាដំបូង ហើយការបដិសេធបណ្តឹងឧទ្ធរណ៍ "បង្កការខូចខាតដែលមិនអាចជួសជុលបានដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌" នោះ វិធាន ២១ នៃវិធានផ្ទៃក្នុងអាចតម្រូវឱ្យ ធ្វើការបកស្រាយក្នុងន័យទូលាយ ចំពោះវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង[139] ។ អង្គជំនុំជម្រះកត់សម្គាល់ថា ក្នុងសំណុំរឿង០០៤/២ អង្គជំនុំជម្រះសម្រេចថាអាចទទួលយកបាន នូវការជំទាស់ចំពោះនីត្យានុកូលភាព នៃការចេញដីកាដំណោះស្រាយពីដាច់ពីគ្នាហើយផ្ទុយគ្នា ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង[140]។ នៅក្នុងករណីនោះ មេធាវីការពារក្តីបានអះអាងក្នុងបណ្តឹងឧទ្ធរណ៍ថា ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយដីកាសម្រេចលើកលែងចោទប្រកាន់ បង្កើតជាកំហុសអង្គច្បាប់[141]។ អង្គជំនុំជម្រះកត់សម្គាល់ថា ទឡ្ហីករណ៍នេះគឺសំដៅប្រឆាំងទៅនឹងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយចោទប្រកាន់ពីកំហុសអង្គច្បាប់ ដោយផ្អែកថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ពីយុត្តាធិការបុគ្គល ទៅលើជនជាប់ចោទ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[142]។ ផ្ទុយទៅវិញ នៅក្នុងករណីបច្ចុប្បន្ន សហមេធាវីអះអាងថា ការបកស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើផលវិបាកនៃដីកាដំណោះស្រាយពីរដែលផ្ទុយ ដែលត្រូវបានតម្កល់ដោយអង្គបុរេជំនុំជម្រះ ថាជាកំហុសអង្គច្បាប់។ បន្ថែមលើនេះ ទឡ្ហីករណ៍បែបនេះត្រូវបានបង្ហាញដាច់តែឯង ដោយមិនមានទឡ្ហីករណ៍ដទៃផ្សេងទៀត សំដៅប្រឆាំងការសម្រេចលើអង្គហេតុ ឬអង្គច្បាប់ ទាក់ទងជាមួយបញ្ហាយុត្តាធិការបុគ្គល នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ដោយសារមូលហេតុទាំងអស់នេះ អង្គជំនុំជម្រះពិចារណាថា ការសម្រេចកន្លងមករបស់អង្គជំនុំជម្រះ ដែលបានធ្វើឡើងនៅក្នុងសំណុំរឿង០០៤/២ មិនបានផ្តល់នូវយុត្តិសាស្ត្រពាក់ព័ន្ធសម្រាប់ករណីបច្ចុប្បន្ននេះឡើយ។

139 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៨។

140 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ១៤៩។

141 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៣០៤។

142 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) ជើងទំព័រ ២១១។

៧៣. អង្គបុរេជំនុំជម្រះនឹងសម្រេចថាតើ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទាំងពីររបស់ មាស មុត អាចទទួលយកបានដែរឬយ៉ាងណា អនុលោមតាមវិធាន ៧៤(៣) និងវិធាន ២១ នៃវិធានផ្ទៃក្នុង។

ក. មូលដ្ឋាន ក

៧៤. មូលដ្ឋាន ក របស់សហមេធាវី បានអះអាងថា ការបកស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ត្រង់ចំណុចដែលថា ដីកាដំណោះស្រាយទាំងពីរ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយ ត្រូវមានអានុភាព ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយ ដោយសម្លេងភាគច្រើនលើសលប់នោះ បានបញ្ជាក់ដោយប្រយោលទៅលើ យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ មាស មុត[143]។ អង្គបុរេជំនុំជម្រះកត់សម្គាល់នៅដើមដំបូងថា ទឡ្ហីករណ៍នេះគឺពាក់ព័ន្ធជាមួយបញ្ហា ដែលបានដោះស្រាយរួចហើយ លើអង្គសេចក្តី ដោយសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ របស់អង្គបុរេជំនុំជម្រះ[144]។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា មូលដ្ឋាន ក ដូចដែលសហមេធាវីបានទទួលស្គាល់ដោយខ្លួនឯង[145] គឺជំទាស់តែចំពោះទស្សនៈ របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលទាយស្មានអំពីបញ្ហា ដែលស្ថិតក្នុងដែនសមត្ថកិច្ចផ្តាច់មុខ របស់អង្គបុរេជំនុំជម្រះ[146]។ ដូច្នេះហើយមូលដ្ឋាននេះ នឹងមិនប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ មាស មុត ឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះសម្រេចថា មូលដ្ឋាននេះមិនអាចទទួលយកថាជា បណ្តឹងជំទាស់មានសុពលភាព អំពីយុត្តាធិការបុគ្គល តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះសម្រេចថា ការពង្រីកសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ តាមរយៈវិធាន ២១ នៃវិធានផ្ទៃក្នុង មិនមានភាពចាំបាច់ឡើយក្នុងករណីនេះ ដោយសារតែអង្គបុរេជំនុំជម្រះ បានបញ្ជាក់បំភ្លឺរួចហើយ អំពីច្បាប់គ្រប់គ្រងលើបញ្ហាដែលចោទនេះ ហើយគោលបំណងនៃ

---

[143] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ២។ ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ៩។

[144] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៨-១២៤, ១៧០-៣០២, ៣០៤-៣២៩។

[145] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ៣២ ("នៅពេលផ្តល់ការយល់ឃើញលើចំណុចបណ្តឹងឧទ្ធរណ៍ដែលមិនស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន [សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] បានស្នើថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះដែលមានអានុភាពអនុវត្ត លើកលែងតែ [អង្គបុរេជំនុំជម្រះ] សម្រេចតម្កល់ដីកាដំណោះស្រាយណាមួយ តាមសំឡេងភាគច្រើនលើសលុប អនុលោមតាមវិធាន ៧៧(១៣)")។ ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ១១។

[146] *សូមមើល ខាងលើ* កថាខណ្ឌ ៦៦ ។

មូលដ្ឋាន ក គឺជាខ្លឹមសារស្វែងរកការកែតម្រូវទៅលើ ការទាយស្មានដែលគ្មានផលវិបាក ហើយដែលមិនមានអានុភាពពន្យាកម្ម ចំពោះសិទ្ធិរបស់ មាស មុត ឡើយ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ សម្រេចថា មូលដ្ឋាន ក មិនអាចទទួលយកបាន តាមវិធាន ៧៤(៣)(ក) និង វិធាន ២១ នៃវិធានផ្ទៃក្នុងឡើយ។

ខ. មូលដ្ឋាន ខ

៧៥. មូលដ្ឋាន ខ របស់សហមេធាវី អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ដោយប្រយោលអំពីយុត្តាធិការរបស់ អ.វ.ត.ក លើ មាស មុត តាមរយៈការមិនបញ្ជាក់ថា លុះត្រាតែអង្គបុរេជំនុំជម្រះ សម្រេចដោយសម្លេងភាគច្រើនលើសលប់ថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសឆ្គង ឬបានរំលោភបំពានទៅលើ កត្តាកំណត់ជាសារវ័ន្ត ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ ក្នុងការសម្រេចថា មាស មុត មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដីកាសម្រេចលើកលែងចោទប្រកាន់ មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*[147]។

៧៦. សហមេធាវីបានលើកឡើងបន្ថែមថា មូលដ្ឋាន ក និងមូលដ្ឋាន ខ នៃបណ្តឹងឧទ្ធរណ៍របស់ពួកគេ "ជាប់ពាក់ព័ន្ធជាមួយគ្នា"[148]។ ប៉ុន្តែអង្គបុរេជំនុំជម្រះសម្រេចថា មូលដ្ឋានទាំងនេះ មិនមែនមិនអាចញែកចេញពីគ្នាបានឡើយ ប្រសិនបើមូលដ្ឋានទាំងនេះ លើកឡើងពីបញ្ហាពីរផ្សេងពីគ្នា[149]។ មូលដ្ឋាន ក ជំទាស់ចំពោះការបកស្រាយបែបទាយស្មាន របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ទាក់ទងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ចំណែកមូលដ្ឋាន ខ បង្កើតទឡ្ហីករណ៍ជាបណ្តុះតគ្នា ដែលចុងក្រោយចង់សំដៅថា វិមតិសង្ស័យដែលកើតឡើងជារួមលើបញ្ហាថាតើ មាស

---

[147] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) កថាខណ្ឌ ២, ៥៩-៦៦, ៧១ ទំព័រ ៧៣-៧៤។ ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ៤-៦, ៥៥-៧០, ៧៣។

[148] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/18.2 និង D367/23.2, ERN 01639988 (ភាសាអង់គ្លេស) ទំព័រ ១៧:២២ ដល់ ១៨:០២ ("នាពេលនេះ បើងាកទៅផ្នែកទីពីរនៃសំណួររបស់លោកចៅក្រម មូលដ្ឋាន ក និង ខ នៃបណ្តឹងឧទ្ធរណ៍របស់យើងជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមក។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនត្រឹមតែមានកំហុសក្នុងការបកស្រាយវិធាន ៧៧(១៣) ដើម្បីលើកឡើងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ឬដីកាដំណោះស្រាយទាំងពីរមានសុពលភាព ប៉ុណ្ណោះទេ តែគាត់ថែមទាំងមិនបានអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ទៀតផង")។

[149] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4) ទំព័រ ២-៣។

មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់នោះ ដែលជាលទ្ធផលនៃការសម្រេចដាច់ពីគ្នា ដែលសហចៅក្រមស៊ើបអង្កេត បានសម្រេចលើបញ្ហានេះ នៅក្នុងដីកាដំណោះស្រាយរបស់ពួកគេនីមួយៗ[150]។

៧៧. អង្គបុរេជំនុំជម្រះសូមរំឭកថា បណ្តឹងឧទ្ធរណ៍របស់សហមេធាវី មិនពាក់ព័ន្ធនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើស្ថានទម្ងន់ និង/ឬ កម្រិតនៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់ប្រឆាំង មាស មុត ឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា មូលដ្ឋាន ខ របស់សហមេធាវី គឺផ្តោតទៅលើស្ថានភាពដែលតាមទស្សនៈរបស់ពួកគាត់ គឺភាពមិនស្របគ្នារវាងដីកាដំណោះស្រាយទាំងពីរអំពីការយល់ឃើញផ្នែកអង្គហេតុនិងអង្គច្បាប់ ពាក់ព័ន្ធលើបញ្ហាថា តើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់នោះ គឺជាភស្តុតាងនៃវិមតិសង្ស័យ លើបញ្ហាយុត្តាធិការគន្លឹះ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរតែបានដោះស្រាយ តាមរយៈការយោងទៅរកគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើច្បាប់ដែលចែងអំពីយុត្តាធិការរបស់តុលាការ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការជំទាស់នេះមិនអាចចាត់បញ្ចូល និងទទួលស្គាល់ថាជាការជំទាស់មានសុពលភាពចំពោះយុត្តាធិការបុគ្គល អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនោះឡើយ។ លើសពីនេះទៀត សហមេធាវីជំទាស់ទៅនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមិនបានសន្និដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់ មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមទៅតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលត្រូវបានសម្រេចរួចមកហើយថាជា បញ្ហាដែលស្ថិតក្រៅយុត្តាធិការរបស់គាត់[151]។ បន្ថែមលើនេះ អង្គជំនុំជម្រះពិចារណាថា ស្ថានភាពដែលចៅក្រមឯករាជ្យពីររូប ចេញសេចក្តីសម្រេចផ្ទុយគ្នា លើបញ្ហាថាតើត្រូវចោទប្រកាន់ បញ្ជូនទៅជំនុំជម្រះដែរឬយ៉ាងណានោះ គឺមិនបណ្តាលឱ្យមានការអនុវត្ត គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* ឡើយ ព្រោះគោលការណ៍នេះកើតចេញពីសច្ចធារណ៍នៃនិរទោស[152] ដែលតាមសច្ចធារណ៍នេះ មាស មុត នៅតែគ្មានទោស បើទោះបីជាត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះក្តី ហើយគាត់នៅតែមិនមានទោស លុះត្រាតែមានការសម្រេចថាមានពិរុទ្ធភាព។ ជាលទ្ធផល អង្គជំនុំជម្រះ

---

[150] *សូមមើល ឧទាហរណ៍* ការឆ្លើយតបរបស់ មាស មុត (D266/7 និង 267/12) កថាខណ្ឌ ៥៩-៦៦។

[151] *សូមមើល ខាងលើ* កថាខណ្ឌ ៦៦ ។

[152] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា ៣៨។ *សូមមើល ផងដែរ ឧទាហរណ៍* សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខក្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១, ៥១។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Limaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-03-66-A អង្គជំនុំជម្រះតុលាការកំពូល សាលដីកា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ២១។

ពិចារណាថា មិនមានភាពចាំបាច់សម្រាប់ការអន្តរាគមន៍របស់អង្គជំនុំជម្រះ ដើម្បីជៀសវាងពន្យាសនកម្ម ដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ហើយអង្គជំនុំជម្រះយល់ឃើញថា ការពង្រីកសិទ្ធិប្តឹងឧទ្ធរណ៍របស់ មាស មុត តាមរយៈវិធាន ២១ នៃវិធានផ្ទៃក្នុង គឺមិនចាំបាច់ឡើយក្នុងករណីនេះ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចថា មូលដ្ឋាន ខ មិនអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) និង វិធាន ២១ នៃវិធានផ្ទៃក្នុង។

## V. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នា

៧៨. នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេតមិនអាចទទួលបានជំហររួមគ្នាស្តីពីបញ្ហាជាគន្លឹះថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា ហើយបានសម្រេចចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នានៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ជំនួសការបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនទៅអង្គបុរេជំនុំជម្រះ ឬប្រតិបត្តិទៅតាមគោលជំហរស្វ័យប្រវត្តិនោះ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ដោយលើកលែងបទចោទទាំងអស់ប្រឆាំង មាស មុត[153] រីឯសហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបញ្ជូនគាត់ទៅជំនុំជម្រះ[154]។ អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើ សកម្មភាពនៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នានៅក្នុងសំណុំរឿងតែមួយត្រូវបានអនុញ្ញាតទៅតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក ឬយ៉ាងណា។ ដើម្បីសម្រេចទៅតាមគោលបំណងនេះ អង្គជំនុំជម្រះនឹង (១) រម្លឹកអំពីច្បាប់ដែលចែងពាក់ព័ន្ធនឹងបញ្ហានេះ (២) វាយតម្លៃនូវសំអាងហេតុតាមផ្លូវច្បាប់ដែលបានផ្តល់ជូនដោយសហចៅក្រមស៊ើបអង្កេតក្នុងការធ្វើយុត្តិកម្មដល់ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និង (៣) ធ្វើការពិភាក្សាទៅលើសំណុំរឿងចំពោះមុខនេះ។

### ក. ច្បាប់ជាធរមាន

៧៩. ទាក់ទិននឹងច្បាប់ដែលជាទូទៅចែងពាក់ព័ន្ធនឹងបញ្ហាដែលស្ថិតក្រោមការពិចារណា ជាដំបូង អង្គបុរេជំនុំជម្រះសូមរម្លឹកដល់សារសំខាន់នៃការទទួលខុសត្រូវរួមគ្នារបស់សហចៅក្រមស៊ើបអង្កេតពីររូប ក្នុងការបើកកិច្ចស៊ើបសួរនៅ អ.វ.ត.ក ដូចដែលមាត្រា ១៤ថ្មី(១) នៃច្បាប់ អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធ

[153] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266)។

[154] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)។

ថា "ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន"។ ជាពិសេស មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖

> រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស [...] អនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

៨០. ទាក់ទិននឹងការចេញដីកាដំណោះស្រាយដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះសូមរម្លឹកថា វិធាន ៦៧ នៃវិធានផ្ទៃក្នុង ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

**វិធាន ៦៧÷ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត**

> ១. សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ។
>
> ២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃទទួលខុសត្រូវព្រហ្មទណ្ឌបើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី។
>
> ៣. សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម៖
>
> ក-អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។
>
> ខ-ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ
>
> គ-ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ។

៤. ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។

៨១. ទាក់ទិននឹងករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា និង/ឬ រវាងសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះសូមរម្លឹកថា មាត្រា ៥(១), (៤) និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

**មាត្រា ៥៖ ចៅក្រមស៊ើបអង្កេត**

១-មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត។

៤-សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧។

**មាត្រា ៧៖ ការដោះស្រាយនូវការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា**

១-ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្រប តាមមាត្រា ៥ វាក្យខណ្ឌ ៤ [...] សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាត្រូវធ្វើឯកសាររាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និងហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួនដាក់ជូនការិយាល័យរដ្ឋបាល។

២-ការខ្វែងគំនិតគ្នានេះនឹងត្រូវដោះស្រាយជាបន្ទាន់ដោយអង្គបុរេជំនុំជម្រះមួយមានចៅក្រមប្រាំរូប [...]។

៣-ពេលដែលទទួលបានឯកសាររាយការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌទី១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯកសាររាយការណ៍នេះ ជូនសមាជិកអង្គបុរេជំនុំជម្រះ។

៤-ការសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្ដឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ ការសម្រេចសេចក្ដីនេះ ត្រូវជូនប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា នឹងត្រូវដំណើរការភ្លាមៗស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើនដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្ដីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។

៨២. វិធាន ៧២ នៃវិធានផ្ទៃក្នុងលើកឡើងជាក់លាក់នូវនីតិវិធីក្នុងការដោះស្រាយករណីខ្វែងយោបល់គ្នាដូចខាងក្រោម៖

**វិធាន ៧២៖ ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត**

១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខានិងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត។ [...] ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណី [នៅពេលករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធនឹងសេចក្ដីសម្រេចដែលភាគីក្នុងកិច្ចដំណើរការនីតិវិធីមានសិទ្ធិប្ដឹងឧទ្ធរណ៍អនុលោមតាមវិធានផ្ទៃក្នុងនេះ]។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូន សំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬ សេចក្តីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែអនុវត្ត លើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម៖

ក-សេចក្តីសម្រេចណាមួយដែលអាចនាំឱ្យជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

ខ-ការជូនដំណឹងអំពីបទចោទប្រកាន់។ ឬ

គ-ដីកាបង្គាប់ឱ្យចាប់ខ្លួន។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬរយៈពេល ៣០(សាមសិប)ថ្ងៃ បានកន្លងហួស ឬអង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម៖ [...]

ឃ-សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសម្លេងគាំទ្រភាគច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ថ្មីនៃច្បាប់ អ.វ.ត.ក សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រមានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព ឬ មានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត។ [...]

៨៣. ចុងក្រោយ អង្គបុរេជំនុំជម្រះរម្លឹកថា មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុងតម្រូវថា នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវស្របទៅនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ។ ទាក់ទិននឹងចំណុចនេះ មាត្រា១(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងក្នុងចំណោមនោះថា ក្រមនេះ "មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ"។ មាត្រា ២០ថ្មី, ២៣ថ្មី, ៣៣ថ្មី និង ៣៧ថ្មី នៃច្បាប់

អ.វ.ត.ក បញ្ជាក់ច្បាស់ថា ស្ថាប័ននានានៅ អ.វ.ត.ក ត្រូវអនុវត្តតាមនីតិវិធីជាធរមានទាំងអស់។ អង្គជំនុំជម្រះបានសម្រេចរួចហើយថា បទប្បញ្ញត្តិទាំងនេះ "មានគោលដៅធានានូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធិភាពរបស់កិច្ចដំណើរការនីតិវិធី អ.វ.ត.ក"[155]។

ខ. សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយផ្ទុយគ្នា

៨៤. ទាក់ទិននឹងសំអាងហេតុតាមផ្លូវច្បាប់ដែលផ្តល់ជូនដោយសហចៅក្រមស៊ើបអង្កេតក្នុងការធ្វើយុត្តិកម្មចំពោះការចេញដីកាដំណោះស្រាយផ្ទុយគ្នានៅក្នុងសំណុំរឿងនេះ ដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នីតិវិធីក្នុងសំណុំរឿង ០០៣ ស្ថិតក្រោមករណីខ្វែងយោបល់គ្នាសម្ងាត់ជាច្រើនរវាងសហចៅក្រមស៊ើបអង្កេត រួមទាំងករណីខ្វែងយោបល់គ្នាមួយដែលបានចុះបញ្ជីនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ "ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា"[156]។ ពុំមានករណីខ្វែងយោបល់គ្នាណាមួយត្រូវបានដាក់ជូនអង្គជំនុំជម្រះនេះទេ តែនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីនៅក្នុងសំណុំរឿងនេះថា សហចៅក្រមពិចារណាចេញដីកាដំណោះស្រាយដែលដាច់ស្រឡះពីគ្នា "ផ្អែកលើករណីខ្វែងយោបល់គ្នា" ដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់ជាធរមាននៅ អ.វ.ត.ក[157]។ អង្គជំនុំជម្រះពិចារណាឃើញថា ការដាក់ដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងករណីនេះ បង្ហាញពីករណីខ្វែងយោបល់គ្នាដែលមិនត្រូវបានដោះស្រាយរវាងសហចៅក្រមទាំងពីររូប យ៉ាងហោចណាស់ទៅលើបញ្ហាថាតើ មាស មុត ត្រូវស្ថិតឬមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

៨៥. ជាពិសេស ទាក់ទិននឹងសំអាងហេតុដែលបានផ្តល់ជូនដោយសហចៅក្រមស៊ើបអង្កេតសម្រាប់ការចេញដីកាដំណោះស្រាយផ្ទុយគ្នានៅក្នុងសំណុំរឿងនេះ ដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជាក់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួនថា "ច្បាប់ [អ.វ.

[155] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៩៥។

[156] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267) កថាខណ្ឌ ២៧។ សូមមើលផងដែរ ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D266) កថាខណ្ឌ ៧។

[157] ដីកាសម្រេចដាក់ដីកាសម្រេចចូលក្នុងលើសំណុំរឿង ០០៣ (D២៦២) សំអាងលើសំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើរបស់ អោន អាន សុំការបំភ្លឺថ្ងៃទី ៥ ខែកញ្ញាឆ្នាំ ២០១៧ លេខ D២៦២.១ (" សេចក្តីសម្រេចលើសំណើសុំការបំភ្លឺ" ករណី ០០៣ សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោន អាន សម្រាប់ការបង្ហាញឯកសារទាក់ទងនឹងការខ្វែងគំនិតគ្នាថ្ងៃទី ១៨ ខែកញ្ញាឆ្នាំ ២០១៧ លេខ ២៦២.២ (" សេចក្តីសម្រេចស្តីពីការបង្ហាញព័ត៌មានទាក់ទងនឹងការខ្វែងគំនិតគ្នា (D២៦២.២)") ។

ត.ក] និង កិច្ចព្រមព្រៀង ក៏មិនបានហាមពីលទ្ធភាពនៃការចេញដីកាដំណោះស្រាយពីរផ្សេងគ្នាទេ” ហើយថា “ការមិនមានចែង មានន័យថាការចេញដីកាដំណោះស្រាយពីរក៏មិនខុសច្បាប់ដែរ”[158] ។ សហចៅក្រមស៊ើបអង្កេតជាតិបានបន្ថែមថា “វិធាន ៧២ [នៃវិធានផ្ទៃក្នុង] បានចែងតែអំពីការខ្វែងយោបល់ពាក់ព័ន្ធនឹងកិច្ចស៊ើបអង្កេត” ហើយថា “សហចៅក្រមស៊ើបអង្កេតទាំងពីរយល់ឃើញថា យន្តការដោះស្រាយការខ្វែងយោបល់នេះ [...] មិនសម្រាប់ការខ្វែងយោបល់លើប្រភេទ និងជម្រើសនៃការចេញដីកាដំណោះស្រាយឡើយ”[159] ។ នៅក្នុងដីកាដំណោះស្រាយនីមួយៗរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតទាំងពីររូបបានយោងទៅលើសំអាងហេតុដែលខ្លួនបានលើកឡើងនៅក្នុងសេចក្ដីសម្រេចពីមុនៗ ជាដំបូងដែលបានចេញនៅក្នុងសំណុំរឿង ០០៤/២ ហើយបន្ទាប់មកបានដាក់ទៅក្នុងសំណុំរឿង ០០៣160 ដោយយល់ឃើញ (១) ថា ការដែលសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាជារឿងស្របច្បាប់ ទៅតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក (“ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ”)[161] (២) ដែលពួកគេក៏យល់ឃើញថា អនុញ្ញាតឱ្យដាក់ដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា (“ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់”)[162]។ អង្គជំនុំជម្រះយល់ឃើញថា ជាការពាក់ព័ន្ធដែលត្រូវលើកឡើងនូវសម្រង់អត្ថបទនៃសំអាងហេតុទាំងនេះជាច្រើន ដោយចាប់ផ្ដើមពីដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់៖

> ១៤. ដើម្បីកុំឱ្យមានការតវ៉ាអំពីចំណុចនេះនាពេលអនាគត [...] និងដើម្បីចំណេញពេលវេលាសម្រាប់ភាគីទាំងអស់ យើងសូមបញ្ជាក់ថា យើងពិចារណាចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា ដូចដែលបានអនុញ្ញាតជាទូទៅតាមច្បាប់ជា

---

[158] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៧។

[159] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៧។

[160] *សូមមើល* ដីកាសម្រេចដាក់ដីកាសម្រេចចូលក្នុងសំណុំរឿង ០០៣ (D262) កថាខណ្ឌ ៧ *ដែលយោងទៅ* ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D262.1 (“ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (D262.1)។ ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D262.2)។

[161] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៩ *យោងទៅ* ដីកាសម្រេចដាក់ដីកាសម្រេចចូលក្នុងសំណុំរឿង ០០៣ (D262) *យោងទៅ ក្នុងចំណោមនោះ* ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (D262.1)។

[162] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៩ *យោងទៅ*ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D262.2) កថាខណ្ឌ ១៣-១៦។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៧ *យោងទៅ* ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D262.2) កថាខណ្ឌ ១៥។

ធរមាន ជាពិសេសតាមសំអាងហេតុដែលយើងបានរកឃើញពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ពាពរផ្ទុយគ្នា។ [...]

១៥. យើងដឹងអំពីបញ្ហាដែលអាចនឹងកើតឡើងនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង គ្រាន់តែចែងអំពីសេណារីយ៉ូដែលមានដីកាលើកលែងចោទប្រកាន់ ឬ ក៏មានដីកាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នាទេ។ យ៉ាងណាក៏ដោយ មិនមានយុត្តិកម្មទេ ប្រសិនបើអះអាងថា មានការហាមឃាត់មិនឱ្យមានដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។ ផ្ទុយទៅវិញ ជាឧទាហរណ៍ នៅក្នុងសាលដីការបស់ខ្លួននៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់យ៉ាងច្បាស់អំពីសេណារីយ៉ូរបស់ [សហចៅក្រមស៊ើបអង្កេត] មានសំអាងហេតុខ្វែងយោបល់អំពីយុត្តាធិការបុគ្គល ហើយក៏ទទួលស្គាល់យ៉ាងច្បាស់ថា នៅក្នុងបរិបទនៃនីតិវិធីខ្វែងយោបល់ កិច្ចស៊ើបសួរត្រូវបន្តទៅមុខ។

១៦. យើងយល់ឃើញថា ដំណាក់កាលស៊ើបសួរ ចប់នៅពេលចុងក្រោយបំផុត គឺនៅពេលដែល [អង្គបុរេជំនុំជម្រះ] ចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ ប្រសិនបើ [អង្គបុរេជំនុំជម្រះ] មិនមានសំឡេងភាគច្រើនគាំទ្រដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ ដីកាដំណោះស្រាយទាំងពីរត្រូវតម្កល់ទុកជាបានការ តាមការអនុវត្តវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង [...][163]។

៨៦. នៅក្នុងដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានលើកឡើងពាក់ព័ន្ធនឹងនីតិវិធីដោះស្រាយករណីខ្វែងយោបល់ថា៖

២៣. ដោយសារថា ការដាក់ដីកាសន្និដ្ឋានស្ពាពរពីរ គឺជាភ័ស្តុតាងបញ្ជាក់ពីការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ទើប បញ្ហាចោទថាតើសហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុងនូវវិធានការដោះស្រាយជម្លោះដែរឬអត់ និយាយម្យ៉ាងទៀតថាតើយន្តការដោះស្រាយយោងតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង គឺជាលក្ខខណ្ឌតម្រូវ ឬក៏ជាឆន្ទានុសិទ្ធិ [...] គឺពិតជាបញ្ហាចោទដែលស្ថិតនៅក្នុងដែនអំណាចរបស់ [សហចៅក្រមស៊ើបអង្កេត] ពីព្រោះថា បញ្ហាចោទនេះពាក់ព័ន្ធនឹងការដែលអាចទទួលយកដីកាសន្និដ្ឋានស្ពាពរ។ [...]

---

[163] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D262.2) កថាខណ្ឌ ១៤-១៦ (លុបជើងទំព័រ)។

២៧. [...] យើង [...] យល់ឃើញថា [...] ក៏មានការបង្ហាញឲ្យឃើញច្បាស់ថា តាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ការធ្វើកំណត់ហេតុករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា គឺជាបញ្ហាឆន្ទានុសិទ្ធិ។ ហេតុនេះ យើងមិនយល់ឃើញថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុង នូវវិធានការដោះស្រាយជម្លោះទេ [...][164]។

៨៧. ទាក់ទិននឹងលទ្ធភាពនៃការដាក់សេចក្តីសន្និដ្ឋានស្ថាពរជាច្រើន សហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាសម្រេចដដែលនោះថា៖

៣២. ទោះបីយើងយល់ស្រប [...] ថា ខ្លឹមសារមួយនៃវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង ចែងអំពីដីកាសន្និដ្ឋានស្ថាពរមួយ ប៉ុន្តែ ភាសានេះ មិន*តម្រូវឲ្យមាន*ដីកាសន្និដ្ឋានស្ថាពរមួយរួមគ្នាទេ ហើយក៏មិនបានដកចេញនូវការដាក់ដីកាសន្និដ្ឋានដាច់ដោយឡែកពីគ្នាដែរ [...]។ ទោះបីសហព្រះរាជអាជ្ញាត្រូវធ្វើការរួមគ្នាដើម្បីរៀបចំសេចក្តីសន្និដ្ឋានចោទប្រកាន់ ប៉ុន្តែការដែលសហព្រះរាជអាជ្ញាអាចខ្វែងយោបល់គ្នាត្រូវបានទទួលស្គាល់នៅក្នុង [កិច្ចព្រមព្រៀង] ដែលតម្រូវឲ្យសហព្រះរាជអាជ្ញា "សហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់" ហើយពិតណាស់ មានបទប្បញ្ញត្តិអំពីយន្តការដោះស្រាយជម្លោះ ដោយ [កិច្ចព្រមព្រៀង] ចែងយ៉ាងច្បាស់ថាអាចមានករណីខ្វែងយោបល់គ្នា "ថាតើ ត្រូវបន្តការចោទប្រកាន់ដែរឬអត់"។

៣៣. ការពិចារណាថែមទៀតគឺថា [...] [សហចៅក្រមស៊ើបអង្កេត] មិនជាប់កាតព្វកិច្ចត្រូវទទួលយកខ្លឹមសារនៃដីកាសន្និដ្ឋានស្ថាពរណាមួយ [...]. [...]

៣៤. ចំពោះការអះអាងដែលថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរគឺដណ្តើមយក "អំណាចផ្តាច់មុខ" [របស់អង្គបុរេជំនុំជម្រះ] ដើម្បីដោះស្រាយជម្លោះ [...] យើងមិនយល់ឃើញថា ការប្តឹង [ទៅ អ.ប.ជ] គឺជាលក្ខខណ្ឌតម្រូវចាំបាច់ទេ ហេតុនេះ មិនមានអំណាចផ្តាច់មុខត្រូវដណ្តើមទេ[165]។

៨៨. តាំងពីដំបូងមក អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរដាច់ដោយឡែកពីគ្នារបស់សហព្រះរាជអាជ្ញា ដែលអង្គជំនុំជម្រះចាត់ទុកថាជាភាពមិនប្រក្រតីផ្នែកនីតិវិធីដំបូងនៅក្នុងដំណើរកាលបិទការស៊ើបអង្កេតនៅក្នុងសំណុំរឿងនេះ ក៏បានកើតឡើងនៅក្នុងសំណុំរឿង ០០៤/១ ដែរ

---

[164] ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (D262.1) កថាខណ្ឌ ២៣, ២៧។

[165] ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (D262.1) កថាខណ្ឌ ៣២-៣៤ (គូសបញ្ជាក់បន្ថែម និងលុបជើងទំព័រ)។

01667318



ហើយមិនអាចរារាំងមិនឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយតែមួយនៅក្នុងសំណុំរឿងផ្សេងបានទេ។ អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា នៅក្នុងចំណុចនេះ បញ្ហាបឋមគឺថា មានភាពខុសគ្នាជាមូលដ្ឋាននូវមុខងារ និងសិទ្ធិអំណាច រវាងសារណារបស់ភាគី និងសេចក្តីសម្រេចរបស់តុលាការដែលចេញដោយចៅក្រម ដូចជាដីកាដំណោះស្រាយ166។ ចំពោះសំណួរថាតើការដាក់សារណាសន្និដ្ឋានស្ថាពរដាក់ដោយឡែកពីគ្នារបស់សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតនៅក្នុងប្រព័ន្ធច្បាប់នៅ អ.វ.ត.ក ឬយ៉ាងណានោះ អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសលើអង្គច្បាប់ដ៏ធំធេង ដោយសន្និដ្ឋានថា ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។

## គ. ការពិភាក្សា

៨៩. ដូចដែលបានកត់សម្គាល់ពីខាងលើ អង្គបុរេជំនុំជម្រះបានពិចារណាថា ការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងនេះ បានបង្ហាញពីការខ្វែងយោបល់គ្នា ដែលមិនអាចដោះស្រាយបាន រវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ ទៅលើបញ្ហាថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា។ អង្គជំនុំជម្រះបានសម្រេចរួចហើយ នៅក្នុងសំណុំរឿងមួយផ្សេងទៀតថា ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនអនុញ្ញាតឱ្យមានការចេញដីកាដំណោះស្រាយផ្ទុយគ្នាឡើយ[167]។ អង្គបុរេជំនុំជម្រះនឹងយោងទៅយុត្តិសាស្ត្ររបស់ខ្លួនក្នុងការពិចារណាចំពោះសំណុំរឿងបច្ចុប្បន្ន ដោយជាដំបូងត្រូវកែប្រែការបកស្រាយគតិយុត្តិ ដែលសហចៅក្រមស៊ើបអង្កេតបានសម្រេច ហើយជាបន្ទាប់ត្រូវបញ្ជាក់បំភ្លឺ អំពីលក្ខណៈនៃកំហុសឆ្គង ដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្ត នៅក្នុងសំណុំរឿងនេះ។

៩០. ជាដំបូង អង្គបុរេជំនុំជម្រះសូមរំឭកថា ដូចគ្នានឹងប្រព័ន្ធគតិយុត្តិដទៃផ្សេងទៀត ច្បាប់គ្រប់គ្រង អ.វ.ត.ក មិនចាំបាច់ត្រូវតែដោះស្រាយ នូវរាល់ភាពមិនប្រាកដប្រជាផ្នែកគតិយុត្តិទាំងអស់ ដែលអាចកើតចេញពីបញ្ហានីតិវិធី និង/ឬអង្គសេចក្តីឡើយ[168]។ ទោះជាយ៉ាងនេះក្តី ច្បាប់នេះបានចែងអំពីនីតិវិធី ដែលត្រូវអនុវត្តក្នុងករណីមានភាពចន្លោះប្រហោង ក្នុងក្របខណ្ឌគតិយុត្តិ[169] ព្រមទាំងត្រៀមបម្រុងជាចំហរចំពោះការខ្វែងយោបល់គ្នាដែលអាចកើត

---

[166] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២២។

[167] *សូមមើល* សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៨៨-១២៤។

[168] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១០១។

[169] *សូមមើល* មាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុង។ ជាពិសេសគឺការអនុវត្តរបស់ សហចៅក្រមស៊ើបអង្កេត សូមមើលផងដែរ មាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក។

មាន ក្នុងបរិបទចម្រុះរបស់ អ.វ.ត.ក ហើយបានចែងអំពីនីតិវិធីជាក់លាក់ក្នុងការចាត់ចែង និងដោះស្រាយ ការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី។ បើតាមកិច្ចព្រមព្រៀង អ.វ.ត.ក មុខងារចម្បងដែលផ្តល់ដល់អង្គបុរេជំនុំជម្រះ គឺប្រាកដណាស់ដើម្បីផ្តល់នូវយន្តការប្រកបដោយប្រសិទ្ធិភាព ដើម្បីដោះស្រាយជាស្ថាពរនូវការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និងរវាងសហចៅក្រមស៊ើបអង្កេត។ ដូចដែលបានសង្កត់ធ្ងន់ពីខាងលើ សហចៅក្រមស៊ើបអង្កេត បានសម្រេចដោយចេតនា ក្នុងការគេចវេសពីយន្តការនេះ ហើយបែរជាចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ទាំងដែលដឹងយ៉ាងច្បាស់អំពីបញ្ហាដែលនឹងកើតចេញពីសកម្មភាពរបស់ខ្លួនចំពោះកិច្ចដំណើរការនីតិវិធី នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក។

៩១. អង្គបុរេជំនុំជម្រះ ចាំបាច់ត្រូវតែសម្រេចលើបញ្ហាថាតើ សកម្មភាពទាំងនេះ គោរពទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក នៅក្នុងករណីនេះដែរឬយ៉ាងណា។ សម្រាប់សំអាងហេតុដូចរៀបរាប់លម្អិត នៅផ្នែកបន្ទាប់នេះ អង្គជំនុំជម្រះសម្រេចថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត បានរំលោភបំពានទៅលើមូលដ្ឋានស្នូល នៃប្រព័ន្ធច្បាប់ អ.វ.ត.ក។ អង្គជំនុំជម្រះនឹង (ក) អះអាងឡើងវិញនូវគោលការណ៍ជាមូលដ្ឋានគ្រប់គ្រងលើការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត និង (ខ) រំឭកឡើងវិញនូវនីតិវិធីខុសគ្នា ដែលមានសម្រាប់ការដោះស្រាយ ការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មក (គ) ផ្តល់នូវការសង្កេតរបស់អង្គជំនុំជម្រះ លើការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា ក្នុងពេលដំណាលគ្នា ដែលមិនអាចអនុញ្ញាតបាននៅក្នុងករណីបច្ចុប្បន្ននេះ។

១. គោលការណ៍ជាសារវន្ត គ្រប់គ្រងលើការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត

៩២. ទីមួយ អង្គបុរេជំនុំជម្រះសូមរំឭកថា ការបំពេញកិច្ចស៊ើបសួររួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ គឺជាគោលការណ៍គតិយុត្តិ ជាសារវន្តចម្បងនៅ អ.វ.ត.ក ដូចដែលមានចែងក្នុងមាត្រា ៥(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក "មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត"។

៩៣. ច្បាប់ អ.វ.ត.ក បានពង្រឹងលើគោលការណ៍ជាសារវន្តនេះ ដូចដែលចែងតម្រូវដោយ មាត្រា ១៤(១) នៃច្បាប់ដែលថា "ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបាន ភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន"។ មាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក បានចែងលម្អិតពីវិធីសាស្ត្រ ដែលគោលការណ៍នេះត្រូវយកមកអនុវត្ត ដោយតម្រូវថា "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នា របស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន"។ អង្គបុរេជំនុំជម្រះបានសម្រេចថា បទបញ្ញត្តិនេះដែលឆ្លុះបញ្ចាំងអំពីមាត្រា ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា ក្រមនេះ

"មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាព នៃបទល្មើសព្រហ្មទណ្ឌណាមួយ" តម្រូវថា សហចៅក្រមស៊ើបអង្កេតចាំបាច់ ត្រូវបំពេញកិច្ចស៊ើបសួររួមគ្នា ហើយអនុលោមទៅតាមច្បាប់ជាធរមាននៅ អ.វ.ត.ក[170]។

៥៤. អង្គបុរេជំនុំជម្រះបានបញ្ជាក់បំភ្លឺបន្ថែមទៀតថា "សហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលដែលខ្លួនមិនព្រមព្រៀងគ្នា លើបញ្ហាណាមួយដែលនៅចំពោះមុខ" ក្នុងវិសាលភាពដែលសហចៅក្រមស៊ើបអង្កេតឯកភាពលើវិធីសាស្ត្រដែល "ស្រប" ទៅនឹង "គោលជំហរស្វ័យប្រវត្តិ" ដែលបានដាក់បញ្ចូលទៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក គឺថា "ការស៊ើបអង្កេតត្រូវតែបន្ត"[171]។ ប្រហែលគ្នានេះ អង្គជំនុំជម្រះកត់សម្គាល់ថា មាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក បញ្ជាក់ច្បាស់ពីមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដោយចែងថា "ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម [...] ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្ដឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃ ថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ"[172]។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង ដែលចែងពីការដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ដោយអង្គបុរេជំនុំជម្រះ បានគាំទ្របន្ថែមដល់គោលជំហរ ជាសារវន្តមួយនេះ ដោយចែងថា៖

> ៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម ៖
>
> ឃ-សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច ។ សេចក្ដីសម្រេចនេះបិទផ្លូវប្ដឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរកបាននូវសម្លេងគាំទ្រ ភាគច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជានោះ សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រមានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព ឬមានន័យថា ដីកា ឬ កិច្ចស៊ើបសួរ ដែលបម្រុងនឹងធ្វើដោយ សហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវ

---

[170] សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១០៥។

[171] សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១០៦។ *យោងទៅរក* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D427/1/30) កថាខណ្ឌ ២៧៥។

[172] សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១០៧។

តែយកមកអនុវត្ត។

៩៥. ក្នុងករណីនេះ អង្គជំនុំជម្រះត្រូវតែបញ្ជាក់ថាតើ គោលការណ៍គតិយុត្តិទាំងអស់នេះ អនុញ្ញាតិឱ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយផ្ទុយគ្នា តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែរឬទេ ជំនួសឱ្យការបញ្ជូនរឿងដែលពួកគាត់ខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

២. ការដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត

៩៦. ជាបញ្ហាទូទៅ អង្គបុរេជំនុំជម្រះពិចារណាថា បញ្ហាថាតើសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចដែរឬទេ ក្នុងការបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺស្ថិតក្រោមការគ្រប់គ្រងដោយគោលការណ៍ដែលមានអានុភាពជាងដែលថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធិភាព នៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ ក្នុងករណីនេះ អង្គជំនុំជម្រះនេះ ឱ្យតម្លៃជាពិសេសទៅលើ លក្ខខណ្ឌតម្រូវនៃយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព។

៩៧. មធ្យោបាយមួយដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ធានានូវយុត្តិធម៌ប្រកបដោយប្រសិទ្ធិភាព នៅក្នុងបរិបទ អ.វ.ត.ក គឺតាមរយៈការធានាថា នីតិវិធីដែលមានជាធរមាន មិនត្រឹមតែអាចដោះស្រាយការខ្វែងយោបល់គ្នាដែលកើតចេញ ក្នុងដំណើរការស៊ើបអង្កេត និងជំនុំជម្រះក្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានប្រសិទ្ធិភាពក្នុងការដោះស្រាយ ការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការទាល់ច្រកផ្នែកនីតិវិធី ដែលអាចបណ្តាលផងដែរឲ្យមានការប៉ះពាល់ដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ នៅដំណាក់កាលមុនពេលជំនុំជម្រះ ដំណើរការនីតិវិធីទាំងអស់នេះ ត្រូវបានគូសបញ្ជាក់ និងកំណត់ជាស្ថាពរដោយ "គោលជំហរស្វ័យប្រវត្តិ" ដែលមានចែងផងដែរដោយ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលបញ្ជាក់យ៉ាងច្បាស់លាស់ថា នៅពេលដែល "ចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំ [...] ឱ្យដោះស្រាយការខ្វែងគំនិតគ្នា" ដោយអង្គបុរេជំនុំជម្រះ។

៩៨. ផ្អែកលើចំណុចនេះ អង្គបុរេជំនុំជម្រះបានសម្រេចថា បញ្ហាថា តើសហចៅក្រមស៊ើបអង្កេត មានបុព្វសិទ្ធិដែរឬអត់ ក្នុងការចេញដីកាដំណោះស្រាយផ្ទុយគ្នា ដោយមិនបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ អាស្រ័យលើថាតើ ការដែលសហចៅក្រមស៊ើបអង្កេត គេចវេសពីនីតិវិធីដោះស្រាយ ការខ្វែងយោបល់ដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺជាការកេងចំណេញដែរឬអត់ ទៅលើឥទ្ធិពលជាក់ស្តែងនៃគោលជំហរស្វ័យប្រវត្តិ

ដែលជាធាតុសំខាន់នៃ ប្រព័ន្ធច្បាប់ អ.វ.ត.ក[173]។ ក្នុងន័យនេះ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា គោលការណ៍ដែលមានលក្ខណៈសារវន្ត និងកំណត់សម្រេចដូចជា គោលជំហរស្វ័យប្រវត្តិនេះ គឺមិនអាចលប់ចោល ឬដកចេញនូវស្ថានទម្ងន់ និងអានុភាពពេញលេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយ ដែលជាការកេងចំណេញលើ ភាពមិនច្បាស់លាស់ដែលអាចមាន នៅក្នុងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូល នៃកិច្ចព្រមព្រៀង អ.វ.ត.ក នេះ ទៅជាអាសាឥតន័យនោះឡើយ[174]។ ការសន្និដ្ឋានផ្សេងពីនេះ នឹងនាំទៅដល់លទ្ធផលគតិយុត្តិដែលមិនមានសំអាងហេតុទាល់តែសោះ ហើយនាំឱ្យមានការរំលោភបំពាន ទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា។

៩៥. ដោយផ្អែកលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ នៅក្នុងសេចក្តីសម្រេចកន្លងមក អំពីបណ្តុំផ្សេងៗគ្នាជាច្រើន នៃនីតិវិធីដែលសហចៅក្រមស៊ើបអង្កេត អាចប្រើប្រាស់សម្រាប់ដោះស្រាយការខ្វែងយោបល់គ្នា ដោយគោរពទាំងស្រុងទៅតាម ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[175]។ ក្នុងន័យនេះ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា លក្ខណៈនិងភាពធ្ងន់ធ្ងរ នៃការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែធ្វើឱ្យពួកគាត់ ដឹងអំពីជម្រើសរបស់ពួកគាត់ សម្រាប់នីតិវិធីដែលសមស្របបំផុត ដែលត្រូវអនុវត្តតាម ក្នុងករណីណាមួយក៏ដោយ[176]។ អង្គជំនុំជម្រះរម្លឹកថា អាស្រ័យលើកាលៈទេសៈជាក់លាក់ នៃករណីនីមួយៗ នីតិវិធីដែលសហចៅក្រមស៊ើបអង្កេតអាចជ្រើសរើស គឺមានចាប់ពីការអត់ធ្មត់ដោយស្ងៀមស្ងាត់ ចំពោះកិច្ចឬសេចក្តីសម្រេចរបស់ ចៅក្រមម្នាក់ទៀត[177] រហូតដល់ការចុះបញ្ជីការខ្វែងយោបល់គ្នា[178] ឬបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ ចំពោះកិច្ច ឬសេចក្តី

---

[173] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១២។ *សូមមើលផងដែរ* កថាខណ្ឌ ១១០-១១១។

[174] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១២។

[175] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៣-១២១។

[176] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៣។

[177] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៥ ("អង្គជំនុំជម្រះបានសម្រេចថា តាមមាត្រា ២៣ថ្មី(៣) នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្តឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ ដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម" សហចៅក្រមស៊ើបអង្កេតមួយរូប អាចអនុញ្ញាតដោយត្រឹមត្រូវឱ្យ សហការីរបស់គាត់ អាចអនុវត្តទៅបាន ដោយខ្លួនគាត់មិនចូលរួមពាក់ព័ន្ធ នៅក្នុងកិច្ចបែបនេះ បើទោះបីជាមិនបានចុះកំណត់ហេតុ អំពីការខ្វែងយោបល់គ្នាក្តី ដែលធ្វើដូច្នេះគឺអនុញ្ញាតឱ្យ ការស៊ើបអង្កេតអាចបន្តទៅមុខបាន") (លប់ចោលជើងទំព័រ)។

[178] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៦ ("ក្នុងករណីការខ្វែងយោបល់គ្នា ពាក់ព័ន្ធបញ្ហាធ្ងន់ធ្ងរ ដូចជាបញ្ហាដែលជាចំណុចស្នូល នៃការស៊ើបអង្កេតជាដើម សហចៅក្រមស៊ើបអង្កេតមួយរូប អាចលើកការជំទាស់របស់គាត់ ប្រឆាំងនឹងកិច្ច ឬសេចក្តីសម្រេចរបស់ សហការីគាត់ ដោយការចុះកំណត់

សម្រេចដែលមានការជំទាស់ ដោយអនុលោមទៅតាម វិធាន ៧២ នៃវិធានផ្ទៃក្នុង[179]។

១០០. អង្គបុរេជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា ក្នុងស្ថានភាពណាក៏ដោយ កិច្ចរបស់សហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែស្ថិតក្នុងសមត្ថកិច្ចផ្ទាល់របស់ពួកគាត់ ហើយបំពេញដោយស្របទៅតាមគោលការណ៍សហប្រតិបត្តិការ ដែលមានចែងក្នុងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលឆ្លុះបញ្ចាំងពីឋានៈស្មើគ្នារបស់ សហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងប្រព័ន្ធចម្រុះរបស់ អ.វ.ត.ក[180]។ អង្គជំនុំ

---

ហេតុជាផ្លូវការ លើការខ្វែងយោបល់គ្នា។ អង្គជំនុំជម្រះសម្រេចថា ការបង្ហាញជាផ្លូវការ ពីការខ្វែងយោបល់គ្នា អនុលោមតាមមាត្រា ២៣ថ្មី(៣) នៃច្បាប់ អ.វ.ត.ក និងវិធាន ៧២(១) នៃវិធានផ្ទៃក្នុង ឬការឈានទៅដល់ការឯកភាពគ្នា ទៅលើបញ្ហាដែលកំពុងចោទ ត្រូវបានទទួលស្គាល់និងត្រូវបានអនុញ្ញាត នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក។ ក្នុងករណីបែបនេះ "សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬទាំងពីរ អាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដ នៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារ នៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខានិងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារ នៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជី របស់សហចៅក្រមស៊ើបអង្កេត" ដោយអនុលោមតាមវិធាន ៧២(១) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះយល់ថា បន្ទាប់មកការខ្វែងយោបល់គ្នាត្រូវបានរក្សាទុករវាងសហចៅក្រមស៊ើបអង្កេត ហើយទៅជាការសម្ងាត់។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៣ថ្មី នៃ ច្បាប់ អ.វ.ត.ក និងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា ក្នុងករណីបែបនេះ សហចៅក្រមស៊ើបអង្កេតមួយរូប អាចបំពេញកិច្ចដោយមិនមានការយល់ព្រម ពីចៅក្រមមួយរូបទៀតបាន នៅក្នុងពេលវេលាកំណត់ជាក់ច្បាស់។ បន្ទាប់មកសហចៅក្រមស៊ើបអង្កេតរូបនេះ អាចបន្តនីតិវិធីជាមួយសេចក្តីសម្រេច ដែលរងការជំទាស់ពេលដែលវេលាកំណត់ដែលបានតម្រូវ បានកន្លងផុតទៅ") (លុបចោលជើងទំព័រ)។

[179] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៧ ("អង្គជំនុំជម្រះកត់សម្គាល់ថា នៅពេលដែលការខ្វែងយោបល់គ្នា មានភាពធ្ងន់ធ្ងរខ្លាំង ដែលសហចៅក្រមស៊ើបអង្កេតមួយរូប ចង់បញ្ឈប់ការអនុវត្តសេចក្តីសម្រេច របស់សហការីគាត់នោះ មធ្យោបាយតាមផ្លូវច្បាប់តែមួយគត់ ដែលមានសម្រាប់ចៅក្រមរូបនោះគឺ ការបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ ដែលជាអង្គជំនុំជម្រះទទួលបាន សិទ្ធិអំណាចជាពិសេស និងជាក់លាក់ ដើម្បីដោះស្រាយភាពខុសគ្នា រវាងសហចៅក្រមស៊ើបអង្កេត។ ដើម្បីចាប់ផ្តើមយន្តការដោះស្រាយ ការខ្វែងយោបល់គ្នាប្រកបដោយប្រសិទ្ធិភាពនេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ ត្រូវដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីអង្គហេតុនិងមូលហេតុ នៃការខ្វែងយោបល់គ្នា។ ច្បាប់ជាធរមានរបស់ អ.វ.ត.ក ផ្តល់ដល់អង្គបុរេជំនុំជម្រះ នូវសិទ្ធិអំណាចដែលចាំបាច់សម្រាប់ដោះស្រាយជាស្ថាពរ លើបញ្ហាដែលមានជម្លោះរវាង សហចៅក្រមស៊ើបអង្កេតពីររូប ដែលមានសិទ្ធិអំណាចស្មើគ្នា ហើយសម្រេចថាតើ គួរ ឬមិនគួរ អនុវត្តសេចក្តីសម្រេច ដែលរងការជំទាស់។ ក្នុងករណីដែលអង្គបុរេជំនុំជម្រះ មិនអាចស្វែងរកសម្លេងភាគច្រើនលើសលប់ ដើម្បីដោះស្រាយសម្រេចការខ្វែងយោបល់គ្នាទេនោះ ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក បានចែងថា បញ្ហានេះនឹងត្រូវដោះស្រាយ ដោយស្ថានភាពកំណត់ដែលជាការចែងថា ការស៊ើបអង្កេតចាំបាច់ត្រូវបន្ត") (លុបចោលជើងទំព័រ)។

[180] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៥ *យោងទៅរក* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(១) ដែលត្រូវបកស្រាយរួមជាមួយ ច្បាប់ អ.វ.ត.ក មាត្រា ២៧ ថ្មី។

ជម្រះអះអាងឡើងវិញថា សហចៅក្រមស៊ើបអង្កេត បើតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក មានកាតព្វកិច្ចបន្តស្វែងរកគោលជំហររួម នៅក្នុងដំណើរខ្វែងយោបល់គ្នា[181]។ ប្រព័ន្ធច្បាប់ អ.វ.ត.ក ត្រូវបានតាក់តែងឡើង និងកំណត់ជារចនាសម្ព័ន្ធ ដើម្បីគ្រប់គ្រងលើការបំពេញកិច្ចស៊ើបសួររួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតដែលអាចឈានដល់ការយល់ស្របគ្នា នៅដំណាក់កាលណាមួយ នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ដែលពួកគាត់បានទទួល។ ការបញ្ជាក់បំភ្លឺទៅលើការខ្វែងយោបល់រវាងពួកគាត់ អំពីករណីបែបនេះ គឺអាចអនុញ្ញាតិទៅបាន[182] ប៉ុន្តែក្នុងករណីដែលការបញ្ជាក់បំភ្លឺនេះគោរពទៅតាមនីតិវិធីដែលមានជាធរមាន ហើយដែលនៅតែស្របគ្នាជាមួយនឹងគោលជំហរស្វ័យប្រវត្តិដែលជាធាតុផ្សំសំខាន់នៃប្រព័ន្ធគតិយុត្តិរបស់ អ.វ.ត.ក ដែលចែងអំពីវិធីសាស្ត្រប្រកបដោយប្រសិទ្ធិភាព ក្នុងការគេចចេញពីភាពទាល់ច្រក ផ្នែកនីតិវិធីណាមួយដែលអាចកើតមាន។

១០១. ជាចុងក្រោយ អង្គបុរេជំនុំជម្រះអះអាងឡើងវិញថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចយល់ស្របគ្នាលើគោលជំហររួម និងក្នុងករណីដែលបញ្ហាដែលពួកគាត់ខ្វែងយោបល់គ្នា ឬការខ្វែងយោបល់របស់ពួកគាត់ទៅលើបញ្ហាមួយ អូសបន្លាយពេលវេលា ដែលធ្វើឱ្យខូចខាតដល់ប្រសិទ្ធិភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ពេលនោះក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនអនុញ្ញាតឲ្យការខ្វែងយោបល់គ្នានេះ នៅបន្តគេចផុត ឬមិនទទួលយកដំណោះស្រាយ ប្រកបដោយប្រសិទ្ធិមួយនោះឡើយ[183]។ ហេតុដូច្នេះ អង្គជំនុំជម្រះតម្កល់ការសម្រេចពីមុនរបស់ខ្លួនថា ក្នុងករណីដែលនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា ដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺជាសកម្មភាពដែលនៅសល់តែមួយគត់ សម្រាប់សហចៅក្រមស៊ើបអង្កេត ដើម្បីជៀសវាងពីការកើតឡើងវិញ នូវការជាប់គាំងផ្នែកនីតិវិធី និងដើម្បីការពារនូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃកិច្ចស៊ើបសួរ ដែលធ្វើឡើងនៅ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែប្រើប្រាស់យន្តការនីតិវិធីនេះ ដោយបញ្ជូនការខ្វែងយោបល់របស់ពួកគាត់ ទៅអង្គបុរេជំនុំជម្រះ[184]។

---

[181] អង្គជំនុំជម្រះកត់សម្គាល់ថា ការប្រើប្រាស់ទម្រង់បច្ចុប្បន្ន នៅក្នុងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង បង្ហាញយ៉ាងច្បាស់ដោយឥតមន្ទិលថា សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចបន្តស្វែងរក សំអាងហេតុផ្លូវច្បាប់រួមគ្នា ឬសកម្មភាពដែលឯកភាពគ្នាជារួម នៅក្នុងអំឡុងពេលដោះស្រាយការខ្វែងយោបល់គ្នា និងថាសហចៅក្រមស៊ើបអង្កេតទាំងពីរ មានកាតព្វកិច្ចទៅវិញទៅមក ក្នុងន័យនេះ បើតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (*សូមមើល* សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៨)។

[182] អង្គជំនុំជម្រះទទួលស្គាល់ថា ច្បាប់ដែលអនុវត្តនៅ អ.វ.ត.ក ប្រមើលមើលថា ទោះបីជាមានការខិតខំប្រឹងប្រែងពិតប្រាកដក្នុងការឈានទៅរកការសម្របសម្រួល ឬស្វែងរកការឯកភាពជាឯកច្ឆន្ទក្តី សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិពីររូប ដែលមានឋានៈស្មើគ្នា អាចនៅតែមិនអាចឯកភាពគ្នា លើគោលជំហររួម (*សូមមើល* សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៩)។

[183] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៩។

[184] សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៩។

### ៣. សេចក្ដីសង្កេតទាក់ទងនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា

១០២. ដោយផ្អែកលើគោលការណ៍ដូចបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចថា ក្នុងករណីដែលការខ្វែងយោបល់គ្នា ទាក់ទងនឹងបញ្ហាដែលចាំបាច់ត្រូវសម្រេច ដោយដីកាដំណោះស្រាយ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក អនុញ្ញាតឱ្យមានមធ្យោបាយតែពីរប៉ុណ្ណោះ ដោយអនុលោមទៅតាមមាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចក្នុងការឈានទៅរកការឯកភាពគ្នាដោយស្ងៀមស្ងាត់ ឬដោយចំហរ ទៅលើបញ្ហាទាំងអស់នេះ ឬបញ្ជូនការខ្វែងយោបល់គ្នាទៅលើបញ្ហាបែបនេះ ទៅអង្គបុរេជំនុំជម្រះ[185]។

១០៣. លើសពីនេះទៀត អង្គបុរេជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា អត្ថបទច្បាប់របស់ អ.វ.ត.ក មិនមានភាពស្រពិចស្រពិលច្រើននោះទេ ក្នុងបញ្ហានេះ៖ វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា "សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ចប់ កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ ថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"។ សទ្ទានុក្រមរបស់វិធានផ្ទៃក្នុង បានបន្ថែមថា "ដីកាដំណោះស្រាយសំដៅទៅលើ ដីកាចុងក្រោយដែលធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់"[186]។

១០៤. បទប្បញ្ញត្តិទាំងអស់នេះបានចែងយ៉ាងច្បាស់ថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺជាដីកាសម្រេចតែមួយគត់។ ដូច្នេះ វិធាន ១(២) នៃវិធានផ្ទៃក្នុង ដែលបញ្ជាក់ថា នៅក្នុងវិធានផ្ទៃក្នុង ឯកវចនៈក៏អាចយល់ជាពហុវចនៈ និងការយោងទៅរកសហចៅក្រមស៊ើបអង្កេត "សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ ក្នុងចំណោមអ្នកទាំងពីរ" មិនបានផ្ដល់មូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ ដើម្បីទាត់ចោល ឬកាត់បន្ថយគោលការណ៍ស្នូល នៃការឯកភាពគ្នាដូចជាថា គោលជំហរជាក់ស្ដែង និងវិធានស្ដីពីការបកស្រាយក្នុងន័យចង្អៀត ទៅលើលក្ខន្តិកៈព្រហ្មទណ្ឌ បានទប់ស្កាត់បន្ថែមទៀតចំពោះ ការបកស្រាយតាមអំពើចិត្តណាមួយ នៅក្នុងអត្ថន័យនេះ។

១០៥. សម្រាប់សំអាងហេតុទាំងអស់នេះ អង្គបុរេជំនុំជម្រះច្រានចោល សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីភាពអាចអនុញ្ញាតបានតាមផ្លូវច្បាប់ ក្នុងការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។ បន្ថែមពីលើកំហុសអង្គច្បាប់យ៉ាងច្បាស់ក្រឡែត ដែលសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត បានពឹងផ្អែកទៅ

[185] សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២០។

[186] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣ (ភាសាអង់គ្លេស) (សេចក្ដីបញ្ជាក់បន្ថែម)។ សូមមើល ផងដែរ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២២)។

លើនោះ អង្គបុរេជំនុំជម្រះសូមរំឭកផងដែរថា សហចៅក្រមស៊ើបអង្កេត មានភារកិច្ចតាមផ្លូវតុលាការ ក្នុងការសម្រេចលើបញ្ហាដែលមានវិវាទ ដែលពួកគាត់បានទទួល[187]។ ក្នុងករណីដែលការខ្វែងយោបល់គ្នារបស់ពួកគាត់រារាំងពួកគាត់មិនឱ្យឈានទៅដល់ការសម្រេចជាស្ថាពររួមគ្នា ទៅលើបញ្ហាបែបនេះ ពួកគាត់នៅតែចាំបាច់ត្រូវបញ្ចប់ភារកិច្ចតាមផ្លូវតុលាការរួមគ្នានេះ ដោយគោរពទៅតាមនីតិវិធីជាធរមាន នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក ដើម្បីធានាថាអាចឈានដល់ការសម្រេចជារួម ទៅលើបញ្ហាដែលស្ថិតក្នុងយុត្តាធិការរបស់ពួកគាត់[188]។

១០៦. ជាសន្និដ្ឋាន អង្គបុរេជំនុំជម្រះសូមសង្កត់ធ្ងន់ថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នា ដោយមិនបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ឬប្រតិបត្តិទៅតាមគោលជំហរស្វ័យប្រវត្តិនោះ គឺសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងនេះបានប្រព្រឹត្តកំហុសឆ្គងដែលធ្វើឱ្យប៉ះពាល់ទៅដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និងដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ទោះបីជាលក្ខណៈជាមូលដ្ឋាន នៃបញ្ហាចោទនេះ គឺថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់នោះ ក៏ដោយ តែសហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយដែលមានសំអាងហេតុតិចតួចគួរឱ្យកត់សម្គាល់ ដោយលើកឡើងតែត្រឹមសេចក្ដីសម្រេចកន្លងមករបស់ពួកគាត់ត្រឹមតែពីរប៉ុណ្ណោះ[189]។

១០៧. បន្ថែមលើនេះទៀត និងបើទោះបីជាអាចសន្មតថា សហចៅក្រមស៊ើបអង្កេតអាចប្រព្រឹត្តកំហុសអង្គច្បាប់ទាំងនេះ ក្នុងគោលបំណងល្អក្ដី តាមរយៈដីកាសម្រេចរបស់ពួកគាត់ដែលបានលើកឡើងខាងលើនោះ បង្ហាញយ៉ាងច្បាស់ណាស់ថា ពួកគាត់បានដឹងថា ការបដិសេធមិនបញ្ជូនករណីខ្វែងយោបល់របស់ពួកគាត់ទៅអង្គបុរេជំនុំជម្រះ បញ្ហានានាដែលពួកគាត់មិនយល់ស្របគ្នា រួមទាំងបញ្ហាគន្លឹះថាតើ មាស មុត ស្ថិត ឬមិនស្ថិតក្រោមយុត្តាធិការ

---

[187] *សូមមើល* សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២២។

[188] សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២២។

[189] *សូមមើល ខាងលើ កថាខណ្ឌ* ៨៥-៨៧។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267) កថាខណ្ឌ ១៩ *យោងទៅ* ដីកាសម្រេចដាក់ដីកាសម្រេចចូលក្នុងសំណុំរឿង ០០៣ (ឯកសារ D262) *យោងទៅ* ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D262.1) និងដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (ឯកសារ D262.2) កថាខណ្ឌ ១៣-១៦។ ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D266) កថាខណ្ឌ ៧ *យោងទៅរក* ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (ឯកសារ D262.2) កថាខណ្ឌ ១៥។ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចទាំងនេះ (ឯកសារ D262.1, ឯកសារ D262.2) ដែលបានចេញពីដំបូងដើម្បីឆ្លើយតបចំពោះសំណើនានារបស់ភាគីនៅក្នុងសំណុំរឿង ០០៤/២ ត្រូវបានដាក់ទៅក្នុងសំណុំរឿង ០០៣ តាមរយៈដីកាសម្រេចតែមួយ (ឯកសារ D262) ដោយមិនមានវិធានការណាមួយឡើយ ដើម្បីឆ្លើយតបចំពោះភាពរួមគ្នាតែមួយនៃសំណុំរឿង ដោយស្នើសុំដូចជា សំណើរបស់ភាគី ដោយមិនគិតអំពីផលប៉ះពាល់ធំធេង ដោយសារសកម្មភាពបែបនេះ។

01667327



របស់ អ.វ.ត.ក នោះ នឹងត្រូវបានដោះស្រាយតែក្នុងផ្នែកនៃកិច្ចដំណើរការបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គជំនុំជម្រះនេះប៉ុណ្ណោះ មិនមែនតាមរយៈយន្តការផ្នែកនីតិវិធី ដែលបានចែងជាក់លាក់ដោយក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក សម្រាប់ដំណោះស្រាយតែចំពោះករណីខ្វែងយោបល់គ្នារវាងពួកគាត់នេះទេ។ សហចៅក្រមស៊ើបអង្កេតបានដឹងពីការលំបាកដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់ មិនត្រឹមតែទៅលើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ទៅទៀត[190]។ អង្គបុរេជំនុំជម្រះក៏យល់ឃើញផងដែរថា ជារឿងប្លែកដែលដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ត្រូវបានចេញក្នុងថ្ងៃតែមួយ ជាភាសាតែមួយ[191] ដោយមានការប្រកាសរួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរថា ពួកគាត់ឯកភាពគ្នា លើការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា។

១០៨. ជារួម អង្គបុរេជំនុំជម្រះពិចារណាថា កំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ ក្រៅពីការរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាន នៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក អង្គជំនុំជម្រះយល់ឃើញថា ការអនុវត្តដោយខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត អាចបង្កើតបានជាភាពអយុត្តិធម៌ ជាពិសេសដោយសារតែអង្គជំនុំជម្រះ មិនអាចមិនពិចារណាថា ពួកគាត់ប្រហែលមានចេតនា ធ្វើឱ្យបរាជ័យដល់គោលជំហរស្វ័យប្រវត្តិ ហើយរំខានដល់សិទ្ធិអំណាច របស់អង្គបុរេជំនុំជម្រះ។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមថា មិនត្រឹមតែជាឧទាហរណ៍ដាច់តែឯងប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពរបស់ពួកគាត់ នៅក្នុងករណីនេះគាំទ្រនូវទម្រង់មួយដែលសហចៅក្រមស៊ើបអង្កេតបានអនុម័តយកដោយច្បាស់លាស់ ក្នុងការដោះស្រាយជាមួយបណ្តាសំណុំរឿងចុងក្រោយទាំងអស់ នៅក្នុងបញ្ជីសំណុំរឿងរបស់ អ.វ.ត.ក[192]។

១០៩. ជាថ្មីម្តងទៀត អង្គជំនុំជម្រះកត់សម្គាល់ដោយការសោកស្តាយថា តាមការយល់ដឹង និងបទពិសោធន៍របស់ខ្លួន មិនដែលធ្លាប់មានសំណុំរឿងព្រហ្មទណ្ឌណា នៅក្នុងប្រវត្តិសាស្ត្រនៃប្រព័ន្ធច្បាប់អន្តរជាតិ និងប្រព័ន្ធច្បាប់ជាតិដទៃទៀត ដែលបញ្ចប់ដោយការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរក្នុងពេលដំណាលគ្នា ហើយចេញដោយការិយាល័យចៅក្រមតែមួយនោះទេ។ បន្ទាប់ពីការស៊ើបអង្កេតដប់ឆ្នាំ ទៅលើឧក្រិដ្ឋកម្មដែលស្ថិតក្នុងចំណោមឧក្រិដ្ឋ

---

[190] *សូមមើល* ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D262.2) កថាខណ្ឌ ១៥-១៦។

[191] *សូមមើល* ខាងលើ កថាខណ្ឌ ២៣ (នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D266) បានដាក់តែជាភាសាខ្មែរ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267) បានដាក់តែជាភាសាអង់គ្លេសប៉ុណ្ណោះ)។

[192] *សូមមើល* សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៨៨-១២៤។ សូមមើលផងដែរ សំណុំរឿង០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381សំណុំរឿង០០៤ ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

កម្មដែលធ្ងន់ធ្ងរ និងសាហាវយង់ឃ្នងបំផុត ដែលបានប្រព្រឹត្តឡើងនៅក្នុងសតវត្សទី២០ អង្គបុរេជំនុំជម្រះ អាចត្រឹមតែថ្កោលទោសជាថ្មីម្តងទៀតទៅលើស្ថានការណ៍ដ៏អាក្រក់ផ្នែកផ្លូវច្បាប់ ដែលសកម្មភាពខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេត បានបង្កើតឡើងចំពោះកិច្ចដំណើរការនីតិវិធីផ្សេងទៀតរបស់ អ.វ.ត.ក។

## VI. អង្គសេចក្តី

១១០. ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ និងលក្ខណៈខុសច្បាប់នៃការព្រមព្រៀងគ្នារបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើក្តី ក៏អង្គជំនុំជម្រះ បន្ទាប់ពីប្រជុំពិភាក្សារួច មិនអាចរកសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនប្អូនតាមការកំណត់ ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចមួយលើអង្គសេចក្តី ផ្អែកលើសំអាងហេតុរួម បានឡើយ។ អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង មតិរបស់សមាជិកផ្សេងៗនៃអង្គបុរេជំនុំជម្រះ ត្រូវបានភ្ជាប់មកជាមួយសេចក្តីពិចារណាទាំងនេះ។

## VII. សេចក្តីសម្រេច

**ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយោងតាមសំឡេងឯកច្ឆន្ទៈ**

- **បង្គាប់** ឲ្យដាក់បញ្ចូលគ្នានូវបណ្តឹងឧទ្ធរណ៍ទាំងឡាយប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ

- **សម្រេច** ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិអាចទទួលយកបាន

- **សម្រេច** ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអាចទទួលយកបាន

- **សម្រេច** ថា បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី មាស មុត មិនអាចទទួលយកបានទេ

- **ប្រកាស** ថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ដោយរំលោភទៅលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក

- **ប្រកាស** ថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រពីចៅក្រម (បួន)រូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តី ដោយផ្អែកលើសំអាងហេតុរួមមួយបានឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា។

រាជធានីភ្នំពេញ, ភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២១

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួន។

ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន។

## VIII. **យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន៉ិយ ថុល និងចៅក្រម ហួត វុទ្ធី**

១១១. នៅក្នុងសេចក្តីសម្រេចជាឯកច្ឆ័ន្ទខាងលើ ដែលមាន មាស មុត ជាជនត្រូវចោទ អង្គបុរេជំនុំជម្រះបានសម្រេចត្រង់ចំណុចទី ៥ ថា៖ "**ប្រកាស** ថា ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតគឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក"។

១១២. ផ្អែកតាមសេចក្តីសម្រេចខាងលើនេះ ចៅក្រមជាតិនៃ អ.ប.ជ សូមផ្តល់នូវយោបល់ស្តីពីការយល់ឃើញរបស់ខ្លួន ទៅលើតម្លៃគតិយុត្តិនៃដីកាដំណោះស្រាយទាំងពីរដូចតទៅ៖

- ដីកាដំណោះស្រាយទាំងពីរត្រូវបានដាក់ជូនដាច់ដោយឡែកពីគ្នានៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ជាភាសាអង់គ្លេស និងភាសាខ្មែរតែប៉ុណ្ណោះ ឯសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីជាមុន គឺនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៧ ថា ពួកគាត់បានពិចារណា លើដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នា ដោយសំអាងលើការមិនចុះសម្រុងគ្នារវាងពួកគាត់ ដែលអនុញ្ញាត នៅក្រោមច្បាប់ជាធរមាន នៅចំពោះមុខ អ.វ.ត.ក និងផលវិបាកទំនងជាកើតឡើង សម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៧(១៣)។
- វិធាន ៧២ នៃវិធានផ្ទៃក្នុង ជាវិធាននៃនីតិវិធីសម្រាប់ដោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែ ការខ្វែងយោបល់គ្នាជាសម្ងាត់រវាងសហចៅក្រមស៊ើបអង្កេតត្រូវបានកត់ត្រាក្នុងបញ្ជី៖
    - ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣
    - ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣
    - ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤
    - ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧
    - ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨

១១៣. សហចៅក្រមស៊ើបអង្កេតទាំងពីរនាក់បានឯកភាពគ្នា រក្សាទុកករណីខ្វែងយោបល់គ្នានៅក្នុងការិយាល័យរបស់ខ្លួន ព្រមទាំងឯកភាពគ្នាពុំនាំយកការខ្វែងគំនិតនោះមកចំពោះមុខ អ.ប.ជ បានន័យថាបានឯកភាពពុំអនុវត្តតាមអ្វីដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងទេ។ ដូច្នេះ អ.ប.ជ ពុំអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងឡើយ។

១១៤. វិធាន ៧៧(១៣) ចែងថា ៖

"សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឲ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤ (បួន) រូប យ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖

ក. ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំមោឃភាពដីកា ឬកិច្ចស៊ើបសួរ ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬកិច្ចស៊ើបសួរនោះត្រូវតម្កល់ទុកជាបានការ។

ខ. ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត"។

១១៥. ន័យដូចចែងក្នុងវិធាន ៧៧(១៣) ខាងលើ ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា។

១១៦. សហចៅក្រមស៊ើបអង្កេតទាំងពីរមានឋានៈស្មើគ្នា ហើយយោងតាមអញ្ញត្រកម្មនៃសច្ចាធារណ៍និរទោស ច្បាប់ជាធរមានពុំអនុញ្ញាតឲ្យ អ.ប.ជ សម្រេចថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតណាម្នាក់មានឧត្តមភាពនោះទេ។

១១៧. ដូច្នេះដីកាដំណោះស្រាយទាំងពីររក្សាបាននូវតម្លៃស្មើគ្នាដដែល។

១១៨. ផ្អែកតាមការពិចារណាមកនេះ ចៅក្រមជាតិនៃ អ.ប.ជ យល់ឃើញថា គប្បីបញ្ជូនសំណុំរឿង ០០៣ ដែលមាន មាស មុត ជាជនត្រូវចោទ ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក។

**ហេតុដូច្នេះសម្រេច**

**បញ្ជូន**សំណុំរឿង ០០៣ ដែលមាន មាស មុត ជាជនត្រូវចោទ ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២១

| | | |
|---|---|---|
| ចៅក្រម ប្រាក់ គឹមសាន ប្រធាន | ចៅក្រម ន័យ ថុល | ចៅក្រម ហួត វុទ្ធី |

## IX. យោបល់របស់ចៅក្រម OLIVIER BEAUVALLET និងចៅក្រម KANG JIN BAIK

### ក. បញ្ហាបឋម

១១៩. នៅពេលនេះ ចៅក្រមអន្តរជាតិនឹងពិនិត្យទៅលើបញ្ហាបឋមពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញលើបណ្តឹងឧទ្ធរណ៍ដែលអាចទទួលយកបាន នៅក្នុងសំណុំរឿងនេះ។ តាំងពីដំបូង ចៅក្រមអន្តរជាតិបដិសេធដាច់ខាតចំពោះសញ្ញាណដែលថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗក្នុងសំណុំរឿង០០៤/២ អាចយកមកដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០៣ ដើម្បីគ្រប់គ្រងទៅលើលទ្ធផលនៅក្នុងសំណុំរឿងនេះ។ សំណុំរឿង ០០៣ មានដីកាលើកលែងចោទប្រកាន់មិនពេញលេញគ្មានសុពលភាពដោយមិនបានអើពើចំពោះភស្តុតាងរយៈពេលប្រាំពីរឆ្នាំ និងការចោទប្រកាន់ព្រហ្មទណ្ឌដែលប្តឹងមកសហចៅក្រមស៊ើបអង្កេតជាតិយ៉ាងត្រឹមត្រូវ។ ដីកាមិនពេញលេញនេះ គឺគ្មានសុពលភាព និងទុកជាមោឃៈដោយសារតែហេតុផលមួយនេះប៉ុណ្ណោះ[193]។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាលើកលែងចោទប្រកាន់ទុកជាមោឃៈ ដីកាបញ្ជូនរឿងទៅជំនុំជម្រះតម្កល់ទុកជាបានការ ហើយការចោទប្រកាន់ត្រូវបន្តដំណើរការទៅមុខ។ ចៅក្រមអន្តរជាតិនឹងលើកឡើងអំពី (i) សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ[194] (ii) ការពន្យារពេលហួសហេតុនៅក្នុងកិច្ចស៊ើបសួរនៃសំណុំរឿង ០០៣[195] (iii) ការពិចារណាលើភស្តុតាង[196] និង (iv) តួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា និងអានុភាពនៃសេចក្តីសម្រេចរបស់តុលាការនេះដែលសន្និដ្ឋានថាពុំមានយុត្តាធិការបុគ្គល[197]។

---

193 សូមមើល ខាងក្រោម កថាខណ្ឌ ២៤៩ ដល់ ២៥០

194 *សូមមើល ខាងក្រោម* កថាខណ្ឌ ១២០-១៣៤។

195 *សូមមើល ខាងក្រោម* កថាខណ្ឌ ១៣៥-១៤៩។

196 *សូមមើល ខាងក្រោម* កថាខណ្ឌ ១៥០-១៦៩។

197 *សូមមើល ខាងក្រោម* កថាខណ្ឌ ១៧០-១៧៦។

១. សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ

១២០. ចៅក្រមអន្តរជាតិយល់ឃើញថា ចាំបាច់ត្រូវរំលឹកឡើងវិញ និងបញ្ជាក់ឲ្យបានច្បាស់អំពីមុខងារចម្បងៗដែលអង្គបុរេជំនុំជម្រះអាចអនុវត្តនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីចេញដីកាដំណោះស្រាយរបស់ អ.វ.ត.ក។ នៅក្នុងផ្នែកនេះ ចៅក្រមអន្តរជាតិនឹងលើកឡើងអំពី (១) ប្រភពនៃសិទ្ធិអំណាចទូទៅរបស់ខ្លួន (២) លក្ខណៈនៃយុត្តាធិការរបស់ខ្លួននៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីចេញដីកាដំណោះស្រាយ (៣) អន្តរាគមន៍ផ្សេងៗគ្នាដែលខ្លួនអាចធ្វើទៅបាននៅដំណាក់កាលនោះ និង (៤) ត្រូវតែរម្លឹកដល់ករណីចុងក្រោយពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ។

ក. ប្រភពនៃសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ

១២១. នៅក្នុងសេចក្តីសម្រេចមុនៗ[198] អង្គបុរេជំនុំជម្រះបានបញ្ជាក់អំពីចង្កោមនៃការទទួលខុសត្រូវ និងអំណាចខុសៗគ្នា ដែលខ្លួនមាននៅក្នុងប្រព័ន្ធគតិយុត្តិ អ.វ.ត.ក ដែលលេចចេញយ៉ាងច្បាស់ ជាពិសេសពីវិធានផ្ទៃ ៧៣(ក) ដោយចែងថា យុត្តាធិការរបស់អង្គជំនុំជម្រះរួមបញ្ចូលមុខងារជាសាលាឧទ្ធរណ៍។ អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺបន្ថែមទៀតថា មុខងារជាសាលាឧទ្ធរណ៍របស់ខ្លួនផ្តល់អំណាចឲ្យខ្លួនអាចសម្រេចជាស្ថាពរ និងបិទផ្លូវតវ៉ាលើអង្គច្បាប់ ដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះ[199]។ អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា ក្នុងករណីជាក់លាក់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ខ្លួនមានអំណាចចេញដីកាដំណោះស្រាយថ្មី ឬ កែប្រែឡើងវិញ រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៩ (១) នៃវិធានផ្ទៃក្នុង[200]។

១២២. ទាក់ទងនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងស៊ីសង្វាក់ជានិច្ចថា នៅពេលមានតម្រូវការចាំបាច់ដើម្បីបំពេញចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង ក្របខ័ណ្ឌគតិយុត្តិ អ.វ.ត. ក អនុញ្ញាតឱ្យអង្គ

---

[198] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៣២-៣៤, ៤៦។

[199] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) លេខយោងជើងទំព័រ ១៦៣។

[200] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៣០ លេខយោងជើងទំព័រ ៥៣។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) និងលេខយោងជើងទំព័រ ៥៨។

ជំនុំជម្រះសម្រេចស្របតាមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ[201]។ នៅក្នុងការអនុវត្តជាក់ស្តែង ដោយសារតែតុលាការកម្ពុជា មិនសូវសម្បូរយុត្តិសាស្ត្រអនុវត្ត អង្គជំនុំជម្រះក៏ស្វែងរកគោលការណ៍ណែនាំនៅក្នុងនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តប្រព័ន្ធជជែកសួរដេញដោល ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលជាមូលដ្ឋាននីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ចំពោះបទដ្ឋានអន្តរជាតិ អង្គជំនុំជម្រះផ្តោតសំខាន់លើប្រភពនានា ដែលឆ្លុះបញ្ចាំងអំពីលក្ខណៈពិសេសនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តប្រព័ន្ធជជែកសួរដេញដោល ដែលក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក និងច្បាប់កម្ពុជា អនុវត្តតាមនៅក្នុងដំណាក់កាលនីតិវិធីមុនការជំនុំជម្រះ។

### ខ. លក្ខណៈនៃយុត្តាធិការរបស់អង្គបុរេជំនុំជម្រះនៅដំណាក់កាល នៃកិច្ចដំណើរការនីតិវិធីចេញដីកាដំណោះស្រាយ

១២៣. ផ្ទុយពីវិធានគ្រប់គ្រងបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលប្រគល់យុត្តាធិការឲ្យអង្គជំនុំជម្រះតុលាការកំពូលមានសិទ្ធិពិនិត្យឡើងវិញនូវប្រភេទនៃ "កំហុស" អង្គច្បាប់ និងអង្គហេតុជាក់លាក់[202] វិធានផ្ទៃក្នុងផ្តល់យុត្តាធិការជារួមដល់អង្គបុរេជំនុំជម្រះលើ "ដីកាសម្រេច" និង "សេចក្តីសម្រេច" របស់សហចៅក្រមស៊ើបអង្កេត[203]។

១២៤. ចៅក្រមអន្តរជាតិកត់សម្គាល់ថា វិសាលភាព និងលក្ខណៈនៃអំណាចពិនិត្យមើលឡើងវិញរបស់អង្គបុរេជំនុំជម្រះត្រូវគោរពតាមកាតព្វកិច្ចរបស់ខ្លួនស្របតាមវិធាន ៧៦(៧)នៃវិធានផ្ទៃក្នុងដែលចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ"។ ចៅក្រមអន្តរជាតិពិចារណាឃើញថា "ដោយសារគ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធី [...] អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល" [204] បទប្បញ្ញត្តិនេះ យោងតាមវិធាន ២១(១) នៃវិធានផ្ទៃផ្តល់នូវការសន្មតថា រាល់កិច្ចទាំងអស់ត្រូវអនុវត្តដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ និងភាគីផ្សេងទៀតមុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ។ ហេតុដូច្នេះ នៅពេលអង្គបុរេជំនុំជម្រះទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

[201] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១) និងវិធាន ២ នៃវិធានផ្ទៃក្នុង។

[202] *សូមមើល* វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[203] *សូមមើល* វិធាន ៧៣ និងវិធាន ៧៤ នៃវិធានផ្ទៃក្នុង។

[204] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង ឯកសារ D360/33) កថាខណ្ឌ ៥២។

របស់សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះនេះមានសិទ្ធិអំណាចពិនិត្យមើលឡើងវិញថា តើការចេញដីកាដំណោះស្រាយ និងកិច្ចស៊ើបសួរអនុវត្តស្របតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមានទាំងអស់នៅក្នុងក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ជាពិសេសវិធាន ២១ និង ៧៦ នៃវិធានផ្ទៃក្នុង ក៏ដូចជា មាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែរឬទេ[205]។

១២៥. ចៅក្រមអន្តរជាតិសង្កេតឃើញថា ដោយសារមិនមានបទប្បញ្ញត្តិជាក់លាក់ផ្តល់ជូនអង្គបុរេជំនុំជម្រះនូវយន្តការចាំបាច់ដើម្បីបំពេញកាតព្វកិច្ចដ៏សំខាន់បែបនេះ ហើយកិច្ចព្រមព្រៀង អ.វ.ត.ក ទំនងចែងប្រមើលមើលឱ្យអង្គបុរេជំនុំជម្រះតែមួយគត់ដើរតួជាយន្តការដោះស្រាយការខ្វែងយោបល់គ្នា[206] វិធានផ្ទៃក្នុងផ្តល់អំណាចជាក់លាក់បន្ថែម និងយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[207]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា វិធានផ្ទៃក្នុងមិនត្រឹមតែអនុញ្ញាតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្គាប់ឱ្យអង្គជំនុំជម្រះអនុវត្តអំណាចទូលំទូលាយក្នុងនាមជាសភាស៊ើបសួរកម្ពុជាទៀតផង តាមរយៈការអនុវត្តមាត្រា ១២ នៃកិច្ចព្រមព្រៀង វិធាន ២ នៃវិធានផ្ទៃក្នុង ក៏ដូចជាមាត្រា ១(២) និងមាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ និងភាគីផ្សេងទៀតក្នុងអំឡុងពេលស៊ើបអង្កេត និងធានានូវដំណោះស្រាយចំពោះការរំលោភសិទ្ធិរបស់ភាគី ក្នុងករណីចាំបាច់។

១២៦. លើសពីនេះទៀត ចៅក្រមអន្តរជាតិសូមរម្លឹកថា នៅពេលមានបណ្តឹងឧទ្ធរណ៍ដែលអាចទទួលយកបានដាក់ប្តឹងប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត នៅចំពោះមុខអង្គបុរេជំនុំជម្រះ សំណុំរឿងទាំងមូល ត្រូវបញ្ជូនមកអង្គជំនុំជម្រះ មិនមែនត្រឹមតែផ្នែកសម្រេចសេចក្តីនៃដីកាបង្គាប់ ឬសេច

---

[205] *សូមមើល* សំណុំរឿង ០០៣ (អ.ប.ជ ០១) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D11/1/4/2 មតិយោបល់របស់ចៅក្រម DOWNING និងចៅក្រម LAHUIS កថាខណ្ឌ ៦ (អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយថា ខ្លួនមានយុត្តាធិការពិនិត្យការយកចិត្តទុកដាក់ស្តែងចេញពីកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ដែលវាគឺជា "កត្តាពាក់ព័ន្ធមួយ [សម្រាប់] ពិចារណាលើសិទ្ធិរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី")។

[206] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧។

[207] *សូមមើល* វិធាន ៧៣ នៃវិធានផ្ទៃក្នុង។

ក្តីសម្រេចជាក់លាក់នោះទេ[208] ដូច្នេះ អង្គជំនុំជម្រះទទួលបានសិទ្ធិអំណាចលើសំណុំរឿងទាំងមូល[209]។ ចាប់ពីដំណាក់កាលនោះទៅ សហចៅក្រមស៊ើបអង្កេតលែងមានសិទ្ធិអំណាចលើរឿងក្តីដែលបានប្តឹង ហើយនឹងលែងមានសិទ្ធិអំណាចលើគ្រប់ទិដ្ឋភាពនៃការស៊ើបអង្កេតលើរឿងក្តីនេះ[210]។ យុត្តាធិការរបស់អង្គបុរេជំនុំជម្រះរួមទាំងអំណាចទូលំទូលាយរបស់ខ្លួន ចាប់ផ្តើមមានភ្លាមៗក្រោយពេលទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ អង្គបុរេជំនុំជម្រះបានរកឃើញបន្ថែមទៀតថា ការយល់ឃើញបែបនេះអំពីដំណើរការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺ

---

[208] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៤៨ លេខយោងជើងទំព័រ ៨៨ *យោងលើ* Christian GUÉRY, "*Effet dévolutif de l'appel et manifestation de la vérité: du prétendu pouvoir de révision de la chambre de l'instruction*", Droit pénal n° 5 (étude 8), LexisNexis ខែឧសភា ឆ្នាំ២០១៤ ("GUÉRY, *Effet dévolutif de l'appel et manifestation de la vérité* (2014)") កថាខណ្ឌ ៣។

[209] តុលាការកំពូលព្រហ្មទណ្ឌបារាំង ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩៩ លេខ ៩៩-៨១.៨៥៣ ("*Qu'en effet [l'article 202 du code de procedure pénale] permet à la chambre d'accusation et sans que sa saisine puisse être limitée par l'effet dévolutif de l'appel, de statuer d'office, à l'égard de la personne mise en examen renvoyée devant elle, sur tous les chefs de crimes, délits principaux ou connexes, résultant de la procédure et notamment sur ceux qui, comme en l'espèce, en avaient été distraits par une ordonnance de renvoi devant le tribunal correctionnel*".)។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៤៨។

[210] *សូមមើល* វិធាន ៧៥ នៃវិធានផ្ទៃក្នុង។ (៣)(២)*សូមមើលផងដែរ* តុលាការកំពូលផ្នែកព្រហ្មទណ្ឌបារាំង ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០២ លេខ 01-87.123 ("*l'ordonnance du juge d'instruction qui, sur les réquisitions du procureur de la République, décide que l'information est complète et y met fin, soit en disant qu'il n'y a lieu à suivre, soit en renvoyant la personne mise en examen devant la juridiction compétente, dessaisit le juge d'instruction*")។ តុលាការកំពូលផ្នែកព្រហ្មទណ្ឌបារាំង ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៦៩ លេខ 69-91612 ("*Cette ordonnance qui, sur les réquisitions du procureur de la République, décidait que l'information était complète et y mettait fin, dessaisissait le juge d'instruction de l'ensemble de la procédure*")។ *សូមមើលផងដែរ* សេចក្តីសម្រេចលើភស្តុតាងបានមកពីទារុណកម្មក្នុងសំណុំរឿង ០០៣ (D257/1/8) កថាខណ្ឌ ១១ ("អង្គបុរេជំនុំជម្រះបកស្រាយវិធាន ៦៦(១) វិធាន ៦៧(១) និងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ដោយមានការពាក់ព័ន្ធទៅនឹងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងចាត់ទុកថា "កិច្ចស៊ើបសួរ" ត្រូវបានបញ្ចប់ជាផ្លូវការដោយការចេញដីកាដំណោះស្រាយ និងមិនមែននៅពេលដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងភាគីនានាអំពីគោលបំណងរបស់ខ្លួន ក្នុងការបញ្ចប់ដីកាដំណោះស្រាយនោះទេ")។

01667338



ស្របទៅនឹងលក្ខណៈពិសេសនៃនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តប្រព័ន្ធជជែកសួរដេញដោល ដូចបានកំណត់នៅក្នុងអត្ថបទគតិយុត្តរបស់ អ.វ.ត.ក[211]។

គ. អន្តរាគមន៍ខុសៗគ្នា ដែលអង្គបុរេជំនុំជម្រះអាចធ្វើឡើង

១២៧. អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ខ្លួនអាចធ្វើអន្តរាគមន៍យ៉ាងតិចចំនួន ០៣បែប នៅក្នុងកិច្ចដំណើរការនីតិវិធីចេញដីកាដំណោះស្រាយ ពោលគឺ ជាចម្បង (ក) ការពិនិត្យមើលឡើងវិញនូវបណ្ដឹងឧទ្ធរណ៍ដែលអាចទទួលយកបាន ដាក់ជូនដោយភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធី និង (ខ) ការពិនិត្យមើលឡើងវិញជាយថាហេតុលើការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ និងលើកិច្ចស៊ើបសួរ ដែលបានធ្វើឡើងនៅក្នុងរឿងក្ដីនេះ និង (គ) ការអនុវត្តអំណាចស៊ើបអង្កេតបន្ទាប់បន្សំដើម្បីបំពេញបន្ថែមការស៊ើបអង្កេតតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្នុងករណីចាំបាច់។ ចៅក្រមអន្តរជាតិនឹងរំលឹកឡើងវិញថាតើអំណាចនីមួយៗត្រូវបានអនុវត្តយ៉ាងដូចម្ដេចនៅក្នុងយុត្តិសាស្ត្ររបស់ខ្លួន។

i. ការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ដែលភាគីបានដាក់

១២៨. អង្គបុរេជំនុំជម្រះមានយុត្តាធិការច្បាស់លាស់ក្នុងការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ដែលអាចទទួលយកបាន ដែលបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ អនុលោមតាមវិធាន ៦៧(៥) វិធាន ៧៣(ក) និង វិធាន ៧៤ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានសម្រេចថា វិសាលភាពនៃការពិនិត្យរបស់ខ្លួនទៅលើបណ្ដឹងឧទ្ធរណ៍ទាំងនេះត្រូវបានកម្រិត ត្រឹមតែបញ្ហានានាដែលលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ប៉ុណ្ណោះ[212] ព្រមទាំង ទៅតាមបទដ្ឋានដែលបានបង្កើតជាអន្តរជាតិ សម្រាប់ការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ចំពោះកំហុសអង្គច្បាប់ កំហុសអង្គហេតុ និងឆន្ទានុសិទ្ធិ ដែលភាគីបានចោទប្រកាន់ចំពោះកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ

[211] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៣៨។

[212] *សូមមើលផងដែរ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ១០៤ *យោងទៅ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ (D99/3/42) កថាខណ្ឌ ២៩។

01667339



អន្តរជាតិ ប្រឆាំងនឹងការសម្រេចរបស់តុលាការថ្នាក់ក្រោម[213]។ អង្គជំនុំជម្រះក៏បានសន្និដ្ឋានផងដែរថា អនុលោមតាមបទដ្ឋានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ស្តីពីការពិនិត្យបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះមានយុត្តាធិការឥតស្បៀរចិត្ត ក្នុងការដោះស្រាយបញ្ហា "សំខាន់ទូទៅ" សម្រាប់យុត្តិសាស្ត្រ និង/ឬ កេរដំណែលរបស់ អ.វ.ត.ក[214]។

ii. ការពិនិត្យលើសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត

១២៩. អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ថា យុត្តាធិការរបស់ខ្លួនខុសពីយុត្តាធិការរបស់ស្ថាប័នពិនិត្យលើបណ្តឹងឧទ្ធរណ៍ផ្សេងទៀត នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ គឺថា នៅពេលអង្គជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះអាចធ្វើការពិនិត្យ*តាមផ្តួចផ្តើមរបស់ខ្លួន* ទៅលើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតផង[215] និងទៅលើកិច្ចស៊ើបសួរទាំងអស់ដែលសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាបានធ្វើ[216] ផង។ អង្គជំនុំជម្រះបានកត់

---

[213] *សូមមើល ឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ ៨៦។

[214] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៧៣។

[215] នៅក្នុងទិដ្ឋភាពនេះ គេត្រូវកត់សម្គាល់ថា ខុសពីស្ថាប័នពិនិត្យលើបណ្តឹងផ្នែកព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដែលការពិនិត្យទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំង សាលក្រមសម្រេចលើពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព ហើយដែលជាធម្មតាទំហំនៃការពិនិត្យរារាំងមិនឱ្យស្ថាប័នទាំងនោះធ្វើសន្និដ្ឋានលើអង្គហេតុ*ជាថ្មី* ទៅលើបណ្តឹងឧទ្ធរណ៍ និងកែប្រែសាលក្រមទៅតាមនោះ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក មានសិទ្ធិអំណាចកែតម្រូវដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធានផ្ទៃក្នុង និងយុត្តាធិការរបស់ អ.វ.ត.ក (*សូមមើល* វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ១០៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/14 ទំព័រ ៤-៥)។ អំណាចនេះជួយឱ្យអង្គបុរេជំនុំជម្រះជំនួសសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតទៅលើអង្គច្បាប់ និងអង្គហេតុ ដោយសេចក្តីសន្និដ្ឋានរបស់ខ្លួនផ្ទាល់ នៅពេលការបង្ហាញការពិតតាមផ្លូវតុលាការទៅលើព្រឹត្តិការណ៍នានាដែលស្ថិតក្រោមការស៊ើបអង្កេតតម្រូវឱ្យធ្វើបែបនេះ។ ដោយហេតុនេះ អំណាចត្រូវបានប្រើប្រាស់នៅដំណាក់កាលមុនការជំនុំជម្រះនោះ អំណាចនេះមិនអាចរារាំងដល់សិទ្ធិរបស់មេធាវីការពារក្តី តាមកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានទេ ហើយក៏មិនអាចបំពានទៅលើតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក បានឡើយ។

[216] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤២ និង ជើងទំព័រ ៧៥ *យោងទៅ* Henri ANGEVIN, Jean-Paul VALAT, "*Chambre de l'"instruction.* é

សម្គាល់ថា អំណាចស្រដៀងគ្នានេះក៏បានផ្តល់ដល់ស្ថាប័នតុលាការកូនកាត់ប្រហាក់ប្រហែលគ្នាដែរ ដូចជា *អង្គជំនុំជម្រះ* *Chambre africaine extraordinaire d'accusation* នៅក្នុងសាលាឧទ្ធរណ៍ Dakar[217] និង អង្គជំនុំជម្រះចោទប្រកាន់ពិសេសរបស់សាធារណរដ្ឋអាហ្វ្រិកកណ្តាល[218]។ នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក អង្គបុរេជំនុំជម្រះអាចធ្វើអន្តរាគមន៍នេះបាន អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង និង វិធាន ២ វិធាន ៦៧(៥) វិធាន ៧៣(ក) វិធាន ៧៤ វិធាន ៧៦(៧) និង វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង និង មាត្រា ៥៥ និង ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្រោយពេលទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ។ បទប្បញ្ញត្តិនៃមាត្រាទាំងពីរនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះកំណត់យុត្តាធិការរបស់ សភាស៊ើបសួរ នៅក្នុងសាលាឧទ្ធរណ៍កម្ពុជា ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុង ដំណាក់កាលមុនការជំនុំជម្រះ ក្នុងច្បាប់កម្ពុជា។ នៅក្នុងចំណុចនេះ ចៅក្រមអន្តរជាតិសូមរម្លឹកថា មាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖

---

*Composition. é Comp"tence. é Contr‹le de l"activit" des officiers et agents de police judiciaire*", Jurisclasseur Proc"dure p"nale, LexisNexis, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ១៣។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៧ និង ជើងទំព័រ ៨៤ *យោងទៅ* Jacques GUYµNOT, "*Le pouvoir de r"vision et le droit d""vocation de la chambre d"accusation*", Revue de sciences criminelles et de Droit p"nal compar", Tome XIX (ឆ្នាំ១៩៦៤) ("GUYµNOT, *Le pouvoir de r"vision et le droit d""vocation de la chambre d"accusation* (1964)") កថាខណ្ឌ ៣។

[217] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៣ និង ជើងទំព័រ ៧៦ *យោងទៅ* លក្ខន្តិកៈនៃអង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិកនៅក្នុងតុលាការសេណេហ្កាល់ ត្រូវបានបង្កើតឡើងដើម្បីចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិដែលបានប្រព្រឹត្តនៅប្រទេសឆាដ ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៨២ ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩០ មាត្រា ១១(២)។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌ [សេណេហ្កាល់] មាត្រា ១៨៥។

[218] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៣ និង ជើងទំព័រ ៧៧ *យោងទៅច្បាប់លេខ ១៥.០០៣ ស្តីពី û Cr"ation, organisation et fonctionnement de la cour p"nale sp"ciale ™* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ JORCA/ES n¢05, មាត្រា ១២(១)។ *ច្បាប់លេខ ១៨.០១០ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពី û R—glement de proc"dure et de preuve devant la cour p"nale sp"ciale de la R"publique centrafricaine ™* JORCA/ES N©5, ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ មាត្រា ១០៧ក ("*La Chambre d"accusation sp"ciale statue en Chambre du conseil sur les appels des ordonnances rendues par les Cabinets d"instruction*")។

01667341



នៅរាល់ពេលដែលទទួលពាក្យបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តិទៅដ៏ល្អ នៃនីតិវិធីនេះ។ កាលណាពិនិត្យឃើញថាមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈ ដោយឯកឯង នូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា ២៨០ (អានុភាពនៃមោឃកម្ម) នៃក្រមនេះ[219]។

ចំពោះផ្នែកដែលពាក់ព័ន្ធ យុត្តាធិការរបស់អង្គបុរេជំនុំជម្រះបានតម្កល់ទស្សនៈដែលថា៖

សភាស៊ើបសួរអាចត្រូវបានកំណត់ថាជាសភាសាលាឧទ្ធរណ៍ [...] ដែលមានបេសកកម្មមិនត្រឹមតែដឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់យុត្តាធិការសាលាដំបូងប៉ុណ្ណោះទេ ដែលថា សហចៅក្រមស៊ើបអង្កេត [...] ប៉ុន្តែ ថែមទាំងពិនិត្យមើលជាប្រចាំចំពោះភាពត្រឹមត្រូវនៃការស៊ើបអង្កេត និងកាន់តួនាទីត្រួតពិនិត្យជាមួយចៅក្រមស៊ើបសួរ ដោយសភាស៊ើបសួរអាចធ្វើឧបាស្រ័យដល់កំហុសទាំងឡាយរបស់ចៅក្រមស៊ើបសួរ។ ក្នុងន័យនេះ គេអាចចាត់ទុកថាសភានេះថាជាតុលាការស៊ើបសួរជាន់ខ្ពស់[220]។

iii. អំណាចបំពេញកិច្ចបន្ថែមទៀត

១៣០. អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា នៅពេលទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង និង វិធាន ២ វិធាន ៧៦(២), (៣) និង (៧) និង វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង និង មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[221] អង្គជំនុំជម្រះក៏អាចបំពេញកិច្ចនានា ដែលចេញពីសិទ្ធិអំណាចរបស់សភាស៊ើបសួរកម្ពុជា រួមទាំងកិច្ចស៊ើបសួរនានាក្នុងការស្វែងរក និងបញ្ជាក់ការពិត[222]។ ហេតុនេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា អំណាចពិនិត្យដូចបាន

---

[219] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤០ និង ជើងទំព័រ ៧៣។

[220] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤២ និង ជើងទំព័រ ៧៥។

[221] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៣៩។

[222] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៧ និង ជើងទំព័រ ៨៦ *យោងទៅ* Fr"d"ric DESPORTES, Laurence LAZERGES, *Trait" de proc"dure p"nale* (Economica, Corpus ការកែសម្រួលលើកទី៣ ឆ្នាំ២០១៣) កថាខណ្ឌ ២១៤៤។

លើកឡើងខាងលើរបស់អង្គជំនុំជម្រះអាចត្រូវបានបំពេញ ដោយកិច្ចបន្ថែមដែលចាំបាច់ ដើម្បីបញ្ចប់កិច្ចស៊ើបសួរ[223] និង/ឬ កិច្ចនានាដែលចាំបាច់ ដើម្បីកែតម្រូវភាពមិនប្រក្រតីនៃនីតិវិធី នៅក្នុងកិច្ចដំណើរការនីតិវិធី និង/ឬ អនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះផ្ទាល់ រួមទាំង ការផ្លាស់ប្តូរដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេត ក្នុងករណីចាំបាច់។ ចៅក្រមអន្តរជាតិរម្លឹកថា ស្រដៀងនឹងតុលាការស៊ើបសួរ នៅតាមប្រព័ន្ធច្បាប់ដផែកសួរដេញដោល នៅតាមប្រទេសផ្សេងទៀតដែរ ដែលផ្តល់អំណាចប្រហាក់ប្រហែលគ្នា នៅពេលបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធី[224]។

ឃ. ការរម្លឹកពីសិទ្ធិអំណាចរបស់អង្គបុរជំនុំជម្រះ៖ ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបង្គាប់ឲ្យបោះត្រា និងបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ

១៣១. ចៅក្រមអន្តរជាតិកត់សម្គាល់ថា ក្រោយពីមានសេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២[225] និងភ្លាមៗបន្ទាប់ពីមានសេចក្តីសម្រេចបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះតុលាការកំពូល[226] សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាបង្គាប់ឲ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ" ("ដីកាបង្គាប់ឲ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅ

---

[223] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៨ ជើងទំព័រ ៨៩ *យោងទៅ* Henri ANGEVIN, Jean-Paul VALAT, "*Chambre de l'"instruction. é Pouvoirs de la chambre de l'"instruction: r"vision, "vocation, annulation. é suppl"ment d'"information. é d'"cisions sur le fond*", Jurisclasseur Proc"dure p"nale, LexisNexis, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ("ANGEVIN និង VALAT, *Chambre de l'"instruction é pouvoirs de la chambre de l'"instruction* (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩)") កថាខណ្ឌ ១៣៩។

[224] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៣។

[225] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០។ https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (ចូលមើល ៧ មេសា 2021)

[226] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2។

ក្នុងបណ្ណសារ"[227] ជាការឆ្លើយតបទៅនឹង "សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ" ពីសហមេធាវីការពារក្តី អោ អាន ("សំណើរបស់សហមេធាវីការពារក្តី អោ អាន"[228]។

១៣២. តាំងពីដំបូងមក ចៅក្រមអន្តរជាតិសូមរម្លឹកថា ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចទទួលយកត្រឹមតែដីកាសន្និដ្ឋានពីសហព្រះរាជអាជ្ញាមកពិនិត្យប៉ុណ្ណោះ[229]។ ជាងនេះទៀត ការិយាល័យសហចៅក្រមស៊ើបអង្កេត *បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ (functus officio)* បន្ទាប់ពីចេញដីកាដំណោះស្រាយ[230] លើកលែងតែតួនាទីផ្នែករដ្ឋបាលដែលមានចែងច្បាស់នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[231] ចៅក្រមអន្តរជាតិសូមអះអាងជាថ្មីថា ក្នុងនាមជាសភាស៊ើបសួរកម្ពុជានៅ អ.វ.ត.ក និងអនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង មាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អង្គបុរេជំនុំជម្រះមានយុត្តាធិការចុង

---

[227] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ដ ("សំណុំរឿង ០០៤/២") ដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ឯកសារ D363/3 ("ដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (D363/3)")។

[228] សំណុំរឿង ០០៤/២ សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ឯកសារ D363។

[229] វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង។

[230] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ១/(D308/3/1/20) កថាខណ្ឌ ៣៣។

[231] ឧទាហរណ៍ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវតែបញ្ជូនសំណុំរឿងទៅអង្គបុរេជំនុំជម្រះ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សូមមើល វិធាន ៦៩(១) នៃវិធានផ្ទៃក្នុង។ លើសពីនេះទៀត ទោះបីចៅក្រមអន្តរជាតិទទួលស្គាល់ថាសំណុំរឿង ០០៤/២ ត្រូវបានបញ្ចប់អានុភាពជាលក្ខណៈតែមួយក្តី តែចៅក្រមអន្តរជាតិពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមានការភាន់ច្រឡំដោយចេញដីការបស់ខ្លួនបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារដោយផ្អែកលើវិធាន ៦៩(២)(ខ) *ដូចគ្នា*[231] ដោយពិចារណាលើអង្គហេតុដែលថា មានបណ្តឹងឧទ្ធរណ៍ជាច្រើនបានធ្វើឡើងប្រឆាំងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/២ សូមមើល សំណុំរឿង ០០៤/២ ដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (ឯកសារ D363/3) កថាខណ្ឌ ៩។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា វិធាននេះមិនអាចបង្កើតជាមូលដ្ឋានផ្លូវច្បាប់ត្រឹមត្រូវសម្រាប់ចាត់វិធានការនេះទេ ទោះបីដូចគ្នាក៏ដោយ។

ក្រោយលើការស៊ើបអង្កេត[232] រួមទាំងរាល់សំណើទាំងអស់ ពាក់ព័ន្ធនឹងដំណាក់កាលមុនជំនុំជម្រះ បន្ទាប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតលែងមានសិទ្ធិទទួលសំណុំរឿង[233]។

១៣៣. ចៅក្រមអន្តរជាតិសូមរំលឹកថា តាមខ្លឹមសារនៃមាត្រា ១២(២)នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង "ការិយាល័យតុលាការចុងក្រោយដែលទទួលបានសំណុំរឿងត្រូវធ្វើការពិនិត្យឡើងវិញចំពោះឯកសារស្តីអំពីសុវត្ថភាពនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញនៅក្នុងសំណុំរឿង"។ ចៅក្រមអន្តរជាតិយល់ឃើញថា ការិយាល័យតុលាការចុងក្រោយដែលទទួលបានសំណុំរឿង ០០៤/២ គឺអង្គបុរេជំនុំជម្រះ ឬអង្គជំនុំជម្រះតុលាការកំពូល។ ការិយាល័យសហចៅក្រមស៊ើបអង្កេតលែងទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យទៀតហើយ បន្ទាប់ពីចេញដីកាដំណោះស្រាយរបស់ខ្លួនក្នុងសំណុំរឿងនោះ។ ហេតុនេះ ពុំមានសិទ្ធិអំណាចក្នុងការចេញសេចក្តីសម្រេច ឬដីកានានាពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២ ទៀតទេ រួមទាំងដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ។

១៣៤. ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ទោះបីការិយាល័យនេះលែងមានយុត្តាធិការលើសំណុំរឿងនេះទៀតហើយក៏ដោយ។

## ២. ការពន្យារពេលហួសហេតុក្នុងការចេញដីកាដំណោះស្រាយ

១៣៥. ចៅក្រមអន្តរជាតិសូមរម្លឹកថា វិធាន ២១(៤) នៃវិធានផ្ទៃក្នុងចែងថា កិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់ "ក្នុងរយៈពេលមួយសមស្រប"។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលជាតុលាការត្រួតពិនិត្យ

---

[232] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើការគ្រប់គ្រងគំណត់ហេតុនៃករណីខ្វែងយោបល់ និងឯកសារផ្សេងទៀតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបច្ចុប្បន្នស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពបណ្ណសារ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D360/32 ទំព័រ ៤-៥ *យោងទៅ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ (D99/3/42) កថាខណ្ឌ ៤១។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤០។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ២២។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៧។

[233] សូមមើល ឧទាហរណ៍ សំណុំរឿង ០០៤/២ (អបជ៥៩) សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 កថាខណ្ឌ ៥,១៣។ សូមមើល ផងដែរ ខាងលើ កថាខណ្ឌ ១២៧-១៣០។

01667345



នៅដំណាក់កាលស៊ើបអង្កេត[234] យល់ឃើញថា ទោះបីជាវិធានផ្ទៃក្នុងពុំបានចែងឲ្យបានច្បាស់លាស់អំពីពេលវេលាកំណត់ សម្រាប់ការចេញដីកាដំណោះស្រាយក្តី ក៏សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចចេញដីកាដំណោះស្រាយក្នុងរយៈពេលមួយសមស្រប ដោយសារតែគោលការណ៍នេះ រួមទាំងផ្នែកពាក់ព័ន្ធរបស់វានៅក្នុងមាត្រា ៣៥*ថ្មី* នៃច្បាប់ អ.វ.ត.ក គឺជាគោលការណ៍មូលដ្ឋានដែលមានចែងក្នុងមាត្រា ១៤(៣)(គ) នៃ ICCPR[235]។

១៣៦. ចៅក្រមអន្តរជាតិសូមបញ្ជាក់ឡើងវិញអំពីសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះលើអង្គច្បាប់ពាក់ព័ន្ធនឹងការពន្យារពេលក្នុងការចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ និង ០០៤/២[236] និងពិនិត្យមើលលើការពន្យារពេលយូរហួសហេតុនូវការបញ្ចប់កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ ការពន្យារពេលហួសហេតុ ក្នុងការចេញដីកាដំណោះស្រាយរបស់ខ្លួន ព្រមទាំងការពន្យារពេលបន្ថែមទៀតក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៣ ដែលបង្កឡើងដោយការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា មានសរសេរតែមួយភាសា ក្នុងចំណោមភាសាផ្លូវការរបស់ អ.វ.ត.ក។

ក. ការពន្យារពេលបញ្ចប់ការស៊ើបអង្កេត

១៣៧. ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងករណីនេះ មានការចេញសេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុងចំនួនបីលើក នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដោយសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ[237] នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧[238] និងនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧[239] ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង ដោយមានការបកស្រាយតាមអំពើចិត្តនូវវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ទាក់ទិននឹងរយៈពេល ១៥ ថ្ងៃ សម្រាប់ភាគីដាក់ពាក្យសុំ

---

[234] សំណុំរឿង ០០៤/២ (អបជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 កថាខណ្ឌ ៦១។

[235] ICCPR មាត្រា ១៤(៣)(គ)។

[236] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ២៨-៣១។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៦០-៧២។

[237] *សូមមើល* សេចក្តីជូនដំណឹង ឆ្នាំ២០១១ តាមវិធាន ៦៦(១) (D13)។

[238] *សូមមើល* សេចក្តីជូនដំណឹងលើកទីមួយ តាមវិធាន ៦៦(១) (D225)។

[239] *សូមមើល* សេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) (D252)។

01667346



បំពេញកិច្ចស៊ើបសួរ ក្រោយពេលជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ចៅក្រមអន្តរជាតិសង្កេតឃើញបន្ថែមថា សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញានៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧[240] រយៈពេលពីរខែ ក្រោយពេលចេញសេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) ដែលបានសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរចុងក្រោយនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧[241] និងមិនបាន "ភ្លាមៗ" អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុងទេ។

១៣៨. ចៅក្រមអន្តរជាតិសូមរម្លឹកថា កិច្ចស៊ើបសួរមិនមែនជាការអនុវត្តឆន្ទានុសិទ្ធិទេ[242]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតត្រូវដំណើរការអនុលោមតាមច្បាប់ជាធរមាន ហើយអនុវត្តអំណាចរបស់ខ្លួនដែលច្បាប់បានផ្តល់ឱ្យដោយប្រុងប្រយ័ត្ន។[243] មាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងច្បាស់ថា សហចៅក្រមស៊ើបអង្កេត "ត្រូវអនុវត្តតាមនីតិវិធីដែលនៅជាធរមាន"[244]។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបំពេញកិច្ចស៊ើបសួររបស់ខ្លួននៅក្នុងក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក ដែលអង្គបុរេជំនុំជម្រះមានតួនាទីជាតុលាការត្រួតពិនិត្យឡើងវិញ និងរួមចំណែកផ្តល់យុត្តិសាស្ត្ររបស់ខ្លួនឱ្យបានសមស្រប។

១៣៩. ចៅក្រមអន្តរជាតិសូមរម្លឹកបន្ថែមថា នីតិវិធីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវស្របទៅនឹងច្បាប់កម្ពុជា អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[245] និងសូមបញ្ជាក់ជាថ្មីថា ច្បាប់ជាធរមាននៅ អ.វ.ត.ក និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រូវបកស្រាយយ៉ាងចង្អៀតបំផុត ដូចបានណែនាំដោយមាត្រា ១ នៃក្រម ដែលចែងថា "ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពី *វិធានទាំង*

---

[240] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ (D256)។

[241] សេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) (D252)។

[242] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៦៨។

[243] សំណុំរឿង ០០៤/២ ការពិចារណាលើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (D359 / 24 & D360 / 33) កថាខណ្ឌ ៤៩; សំណុំរឿង ០០៤/១ ការពិចារណាលើបណ្តឹងឧទ្ធរណ៍ក្នុងដីកាដំណោះស្រាយ (D308 / 3/1/20) កថាខណ្ឌ ២០ ។

[244] ក្នុងចំណុចនេះ សហចៅក្រមស៊ើបអង្កេតក៏ត្រូវបានរំពឹងថា អនុវត្តតាមការបកស្រាយច្បាប់គ្របគ្រងការស៊ើបអង្កេត ដោយអង្គបុរេជំនុំជម្រះផងដែរ (*សូមមើលឧទាហរណ៍* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) ជើងទំព័រ ១៦៣)។

[245] *សូមមើលឧទាហរណ៍* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៣៨។

*ឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់* ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ”[246]។

១៤០. នៅក្នុងករណីនេះ ជាបឋម អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើតាមអំពើចិត្ត ស្របទៅនឹងវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ដោយគាត់មិនបានផ្តល់រយៈពេល ១៥ ថ្ងៃដល់ភាគីតាមវិធានដែលបានលើកឡើងខាងលើ ដោយជូនដំណឹងដល់ពួកគេនូវសេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) របស់គាត់ ដែលមិនបានផ្តល់ឱកាសបន្ថែមទៀតដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរក្រោយពេលចេញសេចក្តីជូនដំណឹង[247] ចំណែកឯសេចក្តីជូនដំណឹងលើកទីមួយ តាមវិធាន ៦៦(១) របស់គាត់ គាត់បានពន្យារពេលវេលាពី ១៥ ថ្ងៃដល់ទៅ ៣០ ថ្ងៃ[248]។

១៤១. ទាក់ទិននឹងចំណុចនេះ ចៅក្រមអន្តរជាតិសូមបញ្ជាក់ជាថ្មីអំពីសិទ្ធិរបស់ភាគីក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសំណុំរឿងរបស់ខ្លួន ដោយរម្លឹកថា អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ដែលភាគីមានថិរវេលា ១៥ (ដប់ប្រាំ) ថ្ងៃក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមត្រូវអនុវត្តក្រោយពេលមានការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ “មិនថា សេចក្តីជូនដំណឹងនោះជាសេចក្តីជូនដំណឹង “លើកទីមួយ” ឬ “លើកទីពីរ” ដែលបានចេញក្រោយពេលបញ្ចប់កិច្ចស៊ើបសួរបន្ថែមនោះទេ[249]។ ជាងនេះទៀត បទប្បញ្ញត្តិនេះចែងច្បាស់ថា “*ភាគីទាំងអស់មាន* រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម។ *ភាគីទាំងអស់* អាចលះបង់ថិរវេលានេះបាន”[250]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិពិចារណាឃើញថា ផ្ទុយពីការប្រកាសបែបលាក់លៀមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងជើងទំព័រមួយនៃដីកាដំណោះស្រាយរបស់ខ្លួន[251] សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានសិទ្ធិអំណាចក្នុងការសម្រេច ឬផ្តល់

[246] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ មាត្រា ១ (គូសបញ្ជាក់បន្ថែម)។

[247] សេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) (D252) កថាខណ្ឌ ១៧, ១៩។

[248] សេចក្តីជូនដំណឹងលើកទីមួយ តាមវិធាន ៦៦(១) (D225) កថាខណ្ឌ ៤, ៧។

[249] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៦៣។ សេចក្តីសម្រេចលើសំណើសុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ក្នុងសំណុំរឿង ០០៤ (D361/4/1/10) កថាខណ្ឌ ២៣-២៧។

[250] វិធានផ្ទៃក្នុង ៦៦(១) នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។

[251] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) ជើងទំព័រ ២២ (“យើងចាត់ទុកថា ពុំមានការចាំបាច់ក្នុងការផ្តល់ដល់ភាគីក្នុងសំណុំរឿង ០០៣ នូវពេលវេលា១៥ថ្ងៃបន្ថែម ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធទៅនឹងការលើកឡើងរបស់អង្គបុរេជំនុំជម្រះឡើយ ដោយសារយើងយល់ឃើញថា មិនទំនងថាមានភាគីណាមួយបានរងនូវការខូចខាត ដោយសារតែយើងមិន

01667348



ការពិចារណារបស់ខ្លួន ថា តើថិរវេលានេះចាំបាច់ត្រូវផ្តល់ឱ្យ ឬមិនផ្តល់ឱ្យនោះទេ ហើយជាលទ្ធផល និង កាន់តែសំខាន់ទៅទៀតនោះ ថិរវេលានេះមិនមែនសម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិជា "អ្នកផ្តល់ឱ្យ" នោះទេ។

១៤២. ហេតុនេះ ដោយពិចារណាដល់កាតព្វកិច្ចមូលដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការធានាឱ្យមានតុល្យភាពរវាងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់ភាគីអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអនុវត្តស្របទៅតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក[252] ដោយមិនផ្តល់រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដល់ភាគី ដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីចេញសេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) ។

១៤៣. ចំពោះការណ៍ដែលសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងឱ្យពិនិត្យវិញ ចៅក្រមអន្តរជាតិសូមរម្លឹកថា វិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ឆ្លុះបញ្ចាំងនូវមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលណែនាំថា ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញា "២ (ពីរថ្ងៃ)" ក្រោយពីការជូនដំណឹងថាការស៊ើបសួរត្រូវបានបញ្ចប់។ ចៅក្រមអន្តរជាតិសូមបញ្ជាក់ជាថ្មីថា ការបង្កើតសំណុំរឿង និងការយកចិត្តទុកដាក់នៅក្នុងការផ្តល់ព័ត៌មានអំពីនីតិវិធី *ដែលជា* ការរៀបចំសំណុំរឿងឱ្យទាន់ពេលវេលារបស់សហចៅក្រមស៊ើបអង្កេតជាមួយនឹងនីតិវិធីដែលត្រូវគិតគូឱ្យបានសមស្រប គឺជាលក្ខខណ្ឌតម្រូវផ្លូវច្បាប់នៅក្នុង

---

បានផ្តល់នូវថិរវេលា១៥ថ្ងៃនោះឡើយ ហើយជាការពិតមិនបានរងនូវការខូចខាតក្នុងកម្រិតមួយដែលបង្កើតបានជាករណីពិសេសដែលតម្រូវឱ្យមានការពិចារណាឡើងវិញនៃសេចក្តីសម្រេចរបស់យើង")។

[252] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៦៥។ សេចក្តីសម្រេចលើសំណើសុំពេលរៀបចំឱ្យបានគ្រប់គ្រាន់ក្នុងសំណុំរឿង ០០៤ (D361/4/1/10) កថាខណ្ឌ ២៧។ *សូមមើលផងដែរ* សេចក្តីពិចារណាលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍លើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ (D362/6)") យោបល់របស់ចៅក្រម BAIK និង ចៅក្រម BEAUVALLET កថាខណ្ឌ ១១០។

ប្រព័ន្ធស៊ើបសួរដោយតុលាការ ដែលមានធម្មតាចំពោះយុត្តាធិការកូនកាត់ប្រភេទនេះ ហើយមានលក្ខណៈ វិសាមញ្ញបំផុត និងមានតែមួយគត់សម្រាប់ អ.វ.ត.ក បើប្រៀបធៀបនឹងតុលាការអន្តរជាតិដទៃទៀត[253]។

១៤៤. ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿង ទៅឱ្យសហព្រះរាជអាជ្ញាពិនិត្យរយៈពេលពីរខែក្រោយពេលចេញសេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) នៅក្នុងករណីនេះ គឺជាការពន្យារពេលហួសហេតុ។

ខ. ការពន្យារពេលយូរហួសហេតុក្នុងការចេញដីកាដំណោះស្រាយ

១៤៥. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដែលបញ្ចប់កិច្ចស៊ើបសួរ ក្នុងរយៈពេលជាង ១៨ ខែ ក្រោយពេលចេញសេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) របស់ខ្លួន ដែលបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧[254]។ សហចៅក្រម ស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដដែលនោះ ទោះបីពិចារណាថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ក្តី។ ចៅក្រមអន្តរជាតិនឹង ពិនិត្យទៅលើនីត្យានុកូលភាពនៃការបកស្រាយនេះ នៅផ្នែកមួយទៀត[255]។

១៤៦. ចៅក្រមអន្តរជាតិសូមរម្លឹកដល់ការយល់ឃើញរបស់អង្គបុរេជំនុំជម្រះពីមុននៅក្នុងសំណុំរឿង ០០៤/១ និង ០០៤/២ ដែលថា ថិរវេលា ១៦ ខែ និង ១៨ ខែ ក្នុងការចេញដីកាដំណោះស្រាយ ក្រោយពេល បញ្ចប់កិច្ចស៊ើបសួរ មានភាពហួសហេតុ បើប្រៀបធៀបជាពិសេសជាមួយនឹងដីកាដំណោះស្រាយដែលបាន ចេញនៅក្នុងសំណុំរឿង ០០១ និង ០០២ ដែលមានថិរវេលាត្រឹម បី ខែ និងប្រាំបីខែប៉ុណ្ណោះ[256]។

១៤៧. ដោយបានពិចារណាយ៉ាងត្រឹមត្រូវទៅលើភាពស្មុគស្មាញនៃសំណុំរឿង ០០៣ និងទំហំនៃកំណត់ ហេតុរបស់សំណុំរឿងនេះ បើប្រៀបធៀបទៅនឹងសំណុំរឿង ០០១, ០០២, ០០៤/១ និង ០០៤/២ នោះ

---

[253] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៦៩។

[254] សេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) (D252)។

[255] *សូមមើល ខាងក្រោម* កថាខណ្ឌ ២២៦-២៥០ ។

[256] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៣០។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៧១។

ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានចេញដីកាដំណោះស្រាយនៅក្នុងអំឡុងពេលសមស្របឡើយ នៅក្នុងករណីនេះ។ ជាងនេះទៀត ចៅក្រមអន្តរជាតិពិចារណាឃើញថា ការលំបាកនានាដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[257] មិនបានផ្តល់យុត្តិកម្មដល់ការពន្យារពេលនេះឡើយ ដោយហេតុថា *ក្នុងចំណោមនោះ* បញ្ហានានាពាក់ព័ន្ធនឹងបុគ្គលិក និងការបកប្រែភាសា[258] អាចប្រមើលមើលជាមុនបាន តាមបទពិសោធន៍មុនៗរបស់ខ្លួននៅក្នុងសំណុំរឿងផ្សេងៗទៀតនៅ អ.វ.ត.ក ដូច្នេះហើយគេអាចបន្ថយការពន្យារពេលបែបនេះបាន។

គ. ការពន្យារពេលផ្សេងៗទៀតដែលអាចចៀសវាងបាន

១៤៨. ចៅក្រមអន្តរជាតិយល់ឃើញថា ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នារបស់សហចៅក្រមស៊ើបអង្កេត ដែលដីកានីមួយៗមានជាង ២០០ទំព័រ មានសរសេរតែមួយភាសា ក្នុងចំណោមភាសាផ្លូវការរបស់ អ.វ.ត.ក[259] មិនត្រឹមតែជាការរំលោភទៅលើមាត្រា ៧ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[260] ប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះ ជាការជំរុញឲ្យមានការពន្យារពេលហួសហេតុបន្ថែមទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៣ ទាំងមូលតែម្តង ដែលចៅក្រមអន្តរ

---

[257] *សូមមើល* សំណុំរឿង ០០៣ កាលប្បវត្តិនៃផែនការបញ្ចប់គម្រោង ឧបសម្ព័ន្ធ I នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267.1 ("ឧបសម្ព័ន្ធ I នៃនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267.1)")។ សំណុំរឿង ០០៣ ញត្តិ និងសំណើនានាដែលបានដាក់ជូន [សហចៅក្រមស៊ើបអង្កេត] ឧបសម្ព័ន្ធ II នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267.2។

[258] *សូមមើលឧទាហរណ៍* ឧបសម្ព័ន្ធ I នៃនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267.1) ERN (ភាសាអង់គ្លេស) 01596616 កថាខណ្ឌ ២៥-២៦។

[259] សូមមើលខាងលើ កថាខណ្ឌ ២៣ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ជាភាសាខ្មែរតែមួយប៉ុណ្ណោះ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះតែជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ។

[260] *សេចក្តីណែនាំស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក* អ.វ.ត.ក/០១/២០០៧/វិ.លើកទី ៨ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ មាត្រា ៧.១។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយត្រូវដាក់អំណះអំណាងឲ្យបានពេញលេញ អនុលោមទៅតាម មាត្រា ៧.១ ដែលចែងថា "គ្រប់ឯកសារទាំងអស់ ត្រូវដាក់ជាភាសាខ្មែររួមជាមួយភាសាអង់គ្លេស និង/ឬ ភាសាបារាំង" រាល់សារណាលើបណ្តឹងឧទ្ធរណ៍/សាទុក្ខ ចម្លើយតបទៅនឹងសារណាទាំងនោះ និងការឆ្លើយតបទៅនឹងចម្លើយតបទាំងនោះត្រូវដាក់ជាភាសាខ្មែរ និង ភាសាអង់គ្លេស ឬភាសាបារាំង។

ជាតិយល់ឃើញថា គេអាចបញ្ចៀសបាន ដោយប្រកាន់ខ្ជាប់ឲ្យបានតឹងរ៉ឹងទៅតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក[261]។

ឃ. សេចក្តីសន្និដ្ឋាន

១៤៩. ដោយអនុលោមទៅតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា ដំណើរការបើកកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតមានការពន្យារពេលហួសហេតុ និងអាចចៀសវាងបាន ដែលប្រាសចាកពីក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក។

៣. សេចក្តីពិចារណាលើភស្តុតាង

១៥០. នៅក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានបន្តអនុវត្ត "សេចក្តីពិចារណាលើភស្តុតាង" ចំពោះដីកាដំណោះស្រាយរបស់ពួកគាត់រៀងៗខ្លួន[262] ដោយបង្ហាញវិធីសាស្ត្រស្រដៀងៗគ្នាលើការវាយតម្លៃលើភស្តុតាង[263]។ អង្គបុរេជំនុំជម្រះធ្លាប់បានជំទាស់ការអនុវត្តបែបនេះនៅក្នុងសំណុំរឿង ០០៤/១[264] និង ០០៤/២[265] ដោយយល់ថា វាមិនចាំបាច់ និងមិនត្រឹមត្រូវតាមផ្លូវច្បាប់ ដោយសារវិធីសាស្ត្រនេះមិនត្រឹមតែផ្ទុយនឹងក្របខណ្ឌគតិយុត្តិជាធរមាន និងយុត្តិសាស្ត្រដែលតុលាការបានបង្កើតឡើងប៉ុណ្ណោះទេ វាថែមទាំងបំពានកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវពិចារណាលើភស្តុតាងទាំងអស់នៅពេលចេញដីកាដំណោះស្រាយស្របតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុងផងដែរ។ នៅក្នុងផ្នែកនេះ ចៅក្រមអន្តរជាតិធ្វើការពិនិត្យថាតើ សហចៅក្រមស៊ើបអង្កេតបានបង្ហាញត្រឹមត្រូវដែរឬទេចំពោះអង្គច្បាប់អនុវត្តចំពោះ (i)

---

[261] ចៅក្រមអន្តរជាតិសូមរម្លឹកថា ការពន្យារពេលទាំងនេះជាលម្អិត នៅក្នុងផ្នែកប្រវត្តិនីតិវិធីនៃសេចក្តីពិចារណានេះ (*សូមមើលខាងលើ* កថាខណ្ឌ ១-៣៦ )។

[262] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១១៨-១៤៨។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៤-៣៥៩។

[263] *សូមមើល* ខាងក្រោម កថាខណ្ឌ ២២៦-២៥០ (សម្រាប់ការពិចារណារបស់អង្គបុរេជំនុំជម្រះទៅលើមូលដ្ឋាននៃភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតជាតិ បានសំអាងដើម្បីចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់)។

[264] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤២។

[265] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៣។

ការវាយតម្លៃភស្តុតាង (ii) បទដ្ឋាននៃការបង្ហាញភស្តុតាង និង (iii) ការប៉ាន់ស្មាន ចំនួនជនរងគ្រោះនៅក្នុងដំណាក់កាលចេញដីកាដំណោះស្រាយនៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក។

## ក. ការវាយតម្លៃលើភស្តុតាង

### i. គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង

១៥១. ចៅក្រមអន្តរជាតិសូមរំលឹកថា អ.វ.ត.ក គឺជាតុលាការចម្រុះ ដែលត្រូវអនុវត្តតាមវិធានផ្ទៃក្នុងរបស់ខ្លួន ច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ[266]។ គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង និងគោលការណ៍ស្រដៀងគ្នា ពោលគឺ គោលការណ៍នៃជំនឿស្មោះត្រង់ពិតប្រាកដរបស់ចៅក្រម មានចែងនៅក្នុងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង ៨៧(១) ចែងថា "លើកលែងមានបទប្បញ្ញត្តិផ្សេងក្នុង [វិធានផ្ទៃក្នុង] នេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។

១៥២. ដូច្នេះ ចៅក្រមអន្តរជាតិសូមបញ្ជាក់សាជាថ្មីថា ការប្រមូលភស្តុតាងនៅក្នុងដំណាក់កាលស៊ើបអង្កេត នៅ អ.វ.ត.ក ត្រូវអនុវត្តតាមគោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង[267] ដែលជាលក្ខណៈពិសេសនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ[268]។ អាស្រ័យហេតុនេះ គ្រប់ភស្តុតាងទាំងអស់គឺអាចទទួលយកបាន និង ជាទូទៅ

---

[266] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៦។ *សូមមើល ផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២។ វិធាន ២ នៃវិធានផ្ទៃក្នុង។

[267] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤៤។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៦។ *សូមមើល ផងដែរ* សំណុំរឿង ០០៤ (អបជ៥១) សេចក្តីសម្រេចលើពាក្យសុំធ្វើមោឃភាពលើសំណើសុំ និង ការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សម្ភារៈស៊ើបអង្កេតពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ឯកសារ D370/1/1/6 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី (D370/1/1/6)") កថាខណ្ឌ ១៧។

[268] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ៤៤។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៦។ *សូមមើល ផងដែរ* L.G.D.J (ed.), *Droit du Cambodge* (Biblioth—que de l"Association Henri Capitant, បោះពុម្ពផ្សាយលើកទី ១ ឆ្នាំ២០១៦) ទំព័រ ៤៤-៤៥។ Jean PRADEL, *Proc"dure p"nale* (Cujas, បោះពុម្ពផ្សាយលើកទី ១៤៣ ឆ្នាំ២០០៦-២០០៧) ទំព័រ ៣៦៤។ Bernard BOULOC, *Proc"dure p"nale* (Dalloz, បោះពុម្ពផ្សាយ

01667353



មានតម្លៃជាភស្តុតាងស្មើគ្នានៅក្នុងដំណាក់កាលមុនអង្គសេចក្តី នៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក លើកលែងតែមានកិច្ចដំណើរការនីតិវិធីមោឃភាព ឬ មានបទប្បញ្ញត្តិជាក់លាក់ចែងផ្ទុយពីនេះ[269]។

១៥៣. ចៅក្រមអន្តរជាតិសូមរំលឹកបន្ថែមទៀតថា មាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក ដែលបានបង្គាប់ថា "សហចៅក្រមស៊ើបអង្កេតអាចផ្អែកលើមូលដ្ឋាននៃព័ត៌មាន ដែលទទួលបានពីស្ថាប័ននានា"[270] ដោយមិនរាប់បញ្ចូលការកំណត់ប្រភេទនៃភស្តុតាងនានា ដែលមានលក្ខណៈអត្តនោម័ត ដោយផ្អែកលើប្រភពរបស់វាទេ ហើយគួសបញ្ជាក់ថា ភស្តុតាងទាំងអស់ទទួលបានការសន្មតតាមផ្លូវច្បាប់ថាមានតម្លៃជាភស្តុតាងដូចគ្នា ដរាបណាភស្តុតាងទាំងនេះត្រូវបានប្រមូលតាមផ្លូវច្បាប់ លើកលែងតែមានចែងជាក់លាក់ផ្សេងពីនេះនៅក្នុងច្បាប់[271]"។ តុលាការចម្រុះដទៃទៀត ក៏បានអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌនៃប្រព័ន្ធច្បាប់ស៊ីវិលឡូ ហើយក៏អនុវត្តតាមវិធីសាស្ត្រពិចារណាលើភស្តុតាង ដែលមានលក្ខណៈស្រដៀងគ្នា[272]។

---

លើកទី ២៤ ឆ្នាំ២០១៤) ទំព័រ ១២១។ *សូមមើល ផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣២១។ ក្រមនីតិវិធីព្រហ្មទណ្ឌ ("CCP") [ប្រទេសបារាំង] មាត្រា ៤២៧។ ក្រមនីតិវិធីព្រហ្មទណ្ឌ [ប្រទេសសេណេហ្គាល់] មាត្រា ៤១៤។ ក្រមនីតិវិធីព្រហ្មទណ្ឌ [ប្រទេសអាយវ៉ូរីខូស] មាត្រា ៤១៨។ ក្រមនីតិវិធីព្រហ្មទណ្ឌ [ប្រទេសហ្គីនេ] មាត្រា ៤២០។ ក្រមនីតិវិធីព្រហ្មទណ្ឌ [ប្រទេសម៉ាលី] មាត្រា ៤១២។

[269] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៦ *យោងទៅ* សេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី (D370/1/1/6)") កថាខណ្ឌ ១៧។

[270] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៧។

[271] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៧។

[272] *សូមមើល ឧទា.* តុលាការ EAC *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Habr" និងជនជាប់ចោទផ្សេងទៀត* Ordonnance de non-lieu partiel, de mise en accusation et de renvoi devant la Chambre Africaine Extraordinaire d"Assises, Chambre d"instruction, ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D2819 ("*Habr*" Ordonnance de non-lieu partiel (EAC)") ទំព័រ ៦ (អង្គបុរេជំនុំជម្រះបានបញ្ជាក់អះអាងថា សេរីភាពនៃភស្តុតាង ដូចមានចែងក្នុងមាត្រា ៤១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសសេណេហ្គាល់ អាចអនុវត្តបាននៅដំណាក់កាលមុនការជំនុំជម្រះ)។ ច្បាប់លេខ ១៨-០១០ ដែលបង្កើតវិធានស្តីពីភស្តុតាង និងនីតិវិធី សម្រាប់តុលាការព្រហ្មទណ្ឌពិសេសនៃសាធារណរដ្ឋអាហ្វ្រិកកណ្តា មាត្រា ១៦១ ("តុលាការអនុវត្តវិធានទូទៅស្តីពីភស្តុតាង ដែលមានចែងក្នុងវិធានផ្ទៃក្នុង និងជាពិសេស គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង") (បកប្រែក្រៅផ្លូវការ)។

01667354



១៥៤. នៅក្នុងរឿងក្ដីនេះ ចៅក្រមអន្តរជាតិសង្កេតឃើញថា ទោះបីជាអង្គបុរេជំនុំជម្រះបានបញ្ជាក់បំភ្លឺច្បាស់ពាក់ព័ន្ធជាធរមាននៅក្នុងសំណុំរឿង ០០៤/១ នៅមុនពេលចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតទាំងពីរបានច្រានចោលគោលការណ៍ស្តីពីសេរីភាពនៃភស្តុតាងនៅក្នុងសេចក្តីពិចារណាលើភស្តុតាងរបស់ខ្លួន ហើយបែរជាអនុវត្តគោលការណ៍កំណត់ប្រភេទនៃភស្តុតាងតាមឋានានុក្រម ដែលពុំត្រឹមត្រូវតាមទម្រង់ច្បាប់ និងដែលបានធ្វើឡើងតាមអំពើចិត្តទៅវិញ ជាពិសេសដោយពុំមានបទប្បញ្ញត្តិគតិយុត្តិគាំទ្រណាមួយឡើយ នៅក្នុងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក[273]។ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានលើកឡើងថា ភស្តុតាងប្រមូលបាន និងបង្កើតឡើងដោយការិយាល័យរបស់ខ្លួន ដូចជា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ដែលទទួលបានពីសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក ហើយដែលត្រូវបាន "រៀបចំនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយគោរពតាមការធានាផ្លូវច្បាប់ និងផ្នែកនីតិវិធីជាក់លាក់" គួរតែស្ថិតនៅក្នុងឋានានុក្រមខ្ពស់បំផុត និងទទួលបានសច្ចធារណ៍នៃភាពអាចទុកចិត្តបានខ្ពស់ និងតម្លៃជាភស្តុតាង[274]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានចាត់ប្រភេទភស្តុតាងដែលប្រមូលបានដោយពុំមានការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយអង្គភាពផ្សេងៗទៀត ដូចជាការស្តាប់ចម្លើយ ដែលសហព្រះរាជអាជ្ញាបានធ្វើឡើងនៅក្នុងអំឡុងពេលស៊ើបសួរបឋម ឯកសារ ឬរបាយការណ៍មួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទអំពីជនរងគ្រោះ ថាជាភស្តុតាងដែលពុំទទួលបានសច្ចធារណ៍បែបនេះឡើយ ដូច្នេះសហចៅក្រមស៊ើបអង្កេតបានផ្តល់តម្លៃជាភស្តុតាងតិចជាង ឬពុំបានផ្តល់តម្លៃជាភស្តុតាងតែម្តង ហើយពួកគាត់បានយកមកសំអាងតែក្នុងករណីណាដែលវាស៊ីសង្វាក់គ្នាជាមួយប្រភពផ្សេងទៀតប៉ុណ្ណោះ[275]។ ជាលទ្ធផល ភស្តុតាងភាគច្រើនដែលសហចៅក្រមស៊ើបអង្កេតបានយកមក

---

273 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៣-៧៤។

274 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១១៨, ១២២។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៤។

275 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១១៩-១២១។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៥-៣៥៦។

01667355



សំអាងនៅក្នុងដីកាដំណោះស្រាយ មានកំណត់ហេតុស្តាប់ចម្លើយដែលការិយាល័យរបស់ពួកគាត់ប្រមូលបាន[276]។

១៥៥. ចៅក្រមអន្តរជាតិសូមរំលឹកថា "សំណុំរឿងទាំងមូលត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត គឺមិនមែនតែភស្តុតាងដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើងនោះឡើយ"[277] ហើយសូមបញ្ជាក់ម្តងទៀតថា វាជាកំហុសអង្គច្បាប់ចំពោះការធ្វើសេចក្តីអះអាងទូទៅ និងបុរេវិនិច្ឆ័យនៅដំណាក់កាលមុនអង្គសេចក្តី ពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងនៃប្រភេទភស្តុតាងមួយចំនួន ដោយសារវាបង្កើតឲ្យមានឋានានុក្រមនៃភស្តុតាង ដោយផ្អែកលើប្រភពផ្លូវការ ជាជាងខ្លឹមសារ ឬ អង្គសេចក្តីនៃភស្តុតាង[278]។ ចៅក្រមអន្តរជាតិសូមបញ្ជាក់ថា យោងតាមវិធាន ៦៧ "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់ចំពោះការវាយតម្លៃលើភស្តុតាង" នៅដំណាក់កាលមុនអង្គសេចក្តី គឺ "ផលប៉ះពាល់នៃតម្លៃខ្លឹមសារភស្តុតាង ចំពោះជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេត ដោយត្រូវពិចារណាថាតើវាមានភស្តុតាងគ្រប់គ្រាន់ចំពោះបទចោទដែរឬទេ"[279]។ ម្យ៉ាងវិញទៀត នៅដំណាក់កាលនីតិវិធីចេញដីកាដំណោះស្រាយ ភារកិច្ចតែមួយគត់របស់សហចៅក្រមស៊ើបអង្កេតក្រោមវិធាន ៦៧ គឺត្រូវចេញដីកាដំណោះស្រាយ ពោលគឺ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ ដោយផ្អែកលើការវាយតម្លៃខ្លឹមសារភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង[280]។ ទាក់ទិននឹងកាតព្វកិច្ចរបស់ពួកគាត់ក្នុងការយកភស្តុ

[276] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១១៨។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៤។

[277] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥0 និងលេខជើងទំព័រយោងលេខ ១០៣ *យោងទៅ* វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៧។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨០។

[278] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨០។

[279] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33 ) កថាខណ្ឌ ៨០។

[280] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៣។

01667356



តាងទាំងអស់នៅក្នុងសំណុំរឿង មកពិចារណា[281] សហចៅក្រមស៊ើបអង្កេត ពុំអាចច្រានចោល ឬ បន្ថយតម្លៃប្រភេទភស្តុតាងទាំងអស់ឡើយតាមអំពើចិត្ត[282] នៅមុនពេល ដែលភស្តុតាងនីមួយៗត្រូវបានភាគីយកមកជជែកដេញដោល នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីសួរតទល់គ្នានោះទេ[283]។

១៥៦. យោងតាមហេតុទាំងនេះ ចៅក្រមអន្តរជាតិយល់ឃើញថា នៅក្នុងរឿងក្តីនេះ សហចៅក្រមស៊ើបអង្កេតទាំងពីរមានកំហុសអង្គច្បាប់ ដោយសារបានតម្កល់គោលការណ៍កំណត់ប្រភេទនៃភស្តុតាងតាមឋានានុក្រម និងតាមទម្រង់ច្បាប់ ដោយផ្អែកលើប្រភព ជាជាងអង្គសេចក្តី ដែលចំណុចនេះពុំមែនត្រឹមតែពុំបានគោរពតាមការអនុវត្តពីមុនរបស់ខ្លួន[284] និងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[285] ជាងនេះទៅទៀត ថែមទាំងមិនបានអនុវត្តត្រឹមត្រូវ យោងតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ហើយជាទូទៅមិនមានមូលដ្ឋានគាំទ្រនៅក្នុងប្រព័ន្ធច្បាប់ ដែលមានជជែកសួរដេញដោលឡើយ។

១៥៧. ម្យ៉ាងវិញទៀត ចៅក្រមអន្តរជាតិសូមរំលឹកថា *យោងតាមការពិនិត្យបឋម* ទោះបីជាតម្លៃជាភស្តុតាងនៃសម្ភារៈជាក់លាក់ណាមួយ ដែលពេលនៅដាច់តែឯងអាចមានតម្លៃតិចតួចក្តី ប៉ុន្តែការពិតដែលថាស

[281] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៣។

[282] បញ្ហាមួយផ្សេងទៀត ដែលនាំឱ្យសហចៅក្រមស៊ើបអង្កេតជាតិច្រានចោលផ្នែកទាំងមូលនៃភស្តុតាង ដែលបានដាក់ចូលយ៉ាងមានសុពលភាពទៅក្នុងសំណុំរឿង ទាក់ទងនឹងការបកស្រាយពុំបានត្រឹមត្រូវរបស់គាត់ ទៅលើអានុភាពគតិយុត្តិ ដែលបានត្រូវបានអនុញ្ញាតឱ្យបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការឡើងវិញ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១។ បញ្ហានេះនឹងត្រូវបានលើកយកមកដោះស្រាយនៅក្នុងការពិនិត្យរបស់ចៅក្រមអន្តរជាតិនៃការពិចារណាផ្នែក ខ និង គ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ *សូមមើល ខាងក្រោម* កថាខណ្ឌ ២២៦-២៥០។

[283] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៣។

[284] *សូមមើល* សំណុំរឿង ០០១ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ D99 ("ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ (D99)")។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 ("ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427)")។ សំណុំរឿង ០០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D420 ("ដីកាសម្រេចលើកលែងចោទប្រកាន់ (D420)")។

[285] *សូមមើលឧទា.* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤១-៦៣។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៧៣-៨៧។

ម្ភារៈនោះមានភាពពាក់ព័ន្ធខ្លះ គឺមានន័យថាសម្ភារៈទាំងនោះចាំបាច់ត្រូវតែយកមកពិចារណា[286]។ ជាការពិត នៅពេលពិនិត្យមើលភស្តុតាងទាំងអស់នៅក្នុងសំណុំរឿងក្នុងទិដ្ឋភាពទូលាយ វាអាចបង្ហាញឱ្យឃើញបែបផែន ឬ បរិបទជុំវិញនៃអំពើឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ដែលជាផលតបស្នងអាចមានអានុភាពលើការវាយតម្លៃបឋមលើភស្តុតាងចំពោះផ្នែកនីមួយៗនៃភស្តុតាង ជាឧទាហរណ៍ វាបង្ហាញថា ផ្នែកនៃភស្តុតាងខ្លះពិតជាស៊ីសង្វាក់នឹងគ្នា។ ដូច្នេះ ចៅក្រមអន្តរជាតិសង្កេតឃើញថា ការស្ដាប់ចម្លើយធ្វើឡើងដោយសហព្រះរាជអាជ្ញា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅមានក្នុងសំណុំរឿង ០០៣ ទោះបីជាសហចៅក្រមស៊ើបអង្កេតបានសម្រេចសន្និដ្ឋានផ្ដល់តម្លៃជាភស្តុតាងតិចតួចក៏ដោយ។ ដូច្នេះ កិច្ចសម្ភាសន៍ ពាក្យសុំ និងឯកសារទាំងនេះ អាចយកទៅពិចារណាឱ្យបានលម្អិតនៅក្នុងដំណាក់កាលជំនុំជម្រះបាន[287]។

### ii. ការពិចារណាលើភស្តុតាងផ្ដល់ជូនដោយជនរងគ្រោះ

១៥៨. ចៅក្រមអន្តរជាតិពិចារណាឃើញថា កំហុសធ្ងន់ធ្ងរនៅក្នុងការកំណត់ឋានានុក្រមនៃភស្តុតាង ដែលពុំត្រឹមត្រូវតាមផ្លូវច្បាប់ បង្ហាញច្បាស់នៅពេលសហចៅក្រមស៊ើបអង្កេតទាំងពីរពិចារណាលើភស្តុតាងដែលជនរងគ្រោះបានផ្ដល់ឱ្យនៅក្នុងសំណុំរឿងនេះ។ ដូចបានកត់សម្គាល់ដោយសង្ខេបខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអះអាងនៅក្នុងដីកាបញ្ជូនរឿងក្ដីទៅជំនុំជម្រះថា៖

> ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពុំអាចទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានទេ

---

[286] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥៣ និងជើងទំព័រយោងលេខ ១០៥ *ដែលយោងទៅ*តុលាការ SCSL *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Norman និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ SCSL-04-14-AR65, FOFANA é បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធសំណើសុំឱ្យដោះលែងបណ្ដោះអាសន្ន អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ កថាខណ្ឌ ២៣។ តុលាការ SCSL *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Sesay និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ SCSL-04-15-T សេចក្ដីសម្រេចលើសំណើរបស់ GBAO សុំឱ្យច្រានចោលភស្តុតាងរបស់សាក្សីជាក់បន្ទុក លោក KOKER អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៩។ *សូមមើលផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨២។

[287] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤៨។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨២។

01667358



ហើយទទួលបានតម្លៃជាភស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើមិនដឹងអំពីកាលៈទេសៈដែល បានកត់ត្រាពាក្យសុំនោះ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ ដែលគ្រាន់តែបង្ហាញពីសេចក្តីសន្និដ្ឋានទូទៅ ហេតុនេះគ្រាន់តែជា *"ការរៀបរាប់ទូទៅ"* ដែលមិនមែនជាបទពិសោធន៍ផ្ទាល់ខ្លួនទេ ត្រូវចាត់ទុកថាមិនមានព័ត៌មានគ្រប់គ្រាន់អាចបញ្ជាក់ពីអង្គហេតុពាក់ព័ន្ធបានទេ។ ចម្លើយដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នៅក្រោមនីតិវិធីតុលាការ ត្រូវទទួលបានតម្លៃជាភស្តុតាងទាប ចំណែកឯសក្ខីកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់តាមនីតិវិធីតុលាការត្រូវបានវាយតម្លៃយ៉ាងប្រយ័ត្នប្រយែង[288]។

១៥៩. ជាបញ្ហាបឋម ចៅក្រមអន្តរជាតិសូមរម្លឹកថា ជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចមានព័ត៌មានផ្ទាល់អំពីអង្គហេតុ ពាក់ព័ន្ធនឹងការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក[289]។ ហេតុដូច្នេះ ភាពអាចជឿជាក់បាននៃភស្តុតាងរបស់ពួកគេគួរយកមកវាយតម្លៃទៅតាមករណីនីមួយៗ[290] ហើយមិនអាចចាត់ទុកដោយស្វ័យប្រវត្តិថាមិនអាចទុកចិត្តបានតែម្តងនោះទេ[291]។ ករណី ដែលថាពួកគេមានផលប្រយោជន៍ជាលក្ខណៈបុគ្គលនៅពេលចុងបញ្ចប់នៃរឿងក្តីនេះ មិនគួរនាំឱ្យមានការសន្និដ្ឋានថា ភស្តុតាងដែលពួកគេផ្តល់ឱ្យអាចជឿជាក់បានតិចជាងនោះឡើយ[292]។ ចៅក្រមអន្តរជាតិសូមបញ្ជាក់សាជាថ្មីថា ការកំណត់ឋានានុក្រមដោយសហចៅក្រមស៊ើបអង្កេតទាំងពីរតាមលក្ខណៈបែបនេះ កម្រិតប្រសិទ្ធភាពនៃ

---

[288] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១២១ (លុបចោលជើងទំព័រយោង និងការបញ្ជាក់បន្ថែម)។

[289] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។

[290] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20), កថាខណ្ឌ ៥៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។

[291] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។

[292] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20), កថាខណ្ឌ ៥៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។

សិទ្ធិរបស់ជនរងគ្រោះក្នុងការប្ដឹងតុលាការ[293] ហើយផ្ទុយនឹងមាត្រា ១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងយ៉ាងច្បាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណី ពុំតម្រូវឲ្យមានលក្ខខណ្ឌផ្លូវការណាមួយ នៅពេលមានបំណងអន្តរាគមន៍នៅដំណាក់កាលស៊ើបអង្កេតនោះទេ[294]។

១៦០. អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិពិចារណាឃើញថា វិធីសាស្ត្រតាមទម្រង់របស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ក្នុងការបដិសេធ *តាមការពិនិត្យបឋម* លើសច្ចធារណ៍នៃភាពអាចទុកចិត្តបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយផ្ដល់ទម្ងន់តិចតួចជាងភស្តុតាង ដែលប្រមូលបានដោយការិយាល័យរបស់ខ្លួន គឺធ្វើឡើងពុំត្រឹមត្រូវតាមផ្លូវច្បាប់យោងតាមក្របខណ្ឌគតិយុត្ត អ.វ.ត.ក ហើយពុំមានហេតុផលត្រឹមត្រូវ និងពុំសមស្របអនុលោមតាមវិធាន ២១(៤) ដោយសារសហចៅក្រមស៊ើបអង្កេតទាំងពីរមានកាតព្វកិច្ចត្រូវស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីធានាតម្លៃនៃភស្តុតាង និងធានាសិទ្ធិរបស់ជនរងគ្រោះ នៅ អ.វ.ត.ក[295] ហើយវានាំឲ្យមានការពន្យារពេលនៅក្នុងកិច្ចដំណើរការនីតិវិធី។

១៦១. យោងតាមហេតុផលទាំងនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រកាន់យកសំអាងច្បាប់ដែលមានវិការៈ ដោយបានអនុវត្តឋានានុក្រមលើភស្តុតាងតាមទម្រង់ ពាក់ព័ន្ធនឹងភស្តុតាង ដែលបានផ្ដល់ជូនដោយជនរងគ្រោះនៅក្នុងរឿងក្ដីនេះ។

---

[293] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥៦។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។

[294] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។ សូមមើល ផងដែរ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍អំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ (D362/6) កថាខណ្ឌ ៣១-៣៨ (ដែលលើកឡើងអំពីលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់ សម្រាប់ការទទួលយកពាក្យសុំតាំងខ្លួនជាដើមរដ្ឋប្បវេណីតែប៉ុណ្ណោះ)។

[295] *សូមមើល* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥៥។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨១។

01667360



ខ. បទដ្ឋានភស្តុតាង

១៦២. ចៅក្រមអន្តរជាតិសង្កេតឃើញថា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រកាសដោយពុំបានបកស្រាយលម្អិតថា "បទដ្ឋានបង្ហាញភស្តុតាងសម្រាប់ដីកាសម្រេចលើការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះគឺផ្អែកលើលក្ខខណ្ឌភវនីយភាព"[296] និងបានសំអាងលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ដើម្បីបង្ហាញគោលការណ៍នានាសម្រាប់វាយតម្លៃលើភស្តុតាង[297]។ ចៅក្រមអន្តរជាតិសូមលើកឡើងបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតជាតិ ពុំបានបង្ហាញបទដ្ឋាននៃការបង្ហាញភស្តុតាងនៅក្នុងដីកាលើកលែងការចោទប្រកាន់ នៅពេលចេញសេចក្ដីសម្រេច។

១៦៣. ចៅក្រមអន្តរជាតិសូមរំលឹកឡើងវិញថា លក្ខណៈនៃសេចក្ដីសម្រេច និងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី មានផលប៉ះពាល់លើបទដ្ឋាននៃភស្តុតាង[298]។ ទោះបីជាវិធាន ៦៧ ចែងថា លក្ខខណ្ឌវិនិច្ឆ័យនៃការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺអត្ថិភាព នៃ "ភស្តុតាងគ្រប់គ្រាន់ [...] ដើម្បីជាមូលដ្ឋានគាំទ្របទចោទ"[299] ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ដើម្បីអាចសម្រេចផ្ដន្ទាទោសបាន ត្រូវមានកាតព្វកិច្ចគោរពតាមលក្ខខណ្ឌបទដ្ឋាននៃការជឿជាក់ "ហួសពីវិមតិ

[296] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៣០ *យោងទៅ* សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 ("សំអាងហេតុនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3)") កថាខណ្ឌ ២ *ដែលក្នុងនោះក៏បានយោងទៅ* ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣២៣-១៣២៦។

[297] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១១៨-១២៩។

[298] *សូមមើល* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៤។ *សូមមើល ផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៦១។

[299] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20), កថាខណ្ឌ ៦១។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៤។

សង្ស័យ”[300] ដែលជាបទដ្ឋានដោយឡែក និងមានលក្ខណៈខ្ពស់ជាងបទដ្ឋាននៃ “ភស្តុតាងគ្រប់គ្រាន់” អនុវត្តនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះ[301]។

១៦៤. ពាក់ព័ន្ធនឹងការសម្រេចលើ “បទចោទគ្រប់គ្រាន់” ចៅក្រមអន្តរជាតិសង្កេតឃើញថា ពាក្យបច្ចេកទេសផ្សេងគ្នាត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿង ០០១ សំណុំរឿង ០០២ សំណុំរឿង ០០៣ សំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២[302] ហើយក៏បានកត់សម្គាល់ថា នៅក្នុងរឿងក្តីបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយកតាម “បទដ្ឋាននៃភាវនីយភាព” ដែលអនុវត្តនៅក្នុងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២[303]៖

> នៅក្នុងដំណាក់កាលស៊ើបសួរមុនអង្គសេចក្តីនេះ មិនមានការតម្រូវឱ្យបង្ហាញអំពីពិរុទ្ធភាពរបស់ជនត្រូវចោទនោះទេ (អង្គជំនុំជម្រះសាលាដំបូងគឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការធ្វើដូច្នោះ) ប៉ុន្តែចាំបាច់ត្រូវមានការបង្ហាញអំពី “ភាវីយភាព” នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានធម្មតា)។ ហេតុដូច្នេះ ការវាយតម្លៃអំពីភស្តុតាងដាក់បន្ទុកនៅក្នុងដំណាក់កាលនេះ មានលក្ខណៈខុសគ្នាពីសញ្ញាណនៃ “ជំនឿស៊ប់” របស់ចៅក្រមនៅក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែ ភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់ (ភស្តុតាងដែលត្រូវយកជាការបានរហូតដល់មានភស្តុតាង

---

[300] *សូមមើល* វិធាន ៨៧(១), ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុង។

[301] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៦១-៦២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៤។

[302] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០១ (D99) កថាខណ្ឌ ១៣០ (“មានភស្តុតាងគ្រប់គ្រាន់”)។ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ (D427) កថាខណ្ឌ ១៣២៣ (“លក្ខខណ្ឌភាវនីយភាពនៃពិរុទ្ធភាព”)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៣០ (លក្ខខណ្ឌភាវនីយភាព)។ សំអាងហេតុនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ (D308/3) កថាខណ្ឌ ២ (“បទដ្ឋានលក្ខខណ្ឌភាវនីយភាព”)។ សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ (D360)”) (ពុំបានបញ្ជាក់ពីបទដ្ឋានទេ)។

[303] ដីកាដំណោះស្រាយ (D267) កថាខណ្ឌ ៣០ *យោងទៅ* សំអាងហេតុនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3) កថាខណ្ឌ ២ *ដែលសំអាងលើ* ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣២៣-១៣២៦។

ផ្ទុយ = Force Probante)[304]។

១៦៥. ទោះបីជាពុំមានបទប្បញ្ញត្តិនៅក្នុងច្បាប់ជាធរមានចំពោះមុខ អ.វ.ត.ក ដែលចែងជាក់លាក់អំពីបទដ្ឋានភស្តុតាងសម្រាប់ការសម្រេចលើ "បទចោទគ្រប់គ្រាន់" អនុលោមតាមវិធាន ៦៧ និងសញ្ញាណនៃ "បទចោទគ្រប់គ្រាន់" ដែលសហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែពិចារណា ក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ គឺមានភាពលំបាកក្នុងការធ្វើសនិទានកម្ម"ក៏ដោយ ក៏ចៅក្រមអន្តរជាតិសូមរំលឹកថា "បទដ្ឋានផ្លូវច្បាប់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ចេញសេចក្ដីសម្រេច វិវឌ្ឍន៍ជាបន្តបន្ទាប់ នៅក្នុងកិច្ចដំណើរការនីតិវិធី "ចាប់ពីត្រឹមលទ្ធភាពឈានទៅដល់ "ភវនីយភាព" ឬ "ភាពអាចជឿជាក់បាន" នៃពិរុទ្ធភាពនៅក្នុងពេលស៊ើបអង្កេត ដើម្បីបង្ហាញភស្តុតាងនៃពិរុទ្ធភាពបែបនេះឲ្យហួសពីវិមតិសង្ស័យនៅដំណាក់កាលជំនុំជម្រះ"[305]។ ដូច្នេះ ចៅក្រមអន្តរជាតិកត់សម្គាល់ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក នៅក្នុងកាលៈទេសៈស្រដៀងគ្នាថា ទោះបីជាវាមានភាពចាំបាច់នៅក្នុងដំណាក់កាលមុនការជំនុំជម្រះត្រូវមានលើសពីសញ្ញាណបញ្ជាក់ ឬ ការសង្ស័យក្នុងការបញ្ជូនបុគ្គលណាម្នាក់ទៅជំនុំជម្រះក៏ដោយ ក៏ភស្តុតាងប្រមូលបានពុំចាំបាច់ត្រូវបញ្ជាក់ពិរុទ្ធភាពឲ្យបានជាក់លាក់នោះទេ[306]។ ការបកស្រាយនេះស្របទៅនឹងយុត្តិសាស្ត្រជាបន្តបន្ទាប់របស់អង្គបុរេជំនុំជម្រះនេះដែលថា បទដ្ឋាននៃ "បទចោទគ្រប់គ្រាន់" សម្រាប់ការចេញដីកាដំណោះស្រាយ ឆ្លើយតបជាអប្បរមាចំពោះលក្ខខណ្ឌស្ដីពី "ភស្តុតាងមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់" ដែលចង្អុលបញ្ជាក់ថា បុគ្គលម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបទឧក្រិដ្ឋមួយ ដើម្បីចោទប្រកាន់ជនសង្ស័យស្របតាមវិធាន

---

[304] ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣២៣ (ជើងទំព័រយោងត្រូវបានលុបចោល) (គូសបញ្ជាក់បន្ថែម)។

[305] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៦២។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៥។

[306] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៥ *យោងទៅ Habr* "Ordonnance de non-lieu partiel (EAC) ទំព័រ៥។

៥៥(៤) បាន[307]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិអះអាងជាថ្មីថា បទដ្ឋាននេះអាចអនុវត្តបានចំពោះរឿងក្តីបច្ចុប្បន្ននេះ។

## គ. ចំនួនជនរងគ្រោះ

១៦៦. ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានព្យាយាមបង្ហាញអំពីចំនួនជនរងគ្រោះជាក់លាក់នៅទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ ក្រោមការស៊ើបអង្កេត[308] ខណៈបានបង្ហាញការអនុវត្តវិធីសាស្ត្រលម្អិតរបស់ខ្លួន ដោយគាត់បានកំណត់ "យ៉ាងប្រុងប្រយ័ត្ន" អំពី "ចំនួនជនរងគ្រោះអប្បបរមា" មកសន្មតថា "ចំនួនជនរងគ្រោះជាក់ស្តែងទំនងខ្ពស់ជាងនេះច្រើន" លើសពីការប៉ាន់ស្មានរបស់គាត់[309]។

១៦៧. ទោះបីចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតមានភារកិច្ចស្វែងរកការពារក្តី តែចៅក្រមអន្តរជាតិទទួលស្គាល់ថា ពេលវេលាដែលកន្លងទៅ និងការលំបាកជាសត្យានុម័តក្នុងការកំណត់អំពីបរិមាណនៃការស្លាប់ គឺជាឧបសគ្គក្នុងការកំណត់ឱ្យបានច្បាស់ពីចំនួនជនរងគ្រោះ។ ចៅក្រមអន្តរជាតិគូសបញ្ជាក់ថា ដោយពិចារណាលើបទដ្ឋានភស្តុតាងអនុវត្តនៅដំណាក់កាលមុនការជំនុំជម្រះ នៅ អ.វ.ត.ក ទោះបីចំនួនជនរងគ្រោះគឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំនានាដែលត្រូវយកមកពិចារណា ដើម្បីវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ក្នុងការកំណត់អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្តី[310] តែសហចៅក្រមស៊ើបអង្កេតពុំចាំបាច់កំណត់ចំនួនជនរងគ្រោះឱ្យបានជាក់លាក់ និងរៀបរាប់លម្អិតអំពីវិធីសាស្ត្រនៃការសម្រេចបែបនេះទេ[311]។ ជាងនេះទៀត ចៅក្រមអន្តរជាតិសូមរំលឹកថា វាពុំមានលក្ខណៈសមស្រប និងពុំ

---

[307] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៦២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៥។

[308] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៣២-១៤៥។

[309] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៣៣។

[310] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៦។

[311] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ២១៤។

មានភាពជាក់ស្តែង ក្នុងការទទួលបានភាពជាក់លាក់កម្រិតខ្ពស់នៅក្នុងរឿងក្តីឧក្រិដ្ឋកម្មធំៗ។ ភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងចំនួនជាក់លាក់នៃជនរងគ្រោះនៅទីតាំងឧក្រិដ្ឋកម្ម ឬព្រឹត្តិការណ៍នីមួយៗ ពុំរារាំងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្រោមយុត្តាធិការអ.វ.ត.ក ត្រូវបានប្រព្រឹត្តឡើងនៅតាមទីកន្លែង និងពេលវេលាជាក់លាក់[312]។

១៦៨. យោងតាមចំណុចនេះ ចៅក្រមអន្តរជាតិសូមបញ្ជាក់ថា យោងតាមគោលបំណងនៃការបញ្ជាក់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នៅដំណាក់កាលមុនការជំនុំជម្រះ "ការប៉ាន់ស្មានក្នុងលក្ខណៈសមហេតុផល" លើចំនួនជនរងគ្រោះ ឬការយោងលើ "ការកាប់សម្លាប់ជាច្រើន" គឺមានលក្ខណៈគ្រប់គ្រាន់ និងសមស្របជាង[313]។

ឃ. សេចក្តីសន្និដ្ឋាន

១៦៩. យោងតាមហេតុផលខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា វិធីសាស្ត្រពិចារណាភស្តុតាងតាមឋានានុក្រមរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងរឿងក្តីនេះ ផ្ទុយនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងច្បាប់ជាធរមាននៅក្នុងដំណាក់កាលនីតិវិធីមុនការជំនុំជម្រះរបស់ អ.វ.ត.ក ហើយមិនស្របតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ឡើយ។

៤. តួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា និងអានុភាពនៃសេចក្តីសម្រេចរបស់តុលាការនេះដែលសន្និដ្ឋានថាពុំមានយុត្តាធិការបុគ្គល

១៧០. ចៅក្រមអន្តរជាតិសូមបញ្ជាក់ជាថ្មីថា ទោះបី អ.វ.ត.ក ស្ថិតក្នុងប្រព័ន្ធច្បាប់នៅកម្ពុជាដែលអនុវត្តយុត្តាធិការរបស់ខ្លួនផ្តាច់មុខ នៅដំណាក់កាលជំនុំជម្រះ និងមិនបញ្ជូនទៅតុលាការមួយទៀត[314] ក៏ដោយ តែ

---

[312] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20), យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ២១៤។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ៨៦។

[313] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៦ *យោងទៅ* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ ("សាលក្រមរឿងក្តី *Stakić* (ICTY)") កថាខណ្ឌ ២០១។

[314] សាលដីកានៃសំណុំរឿង ០០១ (F28) កថាខណ្ឌ ៧១។

ច្បាប់ជាធរមាននៅ អ.វ.ត.ក មិនបានរារាំងយុត្តាធិការថ្នាក់ជាតិ និងតុលាការធម្មតារបស់កម្ពុជា មិនឱ្យមានយុត្តាធិការពេញលេញជាមូលដ្ឋាន ទៅលើបញ្ហាយុត្តិធម៌ព្រហ្មទណ្ឌនោះទេ[315]។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា អាជ្ញាធរតុលាការកម្ពុជាមិនត្រូវបានរារាំងតាមផ្លូវច្បាប់ក្នុងការស្វែងរកយុត្តិធម៌សម្រាប់សំណុំរឿងនានាក្នុងសម័យខ្មែរក្រហម ដែលមិនត្រូវបានបញ្ជូន ឬដែលត្រូវបានសន្និដ្ឋានថាមិនស្ថិតនៅក្នុងយុត្តាធិការផ្ដាច់មុខរបស់ អ.វ.ត.ក នោះឡើយ[316] ។

១៧១. ទាក់ទិននឹងចំណុចនេះ ជាបឋម ចៅក្រមអន្តរជាតិកត់សម្គាល់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ដោយផ្អែកលើការពុំមានយុត្តាធិការបុគ្គល មិនបានសម្រេចទៅលើករណីថាតើ មាន ឬមិនមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ទៅតាមអត្ថន័យនៃវិធាន ៦៧(៣)(គ) នៃវិធានផ្ទៃក្នុងនោះទេ។ ហេតុនេះ ទោះបីដីកានេះរំលត់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនត្រូវចោទនៅចំពោះមុខ អ.វ.ត.ក ក៏ដោយ ក៏វាពុំមែនជាការសម្រេចរបស់តុលាការទៅលើបទចោទព្រហ្មទណ្ឌដែរ ហេតុនេះវាខុសពីការសម្រេចឱ្យជនត្រូវចោទរួចពីការចោទប្រកាន់ ឬការច្រានចោលសំណុំរឿងនេះ ដោយផ្អែកលើសេចក្ដីសន្និដ្ឋាននានាពីបទចោទ[317]។ លក្ខណៈជាក់លាក់នៃដីកាសម្រេចលើកលែងចោទប្រកាន់ដោយផ្អែកលើកង្វះយុត្តាធិការបុគ្គល

---

[315] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ (D359/24 និង D360/33) កថាខណ្ឌ ៥៩។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៧៩។

[316] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៧៩ និង ផ្នែកសម្រេចសេចក្ដី ទំព័រ ៣៨-៣៩។ *សូមមើលផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ (D359/24 និង D360/33) កថាខណ្ឌ ៥៨-៥៩។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៤០ (សេចក្ដីសម្រេចផ្នែកយុត្តាធិការ "មិនអាចរារាំងការពិចារណាសម្រេចចោទប្រកាន់លើឧក្រិដ្ឋកម្មធ្ងន់ធ្ងរចំពោះ [ជនត្រូវចោទ] នៅចំពោះមុខតុលាការជាតិនោះទេ ដោយសារប្រទេសកម្ពុជាមានយុត្តាធិការជាប់មករហូតលើរឿងក្ដីនៅក្នុងសម័យខ្មែរក្រហម ដែល អ.វ.ត.ក មិនបានទទួលរឿងក្ដី ឬ មិនអាចមានសមត្ថកិច្ចទទួលរឿងក្ដីទាំងនោះ" (លុបជើងទំព័រ))។

[317] ករណីយុត្តិសាស្ត្រនៃការវិនិច្ឆ័យផ្នែកព្រហ្មទណ្ឌនៅតុលាការបារាំង។ *សូមមើលឧទាហរណ៍* តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៨៨៥ ("ដីការបស់ចៅក្រមស៊ើបសួរមានតែលក្ខណៈជាដីកាសម្រេចលើកលែងចោទប្រកាន់ ហើយអាចបង្កើតប្រសិទ្ធភាពរបស់វា ចំពោះតែអំពើទុយ៌សដែលពុំមែនជាបទព្រហ្មទណ្ឌ បទល្មើស ឬកំហុស ឬពុំមានបទចោទមកលើជនជាប់ចោទតែប៉ុណ្ណោះ" (ការបកប្រែក្រៅផ្លូវការ))។ *សូមមើលផងដែរ* តុលាការកំពូលព្រហ្មទណ្ឌបារាំង ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ១៩៩២ លេខ ៩២-៨១.៤៦០ ព្រឹត្តិប័ត្រព្រហ្មទណ្ឌលេខ ២៤៨ ("មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រឹមតែអនុញ្ញាតឱ្យចៅក្រមស៊ើបសួរចេញដីកាសម្រេចលើកលែងចោទប្រកាន់ ចំពោះតែអំពើទុយ៌សដែលពុំមែនជាបទព្រហ្មទណ្ឌ បទល្មើស ឬកំហុស ឬពុំមានបទចោទមកលើជនជាប់ចោទតែប៉ុណ្ណោះ។ ចំពោះគោលការណ៍អាជ្ញាអស់ជំនុំ មានសុពលភាពតែចំពោះដីកានេះ

អាចមើលហួសឆ្ងាយយុត្តិសាស្ត្រនៅ អ.វ.ត.ក បាន។ នៅក្នុងសំណុំរឿង ០០៤/១[318] សំណុំរឿង ០០៤/២[319] និងសំណុំរឿង ០០៣[320] ទោះបីចៅក្រមមួយចំនួនបានសន្និដ្ឋានថា ជនត្រូវចោទមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះក្តី តែចៅក្រមអន្តរជាតិសង្កេតឃើញថា ពុំមានការសម្រេចគួរឱ្យកត់សម្គាល់ថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ពុំបានកើតឡើងទេ ឬថា អង្គហេតុនានាដែលស្ថិតក្នុងការស៊ើបអង្កេតមិនជាប់ពាក់ព័ន្ធនឹងជនត្រូវចោទ យ៉ាងហោចណាស់នៅក្នុងផ្នែកណាមួយដែរ។

១៧២. ចៅក្រមអន្តរជាតិសូមរំលឹកថា តុលាការជាតិធម្មតានៅក្នុងប្រទេសកម្ពុជា មានយុត្តាធិការជាប់មកជាមួយ និងពេញលេញលើគ្រប់រឿងក្តីក្នុងសម័យខ្មែរក្រហម ដែល អ.វ.ត.ក មិនបានទទួលរឿងក្តី ឬ មិន

---

ប៉ុណ្ណោះ ហើយម្យ៉ាងវិញទៀត សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរមិនអាចបង្ហាញពីលក្ខណៈនៃដីកាសម្រេចលើកលែងចោទប្រកាន់ ឬមិនអាចបង្កើតប្រសិទ្ធភាពរបស់វាបាន នៅពេលដែលចៅក្រមស៊ើបសួរបានដំណើរការក្នុងការកំណត់លក្ខណៈបទល្មើសជាថ្មី ម្យ៉ាងនៅក្នុងបរិបទនៃការលើកលែងចោទប្រកាន់ និងម្យ៉ាងទៀតបានបញ្ជូនទៅតុលាការកែតម្រូវ" (បកប្រែក្រៅផ្លូវការ))។

[318] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 ("ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (D308/3)") កថាខណ្ឌ ៣០៦-៣១១។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៨២-៩២។

[319] សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ឯកសារ D359 ("ដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៤/២ (D359)") កថាខណ្ឌ ៤៩៧ ("ភស្តុតាងបង្ហាញថា អោ អាន ក៏អាចមានការពាក់ព័ន្ធនឹងការចេញបញ្ជាឱ្យចាប់ និងសម្លាប់មនុស្សមួយចំនួនតូច") កថាខណ្ឌ ៤៩៨ ("ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម ភស្តុតាងក៏បានបង្ហាញដែរថា អោ អាន បានចូលរួមដឹកនាំផ្សព្វផ្សាយ គោលនយោបាយលើជនជាតិចាម បន្តអនុវត្តបញ្ជាដោយឱ្យអ្នកក្រោមបង្គាប់ជាថ្នាក់ស្រុកធ្វើការស្រង់ទិន្នន័យជនជាតិចាម និងតាមដានការអនុវត្តន៍ការងារ តាមរយៈការបង្គាប់ឱ្យរាយការណ៍ និងការទទួលបាននូវរបាយការណ៍ពីថ្នាក់ក្រោមត្រឡប់មកវិញ") កថាខណ្ឌ ៥០០ ("ពាក់ព័ន្ធនឹងបញ្ហាអាពាហ៍ពិពាហ៍ដោយបង្ខំ អោ អាន បានចូលរួមនិងសម្របសម្រួលក្នុងក្របខណ្ឌនៃតំបន់ ៤១")។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៨០ ("ការចូលរួមរបស់ អោ អាន មិនមានស្វ័យភាព មិនសកម្ម គ្មានគំនិតផ្តួចផ្តើម និងមិនកៀកកិតនឹងការប្រព្រឹត្តិបទល្មើស")។

[320] *សូមមើលឧទាហរណ៍* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣១៣-៣១៤ ("មាស មុត ធ្លាប់រាយការណ៍ទៅ សុន សេន ទាក់ទងនឹងការបាញ់ទូកវៀតណាម ១ (មួយ) គ្រឿង នៅកោះខ្យង ការចាប់ទូកថៃ ១ (មួយ) គ្រឿង ដែលមានមនុស្សចំនួន ២១ (ម្ភៃមួយ) នាក់នៅកោះវៃ និងការចាប់ទូកវៀតណាម ២ (ពីរ) គ្រឿងដែលមានមនុស្សចំនួន ៧៦ (ចិតសិបប្រាំមួយ) នាក់នៅកោះតាង។ មាត្រា ក៏បានរាយការណ៍ទៅថ្នាក់លើស្តីពីការចាប់ និងសម្លាប់ជនជាតិវៀតណាមចំនួន ១២០ (មួយរយម្ភៃ) នាក់ និងបានរាយការណ៍ពីការរឹបអូសទូក អាវុធ ព្រមទាំងការដោះដូរអ្នកនេសាទថៃ" (លុបជើងទំព័រ)។

អាចមានសមត្ថកិច្ចទទួលរឿងក្តីទាំងនោះ ហើយពិចារណាឃើញថា ឧក្រិដ្ឋកម្ម ដែលជនល្មើសមានសញ្ជាតិខ្មែរ បានប្រព្រឹត្តលើទឹកដីកម្ពុជាប៉ះពាល់ដល់ជនរងគ្រោះកម្ពុជា គឺស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការជាតិ[321]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា នៅពេលរឿងក្តីក្នុងសម័យខ្មែរក្រហមលែងស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក តុលាការជាតិនឹងទទួលខុសត្រូវបន្តស្វែងរកយុត្តិធម៌ព្រហ្មទណ្ឌ ដោយអនុវត្តយុត្តាធិការពេញលេញរបស់ខ្លួន និងវិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់នៃរឿងក្តីទាំងនេះ។ ម៉្យាងវិញទៀត សេចក្តីសម្រេចណាមួយ ដែលសន្និដ្ឋានថា អ.វ.ត.ក ពុំមានយុត្តាធិការនោះ មិនមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាឡើយ។ ផ្ទុយទៅវិញ វាអនុញ្ញាតឱ្យផ្ទេរដំណើរការនីតិវិធីជូនទៅអាជ្ញាធរតុលាការកម្ពុជា[322] ដែលមានយុត្តាធិការពេញលេញលើបទឧក្រិដ្ឋទាំងនោះ ដែលមានលក្ខណៈធ្ងន់ធ្ងរ ហើយមិនត្រូវបានកំណត់អាជ្ញាយុកាល[323]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិសង្កេតឃើញថា មធ្យោបាយផ្សេងទៀត ហើយក្នុងចំណោមយុត្តាធិការបុគ្គលអកម្ម អាចអនុញ្ញាតឱ្យតុលាការមានសមត្ថកិច្ច

[321] *សូមមើល ឧទា.* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) មតិយោបល់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៤០។ *សូមមើលផងដែរ លិខិតចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ផ្ញើមកពីអគ្គលេខាធិការ Kofi ANNAN ជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខពាក់ព័ន្ធនឹងរបាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ក្រោមរបបខ្មែរក្រហម* ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប A/53/850, S/1999/231 (“នៅក្នុងកិច្ចប្រជុំមួយ ដែលខ្ញុំបានរៀបចំឡើងកាលពីថ្ងៃទី២ ជាមួយរដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ហោ ណាំហុង ឯកឧត្តម បានជម្រាបជូនខ្ញុំអំពីការយល់ឃើញរបស់រដ្ឋាភិបាលថា ផ្អែកតាមមាត្រា ៦ នៃអនុសញ្ញាស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា តុលាការកម្ពុជាមានសមត្ថកិច្ចពេញលេញធ្វើការជំនុំជម្រះទាំងនេះ។ ឯកឧត្តម បានរំលឹកថា ឧក្រិដ្ឋជនគឺជាពលរដ្ឋខ្មែរ ជនរងគ្រោះគឺជាពលរដ្ឋខ្មែរ ហើយឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា”)។

[322] *សូមមើល ឧទា.* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) មតិយោបល់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៤០។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌ (បារាំង) មាត្រា ៤៦៩(១) (“ប្រសិនបើអង្គហេតុដែលបញ្ជូនទៅសាលាមជ្ឈិមជាបទល្មើសដែលមានលក្ខណៈនាំឱ្យមានទោសព្រហ្មទណ្ឌ *តុលាការត្រូវបញ្ជូនបញ្ហានោះត្រឡប់ទៅរដ្ឋអាជ្ញាសាធារណៈវិញ ដើម្បីប្តឹងទៅតុលាការដែលសមស្របឱ្យចាត់ការលើបញ្ហានោះ*” (ការបកប្រែក្រៅផ្លូវការ សេចក្តីបញ្ជាក់បន្ថែម))។ *សូមមើលផងដែរ* Dani—le CARON, Fasc. 20: *TRIBUNAL CORRECTIONNEL. é Jugement. é D"tention provisoire. Comp"tence. é Ajournement, dispense et exemption de peine. Relaxe, Jurisclasseur Proc"dure P"nale* ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ កថាខណ្ឌ ៤៣។

[323] *សូមមើល ឧទា.* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៩។

នៅបរទេសផ្សេងទៀតធ្វើការវិនិច្ឆ័យលើអង្គហេតុទាំងអស់ ឬ មួយផ្នែក និងស្វែងរកជំនួយផ្នែកច្បាប់ ពី អ.វ.ត.ក[324]។

១៧៣. ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា មិនមានបទប្បញ្ញត្តិនៅក្នុងច្បាប់ជាធរមានរបស់ អ.វ.ត.ក រារាំងការិយាល័យសហព្រះរាជអាជ្ញា ឬ សហព្រះរាជអាជ្ញាណាមួយ មិនថាសហព្រះរាជអាជ្ញាជាតិ ឬ សហព្រះរាជអាជ្ញាអន្តរជាតិ ប្ដឹងទៅតុលាការជាតិកម្ពុជាធម្មតានោះឡើយ[325]។ ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា ការចោទប្រកាន់កាត់ទោសរបស់អាជ្ញាធរជាតិកម្ពុជាចំពោះឧក្រិដ្ឋកម្ម នៅក្នុងសម័យខ្មែរក្រហមដែលត្រូវបានគេរកឃើញថាស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក អាចត្រូវបានផ្តួចផ្តើមឡើងដោយព្រះរាជអាជ្ញាជាតិកម្ពុជា និងដោយការិយាល័យសហព្រះរាជអាជ្ញាផងដែរ។

១៧៤. យោងតាមទីត្យានុកូលភាព និងភាពស្របច្បាប់ នៃសេចក្តីសម្រេចរកឃើញថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គល ចៅក្រមអន្តរជាតិសូមរំលឹកអំពីលក្ខណៈ និងជំហររួមរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់

---

[324] យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក (“EAC”) ត្រូវបានកំណត់តាមលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌដែលអនុវត្តជាធរមាននៅចំពោះមុខ អ.វ.ត.ក *សូមមើល* លក្ខន្តិកៈនៃអង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិកនៅក្នុងតុលាការសេណេហ្គាល់សម្រាប់ការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិដែលបានប្រព្រឹត្តឡើងនៅឆាត ចន្លោះថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៨២ និងថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩០ មាត្រា ៣ (ផ្តល់យុត្តាធិការដល់ EAC “ចោទប្រកាន់ និងដាក់ទោសចារីនៃឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិ” នៅក្នុងអំឡុងពេលនៃរបប Habr”)។ ក្នុងខែកក្កដា ឆ្នាំ២០១៣ រដ្ឋអាជ្ញា EAC បានស្នើសុំដីកាបញ្ជូនរឿងទៅជំនុំជម្រះលើ Habr” និងមន្ត្រីប្រាំនាក់ផ្សេងទៀតនៅក្នុងរដ្ឋបាលរបស់លោក *សូមមើល* EAC រឿងក្តី *Minist—re Public ទល់នឹង Habr*" សាលក្រមចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ កថាខណ្ឌ ៦១។ អាជ្ញាធរឆាតបានបដិសេធធ្វើបត្យាប័នបុគ្គលពីរនាក់ (ចំណែកបីនាក់ទៀតទំនងជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យនាំខ្លួន)។ បុគ្គលពីរនាក់នេះ ដំបូងត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការកូនកាត់ ត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការជាតិ *សូមមើល* រឿងក្តី *Minist—re Public និងអ្នកផ្សេងទៀត ទល់នឹង Saleh Younous Ali, Warou Fadil Ali និងអ្នកផ្សេងទៀត* សាលាឧទ្ធរណ៍នៃ N“Djamena (ឆាត) សាលដីកា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ Directory 1/15។ *សូមមើលផងដែរ* តុលាការកំពូលតុលាការបារាំង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩ លេខ 07-88.330 (ទទួលស្គាល់យុត្តាធិការតុលាការបារាំងលើអំពើដែលត្រូវបានប្រព្រឹត្តឡើងនៅទីក្រុងភ្នំពេញកាលពីខែមេសា ឆ្នាំ១៩៧៥)។

[325] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៧៦ និងលេខយោងជើងទំព័រ ១៤៧។ *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៦(៥) (ពាក់ព័ន្ធនឹងការជ្រើសតាំងសហព្រះរាជអាជ្ញាអន្តរជាតិ)។

កម្ពុជា ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ស្ថាប័នអយ្យការទាំងនៅ អ.វ.ត.ក និងតុលាការជាតិកម្ពុជា ទទួលខុសត្រូវបន្តចោទប្រកាន់កាត់ទោសលើសពី អ.វ.ត.ក ដើម្បីរកយុត្តិធម៌លើឧក្រិដ្ឋកម្មដ៏សាហាវទាំងនេះ[326]។

១៧៥. ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង ចៅក្រមអន្តរជាតិសង្កេតឃើញថា ទាំងមុន ឬ ក្រោយការបង្កើត អ.វ.ត.ក ក្រៅពីការកាត់ក្តី ប៉ុល ពត និង អៀង សារី កំបាំងមុខ កាលពីឆ្នាំ១៩៧៩ នៅចំពោះមុខតុលាការបដិវត្តប្រជាជន ដែលត្រូវបានបង្កើតឡើងនៅកម្ពុជា ក្នុងឆ្នាំ១៩៧៩ ក្រោមយុត្តាធិការនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងមានមេធាវីជាតិ និងអន្តរជាតិ[327] មិនមាននីតិវិធីព្រហ្មទណ្ឌណាមួយត្រូវបានធ្វើឡើងដោយអាជ្ញាធរតុលាការកម្ពុជាតែឯង ដើម្បីប្រឆាំងនឹងចារីនៃឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ដែលបានប្រព្រឹត្តិក្នុងនាមកម្ពុជាប្រជាធិបតេយ្យនោះឡើយ[328]។ ជាងនេះទៅទៀត ចៅក្រមអន្តរជាតិកត់សំគាល់ថា ទោះបីមានសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ ប្រឆាំងនឹង អ៊ឹម ចែ

---

[326] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៩០(៦) អនុវត្ត*ដូចគ្នាដោយមិនមានការកែប្រែ*ចំពោះអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល (“ប្រសិនបើតុលាការដែលបានទទួលបណ្តឹងយល់ឃើញថាពុំមានសមត្ថកិច្ចតាមដែនដី តុលាការនេះប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម និងបង្គាប់ឱ្យបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះ ជូនតុលាការដែលមានសមត្ថកិច្ចតាមដែនដី។ ជាយថាហេតុ តុលាការនេះសម្រេចសេចក្តីលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតក្នុងការឃុំខ្លួន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ”)។

[327] *សូមមើល សាលក្រមតុលាការបដិវត្តន៍ប្រជាជន ដែលបានបើកសវនាការនៅក្នុងទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី១៥ ដល់ ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩* ឯកសារ អ.ស.ប A/34/491 ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៩។

[328] Suzannah LINTON “ការស្វែងយល់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងប្រទេសកម្ពុជាក្នុងបរិបទ ” សៀវភៅច្បាប់អន្តរជាតិសិង្ហបុរីប្រចាំឆ្នាំ (២០០៧) ទំព័រ ១៩៥-២៥៩ ជាពិសេស សូមមើល ទំព័រ ២១៥ (“ទោះបីជាច្បាប់ឆ្នាំ១៩៩៤ ស្តីពីការដាក់ខ្មែរក្រហម/កម្ពុជាប្រជាធិបតេយ្យ ឲ្យនៅក្រៅច្បាប់ ចែងថា មានផែនការចោទប្រកាន់កម្មាភិបាលថ្នាក់ទៀត ក៏គ្មានចំណុចណាមួយចែងថា អាជ្ញាធម្មមានយុទ្ធសាស្រ្តប្រកបដោយការទទួលខុសត្រូវជាក់លាក់នោះឡើយ កុំថាឡើយអ្នកពាក់ព័ន្ធនឹងតុលាការច្បាប់ ឬ ដំណើរការទទួលខុសត្រូវក្រៅផ្លូវការ ដែលខ្មែរក្រហក្បាលរឹងនឹងត្រូវកាត់ទោសជាឈុត”)។ *សូមមើលផងដែរ* Tom FAWTHROP និង Helen JARVIS, *Getting away with Genocide,* (Pluto Press, 2004)។ លី សុខឃាង ំ ដំណើរការផ្សះផ្សាជាតិនកម្ពុជា៖ ១៩៧៩-២០០៧ នៅចំពោះមុខសាលាក្តីខ្មែរក្រហម ™ មជ្ឈមណ្ឌលឯកសារកម្ពុជា លេខឯកសារ 24 (2017)។ John HALL “នៅក្នុងស្រមោលនៃសាលាក្តីខ្មែរក្រហម៖ ការជំនុំជម្រះ នួន ប៉ែត ឈួក រិន និង សំ ប៊ិត និងការស្វែងរកភាពស្របច្បាប់តាមផ្លូវតុលាការនៅក្នុងប្រទេសកម្ពុជា” ទិន្នានុប្បវត្តិ *Columbia Journal of Asian Law* (ឆ្នាំ២០០៦) ទំព័រ ២៣៥-២៩៧។ Toshihiro ABE (ed.) *ពិចារណាការជំនុំជម្រះខ្មែរក្រហមនៅក្នុងបរិបទ* (Silkworm, ឆ្នាំ២០១៩)។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤/២ (D359) កថាខណ្ឌ ៤៤៨។

ម នៅក្នុងសំណុំរឿង ០០៤/១ បែបនោះក៏ដោយ[329] អយ្យការជាតិកម្ពុជា មិនបានផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយប្រឆាំងនឹងលោកស្រីទេរហូតមកដល់បច្ចុប្បន្ននេះ។

១៧៦. យោងតាមទំហំ និងទម្ងន់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ ចៅក្រមអន្តរជាតិពិចារណាឃើញថា នៅក្នុងកាលៈទេសៈបច្ចុប្បន្ន អាជ្ញាធរតុលាការកម្ពុជា ត្រូវមានការទទួលខុសត្រូវក្នុងការចោទប្រកាន់ និងអនុវត្តយុត្តាធិការពេញលេញលើរឿងក្តីនានាដែល អ.វ.ត.ក ត្រូវបានរកឃើញថាគ្មានសមត្ថកិច្ចដោយសារពុំមានយុត្តាធិការបុគ្គល។

## ខ. អង្គសេចក្តី

១៧៧. នៅពេលនេះ ចៅក្រមអន្តរជាតិនឹងពិនិត្យមើលទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ទាំងពីរដែលអាចទទួលយកបាន។

### ១. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ

#### ក. សារណា

១៧៨. សហព្រះរាជអាជ្ញាជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[330] ដែលបានសន្និដ្ឋានថា មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ជាបុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបានស្នើសុំឲ្យអង្គបុរេជំនុំជម្រះបដិសេធសំណុំរឿងប្រឆាំង មាស មុត ដោយសារ អ.វ.ត.ក ពុំមានយុត្តាធិការលើរូបគាត់ទេ[331]។

---

[329] *សូមមើល* ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (D308/3) កថាខណ្ឌ ៣០៦-៣១១។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៨២-៩២។

[330] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦។

[331] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧៥។

១៧៩. នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាបឋម សហព្រះរាជអាជ្ញាជាតិ បានបង្ហាញអង្គហេតុ និងអង្គច្បាប់នានាពាក់ព័ន្ធនឹងសំណុំរឿង[332] និងបានផ្តល់ "ការយល់ឃើញ" របស់ខ្លួន ថា (១) មាស មុត "រួចផុតពីការទទួលខុសត្រូវ"[333] និងថា (២) គាត់មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ("ការមិនអាចអនុវត្តយុត្តាធិការបុគ្គល")[334]។ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គបុរេជំនុំជម្រះនៅពេលសវនាការលើបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាជាតិបានបញ្ជាក់បន្ថែមថា កំហុសជាក់លាក់ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនគឺការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលជាកំហុសលើអង្គច្បាប់[335]។

១៨០. ជាពិសេសទៅទៀត ជាបឋម សហព្រះរាជអាជ្ញាជាតិបានលើកជាទឡ្ហីករណ៍ថា មាស មុត រួចផុតពីការទទួលខុសត្រូវ ដោយសារគាត់គ្រាន់តែអនុវត្តទៅតាមគោលនយោបាយ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះ[336]។ នៅក្នុងចំណុចនេះ សហព្រះរាជអាជ្ញាជាតិលើកឡើងថា ស្ថាប័នដែលមានឥទ្ធិពលបំផុតនៃថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យគឺគណៈកម្មាធិការមជ្ឈិម ដែលធ្វើ "សេចក្តីសម្រេចលើការងារសំខាន់ៗ"[337] ចំណែកឯគណៈកម្មាធិការអចិន្ត្រៃយ៍វិញមានសិទ្ធិអំណាចលើការសម្រេចនានា និងដើរ "តួនាទីដ៏សំខាន់" ក្នុងការដឹកនាំការងារប្រចាំថ្ងៃជំនួសគណៈកម្មាធិការមជ្ឈិម[338]។ គាត់បានបន្ថែមថា គោលនយោបាយបោសសម្អាតដែលបានស្តែងឡើងតាមរយៈសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលចែងថា ការបោសសម្អាតនៅថ្នាក់ភូមិភាគត្រូវសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគ[339]។ គោលនយោបាយនេះតម្រូវឲ្យកម្មាភិបាលធ្វើតាម បើមិនធ្វើតាម ពួកគេនឹងរងការបោសសម្អាតមិនខាន[340]។ មានការចោទប្រកាន់ថា ការបង្ក្រាបនេះចាប់ផ្តើម

[332] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ១៤-៥៥។

[333] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៦-៦០, ៧៥។

[334] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦១-៧៥។

[335] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ (D266/16.1 និង D267/21.1) at ERN (EN) 01639983-01639984, ទំព័រ (ភាសាអង់គ្លេស) 21:20-21:23។

[336] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៦-៦០។

[337] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៧។

[338] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៧។

[339] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៦។

[340] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៩។

ដោយការចាប់ខ្លួនមេដឹកនាំភូមិភាគមួយចំនួនយកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១[341]។ ការបង្ក្រាបនេះ កាន់តែរាលដាលលាតសន្ធឹងទូទាំងប្រទេស ជាពិសេសក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៦ ហើយស្រប ពេលដែលពាក្យ "ខ្មាំង" ត្រូវបានពង្រីកន័យ និងប្រើយ៉ាងទូលំទូលាយ[342]។ គាត់អះអាងថា បើសិននរណា ម្នាក់ត្រូវបានចោទថាជាខ្មាំង អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោលមិនខាន[343]។

១៨១. ទីពីរ សហព្រះរាជអាជ្ញាជាតិលើកឡើងថា មាស មុត មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ អ.វ.ត.ក ទេ ដោយសារគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាអ្នកទទួល ខុសត្រូវខ្ពស់បំផុត អនុលោមទៅតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងស្មារតីនៃច្បាប់ អ.វ.ត.ក ដែលតម្រូវឱ្យតុលាការត្រូវធ្វើការស៊ើបអង្កេត និងកាត់សេចក្តីតែចំពោះមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុស ត្រូវខ្ពស់បំផុតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ[344]។ ជាពិសេសទៅទៀត សហព្រះរាជអាជ្ញាជាតិ លើកជាទឡ្ហីករណ៍ថា ដូចតុលាការ ICTY តុលាការ ICTR និងតុលាការ SCSL ដែរ អ.វ.ត.ក មិនមែនជា តុលាការអចិន្ត្រៃយ៍ទេ[345] ហើយថា "ការកម្រិតទៅលើវិសាលភាពនៃយុត្តាធិការបុគ្គល" គឺជា "វិធីសាស្ត្រ មួយដែលអាចទទួលយកបាន" សម្រាប់កំណត់អំពីអាណត្តិការងាររបស់ អ.វ.ត.ក[346]។ គាត់បន្ថែមថា ក្នុង នាមជា "ស្ថាបនិកនៃ [កិច្ចព្រមព្រៀង]" រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុង "ដើរតួដូចក្រុមប្រឹក្សាសន្តិសុខអង្គ ការសហប្រជាជាតិ ដែលក្រុមប្រឹក្សានេះបានអនុវត្តចំពោះតុលាការ ICTY, ICTR និង SCSL"[347] អាចមាន ឥទ្ធិពលទៅលើការកំណត់អំពីអាណត្តិការងាររបស់ អ.វ.ត.ក[348]។ គាត់អះអាងថា "ឥទ្ធិពលលើវិសាលភាព យុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ" ដែល "ស្ថាបនិកតុលាការអន្តរជាតិ" អាចមានគឺ "ដោយមិនធ្វើ ឱ្យប៉ះពាល់ដល់អនាគតិ និងឯករាជភាពរបស់តុលាការឡើយ"[349]។ ដោយផ្អែកលើមូលដ្ឋាននេះ គាត់បញ្ជាក់

---

341 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥៩។

342 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦០។

343 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦០។

344 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦១-៧៥។

345 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦១។

346 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៣, ៦៧។

347 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៧។ សូមមើល ផងដែរ កថាខណ្ឌ ៦៥។

348 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៣, ៦៧។

349 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៧។

ច្បាស់នូវការយល់ដឹងរបស់រដ្ឋាភិបាលកម្ពុជាចំពោះពាក្យ "មេដឹកនាំជាន់ខ្ពស់"[350] និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[351] ដែលកំណត់អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក និងជំរុញឱ្យអង្គបុរេជំនុំជម្រះ "ធ្វើសកម្មភាពស្របតាមការកំណត់ [របស់រដ្ឋាភិបាលកម្ពុជា]" ចំពោះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[352]។

១៨២. នៅក្នុងចំណុចនេះ សហព្រះរាជអាជ្ញាជាតិលើកជាទឡ្ហីករណ៍បន្ថែមថា ស្របទៅតាមការទទួលស្គាល់របស់អង្គការសហប្រជាជាតិថា ត្រូវមានតុល្យភាព "រវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ"" ដោយចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដែលមានបុព្វកថាលើកឡើងអំពី "ការព្រួយបារម្ភពេញច្បាប់" របស់រដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា "ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"[353] កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក មានគោលបំណងកំណត់បុគ្គលតែពីរប្រភេទប៉ុណ្ណោះគឺ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលត្រូវយកមកកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មនៅសម័យខ្មែរក្រហម[354]។

១៨៣. ចុងក្រោយ សហព្រះរាជអាជ្ញាជាតិលើកឡើងថា "ការពង្រីកវិសាលភាពពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល [របស់ អ.វ.ត.ក] ទៅលើ មាស មុត លើសពីវិសាលភាពនៃ [...] សំណុំរឿង ០០១ និង០០២ នឹងអូសបន្លាយពេល និងចំណាយថវិកាដោយមិនចាំបាច់"[355]។ គាត់អះអាងថា "ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការឈឺចាប់របស់ជនរងគ្រោះដែលនៅរស់រានមានជីវិត និងយុត្តិធម៌សម្រាប់ជនរងគ្រោះ អាចទទួលយកបានហើយ តាមរយៈការជំនុំជម្រះសំណុំរឿងលេខ ០០១ និង០០២"[356] ដោយសារសំណុំរឿងទាំងពីរនេះគឺជា "តំណាងយ៉ាងពេញលេញ" ចំពោះវិសាលភាពនៃ

---

350 ត្រូវបានយល់ឃើញថា គ្របដណ្តប់តែទៅលើបុគ្គលមួយចំនួនតូច ដែលជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងសមាជិកសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សតែប៉ុណ្ណោះ។ សូមមើល បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៨។

351 ត្រូវបានយល់ឃើញថា សំដៅទៅតែលើ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ ម្នាក់គត់។ សូមមើល បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៨-៧០។

352 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៧។ សូមមើល ផងដែរ កថាខណ្ឌ ៦៨-៧៣។

353 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧១។

354 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧២។

355 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧៣។

356 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧៣។

ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយឡើងនៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ និងអាណត្តិការងាររបស់ អ.វ.ត.ក[357]។

១៨៤. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិបង្ហាញនូវទឡ្ហីករណ៍ដែលមិនបំពេញតាមបទដ្ឋាននៃការត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍ទេ[358] និង/ឬ ថា មិនគួរឱ្យជឿជាក់បាន[359] និងបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការបដិសេធបណ្តឹងឧទ្ធរណ៍ចោល តម្កល់ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងនាមជាបុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងបញ្ជូនសំណុំរឿងប្រឆាំងនឹងគាត់ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[360]។

១៨៥. ជាបឋម សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិមិនបានបំពេញតាមបទដ្ឋាននៃការត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍ទេ ដោយសារបណ្តឹងឧទ្ធរណ៍មិនបានលើកឡើងនូវមូលដ្ឋានពាក់ព័ន្ធនៃបណ្តឹងឧទ្ធរណ៍ដែលបង្ហាញពីកំហុសលើអង្គច្បាប់ និង/ឬ កំហុសឆ្គងលើអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយពន្យល់ពីមូលហេតុដែលកំហុសទាំងនេះធ្វើឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំមានសុពលភាព និង/ឬ បណ្តាលឱ្យមានភាពអយុត្តិធម៌ និង/ឬ តើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយរបៀបណា នោះទេ[361]។ គាត់បានគូសបញ្ជាក់ថា បណ្តឹងឧទ្ធរណ៍ពុំមានទឡ្ហីករណ៍ពាក់ព័ន្ធនឹងមូលហេតុដែលនាំឱ្យសហ

---

[357] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ (D266/18.2 និង D267/23.2) at ERN (EN) 01640007, ទំព័រ (ភាសាអង់គ្លេស) 36:09-36:13។

[358] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៤, ៥-១៤។

[359] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៤, ១៥-៤១។

[360] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៤២។

[361] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៤-៦។

ចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គង ក្នុងការធ្វើសេចក្ដីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ទេ[362]។ គាត់បន្ថែមថា អំណះអំណាងលើអង្គហេតុដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាជាតិ ទាក់ទិននឹងតួនាទី និងសិទ្ធិអំណាចរបស់ មាស មុត គ្រាន់តែស្វែងរកឲ្យមានការបកស្រាយមួយផ្សេងលើភស្តុតាងនោះប៉ុណ្ណោះ[363]។

១៨៦. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងបន្ថែមថា អំណះអំណាងតាមផ្លូវច្បាប់របស់សហព្រះរាជអាជ្ញាជាតិទាក់ទិននឹងវិសាលភាពនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មិនគួរឲ្យជឿជាក់បានទេ[364]។ ផ្អែកលើមូលដ្ឋាននេះ គាត់អះអាងថា សហព្រះរាជអាជ្ញាជាតិមិនបានបំពេញកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងនៅក្នុងបណ្ដឹងឧទ្ធរណ៍នោះទេ ហើយថា អង្គបុរេជំនុំជម្រះអាចបដិសេធបណ្ដឹងឧទ្ធរណ៍ ដោយពុំចាំបាច់យកមកពិនិត្យឡើយ[365]។

១៨៧. ពាក់ព័ន្ធនឹង "ទឡ្ហីករណ៍មិនត្រឹមត្រូវ" របស់សហព្រះរាជអាជ្ញាជាតិ ស្ដីពីវិសាលភាពនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះ ទោះបីសហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ថា កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក កម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រឹមតែ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[366] ហើយថា បញ្ហាចំនួនបុគ្គលដែលត្រូវយកមកកាត់សេចក្ដីដោយ អ.វ.ត.ក ត្រូវបានយកមកពិភាក្សាយ៉ាងខ្លាំងក្លា មុនពេលអនុម័តច្បាប់ អ.វ.ត.ក ដោយរដ្ឋសភាកម្ពុជា[367] ក្ដី តែគាត់អះអាងថា ការយល់ដឹងរបស់សហព្រះរាជអាជ្ញាជាតិចំពោះ "អ្នកទទួលខុស

---

362 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៧, ១៣។

363 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៧។

364 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ១៥-៤១។

365 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៦-៧, ១៣ និងជើងទំព័រយោងលេខ ១៣-១៤, ១៧-១៩, ៥៥។

366 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ១៦។

367 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ១៩។

01667376



ត្រូវខ្ពស់បំផុត" មិនត្រូវបានគាំទ្រដោយការបកស្រាយទៅលើពាក្យពេចន៍ធម្មតា[368] ផ្ទុយពីសេចក្តីថ្លែងការណ៍នានារបស់មន្ត្រីនៃរដ្ឋាភិបាលកម្ពុជា[369] និងខុសពីការយល់ដឹងរបស់អង្គការសហប្រជាជាតិចំពោះប្រភេទរបស់ចារី[370]។ គាត់លើកជាទឡ្ហីករណ៍បន្ថែមថា ប្រវត្តិនៃការចរចាបង្កើត អ.វ.ត.ក បង្ហាញថា ទាំងភាគីរដ្ឋាភិបាលកម្ពុជា និងភាគីអង្គការសហប្រជាជាតិមានចេតនាទុកឱ្យពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" នៅតែជាប្រភេទបើកចំហដែលត្រូវកំណត់ដោយតុលាការ[371]។ គាត់កត់សម្គាល់ថា ការយល់ដឹងនេះត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ និងគាំទ្រដោយសហចៅក្រមស៊ើបអង្កេតជាតិនៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤/១ និង សំណុំរឿង ០០៤/២[372]។

១៨៨. ពាក់ព័ន្ធនឹងការប្រៀបធៀបមិនស៊ីជម្រៅរបស់សហព្រះរាជអាជ្ញាជាតិ អំពីតួនាទីរបស់រដ្ឋាភិបាលកម្ពុជា ទៅនឹងតួនាទីរបស់ក្រុមប្រឹក្សាសន្តិសុខជាមួយតុលាការ ICTY តុលាការ ICTR និងតុលាការ SCSL[373] វិញ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា កិច្ចព្រមព្រៀងត្រូវបានអនុម័តដោយភាគីទាំងពីរ គឺអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីការចរចាដែលភាគីទាំងពីរជាអ្នកចូលរួមយ៉ាងស្មើភាពគ្នា[374] ហើយថា មាត្រា ២(៣) នៃកិច្ចព្រមព្រៀងចែងច្បាស់ថា រាល់ការធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក តម្រូវឱ្យមានការពិគ្រោះយោបល់ជាមុនរវាងភាគីទាំងពីរ និងអនុម័តដោយភាគីទាំងពីរ[375]។ ហេតុនេះ

---

[368] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ១៦-១៧។

[369] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣) D267/9 ,កថាខណ្ឌ ១៦ (១៨-១៩២២ ,-២៣។

[370] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ១៦, ២០-២៣។

[371] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៣។

[372] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៣។

[373] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៤-២៦។

[374] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៧។

[375] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿង

01667377



គាត់អះអាងថា ទាំងភាគីរដ្ឋាភិបាលកម្ពុជា ទាំងភាគីអង្គការសហប្រជាជាតិមិនអាចធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងជាឯកតោភាគីបានទេ។ សហព្រះរាជអាជ្ញាអន្តរជាតិសង្កេតឃើញថា មកទល់នឹងពេលនេះពុំមានភាគីណាមួយស្នើសុំដកចេញពីកិច្ចព្រមព្រៀង ឬធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិនៃច្បាប់ អ.វ.ត.ក ពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក ទេ[376]។ គាត់បន្ថែមថា គម្រោងបញ្ចប់ផែនការរបស់តុលាការ ICTY និងតុលាការ ICTR មិនអាចផ្លាស់ប្តូរកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មនានានៅក្នុងយុត្តាធិការរបស់សាលាក្តីទាំងនេះបានឡើយ[377]។ ជាងនេះទៀត គាត់បានចង្អុលបង្ហាញថា ក្រុមប្រឹក្សាសន្តិសុខគោរពដល់ឯករាជភាពផ្នែកតុលាការរបស់សាលាក្តីមិនអចិន្ត្រៃយ៍ ដោយមិនសម្តែងមតិនានាទៅលើការសម្រេចសេចក្តីនៅក្នុងសំណុំរឿងនានានៅតុលាការ ICTY និងតុលាការ ICTR ទេ[378]។ ត្រង់ចំណុចនេះ គាត់កត់សម្គាល់ថា លក្ខខណ្ឌតម្រូវឱ្យមានស្ថាប័នតុលាការឯករាជ្យ មានកំណត់នៅក្នុងមាត្រា ៣(៣) នៃកិច្ចព្រមព្រៀង និងមាត្រា ១០ថ្មី នៃច្បាប់ អ.វ.ត.ក ដែលចែងថា ចៅក្រមនៅ អ.វ.ត.ក ត្រូវតែឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ[379] ហើយត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[380] លិខិតុបករណ៍អន្តរជាតិជាច្រើនទៀត[381] និងគោលការណ៍នីតិរដ្ឋដែលគ្រប់គ្រងការបែងចែកដាច់ពីគ្នារវាងស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នតុលាការ[382]។

---

ទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៧។

376 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៧-២៨។

377 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៩។

378 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ២៩។

379 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣០។

380 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣១។

381 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣១។

382 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿង

១៨៩. ចំណុចចុងក្រោយ ចំពោះ "ការអះអាងដែលមិនគួរឱ្យជឿជាក់បាន" របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងការផ្សះផ្សាជាតិ និងការស្វែងរកយុត្តិធម៌តាមរយៈសំណុំរឿង ០០១ និង ០០២[383] សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា គណនេយ្យភាព និងការផ្សះផ្សា តាមពិត ជាការបំពេញបន្ថែម និងជាគន្លឹះក្នុងការធានាស្ថិរភាព[384] ហើយបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ មិនផ្តល់ភស្តុតាងបង្ហាញថា ការបញ្ជូន មាស មុត ទៅជំនុំជម្រះ នឹងរារាំងដល់ការផ្សះផ្សាជាតិ[385]។ លោកស្រីលើកទឡ្ហីករណ៍ថា ផ្ទុយមកវិញ ការជំនុំជម្រះលើរូបគាត់អាចជួយសម្រេចបានយុត្តិធម៌ខ្លះ និងលើកកម្ពស់ការផ្សះផ្សាជាតិ[386]។ ចំពោះបញ្ហានេះ សហព្រះរាជអាជ្ញាអន្តរជាតិសង្កត់ធ្ងន់ថា មិនមានប្រតិកម្មអវិជ្ជមានជាសាធារណៈណាមួយចំពោះសេចក្តីប្រកាសថា មាស មុត កំពុងត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ[387] ហើយ បច្ចុប្បន្ន មិនមានក្រុមប្រដាប់អាវុធអនុវត្តអំណាចលើទឹកដីកម្ពុជានោះទេ[388]។ លោកស្រីចង្អុលបញ្ជាក់បន្ថែមទៀតថា សំណុំរឿង ០០៣ លើកឡើងអំពីបញ្ហា និងទីតាំងឧក្រិដ្ឋកម្ម ដែលមិនមែនជាកម្មវត្ថុនៃសំណុំរឿង ០០១ សំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២[389]។ លោកស្រីសន្និដ្ឋានដោយសំអាងលើការសិក្សា[390] និង

---

ទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣២។

[383] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៣-៤១។

[384] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៤។

[385] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៣។

[386] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៣។

[387] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៥។

[388] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៥។

[389] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៤០។

[390] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៣៦-៣៩។

ចំនួនបុគ្គល ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣[391] ថា មាន "ការចង្អុលបង្ហាញយ៉ាងរឹងមាំ" ថា ជនរងគ្រោះ និងសាធារណជន មានចំណាប់អារម្មណ៍ខ្លាំងចង់ស្ដាប់ការពិតអំពីឧក្រិដ្ឋកម្ម ដែលបានលើកឡើងនៅក្នុងរឿងក្ដីនេះ និងចង់មើលឃើញការជំនុំជម្រះនេះដំណើរការទៅមុខ[392]។

## ខ. ការពិភាក្សា

១៩០. ចៅក្រមអន្តរជាតិសូមរំលឹកថា ទោះបីជាសហព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងរាល់ដីកា ដែលចេញដោយសហចៅក្រមស៊ើបអង្កេតក៏ដោយ[393] ក៏វិធាន ៧៥(៤) កំណត់ថា "ការដាក់សារណាបណ្ដឹងឧទ្ធរណ៍ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ ដោយមានភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងនោះ"។ ចំពោះបញ្ហានេះ សហចៅក្រមអន្តរជាតិសូមបញ្ជាក់សាជាថ្មីថា អង្គបុរេជំនុំជម្រះអាចបដិសេធភ្លាមៗនូវសេចក្ដីសន្និដ្ឋាន ដែលមិនបំពេញតាមបទដ្ឋាន ដែលបានបង្កើតឡើងសម្រាប់ការពិចារណាលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍[394]។ ពាក់ព័ន្ធនឹងចំណុចនេះដែរ ចៅក្រមអន្តរជាតិគួសបញ្ជាក់ថា មិនខុសពីអង្គជំនុំជម្រះតុលាការកំពូលព្រហ្មទណ្ឌអន្តរជាតិ និងកូនកាត់ដទៃទៀត អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិជ្រើសរើសសេចក្ដីសន្និដ្ឋានទាំងឡាយណា ដែលត្រូវបង្ហាញមតិយោបល់ជាមួយនឹងហេតុផលលម្អិតជាលាយលក្ខណ៍អក្សរ និងសេចក្ដីសន្និដ្ឋានណា ដែលនឹងត្រូវ

[391] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ (D267/9) កថាខណ្ឌ ៤០។

[392] សហមេធាវីរបស់ មាស មុត ពុំបានដាក់ចម្លើយតបទេ។ សហព្រះរាជអាជ្ញាជាតិពុំបានដាក់ការឆ្លើយតបទេ។

[393] *សូមមើល ខាងលើ* កថាខណ្ឌ ៥១, ៥៣ ដែលយោងទៅវិធាន ៦៧(៥) ៧៣(ក) និង ៧៤(២) នៃវិធានផ្ទៃក្នុង។

[394] សំណុំរឿង ០០៤/២, សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៦៤៩ និង ជើងទំព័រយោងលេខ ១៣៤៥ *ដែលយោងទៅ*សំណុំរឿង ០០២ (អ.ប.ជ៤៧), សាលដីកាលើបណ្ដឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០, ឯកសារ D250/3/2/1/5 ("ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២ (D250/3/2/1/5)") កថាខណ្ឌ ២២ *ដែលសំអាងទៅ*តុលាការ ICTY, រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *BlaĖkić*, សំណុំរឿង, ICTY-IT-95-14-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ ("សាលដីកា *BlaĖkić* (ICTY)") កថាខណ្ឌ ១៣។ តុលាការ ICTR, រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Rutaganda*, សំណុំរឿង, ICTR-96-3-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ("សាលដីកា *Rutaganda* (ICTR)") កថាខណ្ឌ ១៨។

បដិសេធដោយមិនបង្អង់ ដោយពុំចាំបាច់ផ្តល់ហេតុផលលម្អិតបែបនេះ[395]។ ចៅក្រមអន្តរជាតិយល់ថា វាពាក់ព័ន្ធដែលត្រូវរំលឹកឡើងវិញនូវលក្ខណៈវិនិច្ឆ័យដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលជាគោលការណ៍ណែនាំសម្រាប់ការសម្រេចនេះ។

១៩១. ជាគោលការណ៍ទូទៅ បណ្តឹងឧទ្ធរណ៍មិនអាចត្រូវបានអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះទាយស្មាននោះទេ[396] ដែលនឹងមិនពិចារណាទទឹ្ករណី ដោយគ្រាន់ត្រឹមតែអះអាងថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬ ការរកឃើញនោះ មានកំហុស ដោយគ្មានផ្តល់មូលហេតុច្បាស់លាស់ថាហេតុអ្វីដីកាសម្រេច ឬការរកឃើញនោះមានកំហុសនោះឡើយ[397]។ ចំណុចនេះមានន័យថា ភាគីដែលអះអាងថា សហចៅក្រមស៊ើបអង្កេត មាមកំហុសអង្គច្បាប់ ឬ អង្គហេតុ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីកំហុសដូចបានចោទប្រកាន់

[395] *សូមមើល ឧទា.* យន្តការអន្តរជាតិនៅសេសសល់សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("MICT") *រដ្ឋអាជ្ញា ទល់នឹង Karadžić*, សំណុំរឿងលេខ MICT-13-55-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ("សាលដីកា *Karadžić* (MICT)") កថាខណ្ឌ ២០។ តុលាការ MICT, រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង ËeĖelj*, សំណុំរឿងលេខ MICT-16-99-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ("សាលដីកា *ËeĖelj* (MICT)") កថាខណ្ឌ ១៨។ តុលាការ ICTY, រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ IT-04.74-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ("សាលដីកា *Prlić* (ICTY)") កថាខណ្ឌ ២៤។ តុលាការ ICTR, រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ ICTR-98-42-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកា *Prlić* (ICTY)") កថាខណ្ឌ ៣៥, ១៧៩៩។ សាលដីកា *Rutaganda* (ICTR) កថាខណ្ឌ ១៩។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ("SCSL") រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Taylor*, សំណុំរឿងលេខ SCSL-03-01-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ("សាលដីកា *Taylor* (SCSL)") កថាខណ្ឌ ៣១។ តុលាការ SCSL, រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Sesay និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ SCSL-04.15-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ ("សាលដីកា *Sesay* (SCSL)") កថាខណ្ឌ ៣៦។ តុលាការពិសេសសម្រាប់ប្រទេសឡេបាណន់ ("STL") រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Al Jadeed និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ STL-14-05/A/AP, សាលដីកាលើបណ្តឹងឧទ្ធរណ៍, ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៦ ("សាលដីកា *Al Jadeed* (STL)") កថាខណ្ឌ ១៨។ *សូមមើល ផងដែរ* តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Lubanga*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សំណុំរឿងលេខ ICC-01/04-01/06-3122, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងលោក Thomas Lubanga Dyilo ប្រឆាំងនឹង "សេចក្តីសម្រេចលើការផ្តន្ទាទោស អនុលោមតាមមាត្រា ៧៦ នៃលក្ខន្តិកៈ", ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ ("សាលដីកា *Lubanga* (ICC))") កថាខណ្ឌ ៣០។

[396] តុលាការ ICTY, រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង KupreĖkic និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ IT-95-16-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ ("សាលដីកា *KupreĖki* (ICTY)") កថាខណ្ឌ ២៧។

[397] សាលដីកាលើសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ១០២។

និងបង្ហាញទឡ្ហីករណ៍គាំទ្រការអះអាងនោះ[398]។ ភាពចាំបាច់ត្រូវបង្ហាញមូលដ្ឋានសំអាង អាស្រ័យលើប្រភេទនៃកំហុសដូចបានចោទប្រកាន់។ ចំពោះកំហុសអង្គច្បាប់ដែលត្រូវបានចោទប្រកាន់ ភាគីត្រូវបង្ហាញមូលដ្ឋានថាតើសហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយដោយមិនត្រឹមត្រូវយ៉ាងដូចម្តេច[399]។ ទាក់ទងនឹងកំហុសអង្គហេតុដូចបានចោទប្រកាន់ យ៉ាងហោចណាស់ ភាគីត្រូវរកឱ្យឃើញនូវសំអាងហេតុ ដែលត្រូវបានជំទាស់[400]។ ដោយមិនគិតពីប្រភេទនៃកំហុស ដែលត្រូវបានចោទប្រកាន់ ភាគីត្រូវបង្ហាញអំពីរបៀបដែលកំហុសនេះប៉ះពាល់ផ្នែកសម្ភារៈដល់ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតតាមវិធីណា[401] និងផ្តល់ឯកសារយោងលើកថាខណ្ឌពាក់ព័ន្ធនៅក្នុងដីកាសម្រេចដែលរងការជំទាស់[402]។ ក្នុងករណីភាគីណាមួយគ្រាន់តែមានបំណងយកការវាយតំលៃរបស់ខ្លួនផ្ទាល់លើភស្តុតាង ទៅជំនួសការវាយតម្លៃលើភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេត សេចក្តីសន្និដ្ឋានបែបនេះអាចត្រូវបានច្រានចោលភ្លាមៗដោយអង្គបុរេជំនុំជម្រះ[403]។ ស្រដៀងគ្នានេះ ទឡ្ហីករណ៍ទាំងឡាយ ដែលមិនមានអានុភាពជម្រុញឲ្យច្រានចោល ឬ កែប្រែដីកា

[398] សាលដីកា *KupreÈkic* (ICTY) កថាខណ្ឌ ២៧។ សាលដីកា *Al Jadeed* (STL), កថាខណ្ឌ ១៩។ សាលដីកា *Lubanga* (ICC) ១៩។ សាលដីកា *Lubanga* (ICC) កថាខណ្ឌ ៣០។

[399] *សូមមើល ឧទា.* សាលដីកា *Lubanga* (ICC) កថាខណ្ឌ ៣១។

[400] *សូមមើល ឧទា.* សាលដីកា *Prlić* (ICTY) កថាខណ្ឌ ២៥។ តុលាការ ICTY, រដ្ឋអាជ្ញា ទល់នឹង *StaniÈić* និង *Župljanin*, សំណុំរឿងលេខ IT-08-91-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ("សាលដីកា *StaniÈić* និង *Župljanin* (ICTY)") កថាខណ្ឌ ២៥។ តុលាការ ICTY, រដ្ឋអាជ្ញា ទល់នឹង *StaniÈić* និង *Simatović*, សំណុំរឿងលេខ IT-03-69-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកា *StaniÈić* និង *Simatović* (ICTY)") កថាខណ្ឌ ២២។ សាលដីកា Taylor (SCSL)") កថាខណ្ឌ ៣១។ សាលដីកា *Sesay.* (SCSL) កថាខណ្ឌ ៣៨។ សាលដីកា (STL) កថាខណ្ឌ ១៨។

[401] *សូមមើល ឧទា.* សាលដីកា *Taylor* (SCSL)") កថាខណ្ឌ ៣១។ សាលដីកា *Sesay.* (SCSL) កថាខណ្ឌ ៤១។ សាលដីកា Lubanga (ICC) កថាខណ្ឌ ៣០។

[402] ដីកាសម្រេចលើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D250/3/2/1/5) កថាខណ្ឌ ២២ ដែលយោងទៅសាលដីកា *BlaÈkić* (ICTY) កថាខណ្ឌ ១៣។ សាលដីកា *Rutaganda* (ICTR) កថាខណ្ឌ ១៨។

[403] តុលាការ ICTY, រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *KrajiÈnik*, សំណុំរឿងលេខ IT-00-39-A, កថាខណ្ឌ ២៧។ តុលាការ ICTY, រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Krnojelac*, សំណុំរឿងលេខ IT-97-25-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣, កថាខណ្ឌ ២២។ តុលាការ ICTY, រដ្ឋអាជ្ញា ទល់នឹង *Simić*, សំណុំរឿងលេខ IT-95-9-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៦, កថាខណ្ឌ ១៤។ តុលាការ ICTY, រដ្ឋអាជ្ញា ទល់នឹង *Halilović*, សំណុំរឿងលេខ IT-01-48-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧, កថាខណ្ឌ ១២។ សាលដីកា *Taylor* (SCSL) កថាខណ្ឌ ៣១។ សាលដីកា *Sesay* (SCSL), កថាខណ្ឌ ៤០។

សម្រេច អាចត្រូវបានច្រានចោលដោយពុំចាំបាច់វិភាគលើអង្គសេចក្តីនោះទេ[404]។

១៩២. អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិមិនបំពេញតាមបទដ្ឋានអប្បបរមានៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ ដោយអង្គបុរេជំនុំជម្រះ ហេតុដូច្នេះសូមច្រានចោលបណ្តឹងឧទ្ធរណ៍នេះទាំងស្រុងដោយមិនបង្អង់។ បណ្តឹងឧទ្ធរណ៍ត្រូវបានភាន់ច្រឡំដោយសារវាពុំបានផ្តល់ការណែនាំអំពីវិធីអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តីនេះ ដើម្បីច្រានចោល និង/ឬ កែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ចៅក្រមអន្តរជាតិសង្កេតឃើញថា បណ្តឹងឧទ្ធរណ៍របស់លោកស្រីកម្រិតត្រឹមតែការអះអាងអង្គហេតុទូទៅអំពីសាវតាប្រវត្តិសាស្ត្រ និងបរិបទរួមនៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ[405] ហើយនឹងការលើកឡើងយោបល់របស់លោកស្រីសាជាថ្មីអំពីអត្ថន័យនៃពាក្យថា"មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[406] ដោយមិនមានមូលដ្ឋានបញ្ជាក់ ឬ មិនបានព្យាយាមបញ្ជាក់មូលហេតុ ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឬ ការរកឃើញថា មាស មុត ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មានកំហុស។ ចៅក្រមអន្តរជាតិរកឃើញថា គ្មានមូលដ្ឋានណាមួយនៅក្នុងបណ្តឹងឧទ្ធរណ៍ ដែលអាចឱ្យខ្លួនកែប្រែដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

១៩៣. ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិសូមរំលឹកថា អង្គបុរេជំនុំជម្រះមានអំណាចក្នុងការសម្រេចលើបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់ជាទូទៅ ដើម្បីបង្កើតជាយុត្តាធិការ និងកេរ្តិ៍ដំណែលរបស់

---

[404] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៦៤៩ ដែលយោងទៅដីកាសម្រេចលើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២ (D250/3/2/1/5) កថាខណ្ឌ ២២ ដែលសំអាងលើសាលដីកា *BlaÈkić* (ICTY) កថាខណ្ឌ ១៣។ សាលដីកា *Rutaganda* (ICTR) ១៨។ សូមមើល ផងដែរ សាលដីកាលើសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០។

[405] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៥១-៥៤, ៥៦-៦០។

[406] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៦-៦៨, ៧២។

អ.វ.ត.ក[407] ដែលស្ថិតនៅក្រៅវិសាលភាពនៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ[408]។ អំណាចបែបនេះគឺជាអំណាចឆន្ទានុសិទ្ធិ[409]។ ក្នុងន័យនេះ ចៅក្រមអន្តរជាតិយល់ឃើញថា វាមានពាក់ព័ន្ធត្រូវដោះស្រាយតាមផ្នែក ចំពោះបញ្ហាទាំងពីរ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនពោលគឺ៖ (i) តួនាទី និងអំណាចរបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងព្រំដែននៃវិសាលភាពយុត្តាធិការបុគ្គលរបស់

អ.វ.ត.ក[410] និង (ii) ការអះអាងថា កិច្ចព្រមព្រៀងចុះហត្ថលេខារវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ទាមទារ "ធ្វើឱ្យថ្លឹងថ្លែង" រវាង "យុត្តិធម៌ និងការផ្សះផ្សាជាតិ" សម្រាប់ជនរងគ្រោះក្នុងសំណុំរឿង ០០៣[411]។

១៩៤. ចំណុចទីមួយ ចៅក្រមអន្តរជាតិ សូមរំលឹកថា វិសាលភាពនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ដែលបានចុះហត្ថលេខារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ កិច្ចព្រមព្រៀង អ.វ.ត.ក គឺជាសន្ធិសញ្ញាអន្តរជាតិ ដែលអនុលោមតាមគោលការណ៍នៃ *ការរក្សាតាមការព្រមព្រៀង* ដូចបានកំណត់នៅក្នុងមាត្រា ២៦ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិ

---

[407] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៣២។ សំណុំរឿង ០០៤/១, សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1/20) កថាខណ្ឌ ៧៣ ដែលយោងទៅតុលាការ ICTR, រដ្ឋអាជ្ញា ទល់នឹង *Akayesu*, សំណុំរឿង ICTR-96-4-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ("សាលដីកា *Akayesu* (ICTR)") កថាខណ្ឌ ១៩, ២៣-២៤។ តុលាការ ICTY, រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadić, សំណុំរឿង IT-94-1-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ("សាលដីកា Tadić (ICTY)") កថាខណ្ឌ ២៤៧, ២៨១, ៣១៦។ តុលាការ ICTY, រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Mucić និងជនជាប់ចោទផ្សេងទៀត, សំណុំរឿង IT-96-21-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១, កថាខណ្ឌ ២២១។

[408] សូមមើល ឧទា. សាលដីកា *Tadić* (ICTY) កថាខណ្ឌ ២៤៧។ តុលាការ ICTY, រដ្ឋអាជ្ញា ទល់នឹង *Delalić* និងជនជាប់ចោទផ្សេងទៀត, សំណុំរឿង IT-96-21-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១, ("សាលដីកា *Delalic* (ICTY)") កថាខណ្ឌ ២១៨។ សាលដីកា Akayesu (ICTR)") កថាខណ្ឌ ១៧-១៨។ តុលាការ ICTR, រដ្ឋអាជ្ញា ទល់នឹង *Kanyarukiga*, សំណុំរឿង ICTR-02-78-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២ ("សាលដីកា *Kanyarukiga* (ICTR)"), កថាខណ្ឌ ២៦៥។

[409] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៣៣។ សូមមើល ឧទា. ខាងលើ កថាខណ្ឌ ១២៨។

[410] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៣, ៦៦-៦៨។

[411] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧១-៧៣។

សញ្ញា ("អនុសញ្ញាទីក្រុងវីយែន") ចងភ្ជាប់កាតព្វកិច្ចរវាងគូភាគី ហើយត្រូវអនុវត្តដោយសុទ្ធចិត្ត។ ដូច្នេះ កិច្ចព្រមព្រៀងនេះ "អាចត្រូវបានធ្វើវិសោធនកម្ម*ដោយការព្រមព្រៀងរវាងគូភាគី*"[412]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិពិចារណាថា រាល់ការកែប្រែជាឯកតោភាគីចំពោះកិច្ចព្រមព្រៀង អ.វ.ត.ក ដោយភាគីណាមួយនឹងរំលោភគោលការណ៍នៃ*ការរក្សាតាមការព្រមព្រៀង*។

១៩៥. អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិច្រានចោលការអះអាងរបស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងតួនាទី និងអំណាចរបស់រាជរដ្ឋាភិបាលកម្ពុជា ដែល មិនខុសពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិសម្រាប់តុលាការ ICTY និងតុលាការ ICTR រដ្ឋាភិបាលកម្ពុជាអាចមាន "ឥទ្ធិពលលើវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ"[413]។ ចៅក្រមអន្តរជាតិពិចារណាឃើញថា គ្មានមូលដ្ឋានច្បាប់ណាមួយ ដែលក្នុងនាមជាភាគីម្ខាងនៃកិច្ចព្រមព្រៀង រដ្ឋាភិបាលកម្ពុជាអាចជាកំណត់ឡើងវិញជាឯកតោភាគីលើអត្ថន័យនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬ បង្ហាញ "ឥទ្ធិពល" របស់ខ្លួនលើមុខងារឯករាជ្យរបស់តុលាការនេះឡើយ[414]។ ការចង្អុលយោងរបស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងប្រវត្តិនៃការចរចាររបស់ អ.វ.ត.ក[415] គ្រាន់តែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់គាត់ប៉ុណ្ណោះ ដូច្នេះមិនបានផ្តល់មូលដ្ឋានសំខាន់ដែលគួរឱ្យជឿជាក់បានសម្រាប់បកស្រាយកិច្ចព្រមព្រៀង និង ច្បាប់ អ.វ.ត.ក ឡើយ ជាពិសេស ក្នុងគោលបំណងបែងចែកឱ្យដាច់លើវិសាលភាពនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[416]។

១៩៦. ចំណុចទីពីរ ចៅក្រមអន្តរជាតិសង្កេតឃើញថា បុព្វហេតុនៃកិច្ចព្រមព្រៀងចែងថា "មហាសន្និបាត[អង្គការសហប្រជាជាតិ] បានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ"។ ដោយពិចារណាលើអត្ថន័យត្រង់ នៃអត្ថបទ ចៅក្រមអន្តរជាតិយល់ឃើញថា ប្រយោគនេះកំណត់គោលដៅដូចបានរៀបរាប់ទាំងអស់ ដោយឈរលើគោលការណ៍សមភាពជាជាងការទាមទារចង់ឱ្យថ្លឹងថ្លែងឱ្យបានស្មើគ្នាលើគោលដៅ

---

412 អនុសញ្ញាទីក្រុងវីយែន, មាត្រា ៣៩ (មានសេចក្តីបញ្ជាក់បន្ថែម)

413 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៧។

414 *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET, កថាខណ្ឌ ៦៥២។

415 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៦៨។

416 *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET, កថាខណ្ឌ ៦៥២។

ចំនួនពីរ ដែលបានជ្រើសរើសតាមអំពើចិត្ត។ ដូច្នេះ ចៅក្រមអន្តរជាតិពុំជឿលើការអះអាងរបស់សហព្រះរាជអាជ្ញាជាតិថា កិច្ចព្រមព្រៀងនេះ យោងតាមប្រយោគនៅក្នុងបុព្វកថា តម្រូវឱ្យ "ធ្វើការថ្លឹងថ្លែង" រវាងយុត្តិធម៌ និងការផ្សះផ្សាជាតិនោះទេ។ តាមទស្សនៈរបស់ចៅក្រមអន្តរជាតិ យុត្តិធម៌ និងការផ្សះផ្សាជាតិ គឺជាគោលដៅផ្ទុយគ្នា។ ផ្ទុយទៅវិញ យុត្តិធម៌ត្រូវបានចាត់ទុកថាជាលក្ខខណ្ឌចាំបាច់សម្រាប់ការផ្សះផ្សាជាតិ[417]។ ទោះបីការអះអាងបែបនេះរបស់សហព្រះរាជអាជ្ញាជាតិមានមូលដ្ឋានខ្លះក៏ដោយ ក៏ចៅក្រមអន្តរជាតិមិនជឿជាក់ឡើយថា ការថ្លឹងថ្លែងរវាងយុត្តិធម៌ និងការបង្រួបបង្រួមជាតិ[418] នឹងសម្រេចទៅតាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិដែលថា "យុត្តិធម៌ជាសមូហភាព" ត្រូវបានផ្ដល់ជូនជនរងគ្រោះក្នុងសំណុំរឿង ០០៣ តាមរយៈការជំនុំជម្រះក្ដីលើសំណុំរឿង ០០១ និង០០២[419] ដោយសាររឿងក្ដីទាំងនេះ គឺជា "តំណាងពេញលេញ" នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[420]។

១៩៧. ចៅក្រមអន្តរជាតិសូមរំលឹកថា មាស មុត ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ដែល

---

[417] *សូមមើល* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33មតិយោបល់លោកចៅក្រម BAIK and BEAUVALLET, កថាខណ្ឌ ៦៥៤។ របាយការណ៍របស់លោកអគ្គលេខាធិការស្ដីពីនីតិរដ្ឋ និងយុត្តិធម៌អន្តរកាលនៅក្នុងសង្គមដែលមានជម្លោះ និងក្រោយជម្លោះ, ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤, ឯកសារ UN Doc. S/2004/616, កថាខណ្ឌ ៧ ("សម្រាប់អង្គការសហប្រជាជាតិ , 'យុត្តិធម៌" គឺជាគំនិតនៃការទទួលខុសត្រូវ និងភាពត្រឹមត្រូវ នៅក្នុងការការពារ និងការដោះស្រាយអំពីសិទ្ធិ និងការទប់ស្កាត់ ព្រមទាំងការផ្ដន្ទាទោសចំពោះកំហុសទាំងឡាយ។ យុត្តិធម៌កំណត់លើការយកចិត្តទុកដាក់ដល់សិទ្ធិរបស់ជនជាប់ចោទ ដល់ផលប្រយោជន៍របស់ជនរងគ្រោះ និងដល់សុខមាលភាពសង្គមទាំងមូលតែម្ដង")។ នៅក្នុងករណីនេះតែម្ដង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលយកការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២២ នាក់ (សូមមើល សំណុំរឿង ០០៣ បញ្ជីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលអាចទទួលស្គាល់ ឧបសម្ពន្ធ ក ភ្ជាប់ជាមួយដីកាសម្រេចលើភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269.1 ("ឧបសម្ពន្ធ ក ភ្ជាប់ជាមួយដីកាសម្រេចលើភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (D269.1)")) ចំណែកឯចំនួន ៦០៤ នាក់ នៅកំពុងតែទាមទារសុំចូលរួមនៅក្នុងរឿងក្ដីនេះ តាមរយៈបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានប្រកាសមិនទទួលយកពាក្យសុំរបស់ពួកគេ (សូមមើល សំណុំរឿង ០០៣ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានសម្រេចថាមិនអាចទទួលស្គាល់ ឧបសម្ពន្ធ ក ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3.2.1)។

[418] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧១។

[419] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3) កថាខណ្ឌ ៧៣។

[420] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ (D266/18.2 និង D267/23.2) at ERN (EN) 01640007 ទំព័រ (ភាសាអង់គ្លេស) 36:09-36:13។

01667386



ជាឧក្រិដ្ឋកម្មអន្តរជាតិដ៏សាហាវបំផុតមួយ ដែលធ្វើឱ្យ មាស មុត "ស្ថិតក្នុងយុត្តាធិការបុគ្គលយ៉ាងរឹងមាំរបស់ [អ.វ.ត.ក]"[421]។ ដោយមិនគិតពីចំនួនជនរងគ្រោះសរុប ដែលត្រូវបានសម្លាប់ និងគ្រួសារ ដែលរងផលប៉ះពាល់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានកំណត់ផងដែរថា យ៉ាងហោចណាស់ មានមនុស្សចំនួន ១៥.០០០នាក់ នៅក្នុងតំបន់ស្វយ័តកំពង់សោម ត្រូវបានបង្ខំឱ្យធ្វើការដោយបង្ខំក្រោមលក្ខខណ្ឌគួរឱ្យស្អប់ខ្ពើម ដែល មាស មុត ត្រូវទទួលខុសត្រូវនៅពេលជំនុំជម្រះ[422]។ ចៅក្រមអន្តរជាតិកត់សម្គាល់យ៉ាងត្រឹមត្រូវថា បុគ្គលរាប់រយនាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ហើយអ្នកទាំងនេះជាច្រើននាក់ បច្ចុប្បន្ន កំពុងប្តឹងនៅចំពោះមុខអង្គបុរេជំនុំជម្រះប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលសម្រេចថា ពាក្យសុំរបស់ពួកគេមិនអាចទទួលយកបានឡើយ[423]។ ចៅក្រមអន្តរជាតិ នឹងពិនិត្យលើបញ្ហាថាតើ មាស មុត ស្ថិត ឬមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នៅក្នុងផ្នែកដាច់ដោយឡែកមួយនៃមតិយោបល់នេះ[424]។

## ២. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ

### ក. សារណា

១៩៨. សហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ និងស្នើសុំដល់អង្គបុរេជំនុំជម្រះ៖ (១) បដិសេធការយល់ឃើញនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា មាស មុត មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក (២) យល់ឃើញថា មាស មុត ជាបុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និង (៣) បង្គាប់ឱ្យបញ្ជូនសំណុំរឿងប្រឆាំងរូបគាត់ទៅជំនុំជម្រះ ដោយផ្អែក

[421] ដីកាដំណោះស្រាយ (D267) កថាខណ្ឌ ៤៦៣។

[422] ដីកាដំណោះស្រាយ (D267) កថាខណ្ឌ ៤៦៨។

[423] សំណុំរឿង ០០៣, ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨, ឯកសារ D269, កថាខណ្ឌ ២។ បញ្ជីស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់, ឧបសម្ព័ន្ធ ក ភ្ជាប់ទៅនឹងដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨, ឯកសារ D269.1។

[424] *សូមមើល ខាងក្រោម* កថាខណ្ឌ ២៨៥-៣៤០។

01667387



លើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[425]។

i. មូលដ្ឋាន ក៖ កំហុសផ្នែកអង្គច្បាប់ស្តីពីការខកខានមិនបានធ្វើសំអាងហេតុ និងសំអាងច្បាប់ទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត និង ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងនោះ

១៩៩. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសដោយមិនបានធ្វើសំអាងហេតុ និងសំអាងច្បាប់ទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត និង ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងនោះ ដោយសារដីកាសម្រេចលើកលែងចោទប្រកាន់ពុំមាន៖ (១) សំអាងហេតុពាក់ព័ន្ធនឹងថាតើ ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពិតជាត្រូវបានប្រព្រឹត្ត ឬយ៉ាងណា និងថាតើ មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ឬយ៉ាងណា និង (២) សេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ដែលផ្អែកលើសំអាងហេតុរបស់ដីកានោះ[426]។

២០០. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីការពារក្តី មាស មុត លើកជាទឡ្ហីករណ៍ថា មូលដ្ឋាន ក នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិគួរត្រូវបានច្រានចោល ដោយសារ (១) សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញអំពីកំហុសផ្នែកអង្គច្បាប់ នៅក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលមិនកំណត់ប្រភេទឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវតាមច្បាប់ ដែលនាំឱ្យមោឃភាពការសម្រេចអំពីយុត្តាធិការបុគ្គលរបស់គាត់នោះទេ និង (២) សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិនេះមិនមែនមានភាពអយុត្តិធម៌ ឬមិនសមហេតុផលដែលបង្កើតឱ្យមានការបំពានឆន្ទានុសិទ្ធិនោះឡើយ[427]។ សហមេធាវីអះអាងបន្ថែមថា ដីកាសម្រេចលើកលែងចោទប្រកាន់មានសំអាងហេតុគ្រប់គ្រាន់ ហើយថា សហចៅក្រមស៊ើបអង្កេតជាតិបានធ្វើការសន្និដ្ឋានចាំបាច់ទៅលើអង្គហេតុទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតបានទទួល[428]។

---

[425] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៣, ២០២-២០៣។

[426] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ២០-៣៤។

[427] សំណុំរឿង ០០៣ ចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D266/5 ("ចម្លើយតបរបស់ មាស មុត (D266/5)") កថាខណ្ឌ ៥៤។

[428] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៥៤។

01667388



២០១. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា នៅក្នុងចម្លើយតប សហមេធាវី (១) ពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា សហចៅក្រមស៊ើបអង្កេតជាតិពុំចាំបាច់កំណត់ប្រភេទនៃសំអាងហេតុទៅតាមផ្លូវច្បាប់ទេ (២) លើកឡើងដោយមិនត្រឹមត្រូវថា កំហុសឆ្គងនេះមានផលប៉ះពាល់ទៅលើការយល់ឃើញរបស់គាត់អំពីយុត្តាធិការបុគ្គល និង (៣) បកស្រាយមិនបានត្រឹមត្រូវនូវការដែលគាត់មិនបានមានសំអាងហេតុដែលចាំបាច់ត្រូវមាន[429]។

ii. មូលដ្ឋាន ខ៖ កំហុសផ្នែកអង្គច្បាប់ស្តីពីការខកខានមិនពិចារណាភស្តុតាងដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១

២០២. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសផ្នែកអង្គច្បាប់ ដោយមិនបានពិចារណាទៅលើភស្តុតាងនានាដែលបានដាក់ក្នុងសំណុំរឿង ០០៣ ក្រោយពេលចេញសេចក្តីជូនដំណឹងតាមវិធាន ៦៦(១) ឆ្នាំ២០១១ ដោយសហចៅក្រមស៊ើបអង្កេត ដោយសារ៖ (១) សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរមិនរារាំងមិនឲ្យសំណុំរឿង "បើកឡើងវិញ" ទេ[430] (២) សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបើកការស៊ើបសួរឲ្យបានពេញលេញ[431] (៣) ការស៊ើបសួរក្នុងសំណុំរឿង ០០៣ ពុំបានពេញលេញទេនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[432] និង (៤) ការមិនបានវាយតម្លៃទៅលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង មានផលប៉ះពាល់យ៉ាងខ្លាំងបំផុតដល់ការវិភាគទៅលើយុត្តាធិការបុគ្គលរបស់គាត់[433]។

២០៣. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកជាទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតជាតិពុំមានកំហុសផ្នែកអង្គច្បាប់ ដោយមិនបានពិចារណាលើភស្តុតាងនានាដែលប្រមូលបានក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[434] ទេ ដោយសារ (១) ការស៊ើបសួរបានបញ្ចប់ត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និង (២) សេចក្តីជូនដំណឹងចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មិនអស់សុពលភាព ឬត្រូវបានចាត់ទុកជាមោឃៈដោយសារ "ការបើក" កិច្ចស៊ើបសួរ "ឡើងវិញ" ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង

[429] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ១២។

[430] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៣៦-៤២។

[431] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៤៣-៤៨។

[432] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៤៩-៥៧។

[433] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៥៨-៦២ យោងទៅ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២។ សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ឆ្នាំ២០១១ (D13)។

[434] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ២២-៣២។

01667389



KASPER-ANSERMET ឡើយ[435]។ សហមេធាវីអះអាងបន្ថែមថា អង្គបុរេជំនុំជម្រះគួរបដិសេធចោល ដោយពុំចាំបាច់យកមកពិចារណាចំពោះការអះអាងដែលថា ការស៊ើបសួរដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ គឺលម្អៀង ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញនូវភស្តុតាងពីភាពលម្អៀង[436]។

២០៤. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា សហមេធាវី (១) បកស្រាយមិនត្រឹមត្រូវអំពីភារកិច្ចស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត និង (២) មិនបានផ្តល់សំអាងហេតុគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនដែលលើកឡើងថា សេចក្តីជូនដំណឹងតាមវិធាន ៦៦(១) ឆ្នាំ២០១១ ជាសេចក្តីជូនដំណឹងចុងក្រោយ ហើយបានបិទការស៊ើបសួរយ៉ាងត្រឹមត្រូវ នោះទេ[437]។

iii. មូលដ្ឋាន គ៖ កំហុសផ្នែកអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់ក្នុងវិសាលភាពនៃសំណុំរឿង ០០៣

២០៥. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសផ្នែកអង្គច្បាប់ក្នុងការសម្រេចអំពើយុត្តាធិការបុគ្គល ដែលតម្រូវឱ្យមានការវាយតម្លៃឱ្យបានពេញលេញទាំងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត ដោយសារ ការរំលោភបំពានទៅលើភារកិច្ចរបស់ខ្លួនក្នុងការចេញសេចក្តីសម្រេចលើអង្គហេតុទាំងអស់ដែលគាត់បានទទួល[438] (១) គាត់មិនបានពិចារណាទៅលើទីតាំងឧក្រិដ្ឋកម្មជាច្រើន ដែលស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[439] ដែល (២) បង្កើនភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែល មាស

---

[435] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៣៣-៣៩។

[436] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦(ក)។

[437] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ១៩។

[438] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៦៣ យោងទៅ សំណុំរឿង ០០១ (អបជ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 ("សាលដីកាក្នុងសំណុំរឿង ០០១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D99/3/42)") កថាខណ្ឌ ៣៣, ៣៧-៣៨។ សំណុំរឿង ០០២ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបំភ្លឺអំពីបទចោទ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D198/1 ("ដីកាសម្រេចលើសំណើសុំបំភ្លឺក្នុងសំណុំរឿង ០០២ (D198/1)") កថាខណ្ឌ ១០។ តុលាការកំពូលបារាំង, Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ 76-91.442។

[439] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៦៤-៦៩។

01667390



មុត ទទួលខុសត្រូវ[440]។

២០៦. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកជាទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតជាតិពុំមានកំហុសផ្នែកអង្គច្បាប់ ក្នុងការពិចារណា និងចេញសេចក្ដីសម្រេចទៅលើអង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣ ទេ[441] ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិអានដីកាសម្រេចលើកលែងចោទប្រកាន់ខុស ដោយអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិមិនបានពិចារណាលើទីតាំងឧក្រិដ្ឋកម្ម និង ព្រឹត្តិការណ៍បទល្មើស នៅពេលធ្វើការសម្រេចលើអង្គហេតុ[442]។ សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញកំហុសផ្នែកអង្គច្បាប់ នៅក្នុងការពិចារណារបស់សហចៅក្រមស៊ើបអង្កេតជាតិ "លើអង្គហេតុទាំងអស់ ប៉ុន្តែអង្គហេតុទាំងនោះគឺជាផ្នែកមួយនៃកិច្ចស៊ើបសួរ" ឬថា ការសម្រេចរបស់គាត់មិនធ្វើការសន្និដ្ឋានជាក់លាក់ទៅលើទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលបង្កើតជាផ្នែកនៃអង្គហេតុ មានភាពអយុត្តិធម៌ ឬមិនសមហេតុផលដែលបង្កើតជាការបំពានឆន្ទានុសិទ្ធិ[443]។

២០៧. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីបកស្រាយច្បាប់ដោយមិនត្រឹមត្រូវ និងការពារខុសដល់ការដែលសហចៅក្រមស៊ើបអង្កេតជាតិមិនបានបំពេញកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញសំអាងហេតុ និងសំអាងច្បាប់ឲ្យបានពេញលេញ[444]។ គាត់អះអាងបន្ថែមថា ការពិចារណាទៅលើភស្តុតាង "តិចតួច" របស់សហចៅក្រមស៊ើបអង្កេតជាតិ ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលបានបាត់បង់ គឺមិនគ្រប់គ្រាន់ដើម្បីបំពេញទៅតាមបទដ្ឋាននៃការផ្តល់យោបល់ដែលមានសំអាងហេតុទេ[445]។

### iv. មូលដ្ឋាន ឃ៖ កំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ពាក់ព័ន្ធនឹងការពិចារណាទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ នៅពេលធ្វើការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

[440] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៧០-៨២។
[441] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៥០-៥១។
[442] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៥២។
[443] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៥២-៥៤។
[444] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៣១-៣៣។
[445] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៣៤-៣៦។

២០៨. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ នៅក្នុងការពិចារណារបស់ខ្លួនទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ នៅពេលធ្វើការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយ មាស មុត ដោយសារៈ (១) គាត់ផ្តល់ទម្ងន់ហួសហេតុទៅលើបញ្ជាថ្នាក់លើ និងការគាបសង្កត់ នៅក្នុងការវិភាគអំពីយុត្តាធិការបុគ្គល[446] (២) មាស មុត បានប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានឆន្ទៈ និងចំណាប់អារម្មណ៍ ដោយគ្មានការបង្ខិតបង្ខំ ឬគាបសង្កត់[447] (៣) សុន សេន បានប្រគល់ឲ្យ មាស មុត នូវអំណាចចាប់ខ្លួន និងកម្ទេចជនបរទេសដែលចាប់បាននៅសមុទ្រ[448] (៤) មាស មុត បានបង្កើត និងចូលរួមក្នុងយន្តការកំណត់អត្តសញ្ញាណអ្នកដែលត្រូវចាត់ទុកថាជាខ្មាំងបញ្ជាឲ្យចាប់ខ្លួនទាំងនោះ និងបញ្ជូនអ្នកខ្លះទៅ ស-២១[449] និង (៥) ការពិចារណាខុសគ្នាតាមអំពើចិត្តចំពោះការបញ្ជាថ្នាក់លើ ការបង្ខិតបង្ខំ និងការគំរាមកំហែង នៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០៣[450]។

២០៩. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិពុំមានកំហុសផ្នែកអង្គច្បាប់ ឬអង្គហេតុ នៅក្នុងការពិចារណារបស់ខ្លួនទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើទេ ដោយសារ (១) គាត់បានពិចារណាចំពោះកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត ដោយផ្អែកលើមុខតំណែង និងតួនាទីរបស់គាត់នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ដោយគាត់បានវិភាគទៅលើមុខតំណែងរបស់ មាស មុត នៅក្នុងចង្កោមរួមនៃអ្នកទទួលខុសត្រូវ ទំនាក់ទំនងរបស់គាត់ក្នុងជាអ្នកក្រោមបង្គាប់ជាមួយ សុន សេន ជាថ្នាក់លើ កម្រិតនៃសិទ្ធិអំណាចព្រមទាំងតួនាទី និងការចូលរួមជាក់ស្តែងរបស់គាត់ទៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង (២) ការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើគឺជាកត្តាដែលអាចយកមកពិចារណាបាន ក្នុងគោលបំណងផ្តន្ទាទោស និងយុត្តាធិការបុគ្គល[451]។

២១០. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកជាទឡ្ហីករណ៍ថា ចម្លើយតបរបស់សហ

---

[446] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៨៣-៩១។

[447] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៩២-៩៧។

[448] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៩៨-១០២។

[449] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១០៣១-០៧។

[450] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១០៨-១១១។

[451] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៥៥-៦៤។

មេធាវីធ្វើយុត្តិកម្មដោយមិនត្រឹមត្រូវចំពោះកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងការពិចារណាទៅលើបញ្ហាថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់ ថាជាកត្តាដែលអាចកាត់បន្ថយកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត[452]។ គាត់ជំទាស់ថា សហមេធាវី (១) យល់ខុសពីច្បាប់ និងខកខានមិនបានបង្ហាញពីកាលៈទេសៈ ដែលកត្តាទាំងនេះអាចកាត់បន្ថយកម្រិតនៃការទទួលខុសត្រូវរបស់គាត់ និង (២) បង្ហាញខុសអំពីភស្តុតាងនៃឆន្ទៈរបស់ មាស មុត ក្នុងការចូលរួមទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ព្រមទាំងកម្រិតនៃការសិទ្ធិអំណាច និងការការពារ ដែលគាត់ទទួលបាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[453]។

### V. មូលដ្ឋាន ង៖ កំហុសផ្នែកអង្គច្បាប់ និងអង្គហេតុនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ពាក់ព័ន្ធនឹងការពិនិត្យទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅពេលកំណត់កម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

២១១. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ នៅក្នុងការពិចារណារបស់ខ្លួនទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅពេលកំណត់កម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដោយសារ (១) នៅពេលធ្វើការវិភាគអំពីយុត្តាធិការបុគ្គល គាត់បានផ្តល់ទម្ងន់ហួសហេតុទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត[454] និង (២) មាស មុត ពិតជាបានដើរតួនាទីដោយផ្ទាល់ និងយ៉ាងសកម្មនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[455]។

២១២. នៅក្នុងការចម្លើយតបរបស់ខ្លួន សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិពុំមានកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ ក្នុងការពិចារណារបស់ខ្លួនទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងឧក្រិដ្ឋកម្ម នៅពេលកំណត់អំពីកម្រិតនៃការទទួលខុសត្រូវរបស់គាត់ទេ[456] ដោយសារ៖ (១) សហព្រះរាជអាជ្ញាអន្តរជាតិដកស្រង់នាំឱ្យយល់ខុស នូវយុត្តិសាស្ត្រមិនពាក់ព័ន្ធ អំពីច្បាប់ស្តីពីទម្រង់នៃការទទួលខុស

[452] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ មាស មុត (D267/11) កថាខណ្ឌ ៣៧។

[453] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ មាស មុត (D267/11) កថាខណ្ឌ ៣៧។

[454] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១១២-១២០។

[455] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១២១-១៣៥។

[456] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦៥-៧១។

01667393



ត្រូវ នៅពេលជំនុំជម្រះ[457] (២) សហចៅក្រមស៊ើបអង្កេតជាតិមិនបានពឹងផ្អែកលើមូលដ្ឋាននៃការចូលរួមដោយផ្ទាល់របស់ មាស មុត នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ទេ តែផ្ទុយទៅវិញ គាត់បានផ្តោតទៅលើ "វិសាលភាពនៃសកម្មភាពផ្ទាល់ និងអានុភាពនៃអំពើទាំងនោះ" [458] (៣) ក្នុងការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត សហចៅក្រមស៊ើបអង្កេតជាតិមិនមែនមើលរំលងទេ តែបានពិចារណាយ៉ាងច្បាស់ទៅលើ "ឋានានុក្រម ឬ មុខតំណែង" របស់ មាស មុត[459] (៤) សហចៅក្រមស៊ើបអង្កេតជាតិមិនបានយល់ឃើញចំពោះ មាស មុត ផ្ទុយពីការយល់ឃើញចំពោះជនត្រូវចោទនៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានចាត់ទុកជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ[460] និង (៥) សហព្រះរាជអាជ្ញាអន្តរជាតិនាំឱ្យយល់ខុស និងជ្រើសរើសយកតែចំណុចដែលគាត់ចង់បាន នៅពេលយោងទៅសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាផ្ទេរសមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY នៅពេលពិចារណាអំពីតួនាទី និងកម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្មនីមួយៗ ហើយសហចៅក្រមស៊ើបអង្កេតទាំងពីររូបមិនបានយល់ឃើញថា មាស មុត បានដើរតួនាទីដោយផ្ទាល់ ឬយ៉ាងសកម្មនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ[461]។

២១៣. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកជាទឡ្ហីករណ៍ថា ផ្ទុយពីការអះអាងមិនត្រឹមត្រូវរបស់សហមេធាវីនៅក្នុងចម្លើយតបរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ ដោយ (១) ផ្តល់ទម្ងន់ហួសហេតុដល់ការចូលរួមរបស់ មាស មុត នៅក្នុង "អំពើផ្ទាល់" និង (២) មើលរំលងភស្តុតាងនៃការចូលរួមដោយសកម្ម និងមានការប្តេជ្ញាចិត្ត នៅក្នុងការអនុវត្តគោលនយោបាយលើសត្រូវរបស់ ប.ក.ក ការធ្វើឱ្យទៅជាទាសករ និងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់ដែលគាត់មានសិទ្ធិអំណាច ក្នុងគោលបំណងកំណត់អំពីយុត្តាធិការបុគ្គល[462]។

---

[457] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦៥ យោងទៅ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១១៥ ជើងទំព័រ ៤៦២-៤៦៩។

[458] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦៦ យោងទៅ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨ និង សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៥៧។

[459] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦៧។

[460] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦៨ យោងទៅ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣២៧-១៣២៨។

[461] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦៩-៧០។

[462] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៥៥។

## vi. មូលដ្ឋាន ចះ សំអាងហេតុដោយខុសឆ្គង មានផលប៉ះពាល់ក្នុងការសម្រេចទៅលើបញ្ហាយុត្តាធិការបុគ្គល

២១៤. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិបានធ្វើសំអាងហេតុដោយខុសឆ្គងដែលមានផលប៉ះពាល់ក្នុងការសម្រេចទៅលើបញ្ហាយុត្តាធិការបុគ្គល ដោយសារ មាស មុត ពិតជា (១) លេខាកងពលធំ ១៦៤ និងជាលេខាតំបន់ស្វយ័តកំពង់សោម ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[463] (២) សមាជិកគណៈកម្មាធិការអគ្គសេនាធិការ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៥ និងជាអនុលេខាអគ្គសេនាធិការ ចាប់ពីចុងឆ្នាំ១៩៧៨[464] និង (៣) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ប.ក.ក ចាប់តាំងពីខែមករា ឆ្នាំ១៩៧៦[465] ដែលផ្ទុយពីការសន្និដ្ឋានរបស់ខ្លួន។ គាត់ជំទាស់ថា កំហុសទាំងនេះកើតឡើងដោយសារមិនបានការពិនិត្យទៅលើភស្តុតាងទាំងអស់មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងពិចារណាទៅលើភស្តុតាងពាក់ព័ន្ធផ្សេងទៀតដែលមានក្រោយកាលបរិច្ឆេទនោះ[466] ដែលនាំឲ្យ សហចៅក្រមស៊ើបអង្កេតជាតិអះអាងដោយមិនត្រឹមត្រូវថា ឋានៈរបស់ មាស មុត "នៅក្រោមកម្មាភិបាលប្រមាណ ៥០ នាក់"[467]។

២១៥. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកជាទឡ្ហីករណ៍ថា កំហុសផ្នែកអង្គហេតុដែលសហព្រះរាជអាជ្ញាអន្តរជាតិបានអះអាង ពុំមានផលប៉ះពាល់ជាកត្តាកំណត់លើការវាយតម្លៃពីយុត្តាធិការបុគ្គលទេ[468] ហើយថា ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតជាតិពុំមានកំហុសជាកត្តាកំណត់ពាក់ព័ន្ធនឹងមុខតំណែង កម្រិតនៃឋានានុក្រម ឬសិទ្ធិអំណាចរបស់ មាស មុត ពាក់ព័ន្ធនឹងមុខតំណែងរបស់គាត់ជា (១) មេបញ្ជាការកងពលធំ ១៦៤ ឬលេខាតំបន់ស្វយ័តកំពង់សោម[469] (២) សមាជិកអគ្គសេនាធិ

[463] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៣៧-១៤១។

[464] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៤២-១៤៧។

[465] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៤៨-១៥៤។

[466] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៣៥។

[467] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៥៤។

[468] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៧២-៨៤។

[469] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៧៣-៧៨។

01667395



ការ[470] និង (៣) ជាសមាជិកគណៈកម្មាធិការមជ្ឈិម[471] ទេ។

២១៦. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីមិនបានផ្តល់មូលដ្ឋានដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា សហចៅក្រមស៊ើបអង្កេតជាតិពុំបានធ្វើសំអាងហេតុដោយមិនត្រឹមត្រូវពាក់ព័ន្ធនឹងមុខតំណែង និងតួនាទីរបស់ មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ជាពិសេសពាក់ព័ន្ធនឹងមុខតំណែងរបស់គាត់ជា (១) លេខាកងពលធំ ១៦៤ និងលេខាតំបន់ស្វយ័តកំពង់សោម និង ជាសមាជិក (២) អគ្គសេនាធិការ ព្រមទាំង (៣) គណៈកម្មាធិការមជ្ឈិម[472]។

vii. មូលដ្ឋាន ឆ៖ កំហុសផ្នែកអង្គហេតុ នៅក្នុងផ្នែកនៃការពិនិត្យទៅលើជនរងគ្រោះក្នុងដីកាសម្រេចលើកលែងចោទប្រកាន់

២១៧. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ការពិចារណាទៅលើជនរងគ្រោះនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិបង្កើតជាកំហុសផ្នែកអង្គហេតុ ដោយសារសហចៅក្រមស៊ើបអង្កេតជាតិ៖ (១) មិនបានរាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលមិនបានកើតឡើងនៅ ស-២១[473] (២) មិនបានពិចារណាចំពោះជនរងគ្រោះនៅឯព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្មជាច្រើន ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង[474] (៣) មិនបានពិចារណាដល់ភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង នៅពេលធ្វើសេចក្តីសន្និដ្ឋាន ឬពិនិត្យទៅលើភស្តុតាងពាក់ព័ន្ធនឹងជនរងគ្រោះនៅតាមទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត[475] និង (៤) ផ្តល់តួលេខនៅ ស-២១ ដែលប៉ាន់ប្រមាណខុសទៅលើចំនួនអ្នកទោសស្លាប់នៅ ស-២១ ដែលយ៉ាងហោចណាស់ មាស មុត ក៏ត្រូវទទួលខុសត្រូវមួយផ្នែកដែរ[476]។

២១៨. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកជាទឡ្ហីករណ៍ថា សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតជាតិ ពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មពុំមានភាពខុសឆ្គងទេ ហើយក៏មិនប៉ះពាល់

[470] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៧៩-៨១។

[471] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៨២-៨៨។

[472] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ មាស មុត (D267/11) កថាខណ្ឌ ៥០-៦១។

[473] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៥៧។

[474] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៥៨។

[475] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៥៩-១៦៨។

[476] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៦៩-១៧០។

ធ្ងន់ធ្ងរដែរ ដោយសារ៖ (១) សហព្រះរាជអាជ្ញាអន្តរជាតិនាំឱ្យយល់ខុស ដោយអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិមិនបានពិចារណាលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង យល់ឃើញដែលចាំបាច់ និងកំណត់នូវបទចោទទាំងនោះតាមផ្លូវច្បាប់ នៅពេលគាត់ធ្វើសេចក្តីសន្និដ្ឋានថា មានភាពខុសគ្នាជាខ្លាំងរវាងចំនួនជនរងគ្រោះដែលបានទទួលរងដោយសារអំពើផ្ទាល់របស់ មាស មុត និង ជនរងគ្រោះដោយសារអំពើផ្ទាល់របស់ ឌុច[477] (២) ចំនួនជនរងគ្រោះដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើង មិនត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ទេ ហើយសហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញអំពីកំហុសរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធនូវតួលេខទាំងនេះទេ[478] និង (៣) សហចៅក្រមស៊ើបអង្កេតជាតិលើកឡើងយ៉ាងត្រឹមត្រូវ នៅក្នុងការវាយតម្លៃរបស់គាត់ពីភាពធ្ងន់ធ្ងរ ដោយពិចារណាទៅលើអំពើផ្ទាល់ និងការប្រព្រឹត្តិរបស់ មាស មុត[479]។

២១៩. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់អំពីការយល់ស្របរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសក្នុងការប៉ាន់ប្រមាណទាបទៅលើចំនួនជនរងគ្រោះដែល មាស មុត ទទួលខុសត្រូវ[480] និងបានគូសបញ្ជាក់ថា ផ្ទុយពីការអះអាងរបស់សហមេធាវី សហព្រះរាជអាជ្ញាអន្តរជាតិពុំជាប់កាតព្វកិច្ចទៅនឹងការយល់ឃើញនីមួយៗនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ[481]។ គាត់ជំទាស់បន្ថែមថា "ការដកស្រង់មិនពេញលេញ" របស់សហមេធាវី ចំពោះការប៉ាន់ប្រមាណរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីជនរងគ្រោះ ធ្វើឱ្យខូចធ្ងន់ធ្ងរដល់ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា រាប់ពាន់នាក់គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មរបស់ មាស មុត ជាចំនួនដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប៉ាន់ប្រមាណទាបជាក់លាក់ ដូចដែលគាត់បានទទួលស្គាល់ដោយខ្លួនឯងដែរ[482]។

viii. មូលដ្ឋាន ជ៖ កំហុសផ្នែកអង្គច្បាប់ដោយសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលត្រូវជាន់ខ្ពស់តែម្នាក់គត់

២២០. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិ

[477] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៩០។

[478] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦(គ), ៩១។

[479] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៩២។

[480] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦២។

[481] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦២។

[482] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦៣។

ដែលថា ឌុច ជាបុគ្គលតែម្នាក់គត់ដែលស្ថិតនៅក្នុងប្រភេទជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងឡាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយ ការកាត់សេចក្តីទៅលើមេដឹកនាំជាន់ខ្ពស់មិនត្រូវរាលដាលដល់កម្មាភិបាលថ្នាក់ក្រោម គឺជារឿងមិនត្រឹមត្រូវ[483] ដោយសារការអះអាងទាំងនេះមិនស្របទៅនឹង (១) ភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក[484] (២) ការយល់ឃើញជាក់លាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អំពីយុត្តាធិការបុគ្គល[485] និង (៣) សេចក្តីថ្លែងការណ៍ដោយផ្ទាល់របស់សហចៅក្រមស៊ើបអង្កេតជាតិថា យុត្តាធិការបុគ្គលមិនមានគោលបំណងដើម្បីកំណត់ពីចំនួនបុគ្គលមានចំនួនជាក់លាក់ និងមានឈ្មោះជាក់លាក់នោះទេ[486]។

២២១. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកជាទឡ្ហីករណ៍ថា មូលដ្ឋាន ជ របស់សហចៅក្រមស៊ើបអង្កេតគួរត្រូវបានច្រានចោលដោយពុំចាំបាច់យកទៅពិចារណា ដោយសារគាត់បកស្រាយខុសចំពោះដីកាសម្រេចលើកលែងចោទប្រកាន់ និងជំទាស់ទៅនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតជាតិដែលថា ប្រភេទនៃជនដែលទទួលខុសត្រូវខ្ពស់បំផុត "អាចអនុវត្តបានចំពោះតែ ឌុច ម្នាក់គត់" [487] ដែលសហចៅក្រមស៊ើបអង្កេតជាតិមិនបានយកមកសំអាងនៅក្នុងការកំណត់អំពើយុត្តាធិការបុគ្គលទេ[488]។ សហមេធាវីកត់សម្គាល់នូវការយល់ស្របរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សហចៅក្រមស៊ើបអង្កេតជាតិ "[បានគូសបញ្ជាក់] ត្រឹមត្រូវ [...] បញ្ហាថាតើនរណាអាចស្ថិតនៅក្នុងចំណោម "ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" ពុំត្រូវបានធ្វើបុរេវិនិច្ឆ័យឡើយ"[489]។ សហមេធាវីអះអាងថា ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចផ្ទុយពីសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤/១ ពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចថា ពាក្យថា "ទទួលខុសត្រូវខ្ពស់បំផុត" សំដៅដល់ "ប្រភេទនៃបុគ្គល"[490]។

---

[483] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៧១១៧២។-

[484] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៧៥១៨៨។-

[485] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៧៣១៧៤។-

[486] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៨៩-១៩០។

[487] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦(ឃ), ៩៣។

[488] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៦(ឃ), ៩៣, ៩៥, ៩៦។

[489] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៩៣។

[490] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ៩៤ (ដកការគូសបញ្ជាក់ចេញ)។

២២២. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា ទឡ្ហីករណ៍របស់សហមេធាវីមានភាពផ្ទុយគ្នា និងមិនបានបដិសេធអង្គហេតុដែលថា ការវិភាគមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតជាតិ គឺជាកំហុសផ្នែកអង្គច្បាប់ទេ[491]។ គាត់លើកជាទឡ្ហីករណ៍ថា ផ្ទុយពីភាសាជាក់លាក់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ សហមេធាវីត្រឹមតែអះអាងដោយគ្មានដកស្រង់ ឬទឡ្ហីករណ៍ថា ការកំណត់ប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" តែចំពោះ ឌុច ពុំមានឥទ្ធិពលលើការសម្រេចលើកក្រោយរបស់ខ្លួនលើយុត្តាធិការបុគ្គលទេ[492]។

ix. អំណះអំណាងពាក់ព័ន្ធនឹងដីកាដំណោះស្រាយផ្ទុយគ្នា

២២៣. នៅក្នុងអំណះអំណាងរបស់លោកស្រីពាក់ព័ន្ធនឹងដីកាដំណោះស្រាយផ្ទុយគ្នា សហព្រះរាជអាជ្ញាអន្តរជាតិតវ៉ាថា គោលនយោបាយដែលមានភស្តុតាងបង្ហាញច្បាស់នៅក្នុងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់បង្កើត អ.វ.ត.ក និងបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ជាពិសេស វិធាន៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ក៏ដូចជាយុត្តិសាស្ត្រផ្សេងទៀតនៃអង្គជំនុំជម្រះតុលាការកំពូលតម្រូវថា សំណុំរឿង ០០៣ ត្រូវបន្តទៅជំនុំជម្រះដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនតែនៅពេលដែលអង្គបុរេជំនុំជម្រះសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ ដោយការច្រានចោលការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតជាតិអំពីយុត្តាធិការបុគ្គល នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ស្ថានភាពដែលដីកាដំណោះស្រាយពីរផ្ទុយគ្នានៅតែមានអានុភាពអនុវត្តផងដែរ ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនលើសលប់ដើម្បីចេញសេចក្តីសម្រេចបាន ឬ ក៏ឈានទៅសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់[493]។ ដើម្បីជាការគាំទ្រ លោកស្រីអះអាងថា វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង គឺជា *ច្បាប់ពិសេស*ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុដូច្នេះ មានអានុភាពអនុវត្តលើពាក្យពេចន៍ទូទៅនៅក្នុងវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង[494]។ បន្ថែមលើនេះទៀត លោកស្រីបញ្ជាក់ថា នៅក្នុងសាលដីកាលើសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ" ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូមួយដែលអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬមិនមែនជាជនទាំងឡាយដែល

[491] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦៥។

[492] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦៦។

[493] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៩១-១៩៨។

[494] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៩២-១៩៥។

ទទួលខុសត្រូវខ្ពស់បំផុត[495]។

២២៤. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកឡើងថា អំណះអំណាងទាំងឡាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងដីកាដំណោះស្រាយផ្ទុយគ្នា គឺមិនសមហេតុផល និងមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ពីព្រោះលោកស្រីសុំឱ្យអង្គបុរេជំនុំជម្រះកុំអើពើនឹងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*[496] និងទទួលយក "គោលនយោបាយ" ដែលមិនត្រូវបានបង្ហាញភស្តុតាងច្បាស់ដោយ (១) វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដោយសារសហចៅក្រមស៊ើបអង្កេតបានពិចារណារួមគ្នាថា វិធាននេះ "គ្រាន់តែចែងអំពីសេណារីយ៉ូដែលមានដីកាលើកលែងចោទប្រកាន់ ឬក៏មានដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នាទេ" ហើយថា សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា គឺស្ថិតនៅលើអង្គបុរេជំនុំជម្រះ[497] និងមិនមានបង្ហាញច្បាស់នៅក្នុង (២) យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដោយសារថា *មតិរបស់ចៅក្រម*នៅក្នុងសាលដីកាលើសំណុំរឿង ០០១ គឺពាក់ព័ន្ធនឹងនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នារបស់អង្គបុរេជំនុំជម្រះ *នៅមុន*ការបញ្ចប់កិច្ចដំណើរការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត[498] ឬនៅក្នុង (៣) កិច្ចព្រមព្រៀង អ.វ.ត.ក នោះទេ ដោយសារតែសហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញឱ្យបានរឹងមាំនូវការអះអាងរបស់គាត់ និងការប្រៀបធៀបដែលនាំឱ្យយល់ខុសចំពោះនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នានៅក្នុងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង ជាមួយនឹងដំណោះស្រាយលើបណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា[499]។ ពួកគាត់តវ៉ាថា ដោយសារសហចៅក្រមស៊ើបអង្កេតពីរនាក់ដែលមានសិទ្ធិស្មើគ្នា និង ឯករាជ្យ ចេញដីកាដំណោះស្រាយផ្ទុយគ្នា នោះដីកាលើកលែងចោទប្រកាន់មិនអាចត្រូវបានទុកចោលមួយអន្លើ ដោយមិនមានការសម្រេចពីអង្គបុរេជំនុំជម្រះតាមរយៈសម្លេងភាគច្រើនលើសលប់ថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានិសិទ្ធិរបស់គាត់នោះទេ និងថា ទោះជាមានសេចក្តីសម្រេចបែបនេះក្តី ក៏អង្គបុរេជំនុំជម្រះនៅតែត្រូវតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសម្លេងភាគច្រើនលើសលប់ដែរ[500]។

២២៥. នៅក្នុងការឆ្លើយតបរបស់លោកស្រី សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងជាថ្មីម្តងទៀតថា កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់បង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា សំណុំរឿង ០០៣ ត្រូវតែបញ្ជូនទៅជំនុំ

---

[495] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ១៩៥-១៩៦ ជើងទំព័រ ៧៥០ *យោងទៅ*សាលដីកាលើសំណុំរឿង ០០១ (F28) កថាខណ្ឌ ៦៥ (សេចក្តីបញ្ជាក់បន្ថែម)។

[496] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ១៥, ១៧, ២០។

[497] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ១៥, ១៦។

[498] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ១៥, ១៨។

[499] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ១៥, ១៩។

[500] ចម្លើយតបរបស់ មាស មុត (D266/5) កថាខណ្ឌ ២០។

01667400



ជម្រះ លើកលែងតែដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបដិសេធដោយសម្លេងភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះ[501] និងអះអាង សហមេធាវី (១) អនុវត្តខុសនូវគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ពីព្រោះក្នុងករណីនេះ នៅតែមិនមានវិមតិសង្ស័យនោះទេ ហើយគោលការណ៍នេះអនុវត្តចំពោះបញ្ហាអង្គហេតុ និងច្បាប់សារធាតុ ដែលកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ[502] និង (២) ប្រកាន់យកការបកស្រាយចង្អៀតមែនទែនទៅលើច្បាប់គោល និងយុត្តិសាស្ត្រ ដោយសារលទ្ធផលជាសំខាន់មានលក្ខណៈដូចគ្នា ត្រង់ថាតើអង្គបុរេជំនុំជម្រះបានទទួលដោះស្រាយការខ្វែងយោបល់គ្នា តាមរយៈបណ្ដឹងឧទ្ធរណ៍របស់ភាគី ឬតាមរយៈនីតិវិធីដោះស្រាយវិវាទផ្លូវការ[503]។

## ខ. ការពិភាក្សា

### i. មូលដ្ឋាន ខ និង គ

២២៦. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះកត់សម្គាល់ថា មូលដ្ឋាន ខ នៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលចោទប្រកាន់ថាសហចៅក្រមស៊ើបអង្កេតជាតិមានកំហុសផ្នែកអង្គច្បាប់ ដោយពុំបានពិចារណាទៅលើភស្តុតាងនានានៅក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[504] និងមូលដ្ឋាន គ ដែលចោទប្រកាន់ពីកំហុសផ្នែកអង្គច្បាប់ ដោយពុំបានពិចារណា និងចេញសេចក្ដីសម្រេចទៅលើអង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣[505] មានការអះអាងពីកំហុសជាមូលដ្ឋានដែលអាចប៉ះពាល់ទៅដល់សុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់។ ហេតុនេះ ចៅក្រមអន្តរជាតិពិចារណាឃើញថា វាសំខាន់ចាំបាច់ខ្លាំងណាស់ដែលត្រូវផ្ដួចផ្ដើមឲ្យមានការពិនិត្យមើលលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទាំងពីរនេះ។

#### (ក) មូលដ្ឋាន ខ

២២៧. ចៅក្រមអន្តរជាតិនឹងពិនិត្យមើល (i) ធាតុផ្សំបរិបទ ដែលទាក់ទិននឹងមូលដ្ឋានភស្តុតាងនៃដីកា

[501] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦៧។

[502] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦៧, ៧០, ៧១ (សេចក្ដីបញ្ជាក់បន្ថែម)។

[503] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D267/11) កថាខណ្ឌ ៦៧, ៦៩ ។

[504] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៣៥-៦២។

[505] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៦៣-៨២។

01667401



លើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ[506] ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា (ii) សេចក្ដីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) មិនបានរារាំងការបើកកិច្ចស៊ើបសួរឡើងវិញយ៉ាងមានសុពលភាព[507] (iii) កិច្ចស៊ើបសួរពិតជាមិនពេញលេញទេនៅត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[508] និងថា (iv) ការខកខានមិនបានវាយតម្លៃភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង មានផលប៉ះពាល់យ៉ាងខ្លាំងបំផុតទៅលើការវិភាគអំពីយុត្តាធិការបុគ្គលរបស់សហចៅក្រមស៊ើបអង្កេតជាតិ[509]។

*(i) សាវតារ*

២២៨. នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតជាតិបញ្ជាក់ថា ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ បានបញ្ចប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដោយមានការចេញការជូនដំណឹងអំពីការបិទការស៊ើបសួរក្នុងឆ្នាំ ២០១១ អនុលោមតាមវិធាន ៦៦[510](១)។ ពាក់ព័ន្ធនឹងមូលដ្ឋាននៃដីកាសម្រេចលើកលែងចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតជាតិអះអាងបន្ថែមទៀតថា គាត់ "អនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិចារណាតែភស្តុតាងទាំងឡាយដែលបានដាក់បញ្ចូល [ក្នុងសំណុំរឿង] នៅមុនថ្ងៃបិទការស៊ើបសួរ"[511] ពោលគឺ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[512]។

២២៩. ចំពោះបញ្ហានេះ ចៅក្រមអន្តរជាតិកត់សម្គាល់លើភាពផ្ទុយគ្នាបឋមនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ខណៈដែលសហចៅក្រមស៊ើបអង្កេតជាតិថ្លែងស្របគ្នាថា "ទោះបីជាយ៉ាងណាក្ដី វាអាចមានឯកសារណាមួយដែលជាផ្នែកមួយនៃកិច្ចស៊ើបអង្កេតមុនកាលបរិច្ឆេទបិទការស៊ើបអង្កេត ហើយត្រូវបានដាក់ក្នុងសំណុំរឿងនេះក្នុងពេលបន្តបន្ទាប់ក្រោយមក"[513]។ សហចៅក្រមស៊ើបអង្កេតជាតិលើកឡើង

---

[506] សូមមើល ខាងក្រោម កថាខណ្ឌ ២៣៣-២៣៥។

[507] សូមមើលខាងក្រោម កថាខណ្ឌ ២២៨-២២៩

[508] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៤៩-៥៧។

[509] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៥៨-៦២។

[510] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២, ៤១, ៣៥៩។

[511] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៩។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២, ៤១។

[512] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២, ៣៥៩។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤១។

[513] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២។

01667402



បន្តទៀតថា គាត់ផ្អែកលើ "ឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿងលេខ ០០៣ ដែលទទួលបានមកពីការស៊ើបអង្កេត និងការផ្ទេរបញ្ចូលពីសំណុំរឿងដទៃទៀត រួមមាន សំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ ព្រមទាំងសំណុំរឿងលេខ ០០៤[514]"។ គាត់បន្ថែមទៀតថា ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ រយៈពេល ៧ ឆ្នាំក្រោយពីបញ្ចប់ការស៊ើបអង្កេត "មិនមែនគ្មានមូលដ្ឋានទេ" ពីព្រោះសំណុំរឿង "នៅតែស្ថិតក្នុងដៃរបស់សហចៅក្រមស៊ើបអង្កេតរហូតដីកាដំណោះស្រាយត្រូវបានបញ្ជូនចេញ[515]"។

(ii) សេចក្តីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) និងអានុភាពរបស់វាទៅលើការបញ្ចប់កិច្ចស៊ើបសួរ

២៣០. ចៅក្រមអន្តរជាតិកត់សម្គាល់ថា ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា សេចក្តីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) មិនអាចរារាំងការបើកកិច្ចស៊ើបសួរឡើងវិញនៅក្នុងសំណុំរឿង ០០៣ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា កិច្ចស៊ើបសួរមិនត្រូវបានបញ្ចប់ដោយសេចក្តីជូនដំណឹងដែលបានលើកឡើងនេះទេ[516] ហើយកិច្ចស៊ើបសួរត្រូវបានបើកឡើងវិញយ៉ាងមានសុពលភាព ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET[517]។

២៣១. ចំពោះការអះអាងថា កិច្ចស៊ើបសួរមិនត្រូវបានបញ្ចប់ដោយសេចក្តីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) ដោយសារវាមិនអាចបញ្ចប់ការស៊ើបអង្កេតនោះ ចៅក្រមអន្តរជាតិបញ្ជាក់ជាថ្មីថា ផ្អែកលើការអានវិធាន ៦៦(១) និង ៦៧(១) និង៧៦(២) និង ផ្អែកលើវិធាន ២១(១) នៃវិធានផ្ទៃក្នុង "កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការត្រូវបានបិទបញ្ចប់ជាផ្លូវការ ដោយបានចេញដីកាដំណោះស្រាយហើយពុំមាននៅពេលនោះទេ ដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគី អំពីបំណងរបស់ខ្លួនក្នុងការបិទបញ្ចប់កិច្ចស៊ើបសួរនេះ"[518]។ ការបកស្រាយនេះស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ[519] និងសិទ្ធិរបស់ភាគី អនុលោមតាម

[514] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២។

[515] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៨។

[516] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៣៦-៣៨។

[517] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៣៩។

[518] សំណុំរឿង០០៤ សេចក្តីសម្រេចពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី (D370/1/1/6) កថាខណ្ឌ ៨ (ជើងទំព័រ ត្រូវបានលុប)។ សេចក្តីសម្រេចស្តីពីភស្តុតាងបានមកពីការធ្វើទារុណកម្ម (D257/1/8) កថាខណ្ឌ ១១។

[519] ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា មាត្រា ២៤៧ ("ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ")។

វិធាន ៦៦ ពាក់ព័ន្ធនឹងវិការៈនីតិវិធីនៅក្នុងការស៊ើបអង្កេត[520] ឬសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមមុនពេលបញ្ចប់កិច្ចស៊ើបសួរ[521]។

២៣២. នៅក្នុងករណីនេះ ចៅក្រមអន្តរជាតិរម្លឹកថា ការស៊ើបអង្កេតតាមផ្លូវតុលាការត្រូវបានបញ្ចប់ដោយប្រសិទ្ធភាពនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយការចេញដីកាដំណោះស្រាយដំណាលគ្នារបស់សហចៅក្រមស៊ើបអង្កេត។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សេចក្ដីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) មិនអាចត្រូវបានចាត់ទុកជាឧបសគ្គផ្លូវច្បាប់ ឬផ្នែកនីតិវិធីដែលមានសុពលភាពចំពោះការបើកកិច្ចស៊ើបសួរឡើងវិញក្នុងសំណុំរឿង ០០៣ បានឡើយ ដោយសារសេចក្ដីជូនដំណឹងនេះមិនអាចបញ្ចប់កិច្ចស៊ើបសួរបានទេ មានតែដីកាដំណោះស្រាយប៉ុណ្ណោះដែលអាចបញ្ចប់កិច្ចស៊ើបសួរបាន។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ពាក់ព័ន្ធនឹងការបញ្ចប់កិច្ចស៊ើបសួរ នៅពេលចេញសេចក្ដីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) គឺជាកំហុសផ្នែកអង្គច្បាប់។

២៣៣. ឥឡូវ ចៅក្រមអន្តរជាតិងាកមកដោះស្រាយបញ្ហាថាតើការបើកកិច្ចស៊ើបសួរឡើងវិញយ៉ាងមានសុពលភាពក្រោយពេលចេញសេចក្ដីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) ឬយ៉ាងណា។ ចៅក្រមអន្តរជាតិកត់សម្គាល់ពីការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិដែលថា ការបើកកិច្ចស៊ើបសួរឡើងវិញពុំមានសុពលភាព ពីព្រោះសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ KASPER-ANSERMET មិនទាន់ទទួលបានការតែងតាំងជាផ្លូវការដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[522]។

២៣៤. ចំពោះបញ្ហានេះ ចៅក្រមអន្តរជាតិសង្កេតឃើញថា មាត្រា៥(៥) នៃកិច្ចព្រមព្រៀង អ.វ.ត.ក

[520] វិធាន ៦៦ (២) និង (៣) នៃវិធានផ្ទៃក្នុង ("២. នៅពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើទាំងនេះ [សំណើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម] សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធដោយមានសំអាងហេតុ។ ដីកានេះត្រូវបដិសេធផងដែរនូវសំណើទាំងអស់ដែលបានដាក់ជូនតាំងពីពេលដំបូងនៃការស៊ើបសួរ ដែលខ្លួនមិនទាន់សម្រេចបាននៅឡើយ។ ៣. ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ក្រោយពីទទួលបានដំណឹងអំពីការសម្រេចនេះ ភាគីទាំងអស់អាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ភាគីទាំងអស់អាចបោះបង់ចោលសិទ្ធិប្ដឹងឧទ្ធរណ៍នេះបាន ទោះបីជាមានវត្តមានរបស់មេធាវី ឬក្នុងករណីដែលមេធាវីត្រូវបានកោះហៅដោយត្រឹមត្រូវ ប៉ុន្តែមិនបានចូលបង្ហាញខ្លួន")។

[521] វិធាន ៦៦ (១) ("ភាគីទាំងអស់មានរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម")។

[522] *សូមមើល* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៩។ សូមមើលផងដែរ ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤៤ (ដែលសហចៅក្រមស៊ើបអង្កេត បញ្ជាក់ពីភាពខុសគ្នារវាង "សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិ" (គូសបញ្ជាក់បន្ថែម)។

និងមាត្រា ២៦(៤) នៃច្បាប់បង្កើត អ.វ.ត.ក កំណត់អំពីបែបបទនីតិវិធីចាំបាច់សម្រាប់ការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ លើសពីនេះទៀត មាត្រា ៥(៦) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ២៦(២) នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា សហចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិនៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ។ កាន់តែជាក់លាក់ជាងនេះទៀត មាត្រា ២៧(ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា "ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស"។

២៣៥. ហេតុដូចនេះ ចៅក្រមអន្តរជាតិយល់ឃើញថា មិនដូចចៅក្រមអន្តរជាតិបម្រុងនៃអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវតែមានការចាត់តាំងច្បាស់លាស់ដោយប្រធានអង្គជំនុំជម្រះពាក់ព័ន្ធនោះ "តាមករណីនីមួយៗ ដើម្បីជំនួសចៅក្រមបរទេស ប្រសិនបើចៅក្រមរូបនោះពុំមានលទ្ធភាពអាចបន្តការជំនុំជម្រះតទៅទៀតបាន" [523] ពុំមានលក្ខខណ្ឌនីតិវិធីបន្ថែមឡើយ ក្រៅពីការតែងតាំងដំបូងសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដើម្បីអនុវត្តតួនាទីភារកិច្ចដែលកំពុងកាន់តំណែងនោះ។

២៣៦. ចៅក្រមអន្តរជាតិកត់សម្គាល់ថា ចៅក្រម KASPER-ANSERMET ត្រូវបានតែងតាំងដោយត្រឹមត្រូវជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយព្រះមហាក្សត្រ នរោត្តម សីហមុនី[524] បន្ទាប់ពីមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[525] ហើយបាន

---

[523] *សូមមើល* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១១ ថ្មី (៤)។ សូមមើលផងដែរ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣ (៨)។

[524] សូមមើល ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សហមុនី (លេខ នស/រកត/១១១០/៨០៩) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ("ព្រះរាជក្រឹត្យតែងតាំងចៅក្រម KASPER-ANSERMET ") មាត្រា ២។ សូមើល ផងដែរ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក "លោកបណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ https://www.eccc.gov.kh/sites/default/files/media/ECCC_1_Dec_2010_%28Eng%29.pdf (ចូលមើលនៅ ខែ មីនា ឆ្នាំ២០២១)។ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក ("សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង"ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ https://www.eccc.gov.kh/en/articles/statement-international-reserve-co-investigating-judge (ចូលមើល ៧ មេសា 2021)។

[525] ចៅក្រមអន្តរជាតិសង្កេតឃើញថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានអនុម័តតែងតាំងចៅក្រម KASPER-ANSERMET ។ សូមមើល ព្រះរាជក្រឹត្យតែងតាំងចៅក្រម KASPER-ANSERMET បុព្វកថា។ លើសពីនេះទៀត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទទួលខុសត្រូវក្នុងការលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។ សូមមើល ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (លេខ៖ ០៩ នស.៩៤) ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ មាត្រា ១១ ("ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅ

ស្បថនៅចំពោះមុខកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១[526]។ ជាលទ្ធផល ចៅក្រម KASPER-ANSERMET ចូលបំពេញការងារនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រោយពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ BLUNK លាលែងពីតំណែងនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១១ ដែលអវត្តមានចាប់ពីថ្ងៃនោះតទៅ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា ផ្ទុយទៅនឹងការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិ លក្ខខណ្ឌច្បាប់ដែលលើកឡើងខាងលើសម្រាប់ការតែងតាំងចៅក្រម KASPER-ANSERMET ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រូវបានបំពេញពេញលេញ ដូច្នេះ ចៅក្រម KASPER-ANSERMET មានលទ្ធភាពក្នុងបើកការបើកស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ឡើងវិញដោយស្របច្បាប់។

២៣៧. ត្រង់ចំណុចនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិពាក់ព័ន្ធនឹងសិទ្ធិរបស់ចៅក្រម KASPER-ANSERMET ក្នុងការធ្វើការបំពេញកិច្ចស៊ើបសួរ ស្ថិតនៅក្រោមការខ្វែងយោបល់គ្នា ដែលកើតឡើងនៅពេលដែលចៅក្រម KASPER-ANSERMET ចេញដីកាសម្រេចស្តីពីការបើកការស៊ើបអង្កេតបឋមឡើងវិញនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១[527] ចៅក្រមអន្តរជាតិសង្កេតឃើញថា ការខ្វែងយោបល់គ្នានេះត្រូវបានដាក់ និងកាត់សេចក្តីជាករណីពិសេសដោយអង្គបុរេជំនុំជ

---

ទំនេរ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការហូតងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់"(ការបកប្រែក្រៅផ្លូវការ)។ សូមមើលផងដែរ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ១១៥ ("[...] ) ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់")។ លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ថា ព្រះមហាក្សត្រដែលបានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងចៅក្រម KASPER-ANSERMET ទ្រង់ជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ *សូមមើល* រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ១១៥ "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ ព្រះមហាក្សត្រទ្រង់អាចចាត់ព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ [...]")។

[526] *សូមមើល* សុន្ទរកថាបើកកិច្ចប្រជុំពេញអង្គជាសាធារណៈ ដោយលោក គង់ ស្រ៊ឹម ប្រធានកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ https://www.eccc.gov.kh/en/articles/9th-eccc-plenary-session-commences (ចូលមើល ៧ មេសា 2021)។

[527] ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ (D28)។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានដាក់កំណត់ត្រានៃការខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃដីការបស់គាត់ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដោយបានផ្ញើជូនអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន ៧២ នៅថ្ងៃបន្ទាប់។

ស្រុះ។ ខណៈដែលចៅក្រមជាតិនៃអង្គជំនុំជម្រះចេញអនុស្សរណៈអន្តរការិយាល័យ[528] ដោយប្រកាសភ្លាមៗ "[ចៅក្រម] Laurent KASPER-ANSERMET ពុំមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចស្រប តាមនីតិវិធីច្បាប់ជាធរមាន"[529] ចៅក្រមអន្តរជាតិ CHUNG និង DOWNING[530] បានចេញយោបល់ ដោយឡែកមួយ បង្ហាញពីសំអាងហេតុតាមផ្លូវច្បាប់ក្នុងការសន្និដ្ឋានថា (i) ចៅក្រម KASPER-ANSERMET មានសិទ្ធិនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងឋានៈជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បម្រុងដែលអនុវត្តភារកិច្ចបណ្ដោះអាសន្ន នៅពេលអវត្តមានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញ សិទ្ធិ[531] (ii) កិច្ចដែលបំពេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET មានសុពលភាពតាមផ្លូវច្បាប់ រហូតដល់តំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានបំពេញជាអ ចិន្ត្រៃយ៍[532] និង (iii) ដោយពុំមានសំឡេងភាគច្រើនលើសលប់នៅក្នុងអង្គបុរេជំនុំជម្រះ ដើម្បីសម្រេចលើ

---

[528] អនុស្សរណៈអន្តរការិយាល័យចេញរបស់ចៅក្រម ប្រាក់ គឹមសាន នៃអង្គបុរេជំនុំជម្រះ ផ្ញើជូនការិយាល័យរដ្ឋបាលស្ដីពីការ បញ្ជូនត្រឡប់វិញនូវសំណុំឯកសារដែលការិយាល័យរដ្ឋបាលផ្ញើជូនអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D29/1/1.3 ("អនុស្សរណៈអន្តរការិយាល័យស្ដីពីការបញ្ជូនត្រឡប់វិញនូវសំណុំឯកសារ (D29/1/1.3)")។

[529] *សូមមើល* អនុស្សរណៈអន្តរការិយាល័យស្ដីពីការបញ្ជូនត្រឡប់វិញនូវសំណុំឯកសារ (D29/1/1.3)។

[530] សំណុំរឿង ០០៣/១៦-១២-២០១១/អ.វ.ត.ក/អបជ យោបល់របស់ចៅក្រម DOWNING និង CHUNG នៃអង្គបុរេជំនុំជម្រះ ស្ដីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតដោយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០១២ https://www.eccc.gov.kh/en/document/court/opinion-pre-trial-chamber-judges-DOWNING-and-CHUNG-disagreement-between-co (ចូលមើល ៧ មេសា 2021) ("យោបល់របស់ចៅក្រម DOWNING និង CHUNG")

[531] យោបល់របស់ចៅក្រម CHUNG និង DOWNING កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* យោបល់របស់ចៅក្រម DOWNING និង CHUNG កថាខណ្ឌ ៣៤-៣៧ ដែលចៅក្រម CHUNG និង DOWNING បានពន្យល់ថា មាត្រា២៦ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក បញ្ជាក់ច្បាស់ពីលក្ខខណ្ឌច្បាប់ចំនួនពីរទាក់ទងនឹងការចូលកាន់តំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង គឺ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចូលជំនួសចៅក្រមស៊ើបអង្កេតដែលត្រូវបានតែងតាំងក្នុងពេលអវត្តមានរបស់គាត់ ហើយចៅក្រមនេះត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងរួចហើយ។ *សូមមើលផងដែរ* យោបល់របស់ ចៅក្រម DOWNING និង CHUNG កថាខណ្ឌ ៣៥-៣៦ ដែលចៅក្រមទាំងពីរបានកត់សម្គាល់បន្ថែមថា ចៅក្រម Judge KASPER-ANSERMET បានបំពេញលក្ខខណ្ឌទាំងពីរនេះ ដោយហេតុថា គាត់ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេត អន្តរជាតិបម្រុងរួចហើយ និងបានជំនួសចៅក្រម BLUNK ដែលបានអវត្តមានក្រោយពេលលាឈប់ពីតំណែងរបស់គាត់។

[532] យោបល់របស់ចៅក្រម CHUNG និង DOWNING កថាខណ្ឌ ៤៥។ ពាក់ព័ន្ធនឹងមូលដ្ឋាននៃការខ្វែងយោបល់គ្នាស្ដីពីភាពអាច ទទួលយកបាននៃដីកាសម្រេចស្ដីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ក្នុងសំណុំរឿង ០០៣ ចៅក្រម CHUNG និង DOWNING គូសបញ្ជាក់ឡើងវិញថា មិនត្រូវការនីតិវិធីបន្ថែមណាមួយក្នុងការចូលបំពេញមុខងាររបស់ចៅក្រមស៊ើបអង្កេត អន្តរជាតិបម្រុងឡើយ។ សូមមើល យោបល់របស់ចៅក្រម CHUNG និង DOWNING កថាខណ្ឌ ៤៤។ ចៅក្រម CHUNG និង DOWNING លើកឡើងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអាចពិចារណាឡើងវិញនូវសេចក្ដីសម្រេចកន្លងមក យោងតាម

ការខ្វែងយោបល់នេះ និងអនុលោមតាមវិធាន ៧២(៤)(ឃ) យោងមាត្រា ២៣ ថ្មី នៃកិច្ចព្រមព្រៀង អ.វ.ត.ក សេចក្ដីសម្រេចដែលមិនមានសំឡេងគ្រប់គ្រាន់តម្រូវថា ដីកាសម្រេចស្ដីពីការបើកការស៊ើបអង្កេតឡើងវិញក្នុងសំណុំរឿង០០៣ ដែលស្នើដោយចៅក្រម KASPER-ANSERMET ត្រូវតែអនុវត្ត[533]។

២៣៨. ដោយគិតដល់ចំណុចខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គច្បាប់ ដែលសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET ពុំអាចបើកការស៊ើបអង្កេតឡើងវិញក្នុងសំណុំរឿង ០០៣ និងផ្អែកលើកំហុសឆ្គងបែបនេះ បានសម្រេចដោយមិនយកចិត្តទុកដាក់លើសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងភស្តុតាងក្រោយ ខែមេសា ឆ្នាំ២០១១ នៅក្នុងសំណុំរឿង។

(iii) ការស៊ើបអង្កេតពេញលេញក្នុងសំណុំរឿង ០០៣ ត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១

២៣៩. ចៅក្រមអន្តរជាតិងាកមកពិនិត្យលើការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា ការស៊ើបអង្កេតមិនត្រូវបានបញ្ចប់ជាក់ស្តែងត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដោយសារថា ភស្តុតាងភាគច្រើនដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿងក្រោយកាលបរិច្ឆេទនោះ [534]។ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតជាតិអះអាងថា គាត់ និងសហចៅក្រម

---

យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និងយុត្តិសាស្ត្រអន្តរជាតិ។ សូមមើល យោបល់របស់ចៅក្រម CHUNG និង DOWNING កថាខណ្ឌ ៤៦ យោងទៅលើ ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ (D28) កថាខណ្ឌ ៤ និងដកស្រង់ សំណុំរឿង០០២ (អបជ០៣) សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ C22/I/68 កថាខណ្ឌ ២៥ (យោងទៅលើយុត្តិសាស្ត្រពី ICTY ឧទាហរណ៍ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *MiloÈević* សំណុំរឿងលេខ IT-02-54-T សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំឲ្យពិចារណាសារជាថ្មីលើភ័ស្តុតាងរបស់សាក្សីដោះបន្ទុក Mitar Balević, Vladislav Jovanović, Vukasin Andrić និង Dobre Aleksovski អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៦។ តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Galić* សំណុំរឿងលេខ IT-98-29-AR73 សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតប្តឹងសាទុក្ខអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១ កថាខណ្ឌ ១៣។ តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Mucić* និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-96-2l-Abis សាលដីកាលើបណ្តឹងសាទុក្ខចំពោះការផ្តន្ទាទោស ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣ កថាខណ្ឌ ៤៩)។

[533] យោបល់របស់ចៅក្រម CHUNG និង DOWNING កថាខណ្ឌ ៥០។

[534] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៤៩-៥៧។

ស៊ើបអង្កេតអន្តរជាតិ BLUNK បានបញ្ចប់កិច្ចស៊ើបសួរត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ហេតុនេះបានចេញសេចក្តីជូនដំណឹងឆ្នាំ២០១១ តាមវិធាន ៦៦(១) ដើម្បីបញ្ចប់កិច្ចស៊ើបសួរ[535]។ សហចៅក្រមស៊ើបអង្កេតជាតិបន្ថែមថា "គាត់នៅតែរក្សាជំហរ [ថាការស៊ើបអង្កេតបានបញ្ចប់] និងអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការពិចារណាតែភស្តុតាងទាំងឡាយណាដែលបានដាក់បញ្ចូល [ទៅក្នុងសំណុំរឿង] នៅមុនថ្ងៃបិទការស៊ើបសួរដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប [រូបគាត់ និងចៅក្រម BLUNK] តែប៉ុណ្ណោះ"[536]។

២៤០. ជាបញ្ហាបឋម ចៅក្រមអន្តរជាតិកត់សម្គាល់ថា សេចក្តីសម្រេចក្នុងការបំពេញ ឬ ដូចក្នុងករណីនេះ ក្នុងការមិនបំពេញកិច្ចស៊ើបសួរ ស្ថិតក្នុងដែនឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[537]។ ប៉ុន្តែសិទ្ធអំណាចរបស់ពួកគេមិនមែនពុំមានការកំណត់នោះទេ ដោយហេតុថា វាត្រូវតែអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ច្បាស់[538] និងអាចស្ថិតក្រោមការពិនិត្យលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ[539]។

២៤១. ចៅក្រមអន្តរជាតិរម្លឹកថា អនុលោមតាមវិធាន៥៥(៥) "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត"[540]។ ចៅក្រមអន្តរជាតិ

---

535 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៩។

536 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥៩។

537 *សូមមើល* វិធាន៥៥ (១០) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សាលដីកាលើសំណើសុំដាក់បញ្ចូលភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង (D313/2/2) កថាខណ្ឌ ១៥។

538 សំណុំរឿង០០២ (អបជ២៤) សាលដីកាលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងឯកសារផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ (D164/4/13) កថាខណ្ឌ ២៥-២៧ យោងទៅលើ តុលាការ ICTY រឿងក្តី *MiloĖević តទល់រដ្ឋអាជ្ញា* សំណុំរឿងលេខ IT-02-54-AR73.7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការតែងតាំងមេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ៩-១០។

539 វិធាន ៧៤ (៣) នៃវិធានផ្ទៃក្នុង។

540 វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ សូមមើល ឧទាហរណ៍ សំណុំរឿង០០២ (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ២៤-២៥។ សំណុំរឿង០០៤ (អបជ៣៣) សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយរបស់ អោ អាន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ២១។

បញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលចាំបាច់ ដើម្បីស្វែងរកការពិតនៅក្នុងការបើកកិច្ចស៊ើបសួរ *ទាំងមូល*។ វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងក៏កំណត់កាតព្វកិច្ចដល់សហចៅក្រមស៊ើបអង្កេត "ត្រូវដឹកនាំកិច្ច ស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ"[541]។ ក្នុងន័យម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចអនុលោមតាមវិធាន ៥៥(៥) ក្នុងការស៊ើបអង្កេតទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[542]។ ហេតុដូច្នេះ ដូចដែលអង្គជំនុំជម្រះបានសន្និដ្ឋានកន្លងមកហើយថា សហចៅក្រមស៊ើបអង្កេតមាន "កាតព្វកិច្ចបឋមក្នុងការបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួនមុនពេលវាយតម្លៃថាតើ ការចោទប្រកាន់មានគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់"[543]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសង្កត់ធ្ងន់ថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចជាសារវ័ន្តក្នុងការស៊ើបអង្កេតរឿងក្តីដោយពេញលេញ និងពិចារណាលើភស្តុតាង ទាំងមូលនៅក្នុងសំណុំរឿង។ លើសពីនេះទៀត ចៅក្រមអន្តរជាតិរម្លឹកថា សហចៅក្រមស៊ើបអង្កេតអាច យកចិត្តទុកដាក់លើភស្តុតាងនានា ប្រសិនបើចាត់ទុកថាមានវិការៈនីតិវិធី និងប៉ះពាល់សិទ្ធិរបស់ភាគីដោយពុំចាំបាច់យកមកឱ្យអង្គជំនុំជម្រះធ្វើមោឃភាពអនុលោមតាមវិធាន ៧៦(១)[544]។

---

[541] វិធាន ៥៥នៃវិធានផ្ទៃក្នុង។ (៥)

[542] សំណុំរឿង០០២ សាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 ("សំណុំរឿង០០២ សាលដីកាលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (D164/3/6)") កថាខណ្ឌ ៣៥។

[543] សំណុំរឿង០០២ សាលដីកាលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (D164/3/6) កថាខណ្ឌ ៣៦។ នៅក្នុងន័យនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការកំណត់ថាតើ អ.វ.ត.ក មានយុត្តាធិការបុគ្គលទៅលើជនត្រូវចោទ ឬយ៉ាងណា ហើយត្រូវផ្អែកលើការពិចារណាយ៉ាងត្រឹមត្រូវចំពោះភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ សំណុំរឿង០០២ សាលដីកាលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (D164/3/6) កថាខណ្ឌ ៣៥។ (អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសាលដីកាដែលត្រូវដកស្រង់នេះ ខ្លួនបានបដិសេធចោលនូវបទដ្ឋាននៃ "ភាពគ្រប់គ្រាន់" របស់សហចៅក្រមស៊ើបអង្កេត ដោយយល់ឃើញថា "ជាកិច្ចស៊ើបសួរ មិនអាចបញ្ចប់បានឡើយ រហូតដល់ "កិច្ចស៊ើបសួរទាំងអស់ [...] ចាំបាច់ដើម្បីបង្ហាញការពិត" ត្រូវបានបំពេញ"។

[544] *សូមមើល* សំណុំរឿង០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1/20) កថាខណ្ឌ ៤៧។ ("អង្គបុរេជំនុំជម្រះសូមរំឭកថា ប្រសិនបើមានភស្តុតាងណាមួយ ត្រូវបានចាត់ថាមានកំហុសឆ្គងផ្នែកនីតិវិធី និងរំលោភបំពានទៅលើសិទ្ធិរបស់ភាគី សហចៅក្រមស៊ើបអង្កេតមិនអាចមិនពិចារណាទៅលើភស្តុតាងនោះ ដោយមិនបញ្ជូនមកអង្គបុរេជំនុំជម្រះ ដើម្បីស្នើសុំធ្វើមោឃភាព ផ្អែកតាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុងឡើយ")។

២៤២. តាំងពីដំបូងមក ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា មានសំណុំរឿងតែមួយគត់ដែលមានលក្ខណៈពិសេសខុសពីសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក។ ដូចដែលសហចៅក្រមស៊ើបអង្កេតជាតិបានទទួលស្គាល់គឺថា សហចៅក្រមស៊ើបអង្កេតទាំងពីរអាចពិនិត្យមើលសំណុំរឿងទាំងនេះបាន នៅពេលស្ថិតក្នុងការគ្រប់គ្រងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[545]។ ជាងនេះទៀត ចៅក្រមអន្តរជាតិសង្កេតនូវដំណើរវិវឌ្ឍន៍នៃកិច្ចស៊ើបសួរ រួមទាំងកិច្ចស៊ើបសួរទៅលើឧក្រិដ្ឋកម្មជាទ្រង់ទ្រាយធំដែលស្ថិតក្នុងយុត្តាធិការជាក់ស្តែងរបស់ អ.វ.ត.ក គឺ៖ ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌអាចបោះជំហានទៅមុខដោយមានការរកឃើញនូវភស្តុតាងថ្មីៗ តែក៏មានការផ្អាកមួយរយៈដោយសារមានភាពតានតឹងខ្លាំង តាមរយៈការដកភស្តុតាងជាច្រើនភ្លាមៗ ឧទាហរណ៍ នៅពេលរកឃើញសាក្សីដែលត្រូវបានព្យាយាមស្វែងរកជាយូរមកហើយ។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតជាតិមិនត្រូវបានអនុញ្ញាតឱ្យសំអាងលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបដិសេធមិនពិចារណាទៅលើភស្តុតាងដែលប្រមូលបានក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នោះទេ និងសង្កេតបែបអកម្មចំពោះការប្រមូល និងដាក់បញ្ចូលកំណត់ហេតុចម្លើយជាក់លាក់នៃសំណុំរឿង ០០៣ និងឯកសារផ្សេងៗទៀត ដែលមានយ៉ាងហោចណាស់ជាច្រើនរយ[546] នៅក្នុងសំណុំរឿងដែលស្ថិតក្នុងក្រោមការគ្រប់គ្រងរបស់គាត់ ក្នុងអំឡុងពេលជាង ៧ ឆ្នាំ ដោយមិនចាត់ទុកថាវាជាផ្នែកនៃកាតព្វកិច្ចរបស់គាត់ក្នុងការពិនិត្យទៅលើឯកសារទាំងនោះបានទេ។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់ធ្ងន់ធ្ងរ ដោយអះអាងថា ការស៊ើបអង្កេតបានបញ្ចប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងដោយផ្អែកលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនយកចិត្តទុកដាក់ទៅលើភស្តុតាងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ទាំងស្រុងនៅក្នុងសំណុំរឿង។ កំហុសនេះ បានប៉ះពាល់ជាមូលដ្ឋានទៅលើសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់តាំងពីដំបូងមក។

២៤៣. អនុលោមតាមការលើកឡើងខាងលើ ចៅក្រមអន្តរជាតិពិចារណាឃើញថា ពុំចាំបាច់ពិនិត្យទៅលើអង្គសេចក្តីនៃការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ការពុំបានវាយតម្លៃទៅលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿងមានអានុភាពជាកត្តាកំណត់ទៅលើការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតជាតិចំពោះយុត្តាធិការបុគ្គល នោះឡើយ។ ចៅក្រមអន្តរជាតិរម្លឹកថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រម

[545] សហចៅក្រមស៊ើបអង្កេតជាតិបានប្រកាសថា សហចៅក្រមស៊ើបអង្កេត "នៅមានសំណុំរឿងក្នុងដៃ រហូតដីកាដំណោះស្រាយត្រូវបានបញ្ជូនចេញ" *សូមមើល* ដីកាលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៨។

[546] ការប៉ាន់ស្មាននេះផ្អែកលើការស្រាវជ្រាវនៅក្នុងប្រព័ន្ធ Zylab និងការពិនិត្យទៅលើខ្លឹមសារនៃសំណុំរឿង ០០៣ ចន្លោះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

ស៊ើបអង្កេតជាតិថាតុលាការពុំមានយុត្តាធិការបុគ្គលលើ មាស មុត គឺផ្អែកលើការពិនិត្យទៅលើភស្តុតាងមួយផ្នែកដែលគាត់បានទទួលយកនៅក្នុងសំណុំរឿងតែប៉ុណ្ណោះ[547]។

២៤៤. សរុបមក ចៅក្រមអន្តរជាតិសូមតម្កល់មូលដ្ឋាន ខ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ។

(ខ) មូលដ្ឋាន គ

២៤៥. នាពេលនេះ ចៅក្រមអន្តរជាតិនឹងងាកមកពិភាក្សាអំពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់ ដោយពុំបានពិចារណា និងចេញសេចក្តីសម្រេចទៅលើអង្គហេតុទាំងអស់ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៣[548]។ ជាលទ្ធផល គាត់ពន្យល់ថា អង្គហេតុមួយចំនួនដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដែលពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០៣ ព្រមទាំងការទទួលយកមកពិនិត្យដោយការិយាល័យសហចៅក្រមស៊ើបអង្កេត មិនត្រូវបានយកមកពិចារណាដោយសហចៅក្រមស៊ើបអង្កេតជាតិទេ[549]។ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមថា អង្គហេតុនានាដែលមិនត្រូវបានដោះស្រាយ មានភាពធ្ងន់ធ្ងរជាខ្លាំងដល់ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌប្រឆាំងនឹង មាស មុត[550]។

២៤៦. ជាបឋម ចៅក្រមអន្តរជាតិរម្លឹកថា អនុលោមតាមវិធាន ៥៥(២) មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលមានសង្គតិភាពលើចំណុចនេះ នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចថាតើត្រូវលើកលែងចោទប្រកាន់ ឬបញ្ជូនរឿងទៅជំនុំជម្រះ តែចំពោះការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលចៅក្រមទទួលវិនិច្ឆ័យ[551]។ ចៅក្រមអន្តរជាតិអះអាងសាជាថ្មីថា សេចក្តី

---

[547] ដីកាលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៥៤។

[548] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៦៣-៨២។

[549] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៦៤-៦៩។

[550] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៧០-៨២។

[551] វិធាន ៥៥ (២) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា មាត្រា ១២៥។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំណុំរឿង ០០១ (D99/3/42) កថាខណ្ឌ ៣៥-៣៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួន (D165/2/26)។ យោបល់របស់ចៅក្រម BEAUVALLET និង BAIK កថាខណ្ឌ ១៧៥។

សម្រេចនេះពុំតម្រូវឱ្យប្រើអំណាចឆន្ទានុសិទ្ធិណាមួយឡើយ[552]។ ចៅក្រមអន្តរជាតិសង្កត់ធ្ងន់ថា "សហចៅក្រមស៊ើបអង្កេតក៏ទទួលយកបានកាលៈទេសៈ ជុំវិញអំពើទាំងឡាយដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ កាលៈទេសៈ ដែលគេចោទថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ហើយនាំដល់ការកំណត់បទចោទ មិនត្រូវបានគេយល់ឃើញថា ជាអង្គហេតុថ្មីឡើយ។ ដូច្នេះហើយ កាលៈទេសៈទាំងនេះជាផ្នែកមួយនៃការស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេត យកបទចោទទាំងនោះដែលសហព្រះរាជអាជ្ញាស្នើឡើង មកប្រើប្រាស់ជាត្រីវិស័យ ក្នុងការកំណត់វិសាលភាពនៃការស៊ើបសួរ"[553]។

២៤៧. ចៅក្រមអន្តរជាតិ ដំបូងឡើយ សង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណា "តែអង្គហេតុចំនួនប្រាំពីរ (៧) នៃអង្គហេតុ [ចំនួនដប់(១០)]" ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួន[554] ដោយហេតុថា បើតាមការយល់ឃើញរបស់គាត់គឺថា មានអង្គហេតុតែ ៨ ប៉ុណ្ណោះដែលពាក់ព័ន្ធនឹង មាស មុត ហើយចំណែក "អង្គហេតុទាក់ទងនឹងការបង្ក្រាបក្នុង

---

សំណុំរឿង ០០៤ សេចក្តីពិចារណាលើសំណើសុំធ្វើមោឃភាពកិច្ចស៊ើបសួរទាក់ទងនឹងទំនប់កង្ហត (D345/1/6)។ យោបល់ចៅក្រម BEAUVALLET និង BAIK កថាខណ្ឌ ២៤-២៦។ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន កថាខណ្ឌ ៣៩។ *សូមមើលផងដែរ* ឧទាហរណ៍ សាលាឧក្រិដ្ឋប្រទេសបារាំង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១២ សំណុំរឿងលេខ n¢ 12 81.197 (ពាក់ព័ន្ធនឹងកាតព្វកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបអង្កេត សាលាឧក្រិដ្ឋប្រទេសបារាំង តែងតែអះអាងថាចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតលើអង្គហេតុដែលខ្លួនទទួលវិនិច្ឆ័យ។ កាតព្វកិច្ចនេះអាចបញ្ចប់បាន លុះត្រាតែមានមូលហេតុជំរុញដែលប៉ះពាល់ទៅលើបណ្តឹងអាជ្ញា ដោយផ្អែកលើអង្គហេតុដែលបានចោទប្រកាន់ មិនអាចកាត់សេចក្តីបាន ឬមិនទទួលបានការកំណត់ប្រភេទបទល្មើសណាមួយ)។

[552] សំណុំរឿង០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D99/3/42) កថាខណ្ឌ ៣៧។

[553] សំណុំរឿង០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D99/3/42) កថាខណ្ឌ ៣៥ (លុបជើងទំព័រ)។

[554] ដីកាលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៥៥ (បើតាមការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិ អង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមាន៖ "១. មន្ទីរសន្តិសុខ ស-២១, ២. មន្ទីរសន្តិសុខ ស-២២, ៣. ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង, ៤. មន្ទីរសន្តិសុខវត្តអង្គតាញាណ, ៥. ការដ្ឋានវាយថ្មស្ទឹងហាវ, ៦. ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅលើដែនទឹក និងតាមកោះ ៧. ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម, ៨. កងពលធំ ៨០១ និងមន្ទីរឃុំឃាំង ៨១០, ៩. មន្ទីរសន្តិសុខផ្សេងទៀតរបស់កងទ័ពបដិវត្តកម្ពុជា និងទីកន្លែងផ្សេងទៀត, ១០. ការបោសសម្អាតនៅក្នុងកងពល ១៦៤")។

កងពលលេខ ៨០១ និងមន្ទីរសន្តិសុខ ៨១០ ជាអង្គហេតុទាក់ទងគ្នា"[555]។ ចៅក្រមអន្តរជាតិ បញ្ជាក់ថា ផ្ទុយពីការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ យោងយ៉ាងច្បាស់ទៅលើអង្គហេតុយ៉ាងតិចចំនួន ១១ (ដប់មួយ) មិនមែន ១០ (ដប់) ទេ៖ ១. មន្ទីរសន្តិសុខ ស-២១, ២. ការបោសសម្អាតនៅកងពលធំ ៥០២, ៣. មន្ទីរសន្តិសុខ ស-២២, ៤. ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង, ៥. ការបោសសម្អាតនៅកងពលធំ ១៦៤, ៦. មន្ទីរសន្តិសុខវត្តអង្គតាញាណ, ៧. ការដ្ឋានវាយថ្មស្ទឹងហាវ, ៨. កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ, ៩. ប្រទេសវៀតណាម, ១០. កងពលធំ ៨០១, ១១. មន្ទីរសន្តិសុខផ្សេងទៀតរបស់កងទ័ពបដិវត្តកម្ពុជា និងទីកន្លែងបោសសម្អាតផ្សេងទៀត[556]។ ទីពីរ និងសំខាន់ជាងនេះ ចៅក្រមអន្តរជាតិសង្កេតឃើញថា ទោះបីសហចៅក្រមស៊ើបអង្កេតជាតិអះអាងថា គាត់បានពិចារណាទៅលើអង្គហេតុ និងការចោទប្រកាន់នានាពាក់ព័ន្ធនឹងការបោសសម្អាតនៅកងពលធំ ១៦៤ ក៏ដោយ តែគាត់មិនបានពិចារណាទៅលើការបញ្ជាក់បំភ្លឺទៅលើកាលៈទេសៈនានា ពាក់ព័ន្ធនឹងការបោសសម្អាតទាំងនោះទេ និងវិសាលភាពនៃការចោទប្រកាន់លើអង្គហេតុជាក់លាក់ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់ជូននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ។ ហេតុនេះ គាត់ពុំបានវាយតម្លៃលើការចោទប្រកាន់ផ្នែកអង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍នៅទីតាំងចម្ការធុរេន[557] ឬការធ្វើឱ្យទៅជាទាសករនៅការដ្ឋានកងកេង[558]។ ជាងនេះទៀត ដោយមិនអើពើចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាំងមូល គាត់មិនបានពិចារណាដល់កាចោទប្រកាន់អង្គហេតុនានាដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅតំបន់កំពង់សោម[559]។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់ដ៏ធ្ងន់ធ្ងរ ដោយខកខានមិនបានដោះស្រាយឱ្យបានត្រឹមត្រូវនូវវិសាលភាពពេញលេញនៃការចោទប្រកាន់ព្រហ្មទណ្ឌ

---

[555] ដីកាលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៥៤។

[556] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (D1) កថាខណ្ឌ ៤២-៦៦។ ចៅក្រមអន្តរជាតិសង្កត់ធ្ងន់ថា សហចៅក្រមស៊ើបអង្កេតជាតិមិនត្រឹមតែលើកឡើងដោយមិនត្រឹមត្រូវនូវចំនួនអង្គហេតុដែលបានដាក់បង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះទេ តែគាត់គណនាមិនត្រឹមត្រូវនូវចំនួនអង្គហេតុពាក់ព័ន្ធនឹង ស្វ៊ូ ម៉េត ដែរ។ ពុំមានអង្គហេតុត្រឹមតែ ០២ (ពីរ) នោះទេ តែមាន ៣ (បី)៖ ១. ការបោសសម្អាតជាទូទៅនៅកងពលធំ ៥០២, ២. មន្ទីរសន្តិសុខ ស-២២, ៣. ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

[557] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (D120) កថាខណ្ឌ ៦។

[558] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (D120) កថាខណ្ឌ ៧-៩។

[559] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (D120) កថាខណ្ឌ ២០-២៤។

ដែលគាត់ទទួលយកមកពិនិត្យ និងប្រកាសថា កំហុសផ្នែកអង្គច្បាប់នេះមានអានុភាពទៅលើសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ នៅក្នុងលក្ខណៈជាមូលដ្ឋាន។

២៤៨. អនុលោមតាមការលើកឡើងខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា ពុំចាំបាច់ដោះស្រាយការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា អង្គហេតុដែលមិនបានដោះស្រាយនឹងបង្កើនទូវភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ[560]។ សរុបមក ចៅក្រមអន្តរជាតិសូមតម្កល់មូលដ្ឋាន គ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ។

(គ) សេចក្តីសន្និដ្ឋាន

២៤៩. ទាក់ទិននឹងការពិនិត្យរបស់ខ្លួនចំពោះមូលដ្ឋាន ខ និង គ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសអង្គច្បាប់មួយឈុត ដោយសម្រេចមិនយកចិត្តទុកដាក់លើការចោទប្រកាន់ផ្នែកអង្គហេតុជាច្រើនដែលខ្លួនទទួលវិនិច្ឆ័យ និងភស្តុតាងដែលដាក់នៅក្នុងសំណុំរឿងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ចៅក្រមអន្តរជាតិសង្កត់ធ្ងន់ថា ការរំលោភកាតព្វកិច្ចរបស់គាត់ ដែលជាកត្តាកំណត់ជាសារវ័ន្តនៃការវាយតម្លៃរបស់គាត់លើសំណុំរឿងនេះ បានមោឃភាពដីកាសម្រេចលើកលែងចោទប្រកាន់ ដែលបង្កើតជាដីកាបង្គាប់ដែលគ្មានទីបញ្ចប់ និងមិនអាចត្រូវបានចាត់ទុកថាជាដីកាដំណោះស្រាយមានសុពលភាព នៅតាមអត្ថន័យនៃវិធាន ៦៧ នៃវិធានផ្ទៃក្នុងទេ។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ថា ពុំចាំបាច់បន្តការពិនិត្យទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីមោឃភាពដែលមានអានុភាពទៅលើដីកាសម្រេចលើកលែងចោទប្រកាន់តាំងពីដំបូងមក ហើយយល់ឃើញថា មូលដ្ឋានផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍ត្រូវទុកជាអសារបង់។

២៥០. លើសពីនេះទៀត ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតជាតិបានធ្វើឲ្យមានកំហុសឆ្គងបែបនេះ ដោយជ្រើសរើសយកការបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១ នៅខណៈដែលការស៊ើបអង្កេតតាមផ្លូវតុលាការនេះត្រូវបានបើកឡើងវិញដោយត្រឹមត្រូវដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ និងបន្តអនុវត្តក្រោមការដឹកនាំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលទទួលតំណែងបន្តបន្ទាប់[561]។

[560] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2) កថាខណ្ឌ ៧០-៨២។

[561] *សូមមើលខាងលើ* កថាខណ្ឌ ២២៨-២៤៣ ។

សហចៅក្រមស៊ើបអង្កេតជាតិនៅតែប្រព្រឹត្តកំហុសឆ្គងដដែលៗ ពាក់ព័ន្ធនឹងការដឹកនាំការស៊ើបអង្កេតអស់រយៈពេលជិត ៧ ឆ្នាំរហូតដល់ចេញដីកាដំណោះស្រាយ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ហេតុនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ជាដីកាសម្រេចមិនពេញលក្ខណៈ ជិតដាមដោយអនីត្យានុកូលភាព ដែលត្រូវចាត់ទុកជាមោឃៈ។

### ii. មូលដ្ឋាន ក, ឃ, ង, ច, ឆ និង ជ

២៥១. ទោះបីជាសហព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទាំងអស់ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតក៏ដោយ[562] តែចៅក្រមអន្តរជាតិសូមរម្លឹកថា នៅក្នុងរឿងក្ដីនេះ សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់ជាច្រើន ដោយជ្រើសរើសមើលរំលងការចោទប្រកាន់លើអង្គហេតុមួយចំនួនដែលគាត់បានទទួល និងភស្តុតាងនានាដែលបានដាក់ក្នុងសំណុំរឿង ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលជាកត្តាកំណត់ជាសារវ័ន្តទៅលើការវាយតម្លៃរបស់គាត់ចំពោះរឿងក្ដី ហេតុនេះធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព[563]។

២៥២. ហេតុនេះ ចៅក្រមអន្តរជាតិសូមប្រកាសថា មូលដ្ឋាន ក, ឃ, ង, ច, ឆ និង ជ នៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ លែងជាការចាំបាច់ទៀតហើយ។

## គ. សេចក្ដីសន្និដ្ឋានអំពីសុពលភាព នៃដីកាដំណោះស្រាយ

២៥៣. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយចោទប្រកាន់បញ្ជូន មាស មុត ទៅជំនុំជម្រះ[564] ចំណែកសហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងការចោទប្រកាន់ប្រឆាំង មាស មុត[565]។ ចៅក្រមអន្តរជាតិសូមរំឭកថា កិច្ចព្រមព្រៀងរវាងសហចៅក្រមស៊ើបអង្កេត លើការចេញដីកាដំណោះស្រាយផ្ទុយគ្នាក្នុងពេលតែមួយនោះ បង្កើតបានជាកំហុសអង្គច្បាប់[566]។

---

[562] សូមមើលខាងលើ កថាខណ្ឌ ៥១, ៥៣ យោងទៅវិធាន ៦៧(៥), ៧៤(២) នៃវិធានផ្ទៃក្នុង។

[563] សូមមើលខាងលើ កថាខណ្ឌ ២២៦-២៥០។

[564] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267)។

[565] ដីកាសម្រេចលើកលែងការចោទប្រកាន់ (ឯកសារ D266)។

[566] សូមមើលខាងលើ កថាខណ្ឌ ៧៨-១០៩ ។

01667416



២៥៤. ចៅក្រមអន្តរជាតិកត់សម្គាល់សារណាដែលបានដាក់ជូន ដោយសហព្រះរាជអាជ្ញាអន្តរជាតិ និង ចម្លើយតបរបស់សហមេធាវី ពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ក្នុង ពេលតែមួយរបស់សហចៅក្រមស៊ើបអង្កេត[567]។ បន្ថែមលើនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហ ចៅក្រមស៊ើបអង្កេត បានផ្តល់សិទ្ធិអំណាចឲ្យខ្លួនឯងដោយខុសឆ្គងក្នុងការចេញដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧[568] ហើយថាសហចៅក្រមស៊ើបអង្កេត បានកត់ត្រា នូវការខ្វែងយោបល់គ្នារបស់ពួកគេ ពាក់ព័ន្ធការដាក់ដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា ប្រហែលជាមួយឆ្នាំក្រោយ គឺនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨[569]។ ដោយកត់សម្គាល់អំពីការសម្រេចនេះ ចៅក្រមអន្តរជាតិនាពេលនេះនឹងពិភាក្សាអំពីសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ។

### ១. ច្បាប់ពាក់ព័ន្ធ និងការអនុវត្តក្នុងសំណុំរឿងបច្ចុប្បន្ន

#### ក. អត្ថន័យនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្ត" មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

២៥៥. ចៅក្រមអន្តរជាតិជាដំបូងសូមរំឭកថា សហចៅក្រមស៊ើបអង្កេតមួយរូប អាចចេញដីកាបញ្ជូនរឿង ទៅជំនុំជម្រះ ដោយបំពេញកិច្ចតែម្នាក់ឯង ដោយសុពលភាព[570]។ ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមថា មាត្រា ៥(៤) នៃ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត

---

[567] សំណុំរឿង ០០៣ សេចក្តីសម្រេចអំពីការខ្វែងយោបល់ (*D262.2*) កថាខណ្ឌ ១៣-១៥។

[568] ដីកាសម្រេចលើកលែងចោទ (D267) កថាខណ្ឌ ២៧

[569] សូមមើលខាងលើ កថាខណ្ឌ ២២៣-២២៥។

[570] សូមមើល វិធាន ១(២) នៃវិធានផ្ទៃក្នុង ("លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យ សហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើប អង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង")។ សូមមើលជាឧទាហរណ៍ សំណុំរឿង ០០៤/ ២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ១០៥។ សំណុំ រឿង ០០៤/២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងការបដិសេធសំណើសុំព័ត៌មាន (ឯកសារ D208/1/1/2) កថា ខណ្ឌ ១១។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើសុំឲ្យការអនុវត្តដីកាកោះហៅ (ឯកសារ A122/6.1/3) កថាខណ្ឌ ១៤។ សំណុំរឿង ០០៤/១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងដីកាកោះហៅ (ឯកសារ D236/1/1/8), កថាខណ្ឌ ៣០។

.ក ដែលចែងថា ក្នុងករណីមានការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត "ការស៊ើបអង្កេតត្រូវធ្វើបន្ត" លើកលែងតែសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬតែមួយរូប បានបញ្ជូនការខ្វែងយោបល់របស់ពួកគេទៅអង្គបុរេជំនុំជម្រះ[571]។

២៥៦. ចៅក្រមអន្តរជាតិកត់សម្គាល់ថា គោលការណ៍នៃការបន្តការស៊ើបអង្កេតតាមផ្លូវតុលាការនេះ គ្រប់គ្រងលើបញ្ហាដែលនៅចំពោះមុខពេលនេះ។ ទោះបីជានីតិវិធី ដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង អាចមិនត្រូវបានអនុវត្ត ចំពោះនីតិវិធី *បន្ទាប់ពី* ការចេញដីកាដំណោះស្រាយក្តី តែមិនមានការរារាំងការអនុវត្ត ចំពោះនីតិវិធីនៃ*ការចេញ*ដីកាដំណោះស្រាយ នៅមុនពេលបិទបញ្ចប់ការស៊ើបអង្កេតឡើយ[572]។ ដូចដែលបានបញ្ជាក់ដោយអង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចកន្លងមក ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតមួយរូប បានស្នើចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតមួយរូបទៀតមិនយល់ស្រប សហចៅក្រមស៊ើបអង្កេតមួយរូប ឬទាំងពីររូប អាចបញ្ជូនការខ្វែងយោបល់គ្នា មកអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង[573]។ ចៅក្រមអន្តរជាតិសូមរំឭកបន្ថែម អំពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលថា "ប្រសិនបើអង្គបុរេជំនុំជម្រះ សម្រេចថាសហចៅក្រមស៊ើបអង្កេតណាមួយ មានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬមិនមែនជាជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំ

---

[571] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៥(៤) ("សហចៅក្រមស៊ើបអង្កេត ត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយ ក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេត មិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧") (ដោយគូសបញ្ជាក់បន្ថែម)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី កថាខណ្ឌ ៣ ("ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្តឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នា ត្រូវដោះស្រាយដោយអនុវត្តតាម បទប្បញ្ញត្តិដូចខាងក្រោម") (ដោយគូសបញ្ជាក់បន្ថែម)

[572] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ")។

[573] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ៩៥, ១១៦។

ជម្រះ មិនអាចទទួលបានសម្លេងគាំទ្រភាគច្រើនលើសលប់ ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ""[574]។

២៥៧. ចំពោះករណីបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេត មិនបានបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះទេ ក្នុងរយៈពេល៣០ថ្ងៃ[575] ចាប់តាំងពីពេលដែលបានចុះបញ្ជី ការខ្វែងយោបល់គ្នា នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨។ ក្នុងស្ថានភាពជាក់លាក់នេះ ដែលសហចៅក្រមស៊ើបអង្កេតមួយរូប បានស្នើចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតមួយរូបទៀត មិនយល់ស្រប "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" គឺជាស្ថានភាពជាក់ស្តែងជាធរមាន ក្នុងករណីមានការមិនយល់ស្រប ដែលមិនអាចដោះស្រាយបាន រវាងសហចៅក្រមស៊ើបអង្កេត ដែលមានន័យថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចាំបាច់ត្រូវចេញ ដូចដែលបានស្នើឡើង[576]។

២៥៨. បន្ថែមលើនេះ ក្នុងការត្រួតពិនិត្យលើអត្ថន័យនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្ត" ចៅក្រមអន្តរជាតិសម្រេចថា មិនមាននរណាម្នាក់អាចបកស្រាយដោយសមហេតុផលនូវពាក្យពេចន៍នេះ ក្នុងអត្ថន័យទូទៅរបស់វា និងដោយផ្អែកលើគោលដៅ និងគោលបំណងរបស់វា ដើម្បីបញ្ចូលនូវការចេញ ដីកាសម្រេចលើកលែងការចោទប្រកាន់ឡើយ[577]។ ទីមួយ ក្នុងន័យទូទៅរបស់ពាក្យពេចន៍នេះ ការស្នើចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ដែលមានលក្ខណៈផ្ទុយទាំងស្រុង ជាមួយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបញ្ជូនសំណុំរឿងទៅជំនុំជម្រះ មិនអាចត្រូវបានទទួលស្គាល់ ថាជាកិច្ចស៊ើបសួរផ្សេងឡើយ។ វាគ្រាន់តែជាការកំណត់ប្រភេទផ្សេង នៃការខ្វែងយោបល់របស់សហចៅក្រមស៊ើបអង្កេតជាតិ ទៅលើការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចាំបាច់ត្រូវដោះស្រាយដោយ នីតិវិធីដោះស្រាយការខ្វែងយោបល់ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ទីពីរ គោលបំណងនៃកិច្ចព្រមព្រៀង ស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺដើម្បីនាំខ្លួនមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត របស់កម្ពុជាប្រជាធិបតេយ្យ *មកជំនុំជម្រះ*ពីបទឧក្រិដ្ឋកម្ម[578]។ ជាការសមហេតុផលក្នុងការទាញសន្និដ្ឋាន ពីពាក្យពេចន៍នៃមាត្រា ៥(៤) មាត្រា

---

[574] សំណុំរឿង ០០១ សាលដីកា (ឯកសារ F28) កថាខណ្ឌ ៦៥ (ដោយគូសបញ្ជាក់បន្ថែម)។

[575] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៥(៤) ។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ ថ្មី វិធាន ៧២(២) នៃវិធានផ្ទៃក្នុង។

[576] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥(៤), ៧(៤) ។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ ថ្មី។

[577] អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១(១) ("សន្ធិសញ្ញាមួយ គួរត្រូវបានបកស្រាយដោយចេតនាល្អ ស្របទៅតាមអត្ថន័យទូទៅដែលមានសម្រាប់ពាក្យពេចន៍ នៃសន្ធិសញ្ញានោះ ក្នុងបរិបទរបស់ពួកគេ និងស្របទៅតាមគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញាណនោះ")។

[578] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ១។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១។

៦(៤) និង មាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០ ថ្មី និង២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ១៣(៥) វិធាន ១៤(៧) វិធាន ៧១ និងវិធាន ៧២ នៃវិធានផ្ទៃក្នុង ថាគោលដៅជាគន្លឹះ នៃយន្តការដោះស្រាយ ការខ្វែងយោបល់គ្នា គឺរារាំងភាពជាប់គាំង ដែលបណ្តាលឲ្យកិច្ចដំណើរការនីតិវិធី ផុតចេញពីការបញ្ជូនទៅជំនុំជម្រះ[579]។

២៥៩. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បើទោះបីជាមានការព្រមព្រៀងគ្នា ដោយខុសឆ្គងរបស់គាត់ លើការចេញដីកាសម្រេច លើកលែងការចោទប្រកាន់ របស់សហការីគាត់ ក្នុងពេលជាមួយគ្នាក្តី គឺអនុលោមផ្នែកនីតិវិធីទៅតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ចំណែកការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺមិនមានមូលដ្ឋានគតិយុត្តិឡើយ។

២៦០. ចៅក្រមអន្តរជាតិអះអាងឡើងវិញថា ដីកាដំណោះស្រាយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែជាសេចក្តីសម្រេចតែមួយ[580]។ ចៅក្រមអន្តរជាតិគូសបញ្ជាក់ថា ក្នុងកាលៈទេសៈបច្ចុប្បន្ន ការបញ្ជូនការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ គឺជាការតម្រូវចាំបាច់ខានមិនបាន ហើយថា សហចៅក្រមស៊ើបអង្កេត មិនមានមធ្យោបាយផ្សេង ក្នុងការដោះស្រាយជម្លោះរបស់ពួកគេឡើយ នៅពេលដែលពួកគេមិនបានគោរពទៅតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងការឈានទៅរកគោលជំហររួមមួយ ពាក់ព័ន្ធដីកាដំណោះស្រាយ[581]។ ចៅក្រមអន្តរជាតិពិចារណាថា ការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ដែលផ្ទុយគ្នា ដោយសហចៅក្រមស៊ើបអង្កេតជាតិ ដោយមិនបញ្ជូនទៅអង្គបុរេជំនុំជម្រះ គឺជាការព្យាយាមដោយឥតអៀនខ្មាស់ ក្នុងការគេចវេសទាំងស្រុង ពីលក្ខខណ្ឌតម្រូវជាចាំបាច់ និងសំខាន់នេះ ដែលធ្វើឲ្យខូចខាតដល់អត្ថបទគតិយុត្តិ ដែលជាមូលដ្ឋានរបស់ អ.វ.ត.ក។ ជាពិសេស

---

[579] ប្រវត្តិនៃការចរចាររបស់ អ.វ.ត. គាំទ្រការបកស្រាយនេះ។ សូមមើលជាឧទាហរណ៍ D. SCHEFFER, "The Extraordinary Chambers in the Courts of Cambodia" (ឆ្នាំ ២០០៨) ទំព័រ ២៣១ ("ក្នុងករណីមិនមានសម្លេងភាគច្រើនលើសលប់ ការស៊ើបអង្កេត ឬអនុសាសន៍ឲ្យបញ្ជូនទៅជំនុំជម្រះត្រូវធ្វើបន្ត")។ D. CIORCIARY & A. HEINDEL, Hybrid Justice (1st Edition, USA, The University of Michigan Press, 2014), ឯកសារ D297.1 ទំព័រ ៣១ ("ដើម្បីគ្រប់គ្រងលើហានិភ័យ នៃការខ្វែងយោបល់គ្នា និងការជាប់គាំងរវាង សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត មន្ត្រីរបស់សហរដ្ឋអាមេរិក បានជម្រុញឲ្យបង្កើត ក្រុមប្រឹក្សាជំនុំជម្រះពិសេស សម្រាប់គោលបំណងនេះ។ មន្ត្រីកម្ពុជា និងអង្គការសហប្រជាជាតិ បានឯកភាពភ្លាមៗ បង្កើតនូវអង្គបុរេជំនុំជម្រះ ដែលរួមមានចៅក្រមកម្ពុជាបីរូប និងចៅក្រមអន្តរជាតិពីររូប ដែលមានសិទ្ធិអំណាចរារាំងកិច្ចស៊ើបសួរ ឬការបញ្ជូនរឿងទៅជំនុំជម្រះ តែតាមរយៈសម្លេងភាគច្រើនលើសលប់ប៉ុណ្ណោះ")។

[580] សូមមើលខាងលើ កថាខណ្ឌ ១០៤ ។

[581] សូមមើលខាងលើ កថាខណ្ឌ ១០១,១០៦ ។

01667420



មាត្រា ៥ និងមាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានចែងយ៉ាងច្បាស់ថា អំពីការណែនាំ ស្តីពី ការប្រព្រឹត្តនិងលទ្ធផលតាមការតម្រូវ របស់សហចៅក្រមស៊ើបអង្កេតជាតិ ចំពោះការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះចៅក្រមអន្តរជាតិសម្រេចថា ការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ដែលជាការព្យាយាមមួយ ដើម្បីគេចចេញពីនីតិវិធីដែលតម្រូវចាំបាច់ សម្រាប់ការខ្វែងយោបល់គ្នា គឺមានកំហុសឆ្គងអង្គច្បាប់ ដែលដូច្នេះហើយត្រូវចាត់ទុកថាមោឃៈនិងអសុពលភាព។

២៦១. បន្ថែមលើនេះ ចៅក្រមអន្តរជាតិមានទស្សនៈថា ទឡ្ហីករណ៍អំពីចន្លោះប្រហោងដែលអាចមាន នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងផលវិបាកគតិយុត្តិ នៃការចេញដីកាដំណោះស្រាយផ្ទុយគ្នា គឺមិនអាចអនុវត្តបានឡើយ ក្នុងសំណុំរឿងបច្ចុប្បន្ន។ បើទោះបីជាអង្គបុរេជំនុំជម្រះ ត្រូវទទួលស្គាល់ថា ស្ថានភាពលម្អៀងបែបនេះ គឺមិនត្រូវបានប្រមើលមើលជាមុន នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក្តី តែភាពមិនជាក់លាក់ដែលចោទឡើង ត្រូវបានលប់បំបាត់ចោល តាមរយៈការបកស្រាយដោយសមស្រប ទៅលើអត្ថបទគតិយុត្តិពាក់ព័ន្ធ ជាពិសេស មាត្រា ៥(៤) និង មាត្រា ៧(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២០ និង២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលតម្កល់គោលការណ៍បន្តកិច្ចស៊ើបសួរ និងការជំនុំជម្រះ[582]។ បន្ថែមលើនេះ ចៅក្រមអន្តរជាតិសូមបញ្ជាក់បំភ្លឺថា យោងតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានច្រានចោលទេនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវមានសុពលភាព កិច្ចដំណើរការនីតិវិធីចាំបាច់ត្រូវបន្ត ហើយសំណុំរឿងចាំបាច់ត្រូវបញ្ជូនទៅជំនុំជម្រះ។

២៦២. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ដីកាដំណោះស្រាយដែលចោទជាបញ្ហាទាំងពីរ គឺមិនដូចគ្នាបេះបិទឡើយ សម្រាប់អនុលោមភាពរបស់វា ទៅតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក។ ចៅក្រមអន្តរជាតិសូមរំឭកថា យោងតាមសំអាងហេតុដែលបានបញ្ជាក់ពីខាងលើ ដីកាសម្រេចលើកលែងការចោទប្រកាន់ គឺមោឃៈ[583] ហើយសន្និដ្ឋានថា ការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺហួសដែនសមត្ថកិច្ច ដែលដូច្នេះហើយគឺត្រូវមោឃភាព ដោយសារនេះជាគឺការព្យាយាម ធ្វើឱ្យខូចខាតគោលជំហរជាក់ស្តែង ដែលមានចែងនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ ផ្ទុយទៅវិញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសុពលភាព ដោយសារតែដីកានេះនៅបន្ត អនុលោមភាពរបស់ខ្លួន ជាមួយគោលជំហរជាក់ស្តែងដូចបានបញ្ជាក់ខាងលើ។

[582] សូមមើលខាងលើ កថាខណ្ឌ ២៥៥-២៥៦។

[583] សូមមើលខាងលើ កថាខណ្ឌ ២២៩-២៥០។

## ខ. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០៤/២ មិនមានអានុភាពទៅលើសំណុំរឿងបច្ចុប្បន្នឡើយ

២៦៣. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លើបណ្តឹងសាទុក្ខភ្លាមៗ ក្នុងសំណុំរឿង ០០៤/២ បានប្រកាសថា អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆន្ទថា "ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញជាដីកាដំណោះស្រាយពីដាច់ដោយឡែក ហើយផ្ទុយគ្នា ចាត់ទុកជាមោឃភាព"[584] ហើយជាលទ្ធផលគឺច្រានចោលបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ លើអង្គសេចក្តី[585]។ បន្ទាប់ពីឈានដល់សេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មិនបានទទួលផ្នែករដ្ឋបាល នូវសំណុំរឿង ០០៤/២ និងបន្ទាប់ពីការសម្រេចរបស់ខ្លួនថា "ពុំមានដីកាដំណោះស្រាយណាមួយ មានសុពលភាពឡើយ" អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា "រឿងក្តីប្រឆាំងនឹង អោ អាន ត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក"[586]។

២៦៤. នៅថ្ងៃបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូល បានចេញ "សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ចាត់វិធានការចាំបាច់ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងផ្លូវច្បាប់ នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២" ("សេចក្តីសម្រេចលើសំណើសុំ ចាត់វិធានការចាំបាច់ របស់ដើមបណ្តឹងរដ្ឋប្បវេណី"[587]។ អង្គជំនុំជម្រះតុលាការកំពូល បានអះអាងថា សំណុំរឿង ០០៤/២ "ត្រូវបានបញ្ចប់ដោយអានុភាព នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"[588] ហើយបានសង្កត់ធ្ងន់ឡើងវិញ អំពីទស្សនៈរបស់អង្គជំនុំជម្រះដែលថា "ដូច្នេះ ជៀសពុំរួចពីការពិតដែលថា ពុំមានដីកាដំណោះស្រាយសុពលភាពចាំបាច់មួយ

---

[584] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥៣។

[585] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) ផ្នែកសម្រេចសេចក្តី ទំព័រ ២៤។

[586] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៧១(៥) និង (៦)។

[587] សំណុំរឿង ០០៤/២/០៧ -០៩ -២០០៩ អវតក/អជតក សេចក្តីសម្រេចលើសំណើ របស់មេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ចាត់វិធានការចាំបាច់ ដើម្បីការពារសិទ្ធិជាមូលដ្ឋាន របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងផ្លូវច្បាប់ នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/6 ("សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើសុំ ចាត់វិធានការចាំបាច់ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E004/2/6)")

[588] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើសុំ ចាត់វិធានការចាំបាច់ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E004/2/6) កថាខណ្ឌ ២២។

ត្រូវបានសម្របសម្រួល ដោយទទួលបានការយល់ឃើញ និងការប្រកាសជាឯកច្ឆន្ទ ពីអង្គបុរេជំនុំជម្រះនោះឡើយ"[589]។

២៦៥. គោលជំហរជារួមរបស់អង្គជំនុំជម្រះតុលាការកំពូល ហាក់ដូចជាពឹងផ្អែកទៅលើសសរស្តម្ភស្នូលពីរ៖ ទីមួយគឺ អង្គជំនុំជម្រះសាលាដំបូង មិនបានទទួលផ្នែករដ្ឋបាល នូវសំណុំរឿង ០០៤/២ ដោយសារតែសំណុំរឿង មិនត្រូវបាន "បញ្ជូនជាផ្លូវការ" តាមរយៈ "យន្តការផ្នែករដ្ឋបាល និងនីតិវិធីសមស្រប"[590] ហើយជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូង មិនមានសំណុំរឿងនៅចំពោះមុខខ្លួន ហើយមិនអាចបិទបញ្ចប់ដោយប្រសិទ្ធិភាព នូវកិច្ចដំណើរការនីតិវិធី[591] និងទីពីរ ការកំណត់ប្រភេទដោយ អង្គជំនុំជម្រះតុលាការកំពូល ទៅលើការសម្រេចជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធ ដីកាដំណោះស្រាយចំនួនពីរ ថាជាការប្រកាសផ្លូវច្បាប់អំពី "មោឃភាព"[592] ដែលមានន័យថាដីកាដំណោះស្រាយទាំងពីរ ត្រូវបានសម្រេចដាច់ខាតថា "គ្មានសុពលភាព" និង "ពុំមានអានុភាពផ្លូវច្បាប់" ឡើយ[593]។

២៦៦. ចៅក្រមអន្តរជាតិនៅទីនេះ នឹងពិភាក្សាតែទៅលើសសរស្តម្ភទីពីរ ដែលពាក់ព័ន្ធជាមួយផ្នែកនេះ[594]។ ចៅក្រមអន្តរជាតិ នឹងពិភាក្សាអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការបិទបញ្ចប់

---

[589] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើសុំ ចាត់វិធានការចាំបាច់ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E004/2/6) កថាខណ្ឌ ២១។

[590] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៤៩-៥០។

[591] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥៧។

[592] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥៣។

[593] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៧។

[594] ចំពោះសសរស្តម្ភទីមួយ ដែលជាស្នូលនៃសាលដីកា របស់អង្គជំនុំជម្រះតុលាការកំពូល ចៅក្រមអន្តរជាតិ សូមបញ្ជាក់ឡើងវិញថា ដំណាក់កាលចាំបាច់តាមការតម្រូវទាំងអស់ សម្រាប់ការបញ្ជូនសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន។ សូមមើល សំណុំរឿង ០០៤/២ ទម្រង់ណែនាំការដាក់ឯកសារ និងការជូនដំណឹង ពាក់ព័ន្ធ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) ឧបសម្ព័ន្ធ ក នៃអនុស្សរណៈរបស់ចៅក្រមអន្តរជាតិ ពាក់ព័ន្ធការបញ្ជូនសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/36.1 និង D360/45.1។ សំណុំរឿង ០០៤/២ ទម្រង់សេចក្តីណែនាំលើការជូនដំណឹង ដែលចេញដោយក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ជូនទៅផ្នែកគ្រប់គ្រងតុលាការ សម្រាប់ជូនដំណឹងអំពី សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) ជូនទៅអង្គជំនុំជម្រះសាលាដំបូង ឧបសម្ព័ន្ធ ៤ អនុស្សរណៈអន្តរការិយាល័យ របស់ចៅក្រមអន្តរជាតិ BAIK និង BEAUVALLET ពាក់ព័ន្ធ ការបញ្ជូនសំណុំរឿង ០០៤/២ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឯកសារ D359/36.4 និង D360/45.4។ សូមមើលផងដែរ ទិដ្ឋភាពទូទៅនៃច្បាប់ជាធរមាន និងហេតុការណ៍ពាក់ព័ន្ធ ការបញ្ជូនសំណុំរឿង០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង៖ សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យ របស់

សំណុំរឿង ០០៤/២ បើទោះបីជាខ្លួនមានទស្សនៈច្បាស់លាស់ថា មិនមានដីកាដំណោះស្រាយណាមួយ ដែលមានអត្ថិភាពដោយសុពលភាព នៅក្នុងសំណុំរឿង ០០៤/២ ក្តី។

i. ការបែងចែកគ្នានូវសមត្ថកិច្ចតុលាការ នៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក

២៦៧. ច្បាស់ណាស់ថា អង្គជំនុំជម្រះតុលាការកំពូល មិនបានសម្រេចលើបញ្ហាគតិយុត្តិជាការសម្រេចសេចក្តីជាច្រើន ពាក់ព័ន្ធដំណាក់កាលបុរេជំនុំជម្រះ ដែលនឹងសម្រេចជាសំខាន់ លើបញ្ហាចម្បងដែលថា ដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរ មានអានុភាពតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ ដោយបញ្ជូនយ៉ាងច្បាស់លាស់ នូវបញ្ហាទាំងអស់នេះទៅអង្គបុរេជំនុំជម្រះ[595] អង្គជំនុំជម្រះ

---

ចៅក្រមអន្តរជាតិ BAIK និង BEAUVALLET ពាក់ព័ន្ធការជូនដំណឹងអំពី សេចក្តីពិចារណា របស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២, ឧបសម្ព័ន្ធ ៦ នៃអនុស្សរណៈអន្តរការិយាល័យ របស់ចៅក្រមអន្តរជាតិ BAIK និង BEAUVALLET ពាក់ព័ន្ធការបញ្ជូនសំណុំរឿង ០០៤/២ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារ D359/36.6 និង D360/45.6។ សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យ របស់ចៅក្រមអន្តរជាតិ BAIK និង BEAUVALLET ពាក់ព័ន្ធការបញ្ជូនសំណុំរឿង ០០៤/២ ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/36 និងD360/45។ បន្ថែមលើនេះ ចៅក្រមអន្តរជាតិ បានគូសបញ្ជាក់ថា សសរស្តម្ភទីមួយ ក៏មានកំហុសអង្គច្បាប់ធ្ងន់ធ្ងរដែរ ដែលអាចចាត់ជា និងធ្វើឱ្យច្របូកច្របល់ ភាពផ្លូវការផ្នែករដ្ឋបាល ក្នុងការបញ្ជូនសំណុំរឿង ដែលមានការរារាំងយុត្តាធិការ ដែលហាមឃាត់អង្គជំនុំជម្រះសាលាដំបូង មិនឱ្យបំពេញកិច្ចបាន។ ទោះបីជាអាចមានការព្យាយាម ក្នុងការលើកទឡ្ហីករណ៍ថា សំណុំរឿងគួរត្រូវបានបញ្ជូនទៅ អង្គជំនុំជម្រះសាលាដំបូង ដោយអង្គបុរេជំនុំជម្រះ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង អាចទទួលបានក្តី តែគោលជំហរបែបនេះ គឺមិនមានការគាំទ្រ ហើយផ្ទុយជាមួយ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ទីមួយ បុរេលក្ខខណ្ឌរដ្ឋបាលសុទ្ធសាធ ដែលមានភាពធំធេងបែបនេះ មិនអាចគ្រាន់តែទាញដោយផ្ទុយពីគោលការណ៍ *la compétence de la compétence* (សូមមើលជាឧទាហរណ៍ តុលាការ ICTY, *រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-AR72 សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំដាក់បណ្តឹងសាទុក្ខបន្ទាន់បង្គំ លើយុត្តាធិការ, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១៨-១៩)។ ទីពីរ អង្គជំនុំជម្រះសាលាដំបូង អាច និងគួរតែបង្គាប់ឱ្យមានការបញ្ជូន សំណុំរឿង ប្រសិនបើអង្គជំនុំជម្រះពិចារណាថា ខ្លួនត្រូវការចូលពិនិត្យមើលសំណុំរឿង ដើម្បីដោះស្រាយបញ្ហាបឋម ថាតើអង្គជំនុំជម្រះមានយុត្តាធិការដែរឬទេ ក្នុងការបន្តទៅមុខសម្រាប់ការជំនុំជម្រះ ឬថាតើការជំនុំជម្រះចាំបាច់ត្រូវបញ្ចប់ (សូមមើល វិធាន ៦៩(៣) និង វិធាន ៨៩ នៃវិធានផ្ទៃក្នុង)។ ដោយការសោកស្តាយជាពន់ពេក ចៅក្រមអន្តរជាតិត្រូវបានបង្ខំ ឱ្យធ្វើការសន្និដ្ឋានថា បុរេលក្ខខណ្ឌតម្រូវរដ្ឋបាល អំពីការជូនដំណឹង និងការបញ្ជូន ត្រូវបានតាក់តែងឡើង ដើម្បីជាលេសដ៏ល្អ ក្នុងការធ្វើឱ្យកិច្ចដំណើរការនីតិវិធី ឈានទៅដល់ការបញ្ចប់។ ដោយសារតែក្រឡាបញ្ជី អង្គបុរេជំនុំជម្រះ បានស្នើសុំដោយត្រឹមត្រូវ ឱ្យមានការបញ្ជូនសំណុំរឿង និងឱ្យអង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិចូលពិនិត្យសំណុំរឿង គឺជាការពិបាកយល់ដែលថា ភាពមិនប្រាកដប្រជាផ្នែករដ្ឋបាល អាចរារាំងជារៀងរហូតដល់អង្គជំនុំជម្រះសាលាដំបូង មិនឱ្យទទួលបានសំណុំរឿង។

[595] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៨ (អក្សរទ្រេត គូសបញ្ជាក់លើឯកសារដើម អក្សរដិត ដោយគូសបញ្ជាក់បន្ថែម ហើយជើងទំព័រត្រូវបានលុបចេញ)។ ("ការលើកឡើងរបស់ សហ

01667424



តុលាការកំពូល បានទទួលស្គាល់សមត្ថកិច្ចចុងក្រោយផ្តាច់មុខ និងមានតែមួយគត់របស់ អង្គបុរេជំនុំជម្រះ ក្នុងការសម្រេចលើបញ្ហាគតិយុត្តិ ជាការសម្រេចសេចក្តីទាំងអស់នេះ ដែលពិតជាស្ថិតក្នុងវិសាលភាពនៃ ដំណាក់កាលមុនពេលជំនុំជម្រះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បានបង្ហាញការគោរពរបស់ខ្លួន ចំពោះការបែងចែកដោយប្រុងប្រយ័ត្ន នូវសិទ្ធិអំណាចដែលបានគូសវាសឡើង ក្នុងស្ថាបត្យកម្មតុលាការ របស់ អ.វ.ត.ក។ ដូចគ្នានឹងអង្គជំនុំជម្រះតុលាការកំពូល ដែលបានអនុវត្តសមត្ថកិច្ចស្ថាពរ ដែលមិនអាច ជំទាស់បាន ទៅលើដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ[596] អង្គបុរេជំនុំជម្រះប្រើប្រាស់ សិទ្ធិអំណាចស្ថាពរទៅលើដំណាក់កាលស៊ើបអង្កេត មុនពេលជំនុំជម្រះ[597] គឺជាសិទ្ធិអំណាចដែលទាញ ចេញពីតួនាទីរបស់ខ្លួនក្នុងនាមជាសភាស៊ើបសួររបស់ អ.វ.ត.ក បង្កើតបានជា "យុត្តាធិការចុងក្រោយ បង្អស់ លើដំណាក់កាលបុរេជំនុំជម្រះនៅ អ.វ.ត.ក"[598] និងបិទផ្លូវតវ៉ា[599]។

២៦៨. ជាលទ្ធផល គឺហួសពីវិមតិសង្ស័យដែលថា អង្គជំនុំជម្រះតុលាការកំពូល មិនមានសមត្ថកិច្ចក្នុងការ ច្រានចោល ដីកាសម្រេចលើកលែងការចោទប្រកាន់ ឬដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបាន តម្កល់ ឬមិនត្រូវបានច្រានចោល ដោយសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះនោះ។ ដូចដែលចែងកំណត់ នៅក្នុងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង "លើកលែងតែជាកម្មវត្ថុ នៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវ កែតម្រូវកំហុស នៃការមិនគោរពវិធានបញ្ញត្តិ ក្នុងការស៊ើបសួរ ។ *គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធ ធនឹង កំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះ*

---

ព្រះរាជអាជ្ញាអន្តរជាតិដែលថា *គោលជំហរមិនពេញលេញ* ត្រូវបានគាំទ្រដោយវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលតាម គោលការណ៍ *ច្បាប់ស្តីពីការគ្រប់គ្រងកម្មវត្ថុរឿងក្តីជាក់លាក់* ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានអាទិភាពលើវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ដែលជាវិធានទូទៅ ពាក់ព័ន្ធទៅនឹងដីកាទូទៅ "ជាជាងដីកាចោទប្រកាន់" មិនអាចកំណត់ដាច់ដោយ ឡែកម្នាក់ឯងបានទេ។ នេះនៅតែជាបញ្ហាស្នូល ដែលគួរតែបានដោះស្រាយ ដោយអង្គបុរេជំនុំជម្រះ។ ប្រហាក់ប្រហែលគ្នានេះ ដែរ បញ្ហាថាតើ វិធានធ ១(២) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតចៅក្រមស៊ើបអង្កេត បំពេញកិច្ចជាលក្ខណៈបុគ្គលនីមួយៗ នៅតែពុំ ទាន់បានដោះស្រាយ ដោយអង្គបុរេជំនុំជម្រះ"។

[596] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៤។

[597] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ៤៩។

[598] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ៤១។

[599] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០ ថ្មី, វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

*តុលាការកំពូលឡើយ*'[600]។ ចៅក្រមអន្តរជាតិជំទាស់យ៉ាងមុតមាំ ចំពោះការអះអាងដែលថា ស្ថានភាពគតិយុត្តិរបស់ឯកសារបុរេជំនុំជម្រះ អាចត្រូវបានកែប្រែដោយ អង្គជំនុំជម្រះតុលាការកំពូល នៅពេលក្រោយ (*Post hoc*)។

២៦៩. អង្គជំនុំជម្រះតុលាការកំពូល ក៏មិនមានសមត្ថកិច្ច ក្នុងការចងកាតព្វកិច្ចចំពោះអង្គបុរេជំនុំជម្រះអំពីថា តើអ្វីគឺជាសេចក្តីសម្រេចដែលមិនអាចរកសំឡេងភាគច្រើនតាមការតម្រូវរបស់អង្គបុរេជំនុំជម្រះ តាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង នោះឡើយ[601]។ ការប្រព្រឹត្តផ្ទុយទៅនឹងការបែងចែកសិទ្ធិអំណាចតុលាការរបស់ អ.វ.ត.ក នឹងមានផលវិបាកធ្ងន់ធ្ងរ ចំពោះដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក។

២៧០. សរុបសេចក្តីមក ការប្រកាសផ្លូវច្បាប់ របស់អង្គបុរេជំនុំជម្រះ ទៅលើបញ្ហាមុនពេលជំនុំជម្រះ រួមបញ្ចូលផងដែរនូវ សុពលភាព ឬមោឃភាពនៃ ឯកសារបុរេជំនុំជម្រះ និងប្រតិបត្តិការរបស់វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង គឺមានអានុភាពចងកាតព្វកិច្ច និងមានឧត្តមភាព។ ការប្រកាសរបស់អង្គបុរេជំនុំជម្រះ មិនអាចប្តឹងឧទ្ធរណ៍ និងមិនអាចផ្លាស់ប្តូរនៅពេលក្រោយ ដោយស្ថាប័នតុលាការដទៃផ្សេងទៀតនៅ អ.វ.ត.ក ឡើយ។

### ii. ការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើគោលជំហរជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ

២៧១. ការកំណត់ប្រភេទរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើការសម្រេចជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធដីកាដំណោះស្រាយពីរ ថាជាការប្រកាសផ្លូវច្បាប់អំពី "មោឃភាព"[602] បង្ហាញអំពីការបកស្រាយដោយខុសឆ្គង របស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើគោលជំហរជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ។

---

[600] គូសបញ្ជាក់បន្ថែម។

[601] ដូច្នេះ ជាការរំខានយ៉ាងខ្លាំងដែលសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០៤/២ លើសំណើសុំចាត់វិធានការចាំបាច់របស់ដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងហួសពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់ខ្លួនទៀត ក្នុងការអះអាងថា សំណុំរឿងប្រឆាំង អោ អាន "ត្រូវបានបញ្ចប់ដោយអានុភាព នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។ បន្ថែមលើនេះ ការអះអាងបែបនេះ ហាក់ដូចជាផ្ទុយជាមួយការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា "បញ្ចប់" សំណុំរឿងប្រឆាំង អោ អាន នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ សូមមើលសំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៧១(៦)។

[602] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥៣។

២៧២. សេចក្ដីពិចារណារបស់ អង្គបុរេជំនុំជម្រះ ដោយពិនិត្យទាំងស្រុង គឺរួមបញ្ចូលនូវមតិដាច់ដោយឡែកពីគ្នា ដែលភ្ជាប់ជាឧបសម្ព័ន្ធនោះ មិនអាចត្រូវបានយល់ឃើញដោយស្មោះត្រង់ថាជា ការប្រកាសថាដីកាដំណោះស្រាយទាំងពីរ គឺពិតជាមោឃៈ ដូចដែលអង្គជំនុំជម្រះតុលាការកំពូល ហាក់ដូចជាបានធ្វើការសន្និដ្ឋានឡើយ[603]។ *ចៅក្រមទាំងប្រាំរូបរបស់ អង្គបុរេជំនុំជម្រះ* ពិចារណាថាជាការចាំបាច់ ដែលត្រូវផ្ដល់មតិរបស់ខ្លួន ពាក់ព័ន្ធនឹងសុពលភាពផ្សេងពីគ្នា នៃដីកាដំណោះស្រាយ[604]។ និយាយម្យ៉ាងទៀត ចៅក្រមអង្គបុរេជំនុំជម្រះ សម្រេចជាឯកច្ឆន្ទថា *យ៉ាងហោចណាស់* មានដីកាដំណោះស្រាយមួយ ដែលមានសុពលភាពផ្លូវច្បាប់ បន្ទាប់ពីមានការសម្រេច របស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធកិច្ចដោយខុសច្បាប់ របស់សហចៅក្រមស៊ើបអង្កេត។ ការពិតដែលថា អង្គជំនុំជម្រះតុលាការកំពូល ហាក់ដូចជាចាត់ទុកថា មតិដាច់ដោយឡែកពីគ្នា របស់ចៅក្រមអង្គបុរេជំនុំជម្រះ គឺ "ពុំចាំបាច់" និង "មិនជាប់ពាក់ព័ន្ធ" គឺគ្រាន់តែដើម្បីបង្ហាញអំពី ការយល់ឃើញដោយខុសឆ្គងជាអកុសល របស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើការប្រកាសជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះប៉ុណ្ណោះ[605]។

---

[603] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥៣ ("ទោះបីជាមានសេចក្ដីប្រកាស *ឯកច្ឆន្ទ* ដែលថា **ចំណាត់ការ**របស់ សហចៅក្រមស៊ើបអង្កេត ក្នុងការចេញជាដីកាដំណោះស្រាយ ពីដាច់ដោយឡែក ហើយផ្ទុយគ្នា ចាត់ទុកជា**មោឃភាព**ក៏ដោយ ក៏ចៅក្រមអង្គបុរេជំនុំជម្រះ ផ្ដល់សេចក្ដីពិចារណារបស់ខ្លួន លើ**សុពលភាព**នៃដីកាដំណោះស្រាយផ្ទុយគ្នានេះដែរ"។ (អក្សរទ្រេត គូសបញ្ជាក់លើឯកសារដើម អក្សរដិត ដោយគូសបញ្ជាក់បន្ថែម)។ សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៧ ("អំណះអំណាង [របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធគោលជំហរមិនពេញលេញ]នេះ គេចវេះ ឬមិនអើពើផលវិបាក នៃការយល់ឃើញជា*ឯកច្ឆន្ទ*របស់អង្គបុរេជំនុំជម្រះដែលថា ដីកាដំណោះស្រាយគឺជាលទ្ធផល នៃ*ចំណាត់ការខុសច្បាប់ និងពុំត្រឹមត្រូវតាមច្បាប់*។ កិច្ចដែលគ្មានសុពលភាព មិនអាចបង្កើតផលវិបាក ឬលទ្ធផលត្រឹមត្រូវតាមច្បាប់។ អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើម ដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់")

[604] សូមមើល សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ១២៤ ជើងទំព័រ ១៩៨ យោងទៅរកសំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) មតិចៅក្រមប្រាក់ គឹមសាន ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៧០-៣០២។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) & D360/33) មតិចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣០៤-៣២៩។

[605] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥៣។ ការអះអាងបែបនេះ កើតចេញពីការដែល អង្គជំនុំជម្រះតុលាការកំពូល មិនអើពើបន្ថែមទៀត លើបញ្ញត្តិនៃមាត្រា ១៤(២) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

២៧៣. ចៅក្រមអន្តរជាតិចាំបាច់ត្រូវចង្អុលបង្ហាញ អំពីកំហុសឆ្គងនៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល។ ចំនុចទីមួយនិងសំខាន់បំផុតនោះ អង្គជំនុំជម្រះតុលាការកំពូល ហាក់ដូចជានិយាយពាំត្រណោត ចំពោះការសម្រេចរបស់ អង្គបុរេជំនុំជម្រះដែលថា សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាដំណោះស្រាយ គឺខុសច្បាប់[606] ដោយមានការសន្និដ្ឋានថា ដីកាដំណោះស្រាយគឺ "មោឃៈ" ហើយដោយសារតែបែបនេះហើយ ទើបឈានភ្លាមៗទៅដល់សំអាងហេតុ។ អង្គបុរេជំនុំជម្រះប្រឆាំងជាឯកច្ឆន្ទ ចំពោះ *ការព្រមព្រៀងគ្នា* របស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់សិទ្ធិអំណាចដល់ខ្លួនឯង ក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។ *ការព្រមព្រៀងដោយខុសច្បាប់*នេះ ដែលព្យាយាមធ្វើឡើងដើម្បី "លាក់ការខ្វែងយោបល់គ្នា មិនឱ្យទទួលបានយន្តការដែលមាន សម្រាប់ដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធិភាពបំផុត នៅក្រោមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ដើម្បីធានានូវការជៀសផុត ពីភាពទាល់ច្រកផ្នែកនីតិវិធី"[607] ដែលជាការប្រព្រឹត្តផ្ទុយទាំងស្រុង ជាមួយមូលហេតុដ៏សំខាន់ នៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដោយពិចារណាទៅលើ មូលហេតុសម្រាប់អត្ថិភាព (*raison d'être*) របស់អង្គបុរេជំនុំជម្រះ[608]។ ប៉ុន្តែការពិតដែលថា *សកម្មភាពដាក់លាក់មួយចំនួន* របស់សហចៅក្រមស៊ើបអង្កេត ក្នុងការបង្កើតនូវដីកាដំណោះស្រាយ គឺមានលក្ខណៈខុសច្បាប់នោះ មិនអាចនាំដោយ "សមហេតុផល" ទៅដល់ការសន្និដ្ឋានសរុបជារួប ដោយមិនមានការបង្ហាញដោយសមហេតុផលថា ហេតុអ្វីទើបអនីត្យានុកូលភាព ផ្នែកនីតិវិធី

---

[606] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ១២០-១២៤។

[607] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) កថាខណ្ឌ ១២៣។

[608] *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៩៩-១០០ ("អង្គបុរេជំនុំជម្រះមិនអាចមិនគិតថា សហចៅក្រមស៊ើបអង្កេត *ប្រហែលមានចេតនាពិតប្រាកដ ក្នុងការគេចវេស ពីការអនុវត្តច្បាប់ នៅក្នុងករណីនេះ ហើយបង្កើតភាពទាល់ច្រកផ្នែកនីតិវិធី នាពេលបច្ចុប្បន្ន*។ តាមពិតទៅ តាមរយៈដីកាសម្រេចពីខាងលើរបស់ពួកគេ ច្បាស់ណាស់ថា សហចៅក្រមស៊ើបអង្កេត ព្យាយាមធានាដោយមានចេតនាថា ដំណោះស្រាយណាមួយ ចំពោះបញ្ហាដែលពួកគេខ្វែងយោបល់គ្នា នឹងត្រូវបានដោះស្រាយតែក្នុងផ្នែក នៃកិច្ចដំណើរការបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ *មិនមែនតាមរយៈនីតិវិធី ដែលបានកំណត់ជាក់លាក់ ដោយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សម្រាប់ដោះស្រាយតែចំពោះ ការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេតនោះទេ*។ សហចៅក្រមស៊ើបអង្កេត បានដឹងអំពីការលំបាក ដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់។ ប៉ុន្តែពួកគាត់ធ្វើឱ្យប្រាកដ *ក្នុងការបិទបាំងការខ្វែងយោបល់ ពីយន្តការដោះស្រាយតាមផ្លូវច្បាប់ ប្រកដោយប្រសិទ្ធិភាព* ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះសូមប្រកាសថ្កោលទោស យ៉ាងច្បាស់លាស់ ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើប្រព័ន្ធច្បាប់របស់ អ.វ.ត.ក" (ដោយគូសបញ្ជាក់បន្ថែម))

ជាក់លាក់នេះ នឹងបណ្តាលឲ្យមានការខូចខាតទាំងស្រុង ទៅលើដីកាដំណោះស្រាយ ដែលចោទជាបញ្ហាទាំងពីរនោះ[609]។ ទោះជាបែបណាក្តី ការលោតរំលងទៅដល់សំអាងហេតុនេះ បង្កើតបានជាមូលដ្ឋានមួយសម្រាប់សេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល[610]។

២៧៤. ទីពីរ អង្គជំនុំជម្រះតុលាការកំពូល មិនបានចាត់ទុកថាជាការចាំបាច់ឡើយ ក្នុងការវិភាគលើអត្ថបទនៃសេចក្តីសម្រេចជាក់ស្តែង របស់អង្គបុរេជំនុំជម្រះ ដើម្បីបញ្ជាក់បំភ្លឺលើបញ្ហាស្នូល ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន ដែលនាំទៅដល់ការបិទបញ្ចប់សំណុំរឿង ០០៤/២[611] គឺថាតើអង្គបុរេជំនុំជម្រះ បាន

[609] *សូមមើលជាទូទៅ* សំណុំរឿង ០០២/១ សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ ១០០ ("ម្យ៉ាងវិញទៀត ពុំមែនកំហុសនៃកិច្ចដំណើរការនីតិវិធីទាំងអស់ សុទ្ធតែនាំទៅរកការកែប្រែសាលក្រមនោះឡើយ លើកលែងតែកំហុសនោះបណ្តាលឲ្យ "មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ"")។ ដូចដែលនឹងពន្យល់នៅផ្នែកខាងក្រោម កំហុសនៃកិច្ចដំណើរការនីតិវិធីជាក់លាក់ នៃការមិនបញ្ជូន នឹងត្រូវបានជួសជុល ហើយដោយមិនគិតអំពីប្រភេទកំហុសនៃកិច្ចដំនើរការនីតិវិធី មុនពេលជំនុំជម្រះ មិនអាចលើកឡើង ឬតម្កល់ដោយ អង្គជំនុំជម្រះតុលាការកំពូលឡើយ តាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។

[610] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៧១ (v) ("ដោយផ្អែកលើការយល់ឃើញរបស់ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ដែលថា ការបំពេញកិច្ចរបស់ សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ មានន័យថា ពុំមានដីកាដំណោះស្រាយណាមួយ មានសុពលភាពឡើយ" (ដោយគូសបញ្ជាក់បន្ថែម))។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើសុំ ចាត់វិធានការចាំបាច់ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E004/2/6) កថាខណ្ឌ ២០ (ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូល សង្កត់ធ្ងន់លើសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងសេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ថា "អង្គជំនុំជម្រះសង្កេតឃើញថា ពុំមានដីកាដំណោះស្រាយណាមួយ មានសុពលភាព" (ដោយគូសបញ្ជាក់បន្ថែម))។ ចៅក្រមអន្តរជាតិយល់ឃើញថា ពាក្យដែលអង្គជំនុំជម្រះតុលាការកំពូលបានប្រើប្រាស់ ដូចជា "ដែលថា" និង "សង្កេតឃើញថា" គឺបង្ហាញអំពីអត្ថន័យដូចគ្នា។ បន្ថែមលើនេះ សំអាងហេតុរបស់ អង្គជំនុំជម្រះតុលាការកំពូល បង្ហាញនូវ "ការជឿជាក់ដោយខុសលើសំអាងហេតុដែលបានប្រើប្រាស់" (circular reasoning fallacy) *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៧ (បន្ទាប់ពីបញ្ជាក់ថា "ដីកាដំណោះស្រាយគឺជាលទ្ធផល នៃចំណាត់ការខុសច្បាប់" អង្គជំនុំជម្រះតុលាការកំពូល បានអះអាងថា "កិច្ចដែលគ្មានសុពលភាព មិនអាចបង្កើតផលវិបាក ឬលទ្ធផលត្រឹមត្រូវតាមច្បាប់។ អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើម ដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់")។ នេះគ្រាន់តែសន្មតអំពីការពិត នៃសេចក្តីសន្និដ្ឋានដែលថា ដីកាដំណោះស្រាយមិនមានអានុភាពផ្លូវច្បាប់ ដោយគាំទ្រដោយការសន្មត ដែលត្រូវបានសន្មតថាពិតផងដែរ គឺថាដីកាដំណោះស្រាយគ្មានសុពលភាព មិនអាចបង្កើតបានជាលទ្ធផលស្របច្បាប់)។

[611] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៨ (បើតាមអង្គជំនុំជម្រះតុលាការកំពូល "ក្នុងករណីពុំមានដីកាដំណោះស្រាយសុពលភាព (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)" សំណុំរឿង "ពិតជា" មិនអាចឈានទៅជំនុំជម្រះ ហើយចាំបាច់ត្រូវបិទបញ្ចប់។ នេះបង្កើតបានជាកំហុសធ្ងន់ធ្ងរមួយ និងជាការលោតផ្លោះដ៏ធំ

សម្រេចជាឯកច្ឆន្ទដែរឬទេថា ដីកាដំណោះស្រាយទាំងពីរ គឺមោឃៈ និងអសុពលភាពនោះ។ ជាជំនួស អង្គជំនុំជម្រះតុលាការកំពូល គ្រាន់តែពឹងផ្អែកទៅលើពាក្យពេចន៍ក្នុងផ្នែកសម្រេចសេចក្តីនៃសេចក្តីពិចារណា[612] ដើម្បីធ្វើការប្រកាសជាសេចក្តីសម្រេច អំពីការសន្មតរបស់ខ្លួន លើ អត្ថន័យនៃសេចក្តីប្រកាសជាឯកច្ឆន្ទ។ ប៉ុន្តែ ដោយសន្មតថាសេចក្តីពិចារណាមានភាពមិនច្បាស់លាស់ និងស្រពិចស្រពិល ប្រាកដណាស់ថា ពិតជាមិនអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះតុលាការកំពូល អាចធ្វើសេចក្តីសន្និដ្ឋានជាពីរបីប្រយោគ បែបប្រញិបប្រញាប់ជាសំអាងហេតុដែលថា ដីកាដំណោះស្រាយគ្មានសុពលភាព និងពុំមានអានុភាពផ្លូវច្បាប់ឡើយ។

២៧៥. ជាចុងក្រោយ គួរតែលើកឡើងផងដែរថា ក្រៅពីការបកស្រាយដោយខុសឆ្គង ទៅលើការសម្រេចជា ឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ លើការព្រមព្រៀងដោយខុសច្បាប់ រវាងសហចៅក្រមស៊ើបអង្កេត ក្នុងការគេចចេញពី នីតិវិធីដោះស្រាយការខ្វែងយោបល់ ហើយចេញនូវដីកាដំណោះស្រាយពីរ ក្នុងពេលជាមួយគ្នាហើយនោះ អង្គជំនុំជម្រះតុលាការកំពូល ក៏មិនបានពិចារណាដោយត្រឹមត្រូវ ទៅលើភាពអាចអនុវត្តបានក្នុងសំណុំរឿង ០០៤/២ នូវអធិបញ្ញាដែលមានចែងក្នុង មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា "ការស៊ើបអង្កេតត្រូវធ្វើបន្ត" ព្រមទាំងនៅក្នុងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា "ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត" ព្រមទាំងអានុភាពរបស់អធិបញ្ញានេះ ទៅលើសុពលភាពជាក់លាក់ នៃដីកាដំណោះស្រាយ[613]។ ចៅក្រមអន្តរជាតិបន្តរក្សាថា វិធានដែលបានរៀបរាប់ខាងលើ បង្កើតបានជាការអនុវត្តច្បាប់ដ៏ត្រឹមត្រូវ នៅក្នុងករណីនោះ។

### iii. អង្គជំនុំជម្រះតុលាការកំពូល មិនអាចបិទបញ្ចប់សំណុំរឿង ០០៤/២ ដោយមិនមានដីកាដំណោះស្រាយដែលមានសុពលភាពឡើយ

ក្នុងសំអាងហេតុ ឬជាការផ្ទុយនឹងខ្លួនឯង។ តាមរយៈសំអាងហេតុនេះ មិនមានដីកាដំណោះស្រាយ ដែលមានសុពលភាពនៅសល់ឡើយ ប៉ុន្តែសំណុំរឿងត្រូវបិទ ឬបញ្ចប់ ដោយមិនមានមូលដ្ឋានផ្លូវច្បាប់ណាមួយឡើយ)។ *សូមមើលផងដែរ កថាខណ្ឌខាងក្រោម* កថាខណ្ឌ ២៧៦-២៨០។

[612] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៥១-៥៣។

[613] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24និង D360/33) មតិចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣១៩-៣២៦។

01667430



២៧៦. អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ បានសម្រេចថា "រឿងក្ដីប្រឆាំងនឹង អោ អាន ត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក"[614]។ អង្គជំនុំជម្រះតុលាការកំពូល ឈានដល់សេចក្ដីសន្និដ្ឋាននេះ យោងទៅលើបណ្ដាសំអាងហេតុដូចតទៅ៖ (១) ដោយផ្អែកលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ "មានន័យថា ពុំមានដីកាដំណោះស្រាយណាមួយ មានសុពលភាពឡើយ"[615] (២) បញ្ហានៅក្នុងសំណុំរឿង ០០៤/២ គឺថាតើ រឿងក្ដីនេះឈានទៅជំនុំជម្រះ ក្នុងករណីពុំមានដីកាដំណោះស្រាយមានសុពលភាព (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឬយ៉ាងណា។ ចម្លើយគឺច្បាស់ណាស់ថា ទេ"[616] និងដូច្នេះហើយ (៣) ក្នុងករណីពុំមានដីកា ដែលអាចអនុវត្តបាន និងជាក់លាក់ ប្រឆាំងនឹង អោ អាន សំណុំរឿង ០០៤/២ ប្រឆាំងនឹងរូបគាត់ គប្បីត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក"[617]។

២៧៧. ចៅក្រមអន្តរជាតិមិនជឿជាក់ តាមសំអាងហេតុដែលប្រឆាំងខ្លួនឯងរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ។ ជាពិសេស គឺពិបាកក្នុងការយល់ថាតើ សំណុំរឿងដែលមិនមានដីកាដំណោះស្រាយមានសុពលភាព អាចត្រូវបាន "បញ្ចប់" ដោយស្របច្បាប់តាមរបៀបណា។ បន្ថែមលើនេះ ចៅក្រមអន្តរជាតិ មិនយល់ថាតើ អង្គជំនុំជម្រះតុលាការកំពូល ឈានចេញពីការសន្និដ្ឋានថា សំណុំរឿងមិនអាចបន្តទៅជំនុំជម្រះបាន*នាពេលបច្ចុប្បន្ន* (ដោយសារតែមិនមាន ដីកាបញ្ជូនរឿងទៅជំនុំជម្រះសុពលភាព) ទៅជាការសន្និដ្ឋានភ្លាមៗគួរឲ្យភ្ញាក់ផ្អើលបានដោយរបៀបណាថា សំណុំរឿង*ទាំងមូលគួរត្រូវបានបញ្ចប់ជាអចិន្ត្រៃយ៍*។ ការនេះបង្កើតបានជា ការលោតរំលងសំខាន់មួយទៀត ក្នុងសំអាងហេតុគតិយុត្តិ។

២៧៨. ដោយសន្មត *សម្រាប់គោលបំណងវែកញែក* ថា "ពុំមានដីកាដំណោះស្រាយណាមួយ មានសុពលភាព" និង ដីកាដំណោះស្រាយទាំងពីរ "ពុំមានអានុភាពផ្លូវច្បាប់" តើយោងទៅតាមមូលដ្ឋានផ្លូវច្បាប់អ្វីដែលអង្គជំនុំជម្រះតុលាការកំពូល សម្រេចថា "បិទបញ្ចប់" សំណុំរឿងនោះ? គឺហួសពីការសង្ស័យថា អង្គជំនុំជម្រះតុលាការកំពូល ដោយមិនគិតអំពីឋានៈរបស់ខ្លួន ជាតុលាការចុងក្រោយ នៅដំណាក់កាលជំនុំជម្រះ

---

[614] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៧១ (vi)។ បន្ថែមលើនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូល មិនត្រូវបានប្ដឹងដោយផ្ទាល់ ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ឲ្យបិទបញ្ចប់កិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៤/២ ឡើយ។

[615] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៧១ (v)។ ដូចដែលបានពន្យល់ពីខាងលើ កថាខណ្ឌ ២៧១-២៧៥ ការសន្និដ្ឋានរបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងចំណុចនេះ ផ្អែកលើការបកស្រាយដោយខុសឆ្គង នូវគោលជំហរជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ ដូចដែលបានបង្ហាញក្នុង សេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/២។

[616] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៨។

[617] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៩។

និងដំណាក់កាលបណ្ដឹងសាទុក្ខ មិនមានសិទ្ធិអំណាច ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ដែលស្ថិតនៅដំណាក់កាលស៊ើបអង្កេត បុរេជំនុំជម្រះឡើយ។ ប្រសិនបើគោរពទៅតាមហេតុផលរបស់អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿង ០០៤/២ មិនដែលបានទៅដល់អង្គជំនុំជម្រះសាលាដំបូងឡើយ ហើយកិច្ចដំណើរការនីតិវិធីជំនុំជម្រះ មិនដែលបានចាប់ផ្ដើមនោះ សំណុំរឿងស្ថិតនៅដំណាក់កាលបុរេជំនុំជម្រះ ដែលអង្គជំនុំជម្រះតុលាការកំពូល ពុំមានសមត្ថកិច្ចក្នុងការបញ្ចប់ សំណុំរឿងដោយស្របច្បាប់ឡើយ។ ប៉ុន្តែនេះគឺជាអ្វីដែល អង្គជំនុំជម្រះតុលាការកំពូល បានធ្វើយ៉ាងជាក់ច្បាស់ ដោយមិនមានដីកាសម្រេចលើកលែងការចោទប្រកាន់ និងមិនមានសំអាងហេតុណាមួយ។

២៧៩. ចៅក្រមអន្តរជាតិកោតសរសើរដែលអង្គជំនុំជម្រះតុលាការកំពូល ចាត់ទុកខ្លួនឯងថាជា តុលាការចុងក្រោយ ដែលមាន "កាតព្វកិច្ចស្រាយបំភ្លឺ និងបញ្ចប់" ស្ថានភាពគតិយុត្តិដែលមិនបានដោះស្រាយ[618]។ ចៅក្រមអន្តរជាតិក៏យល់ស្របទាំងស្រុងផងដែរ ជាមួយអង្គជំនុំជម្រះតុលាការកំពូលដែលថា ភាគីនានាមានសិទ្ធិទទួលបាន "សច្ចភាពគតិយុត្តិ" និង "ការសម្រេចជាស្ថាពរ"[619]។ ទោះជាបែបនេះក្ដី ការសម្រេចភ្លាមៗក្នុងការផ្ដល់សច្ចភាពគតិយុត្តិ ទោះបីជាមានចេតនាល្អក្ដី ច្បាស់ណាស់ថាមិនអាចប្រែក្លាយទៅជា ការស្នើសុំឲ្យបិទសំណុំរឿង ដោយមិនមានដីកាសម្រេច លើកលែងការចោទប្រកាន់មានសុពលភាពឡើយ។ ការសម្រេចបាននូវភាពស្ថាពរផ្លូវច្បាប់ និងសច្ចភាពគតិយុត្តិ លើបញ្ហាមួយ (ដូចជាការដោះស្រាយជាស្ថាពរ ថាតើគោលជំហរជាក់ស្ដែង ត្រូវអនុវត្តដែរឬទេ) គឺខុសផ្នែកពីការនាំយកសំណុំរឿងទាំងស្រុងមួយ ទៅដល់ការបញ្ឈប់ទាំងស្រុង។ ដោយសារតែដីកាដំណោះស្រាយទាំងពីរមោឃៈ បើយោងទៅតាមគោលជំហរ របស់អង្គជំនុំជម្រះតុលាការកំពូល ជនរងគ្រោះនៃឧក្រិដ្ឋកម្ម របស់ខ្មែរក្រហម និង អោ អាន ខ្លួនគាត់ផ្ទាល់មុនពេលស្លាប់ ភាគីនានានៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក និងសាធារណជនជាតិ និងអន្តរជាតិ មិនបានដឹងថាលទ្ធផលនៃការស៊ើបអង្កេត ទៅលើ អោ អាន គឺជាអ្វី នៅពេលដែលមិនមានឯកសារគតិយុត្តិដែលមានសុពលភាព បង្ហាញអំពីផ្លែផ្កានៃការស៊ើបអង្កេត ដោយសារឯកសារទាំងពីរ "ពុំមានអនុភាពផ្លូវច្បាប់"។ ការបញ្ចប់តាមអំពើចិត្ត របស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើសំណុំរឿង ដោយមិនមានដីកាដំណោះស្រាយ មិនបាននាំឲ្យមានភាពច្បាស់លាស់ ភាពស្ថាពរ និង សច្ចភាពគតិយុត្តិឡើយ។

---

[618] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៤។

[619] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦០, ៦៤ - ៦៥, ៧១ (iii)។

01667432



២៨០. ជាការគួរឲ្យភ្ញាក់ផ្អើល ដូចដែលអង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង បានទទួលស្គាល់ហើយ អង្គជំនុំជម្រះមិនមានសិទ្ធិចូលពិនិត្យសំណុំរឿងឡើយ នៅពេលចេញសេចក្ដីសម្រេចរបស់ខ្លួន[620]។ ដូច្នេះនៅក្នុងកាលៈទេសៈនៃសំណុំរឿង ០០៤/២ សេចក្ដីសម្រេចស្ថាពរ បញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងការចោទប្រកាន់ទៅលើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវធ្វើឡើងដោយស្ថាប័នតុលាការ ដែលមិនបានមើលភស្តុតាងនៃសំណុំរឿង ហើយធ្វើឡើងតាមរយៈ សេចក្ដីណែនាំបញ្ជូប់ ដែលមានលក្ខណៈជាអនុក្រឹត្យទៅវិញ (executive fiat)[621]។

iv. ការសន្និដ្ឋានពាក់ព័ន្ធនឹងការបកស្រាយដោយភាន់ច្រឡំ របស់អង្គជំនុំជម្រះតុលាការកំពូល

២៨១. សរុបមក សេចក្ដីពិចារណាជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ អាចត្រូវបានយល់ដឹងដោយស្មោះត្រង់ដូចតទៅ៖ (១) ការព្រមព្រៀងរបស់ សហចៅក្រមស៊ើបអង្កេត ក្នុងការបិទបាំងការខ្វែងយោបល់គ្នាពាក់ព័ន្ធដីកាដំណោះស្រាយដែលផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/២ និងការចេញដីកាដំណោះស្រាយគឺខុសច្បាប់ ដោយរំលោភបំពានទៅលើ ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (២) អង្គបុរេជំនុំជម្រះ *មិនបាន* សម្រេចថា ដីកាដំណោះស្រាយទាំងពីរ មោឃៈនិងអសុពលភាពឡើយ បើទោះបីជាមានសកម្មភាពដោយខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេត ដោយសារតែចៅក្រមរបស់ អង្គបុរេជំនុំជម្រះ បានជឿជាក់ថា យ៉ាងហោចណាស់មានដីកាដំណោះស្រាយមួយ ដែលមានសុពលភាព និង (៣) អង្គបុរេជំនុំជម្រះមិនអាចស្វែងរក សម្លេងគាំទ្រពីចៅក្រមយ៉ាងតិចបួនសម្លេង ដើម្បីចេញសេចក្ដីសម្រេចច្រានចោល ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ឬ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤/២។

[620] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើសំណើសុំ ចាត់វិធានការចាំបាច់ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ E004/2/6) កថាខណ្ឌ ២១។

[621] អង្គជំនុំជម្រះតុលាការកំពូល ហាក់ដូចជាពោលបញ្ជិតបញ្ជៀងថា ដោយសារតែការស៊ើបអង្កេត ដែលមានរយៈពេល១៣ឆ្នាំ បានកន្លងហួសទៅហើយ គឺជាការសមស្របដែលត្រូវ បិទបញ្ចប់កិច្ចដំណើរការនីតិវិធី។ *សូមមើល* សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៦៩។ ក្នុងស្ថានភាពដែល អង្គជំនុំជម្រះតុលាការកំពូល ត្រូវបានជម្រុញដោយសារសំអាងហេតុនេះ ការនេះមិនអាចប្រើប្រាស់ធ្វើជា មូលដ្ឋានគតិយុត្តិសុពលភាពឡើយ ដោយសារតែក្របខណ្ឌគតិយុត្តិ អ.វ.ត.ក មិនបានចែងអំពីពេលវេលាកំណត់ជាក់លាក់ ដែលអង្គជំនុំជម្រះតុលាការកំពូល អាចបទបញ្ចប់សំណុំរឿង តាមរយៈដីកាសម្រេចបែបប្រតិបត្តិនោះ។

២៨២. ដោយចងចាំអំពីគោលជំហរជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធកិច្ចរបស់សហចៅក្រមស៊ើបអង្កេត គឺជាការមិនអាចយល់បានដែលថា អង្គជំនុំជម្រះតុលាការកំពូល ចាត់ទុកថាការសម្រេច របស់អង្គបុរេជំនុំជម្រះ ថាជាការធ្វើមោឃភាព។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូល ប្រហែលជាមិនអាច និងមិនអាចបញ្ចប់ កិច្ចដំណើរការនីតិវិធី ផ្អែកលើកំហុសឆ្គងនីតិវិធី បុរេជំនុំជម្រះ ដែលចែងយ៉ាងច្បាស់ដោយវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[622] និងមូលហេតុទាំងស្រុងនៃការបែងចែក សិទ្ធិអំណាចតុលាការរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះតុលាការកំពូល ក៏មិនមានសមត្ថកិច្ច ក្នុងការធ្វើមោឃភាព នាពេលក្រោយមក លើដីកាដំណោះស្រាយណាមួយ ក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីដីកាដំណោះស្រាយនោះ មិនត្រូវបានច្រានចោល ដោយអានុភាពនៃសេចក្តីសម្រេចជាក់ស្តែង របស់អង្គបុរេជំនុំជម្រះ។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូល មិនអាចបញ្ចប់សំណុំរឿង ០០៤/២ ដែលបើតាមហេតុផលរបស់ខ្លួន គឺស្ថិតនៅដំណាក់កាលស៊ើបអង្កេត មុនពេលជំនុំជម្រះ ហើយដែលមិនមានដីកាដំណោះស្រាយដែលមានសុពលភាពឡើយ។

២៨៣. ដោយសារតែការបែងចែកយ៉ាងប្រុងប្រយ័ត្ន នូវសមត្ថកិច្ចតុលាការ តាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងការយល់ឃើញខុសឆ្គងក្នុងសំអាងហេតុ ដូចបានកំណត់បញ្ជាក់ពីខាងលើ ប្រាកដណាស់មិនមានមូលដ្ឋានគតិយុត្តិ សម្រាប់ឲ្យអង្គបុរេជំនុំជម្រះ អនុម័តយកគោលជំហររបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០៤/២ ថាជាយុត្តិសាស្ត្រគ្រប់គ្រង ឬសូម្បីគួរឲ្យជឿជាក់ សម្រាប់សំណុំរឿង ០០៣ ឡើយ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិពិចារណាថា ការសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០៤/២ គឺមិនមែនជាអាជ្ញាប័ណ្ណសម្រាប់ឲ្យ អង្គបុរេជំនុំជម្រះ ធ្វើការបញ្ចប់ដោយស្វ័យប្រវត្តិ នូវសំណុំរឿងដែលនៅសល់ទាំងអស់ ដែលមានដីកាដំណោះស្រាយផ្ទុយគ្នាទេ។ សំណុំរឿងនីមួយៗ ចាំបាច់ត្រូវត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ផ្អែកលើអង្គសេចក្តីផ្ទាល់[623]។

---

[622] *សូមមើល* វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។

[623] ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូល មានការប្រុងប្រយ័ត្ន ក្នុងការជៀសវាងនូវ បុរេនិច្ឆ័យដែលអាចកើតមាន ចំពោះលទ្ធផលនៃសំណុំរឿង ០០៣ ដោយបដិសេធសំណើរបស់ មាស មុត សុំកិច្ចអន្តរាគមន៍។ សូមមើល សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ និងឆ្លើយតបទៅនឹង បណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ លើអានុភាពដែលនាំឲ្យ បញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E004/2/2/1) ទំព័រ ៣។

២. ការសម្រេចលើសុពលភាព នៃដីកាដំណោះស្រាយ

២៨៤. ដូចដែលបានបញ្ជាក់ នៅក្នុងកថាខណ្ឌកន្លងមក ចៅក្រមអន្តរជាតិសម្រេចថា ផ្អែកលើវិការៈអង្គសេចក្ដីរបស់ខ្លួន[624] និងដោយលក្ខណៈមិនអាចអនុញ្ញាតបាន ដែលតាមរយៈលក្ខណៈនោះ ដីកាសម្រេចលើកលែងការចោទប្រកាន់ ត្រូវបានចេញ[625] ទើបដីកានេះមោឃៈ និងអសុពលភាពទាំងផ្នែកខាងក្នុង និងផ្នែកខាងក្រៅ។ ជាសរុបមក ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិ បានចេញនូវកិច្ចមួយដែលមោឃៈផ្នែកនីតិវិធី ដែលមិនអាចអនុញ្ញាតបាន ហើយមិនមានអត្ថិភាពគតិយុត្តិណាមួយឡើយ។ ម៉្យាងវិញទៀត ទោះបីជាមានការចេញដីកាដំណោះស្រាយក្នុងពេលជាមួយគ្នាក្ដី ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពដែរ ដោយសារតែដីកានេះមានសុពលភាពជាសារធាតុ ហើយមានអនុលោមភាពជាមួយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក រួមទាំងគោលជំហរជាក់ស្ដែង ដែលអាចអនុវត្តបាន ក្នុងករណីមានការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ហើយដែលមានគោលដៅនាំយកមកជំនុំជម្រះចំពោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម។

## ឃ. សេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គល

២៨៥. តាំងពីដំបូងមក ចៅក្រមអន្តរជាតិយល់ឃើញថា បញ្ហាយុត្តាធិការបុគ្គល ដែលបង្កើតជា "ធាតុផ្សំនៃយុត្តាធិការដាច់ខាត"[626] និងបញ្ហាសំខាន់ជាទូទៅចំពោះយុត្តិសាស្ត្រ និងកេរ្ដិ៍ដំណែលរបស់ អ.វ.ត.ក[627] ត្រូវតែយកមកដោះស្រាយនៅដំណាក់មុនការជំនុំជម្រះនេះ។ លើសពីនេះទៀត ចៅក្រមអន្តរជាតិសូមរម្លឹកថា ដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាពទេ ដោយសារតែសហចៅក្រមស៊ើបអង្កេតជាតិប្រព្រឹត្តកំហុសអង្គច្បាប់ ទាក់ទិននឹងការស៊ើបអង្កេតមិនពេញលេញរបស់ខ្លួនទៅលើការចោទប្រកាន់ព្រហ្មទណ្ឌនៅក្នុងបណ្ដឹងមកកាន់ខ្លួន និងការពិនិត្យមើលមួយផ្នែករបស់គាត់ទៅលើភស្តុតាងក្នុងសំណុំរឿង ០០៣។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា វាមានភាពពាក់ព័ន្ធ និងចាំបាច់ ដែលត្រូវដាក់បញ្ចូលទៅ

---

624 សូមមើលខាងលើ កថាខណ្ឌ ២២៨-២៥០

625 សូមមើលខាងលើ កថាខណ្ឌ ២៥៥-២៦២

626 សូមមើលខាងលើ កថាខណ្ឌ ៦៧។

627 សូមមើលខាងលើ កថាខណ្ឌ ១២៨-១៩៣សម្រាប់សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះក្នុងការពិនិត្យមើលឡើងវិញទៅលើបញ្ហាសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្រ និងកេរ្ដិ៍ដំណែលរបស់ អ.វ.ត.ក ។

ក្នុងការពិនិត្យមើលបច្ចុប្បន្ននេះ នូវសំអាងហេតុ និងការអះអាងនានា ដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតជាតិ ដែលនាំឱ្យគាត់សន្និដ្ឋានថា ជនត្រូវចោទមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

២៨៦. ចៅក្រមអន្តរជាតិសូមបញ្ជាក់សាជាថ្មីថា ក្នុងគោលបំណងកំណត់អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ការកំណត់អត្តសញ្ញាណបុគ្គលដែលស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ពាក់ព័ន្ធនឹងការវាយតម្លៃបែបបរិមាណវិស័យ និងគុណវិស័យ[628] ទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[629]។ ពុំមានបញ្ជីជាក់លាក់ស្ដីពីកត្តានានាដែលត្រូវយកមកពិចារណាក្នុងការពិនិត្យឡើងវិញនេះទេ ហើយក៏ពុំមានការកម្រិតគណិតវិទ្យាសម្រាប់ចំនួនមនុស្សស្លាប់[630] ឬបទដ្ឋានចម្រាញ់ពាក់ព័ន្ធនឹងតំណែងនៅក្នុងឋានានុក្រមទេ[631]។ ផ្ទុយទៅវិញ ការកំណត់អំពីយុត្តាធិការបុគ្គលតម្រូវឱ្យមានការវាយតម្លៃទៅតាមករណីជាក់ស្ដែងនីមួយៗ ដោយពិចារណា

---

[628] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។

[629] សាលក្រមនៃសំណុំរឿង ០០១ (E188) កថាខណ្ឌ ២២។ *សូមមើល ផងដែរ* តុលាការ SCSL *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Fofana* សំណុំរឿងលេខ SCSL-04-14-PT-026 សេចក្ដីសម្រេចលើសំណើសុំបឋមរបស់មេធាវីការពារក្ដី ស្ដីពីការពុំមានយុត្តាធិការបុគ្គល ដែលបានដាក់ក្នុងនាមជនជាប់ចោទ Fofana អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ ៣៨។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Ntaganda* សំណុំរឿងលេខ ICC-01/04-169 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I មានចំណងជើង "សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំដីកាចាប់ខ្លួន មាត្រា ៥៨" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ៧៦។ តុលាការ ICTY *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Lukić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-98-32/1-PT សេចក្ដីសម្រេចលើការកំណត់សមត្ថកិច្ចរឿងក្ដី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយឧបសម្ព័ន្ធសម្ងាត់ ក និង ឧបសម្ព័ន្ធ ខ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្ដី ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ២៦។

[630] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២, ៣៥៥។ *សូមមើលផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[631] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ *សូមមើល ផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

ដល់បរិបទទូទៅ និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនសង្ស័យ[632]។

១. ការវាយតម្លៃពីឧក្រិដ្ឋកម្មដែលបានចោទ ឬត្រូវបានចោទប្រកាន់

ក. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត

២៨៧. ចៅក្រមអន្តរជាតិរម្លឹកថា ការវាយតម្លៃពីឧក្រិដ្ឋកម្មដែលបានចោទ ឬត្រូវបានចោទប្រកាន់ ពឹងផ្អែកទៅលើកត្តានានាដូចជា ចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រ និងពេលវេលា និង លក្ខណៈដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានលើកឡើងថាបានប្រព្រឹត្ត ចំនួនហេតុការណ៍ដាច់ពីគ្នា លក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់ ព្រមទាំងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទាំងនោះទៅលើជនរងគ្រោះ[633]។

i. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

២៨៨. ចៅក្រមអន្តរជាតិកត់សម្គាល់នូវសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា ភាពខ្លាំងក្លានៃអំពើរបស់ មាស មុត និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ពីអំពើ នាំឲ្យឈានដល់ការសន្និដ្ឋានថា មាស មុត ជាបុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[634]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញថា បទចោទពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម[635] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលជនជាតិថៃ ដែលកងទ័ពជើងកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួន[636]

---

[632] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[633] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១៤១។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២៧។

[634] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦២។

[635] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៨២-៤៨៧។

[636] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥០១-៥០៣។

"ដាក់ឱ្យគាត់ស្ថិតនៃយុត្តាធិការបុគ្គល [របស់ អ.វ.ត.ក] យ៉ាងរឹងមាំ"[637]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញថា យ៉ាងហោចណាស់មានជនជាតិវៀតណាម និងជនជាតិថៃចំនួន ៤.៤៧៦ នាក់គឺជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ "ដែលស្ថិតក្រោមការត្រួតត្រារបស់ មាស មុត"[638]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានគូសបញ្ជាក់នូវចរិតលក្ខណៈដ៏គួរឱ្យខ្លាចក្នុងការបោះចោលសាកសពដែល មាស មុត បានបញ្ជា ដែលហួសពីកម្រិតខ្ពស់ "ធម្មតា" នៃអំពើឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យ[639]។

២៨៩. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញបន្ថែមថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយចំនួនទៀត[640] ឧក្រិដ្ឋកម្មសង្គ្រាម[641] និងចំពោះបទល្មើសថ្នាក់ជាតិនៃអំពើមនុស្សឃាតគិតទុកជាមុន[642] ដោយគូសបញ្ជាក់ពីតួនាទីចម្បងរបស់គាត់នៅក្នុង (១) ការបោសសម្អាតនៅក្នុងកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ នៃកងទ័ពបដិវត្តន៍កម្ពុជា[643] ដែលក្នុងអំឡុងពេលនោះ មានមនុស្សយ៉ាងហោចណាស់ចំនួន ២.១៥២ នាក់ត្រូវបានសម្លាប់[644] និង (២) ការគ្រប់គ្រងរួម និងការរៀបចំចាត់ចែងការដ្ឋាននានានៅកំពង់សោម[645] ដែលគាត់បានរកឃើញថា មានមនុស្សយ៉ាងហោចណាស់ ៨៤៥ នាក់ត្រូវបានសម្លាប់ និងមនុស្សចំនួន ១៥.០០០ នាក់គឺជាជនរងគ្រោះនៃពលកម្មដោយបង្ខំដែលធ្វើការងារ និងរស់នៅក្នុងស្ថានភាពដ៏លំបាកលំបិន[646]។

### ii. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតជាតិ

637 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៣។

638 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៤។

639 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៥។

640 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៨៨-៤៩៥, ៥០១-៥១០, ៥១៥-៥១៨, ៥២២-៥២៩, ៥៣១-៥៣៤, ៥៣៦-៥៤១, ៥៤៣-៥៤៨, ៥៥២-៥៥៣, ៥៥៥, ៥៥៧, ៥៦១។

641 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៩៧-៤៩៨, ៥១២-៥១៣, ៥៥០, ៥៥៩។

642 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៩៩, ៥១៤, ៥២០, ៥៣០, ៥៤២, ៥៥១, ៥៦០។

643 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៦។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៧១-៣២៨។

644 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៧។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៣២៩។

645 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៦។

646 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦៨។

01667438



២៩០. ចៅក្រមអន្តរជាតិកត់សម្គាល់ថា ទោះបីមានការទទួលស្គាល់ពីលក្ខណៈវិនិច្ឆ័យនៃភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មដែលបានចោទ ឬត្រូវបានចោទប្រកាន់ ចំពោះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[647] និងកត្តាពាក់ព័ន្ធនានាដែលត្រូវយកមកពិចារណាក្តី[648] តែសហចៅក្រមស៊ើបអង្កេតជាតិយល់ថា ពុំចាំបាច់លើកឡើងនូវប្រភេទឧក្រិដ្ឋកម្ម លក្ខណៈសម្បត្តិតាមច្បាប់ ឬទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធនៅក្នុងការពិភាក្សាទៅលើអត្ថិភាព ឬនត្ថិភាពនៃភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង មាស មុត ទេ ដោយសំអាងថា ការវិភាគនេះគឺតម្រូវតែចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ[649]។

២៩១. ចៅក្រមអន្តរជាតិសង្កេតឃើញបន្ថែមថា ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះ សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា មាស មុត អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការចាប់ខ្លួនទាហានចំនួន ៤២ នាក់ ក្នុងចំណោម ៦៧ នាក់ពីកងពលធំ ១៦៤ និង "មួយចំនួនទៀត" ដែលបន្ទាប់មកត្រូវបានបញ្ជូនទៅមន្ទីរ
សន្តិសុខ ស-២១ នៅឆ្នាំ១៩៧៧[650] និងបានសន្និដ្ឋានដោយផ្អែកលើមូលដ្ឋាននេះថា ចំនួនជនរងគ្រោះដែលបានទទួលរងដោយសារអំពើផ្ទាល់របស់ មាស មុត "ខុសគ្នាឆ្ងាយ" ពីចំនួនជនរងគ្រោះដែលបានទទួលរងដោយសារអំពើផ្ទាល់របស់ ឌុច[651]។ សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញបន្ថែមថា មាស មុត បានរាយការណ៍ពីការធ្វើសកម្មភាពយោធាជាច្រើនទៅថ្នាក់លើ រួមមាន ការបាញ់ទូកវៀតណាមមួយគ្រឿងនៅកោះខ្យង ការចាប់ខ្លួនជនជាតិថៃចំនួន ២១នាក់នៅកោះវៃ និងជនជាតិវៀតណាម ៧៦នាក់នៅកោះតាង ព្រមទាំងការសម្លាប់ជនជាតិវៀតណាមចំនួន ១២០នាក់ផ្សេងទៀត[652]។ សហចៅក្រមស៊ើបអង្កេតបានបង្ហាញថា ការចាប់ខ្លួន និងការឃុំខ្លួនបានកើតឡើងនៅវត្តឥន្ទញ្ញាណ[653] តែយល់ឃើញថា ពុំមានភស្តុតាងបង្ហាញថាការសម្លាប់ "ពិតជា" បានកើតឡើងនៅទីតាំងនោះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ[654]។ ចុងក្រោយ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានអំពីស្ថានភាពការងារ និងការរស់នៅ នៅការដ្ឋានវាយថ្មស្ទឹង

---

647 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣, ៣៦៥។

648 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៦៦។

649 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣។

650 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២៦។

651 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២៨។

652 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣១៣-៣១៥។

653 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៩០-២៩៥។

654 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៩៦។

01667439



ហារ[655]។

## ខ. ការពិភាក្សា

### i. ការពិនិត្យលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬត្រូវបានចោទប្រកាន់

២៩២. ចៅក្រមអន្តរជាតិយល់ស្របទៅនឹងផ្នែកភាគច្រើននៃសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីឧក្រិដ្ឋកម្មដែលចោទប្រកាំង មាស មុត[656]។ ទីមួយ ចៅក្រមអន្តរជាតិយល់ស្របទៅនឹងការវិភាគរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[657] ជាពិសេសពាក់ព័ន្ធនឹងអំពើព្រហ្មទណ្ឌនៃការកំណត់ជាគោលដៅទៅលើជនជាតិវៀតណាម និងជនជាតិថៃ[658] ដែលសំដៅដល់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំពោះជនជាតិវៀតណាម[659] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលជនជាតិថៃ[660] នៅដំណាក់កាលចេញដីកាដំណោះស្រាយ។

២៩៣. អំពើព្រហ្មទណ្ឌដែលត្រូវបានកំណត់ជាអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តជាទ្រង់ទ្រាយធំដោយមានចេតនាឧក្រិដ្ឋ ដើម្បីបំផ្លាញក្រុមជនជាតិ និងជនជាតិភាគតិចជាក់លាក់ទាំងមូល ឬមួយផ្នែកដែលបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាជនជាគោលដៅនេះ[661]។ មានការទទួលស្គាល់ជាទូទៅនៅក្នុងយុត្តិសាស្ត្រថា ពុំមានឋានានុក្រមក្នុងចំណោមឧក្រិដ្ឋកម្មបំផុតនៅចំពោះមុខយុត្តាធិការអន្តរជាតិ ឬយុត្តាធិការចម្រុះទេ[662]។ ម្យ៉ាងវិញទៀត មានការទទួលស្គាល់ដូចគ្នាថា ចេតនាឧក្រិដ្ឋដែលបង្កើតជាអំពើប្រល័យ

---

[655] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣០៣-៣០៥។

[656] ចំពោះកំហុសដែលបានប្រព្រឹត្តពាក់ព័ន្ធនឹងការគណនាជនរងគ្រោះ *សូមមើល* កថាខណ្ឌ ១៦៦-១៦៨ ។

[657] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២១៧-២៥៧។

[658] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២១៩-២២៥, ២៣២-២៤៧។

[659] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៨២-៤៨៧។

[660] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥០១-៥០៣។

[661] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៨៤-៤៨៧។

[662] បញ្ហាឋានានុក្រមនៃឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានយកមកពិភាក្សាដេញដោលគ្នាយ៉ាងច្រើន ជាពិសេសពាក់ព័ន្ធនឹងការផ្តន្ទាទោស។ នៅតែតម្រូវឱ្យមានគោលជំហរច្បាស់លាស់អំពីថាតើ ឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនមានភាពធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មផ្សេង

ពូជសាសន៍មានភាពធ្ងន់ធ្ងរជាខ្លាំង ដោយសារដំណោះស្រាយច្បាស់លាស់នៃអំពើនេះក្នុងការបំផ្លាញក្រុមមនុស្សទាំងនេះ[663]។ ការពិចារណាជាច្រើនបែបនេះគឺជាធាតុផ្សំមួយដែលចៅក្រមអន្តរជាតិនឹងយកមកពិចារណា។

២៥៤. អំពើរៀបរាប់ខាងលើដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលត្រូវបានប្រព្រឹត្ត បន្ទាប់ពីមានលំនាំនៃគោលនយោបាយចាប់យកទៅសម្លាប់យ៉ាងទូលំទូលាយ និងជាប្រព័ន្ធ[664]។ ក្រៅពីនេះ ជនជាតិវៀតណាម និងជនជាតិថៃមួយចំនួនដែលត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅឯសមុទ្រ មិនត្រូវបានសម្លាប់ភ្លាមទេ តែត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ដែលនៅទីនោះពួកគេបានទទួលរងការធ្វើទារុណកម្មដើម្បីទទួលបានចម្លើយសារភាព[665]។ ការធ្វើសន្និដ្ឋានទាំងនេះបង្កើតជាកត្តារឹងមាំពីភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់ មាស មុត។

២៥៥. ចៅក្រមអន្តរជាតិយល់ឃើញទៀតថា ជារួម សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់ភស្តុតាងគ្រប់គ្រាន់អំពីទង្វើព្រហ្មទណ្ឌរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មនានាដែលប្រព្រឹត្តទៅលើសមាជិកកង

---

ទៀត ឬយ៉ាងណា *សូមមើល* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង BlaĖkić* សំណុំរឿងលេខ IT-95-14-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ៨០០-៨០២។ ទោះជាយ៉ាងណាក្តី សម្រាប់ករណីយុត្តិសាស្ត្រដែលពិភាក្សាអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មអន្តរជាតិ *សូមមើលឧទាហរណ៍* តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana* សំណុំរឿងលេខ ICTR-95-1-A សាលដីកា (សំអាងហេតុ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ កថាខណ្ឌ ៣៦៧។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A និង IT-94-1-Abis សាលដីកាក្នុងការផ្តន្ទាទោសលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦៩។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Furundžija* សំណុំរឿងលេខ IT-95-17/1 សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ("សាលដីកានៃអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Furundžija* (ICTY)") កថាខណ្ឌ ២៤៣។

[663] *សូមមើលឧទាហរណ៍* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Krstić* សំណុំរឿងលេខ IT-98-33-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៧០០។ តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kambanda* សំណុំរឿងលេខ ICTR-97-23-S សាលក្រមនិងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ១៤, ១៦-១៧។

[664] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៣១-២៥៧, ៤៦៤, ៤៨៨។

[665] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៩២, ៥០៧។

ពលធំ ១៦៤[666] កងពលធំ ៥០២[667] កងពលធំ ៣១០[668] និងកងពលធំ ១១៧[669] នៃកងទ័ពបដិវត្តន៍កម្ពុជា ព្រមទាំងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅតាមការដ្ឋាននានានៃតំបន់រាម[670] និងការដ្ឋានវាយថ្មស្ទឹងហាវ[671] នៅមន្ទីរសន្តិសុខទឹកសាប[672] និងមន្ទីរសន្តិសុខឥន្ទញាណ[673] និងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម[674]។ ចៅក្រមអន្តរជាតិយល់ឃើញបន្ថែមថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់យ៉ាងត្រឹមត្រូវថា តើអង្គហេតុទាំងនោះអាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសថ្នាក់ជាតិនៃអំពើមនុស្សឃាតគិតទុកជាមុន[675] ឬយ៉ាងណា។

២៩៦. ទាក់ទិននឹងការវាយតម្លៃពីចំនួនជនរងគ្រោះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ដូចគ្នានឹងសំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២ ដែរ[676] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តវិធីសាស្ត្រមួយដោយផ្អែកលើលក្ខណៈវិនិច្ឆ័យអប្បបរមាបែបអភិរក្សនិយម ដើម្បីគណនាចំនួនអ្នកស្លាប់ និងជនរងគ្រោះដែល មាស មុត អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ[677]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ថា វិធីសាស្ត្រនេះដើម្បីចៀសវាងការរាប់ជនរងគ្រោះពីរដង និងសំដៅត្រឹមតែជនរងគ្រោះដែលភាពរងគ្រោះរបស់ខ្លួនអាចមានទំនាក់ទំនងទៅនឹងវិសាលភាពពេលវេលានៃការស៊ើបអង្កេតតែប៉ុណ្ណោះ[678]។ ហេតុនេះគាត់បានបញ្ជាក់ថា "ចំនួនជនរងគ្រោះជាក់ស្តែង [sic] អាចមានលទ្ធភាពខ្ពស់មានចំនួន*ច្រើនជាងឆ្ងាយពី*

---

[666] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៧១-២៨១។

[667] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៨២-២៨៤, ៣០០-៣០៣។

[668] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៨៥-២៨៧, ៣០៤-៣១៥។

[669] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៨៨-២៩៩, ៣១៦-៣២៨។

[670] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៣៣៩-៣៥៤។

[671] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៣៧១-៤០២។

[672] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤១១-៤២៥។

[673] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៣០-៤៤៣។

[674] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៤៤-៤៥៥។

[675] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៨០-៥៦១។

[676] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣១៨-៣២១។ សំណុំរឿង ០០៤/២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D360) កថាខណ្ឌ ១៣៧-១៥៤។

[677] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៣៣។ *សូមមើលផងដែរ ឧទាហរណ៍* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៥៧ ii., ២៨៩, ៤៤២, ៤៦៤។

[678] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៣៣។

*ចំនួនប៉ាន់ស្មាន*នៅក្នុងដីកាដំណោះស្រាយនេះ"[679]។ ទោះបីចៅក្រមអន្តរជាតិយល់ស្របថា តួលេខនៃការស្លាប់គឺជាសូចនាករក្នុងចំណោមសូចនាករផ្សេងទៀត ដើម្បីពិចារណាក្នុងការវាយតម្លៃពីផលប៉ះពាល់នៃអំពើព្រហ្មទណ្ឌក្តី[680] តែចៅក្រមអន្តរជាតិសូមអះអាងជាថ្មីថា ពុំតម្រូវឱ្យមានចំនួនជនរងគ្រោះពិតប្រាកដ និងច្បាស់លាស់នៅដំណាក់កាលមុនការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីនេះទេ[681]។ ចៅក្រមអន្តរជាតិបានគូសបញ្ជាក់នៅក្នុងសេចក្តីពិចារណាលើសំណុំរឿង ០០៤/១ របស់ខ្លួនថា "វាមិនសមហេតុផលទាល់តែសោះក្នុងការផ្តោតតែលើភាពជាក់លាក់កម្រិតខ្ពស់ក្នុងករណីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងមិនចាំបាច់ដឹងច្បាស់ពីចំនួនជនរងគ្រោះជាក់លាក់នោះទេ"[682]។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញយ៉ាងពេញលេញ ដោយផ្អែកលើតុល្យភាពនៃភាពប្រហាក់ប្រហែល ការប៉ាន់ស្មានសមហេតុផលពីចំនួនជនរងគ្រោះ[683]។ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ទាល់បានទទួលស្គាល់រួចហើយថា ការដែលគាត់ខកខានមិនបានធ្វើបែបនេះ បណ្តាលឱ្យមានការវាយតម្លៃមិនពេញលេញ និងមានតម្លៃទាបពីចំនួនជនរង

---

[679] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៣៣ (គូសបញ្ជាក់បន្ថែម)។

[680] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣០។

[681] *សូមមើលខាងលើ* កថាខណ្ឌ ១៦៧-១៦៨ ។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ២១៤។

[682] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ២១៤ *យោងទៅ* តុលាការ ICC *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bemba Gombo* សំណុំរឿងលេខ ICC-01/05-01/08-424 សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(១៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីបទចោទរបស់រដ្ឋអាជ្ញា ប្រឆាំងនឹង Jean-Pierre BEMBA GOMBO អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ១៣៤។ តុលាការ ICC *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Mbarushimana* សំណុំរឿងលេខ ICC-01/04-01/10-465-Red សេចក្តីសម្រេចលើការបញ្ជាក់ពីបទចោទ អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ១១២។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Stakić* (ICTY) កថាខណ្ឌ ២០១។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kvočka និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-98-30/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ៣០។ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៨២។

[683] *សូមមើលខាងលើ* កថាខណ្ឌ ១៦៨ ។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៨៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣០។

គ្រោះ ដែលគួសបញ្ជាក់បន្ថែមទៀតពីលក្ខណៈបែបសិប្បនិម្មិតនៃវិធីសាស្ត្រនោះ[684]។

២៩៧. ជាសេចក្តីសន្និដ្ឋាន ចៅក្រមអន្តរជាតិយល់ឃើញថា ជារួម ការកំណត់ផ្នែកអង្គច្បាប់ និងអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីទំហំ លក្ខណៈ វិសាលភាព និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំង មាស មុត បានបង្ហាញអំពីកម្រិតធ្ងន់ធ្ងរដែលដាក់ឧក្រិដ្ឋកម្មទាំងនេះទៅក្នុងប្រភេទនៃអំពើព្រហ្មទណ្ឌដែលធ្ងន់ធ្ងរ និងគួរឲ្យស្អប់ខ្ពើមដោយគ្មានការសង្ស័យឡើយ។ ចៅក្រមអន្តរជាតិសូមអះអាងជាថ្មីនូវការយល់ឃើញរបស់ខ្លួនថា ប្រសិនបើការប៉ាន់ស្មានពីការកំណត់ចំនួនជនរងគ្រោះទៅតាមវិធីសាស្ត្រដែលត្រឹមត្រូវនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រាកដជាបានសន្និដ្ឋានថា ការសន្មតពីបទចោទនានាប្រឆាំង មាស មុត មានលក្ខណៈធ្ងន់ធ្ងរជាងនេះទៅទៀត។

### ii. ការពិនិត្យឡើងវិញលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតជាតិលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់

២៩៨. កាលពីដំបូង ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតជាតិ ពុំបានចាត់ទុកថាជាការចាំបាច់ក្នុងការធ្វើសំអាងហេតុតាមផ្លូវច្បាប់ នៅលើមូលដ្ឋានថាការសម្រេចចិត្តបែបនេះគឺជាការតម្រូវសម្រាប់ដីកាសម្រេចចោទប្រកាន់[685]។ ត្រង់ចំណុចនេះ ចៅក្រមអន្តរជាតិ បញ្ជាក់សាជាថ្មីថា គ្រប់សេចក្តីសម្រេចទាំងអស់របស់អង្គតុលាការត្រូវតែមានសំអាងហេតុ តាមបទដ្ឋានអន្តរជាតិ[686]។ ជាពិសេស

---

[684] *សូមមើលខាងលើ* កថាខណ្ឌ ១៦៦-១៦៨ ។

[685] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ២៩៦។

[686] *សូមមើល* សំណុំរឿង០០២ (អ.ប.ជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ២១ *ដែលយោងទៅលើ* គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (HRC) *យោបល់ទូទៅលេខ៣២ មាត្រា១៤ (សិទ្ធិសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌) អង្គប្រជុំលើកទី១៩៩* ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ឯកសារ អ.ស.ប CCPR/C/GC/32, កថាខណ្ឌ៤៩; HRC *រឿងក្តី Van Hulst តទល់នឹង ប្រទេសហូឡង់ លិខិតលេខ* 903/1999 ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ៦.៤។ HRC *រឿងក្តី Bailey តទល់នឹងប្រទេសហ្សាម៉ាអ៊ីក លិខិតលេខ* 709/1996 ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ៧.២។ HRC *រឿងក្តី Morrison តទល់នឹងប្រទេសហ្សាម៉ាអ៊ីក លិខិតលេខ* 663/1995 ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៨.៥។ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Morrison លេខ* IT-99-37-AR65.3, សេចក្តីសម្រេចបដិសេធសំណើសុំការអនុញ្ញាតប្តឹងសាទុក្ខរបស់ Milutinović អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ២២។ សាលដីកា រឿងក្តី (ICTY) កថាខណ្ឌ៦៩។ តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី Suominen តទល់នឹងប្រទេស*

ជាងនេះទៀត វិធាន៦៧(៤)និងមាត្រា២៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ នៅក្នុងសំណុំរឿង០០១ អង្គបុរេជំនុំជម្រះកំណត់ថា "សេចក្ដីសម្រេចក្នុងការច្រានចោលការច្រានចោលអំពើទាំងឡាយ ឬបញ្ជូនជនត្រូវចោទទៅជំនុំជម្រះត្រូវផ្ដល់សំអាងហេតុដូចមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៧(៤)"[687]។ អង្គបុរេជំនុំជម្រះកំណត់បន្ថែមទៀតនៅក្នុងសេចក្ដីពិចារណារបស់ខ្លួនក្នុងសំណុំ រឿង០០៤/០១ថា "ជាអង្គជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ [អង្គបុរេជំនុំជម្រះ] ប្រាកដជាអាចពិនិត្យមើលលើសេចក្ដីសន្និដ្ឋាននានាដែលនាំឲ្យ [មានការសម្រេចលើកងួះយុត្តាធិការបុគ្គល] រួមទាំងសេចក្ដីសន្និដ្ឋានទាំងឡាយពាក់ព័ន្ធអត្ថិភាពនៃបទល្មើសឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ [ជនសង្ស័យ]"[688]។

២៩៩. ហេតុដូច្នេះ ចៅក្រមអន្តរជាតិ ដែលយល់ឃើញថាពុំមានមូលដ្ឋាននៅក្នុងការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិដែលថាមានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ តម្រូវឲ្យមានការសន្និដ្ឋានតាមផ្លូវច្បាប់នោះ ពិចារណាឃើញថា ដីកាដំណោះស្រាយដែលសម្រេចលើកលែងចោទប្រកាន់ជនសង្ស័យលើយុត្តាធិការបុគ្គលត្រូវតែមានសេចក្ដីសន្និដ្ឋានអង្គហេតុនិងអង្គច្បាប់ ដូចជាការសម្រេចបដិសេធការកំណត់តាមផ្លូវច្បាប់នូវបទល្មើសដែលបានចោទប្រកាន់ដូចមាន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនិងទម្រង់នៃការទទួលខុសត្រូវ ដែលមានការចោទប្រកាន់ថាមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិ សន្និដ្ឋានថាការណ៍ដែលលុបចោលទម្រង់ណាមួយនៃសេចក្ដីសន្និដ្ឋានអង្គច្បាប់នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតជាតិយល់ខុសយ៉ាងធ្ងន់ធ្ងរលើវិធានជាធរមាន និងបទដ្ឋាននានា និង ប្រព្រឹត្តកំហុសអង្គច្បាប់ធ្ងន់ធ្ងរ។

### ២. ការវាយតម្លៃអំពីតួនាទី និងការទទួលខុសត្រូវរបស់ មាស មុត

៣០០. សហចៅក្រមអន្តរជាតិបញ្ជាក់សាជាថ្មីថាកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ អាចវាយតម្លៃបានដោយឈរលើមូលដ្ឋាននៃការពិចារណានានាដូចជាកម្រិតនៃការចូលរួមនៅក្នុង ឧក្រិដ្ឋកម្ម ឋានៈ ឬមុខតំណែងតាមឋានានុក្រម រួមទាំងចំនួននៃអ្នកនៅក្រោមបង្គាប់និងអ្នកនៅថ្នាក់លើ និងអចិន្ត្រៃយ៍ភាព

---

*ហ្វាំងឡង់ លេខ* 37801/97 សាលក្រម ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៣៦។ *សូមមើលផងដែរ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំណុំរឿង០០១ កថាខណ្ឌ៣៨ និងជើងទំព័រ ៤០។

[687] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំណុំរឿង០០១ (D99/3/42) កថាខណ្ឌ៣៨។

[688] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1/20) សំណុំរឿង០០៤/១ កថាខណ្ឌ២៦។

01667445



នៃមុខតំណែង[689]។

ក. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតលើតួនាទីរបស់ មាស មុត

i. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

៣០១. ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា មាស មុត ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារមុខតំណែងឋានានុក្រមជាន់ខ្ពស់របស់គាត់និងសិទ្ធិអំណាចរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ[690]។ សហចៅក្រមស៊ើបអង្កេត អន្តរជាតិសន្និដ្ឋានថា មាស មុត នៅក្នុងមុខតំណែងគាត់ជា (i) មេបញ្ជាការកងពលធំ១៦៤ ទទួលខុសត្រូវលើដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យក្នុងចំណោមការទទួលខុសត្រូវផ្សេងទៀត[691] (ii) សមាជិកបម្រុងនៃគណៈកម្មាធិការសេនាធិការ និងជាអនុប្រធានមួយរូបក្នុងចំណោម អនុប្រធានរបស់ សុន សេន[692] (iii) ចាប់ពីចុងឆ្នាំ១៩៧៨មក ជាសមាជិកបម្រុងនៃគណៈកម្មាធិការ មជ្ឈិម[693]បំពេញកិច្ចការក្នុងកម្រិតខ្ពស់នៅក្នុងរចនាសម្ព័ន្ធបញ្ជាការកងទ័ពកម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅក្រោមការដឹកនាំរបស់អ្នកនយោបាយជាតិ និង "មានភាពស្និទ្ធស្នាលបំផុតជាមួយ ថ្នាក់ដឹកនាំជាន់ខ្ពស់"[694]។ សហចៅក្រមអន្តរជាតិលើកឡើងជាក់ច្បាស់ថាតួនាទីរបស់ មាស មុត និងផលប៉ះពាល់ និងលក្ខណៈនៃសកម្មភាពរបស់គាត់គឺលើស អោ អាន, អ៊ឹម ចែម, និង កាំង ហ្គេចអ៊ាវ ហៅ ឌុច យ៉ាងច្បាស់ក្រឡែត[695]។

៣០២. មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសង្កេតឃើញថា មាស មុត ក្នុងនាមជា មេបញ្ជាការកងពលធំលេខ១៦៤ ចូលរួមយ៉ាងសំខាន់នៅក្នុងការអនុវត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម ដែល

---

689 សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣២។ សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ២២។

690 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៥៦, ៤៥៩-៤៦១, ៤៦៩។

691 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៥៦-១៥៨, ៤៥៩។

692 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៦២, ៤៥៩។

693 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៥០, ៤៥៩។

694 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៥៩, ៤៦១។

695 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤៦០។

01667446



ប្រព្រឹត្តជាមួយនឹងកម្មាភិបាលជាន់ខ្ពស់នៃកងទ័ពបដិវត្តកម្ពុជា នូវគោលនយោបាយឧក្រិដ្ឋកម្មរបស់ ប.ក.ក សំដៅ (i)បង្កើតសហករណ៍និងការដ្ឋានធ្វើពលកម្មដោយបង្ខំ[696] (ii) អប់រំ "សមាសភាពមិនល្អ" និងសម្លាប់ "ខ្មាំងទាំងនៅក្នុងជួរនិងក្រៅជួរកងទ័ព"[697] (iii) កំណត់មុខសញ្ញា ក្រុមជាក់លាក់ ជាពិសេស ជាតិពន្ធុឬជនជាតិវៀតណាម ឬថៃ អតីតយោធា និង ជនស៊ីវិល[698] និង (iv) អនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដល់ជនស៊ីវិលនិងកងទ័ពបដិវត្តកម្ពុជា[699]។ សហ ចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថាដោយសារគាត់មានតួនាទីផ្សេងៗ មាស មុត គឺជា បុគ្គលដ៏សំខាន់ដែលទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅក្នុងតំបន់ដែលគាត់មានអំណាច និង ដឹងថាគោលនយោបាយទាំងនេះនឹងត្រូវយកទៅអនុវត្តតាមរយៈ ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[700]។

៣០៣. ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមទៀតទៅលើការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា ឧក្រិដ្ឋកម្មអន្តរជាតិនិងជាតិដែល មាស មុត ត្រូវបានចោទប្រកាន់ គឺត្រូវបានប្រព្រឹត្តក្នុងការលើកតម្កើងគោលនយោបាយរបស់ ប.ក.ក ក្រោមការទទួលខុសត្រូវនិងអំណាច ផ្ទាល់របស់គាត់ ដោយហេតុថាគាត់ចូលរួមយ៉ាងសកម្មក្នុងការបង្កើតនិងរៀបចំវិធីនៃការអនុវត្ត ហើយការណ៍ដែលថាគាត់មិនមានវត្តមានផ្ទាល់នៅមន្ទីរស២១ មិនបានសម្រាលដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ទេ[701]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានទៀតថា មាស មុត ទទួលខុសត្រូវលើការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មតាមច្បាប់ជាតិនិងអន្តរជាតិស្ទើរតែទាំងអស់[702]។ ចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា មាស មុត មានការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្ម តាមច្បាប់អន្តរជាតិ ស្ទើរតែទាំងអស់[703]។

### ii. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតជាតិ

---

[696] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៧៣-១៨០, ៥៦២,៥៦៦។

[697] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៨១-១៨៩, ៥៦២,៥៦៧។

[698] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៩០-១៩៩, ៥៦២,៥៦៨-៥៦៩។

[699] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២០០-២០៥, ៥៦២,៥៧០។

[700] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៦៥។

[701] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៧១, ៥៧៧។

[702] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៧៣, ៥៧៧។

[703] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៧៤-៥៧៥។

៣០៤. ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតជាតិបានឈានដល់ការសន្និដ្ឋានផ្ទុយដែលថា មាស មុត មិនមែនស្ថិតក្នុងចំណោម "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត"ឡើយ ដោយហេតុថាការចូលរួមរបស់គាត់មិនសកម្ម ហើយក៏មិនកៀកកិតទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែរ[704]។

៣០៥. ពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យនៃកម្រិតនៃការទទួលខុសត្រូវរបស់យុត្តាធិការបុគ្គលនិងកត្តា ពាក់ព័ន្ធសម្រាប់ការវាយតម្លៃ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ការអះអាងរបស់សហចៅក្រម ស៊ើបអង្កេតជាតិដែលថាវិសាលភាពនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់និងអានុភាពនៃអំពើ ទាំងនោះគឺជាចំណុចត្រូវពិនិត្យមើលដ៏ត្រឹមត្រូវមួយ"[705]។ គាត់រម្លឹកថាសំអាងហេតុនេះត្រូវបាន គាំទ្រដោយការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ ឌុច[706] ដែលផ្ដោតសំខាន់លើការចូលរួមដោយផ្ទាល់របស់គាត់ សិទ្ធិអំណាច ឥទ្ធិពលក្នុងការ ធ្វើសេចក្ដីសម្រេច និងការចាត់ចែង[707]។ សហចៅក្រមស៊ើបអង្កេតជាតិអះអាងបន្ថែមទៀតថា អ្នកធ្វើសេចក្ដីព្រាងច្បាប់ អ.វ.ត.ក បានបញ្ចូលពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់តែ ឌុច[708] ដែលបង្ហាញតាមទស្សនៈរបស់គាត់ថា ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដូចជា ឌុច គួរតែបានដើរតួនាទីសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទ និង គួរមានភាពកៀកកិតទៅនឹងការប្រព្រឹត្ត ស្វយ័តនិងមានសិទ្ធិអំណាចជាក់ស្ដែង[709]។ គាត់អះអាងទៀតថា ចំនួនជនរងគ្រោះបង្ហាញអំពីផលវិបាកនៃសកម្មភាពផ្ទាល់និងជាក់ស្ដែងរបស់ ឌុច[710]។

៣០៦. សហចៅក្រមអន្តរជាតិកត់សម្គាល់លើការពិភាក្សាអង្គហេតុរបស់សហចៅក្រមស៊ើប អង្កេតជាតិដែលពាក់ព័ន្ធនឹង តួនាទីរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ ទី១ សហចៅក្រមស៊ើបអង្កេតជាតិបានអះអាងថា មាស មុត មិនបានពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាមួយ ដែលបានប្រព្រឹត្តទាក់ទិននឹង

---

704 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៤២៧-៤២៨។

705 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៦៩-៣៦៩ ។

706 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៧០-៣៧២ *យោងទៅលើ* សាលក្រមសំណុំរឿង០០១ (E188) កថាខណ្ឌ ១៨, ២៣, ១១៩, ១២៨, ១៣១, ១៤០-១៤១, ១៥៤, ១៧៤, ១៧៧, ៣៩៥។

707 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៧៣។

708 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៩៦។

709 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៩៧។

710 ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៧៥។

មន្ទីរស២១ឡើយ[711] ដោយហេតុថាគាត់ពុំមានសិទ្ធិចាប់មនុស្ស[712] មិនត្រូវបានពិគ្រោះលើសេចក្តីសម្រេចក្នុងការចាប់ខ្លួន[713] ត្រឹមតែអនុវត្តសេចក្តីសម្រេចចាប់មនុស្សទៅឃុំឃាំងប៉ុណ្ណោះ[714] និងនៅតែរក្សាការអះអាងថាពុំមានទំនាក់ទំនងផ្ទាល់ជាមួយ ឌុច ទេ[715]។ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តឥន្ទ ញាណ[716]សហចៅក្រមស៊ើបអង្កេតជាតិបានពន្យល់ថា មាស មុត មិនមានវត្តមាននៅក្នុងអំឡុង ពេលនៃការចាប់ខ្លួនឬការត្រួតពិនិត្យមន្ទីរសន្តិសុខនោះឡើយ[717]។ ជាងនេះទៀត ទោះបីជាកងវរសេនាតូច៤៥០ ដែលជាផ្នែកមួយនៃកងពលធំលេខ១៦៤ គ្រប់គ្រងការដ្ឋានវាយថ្ម ស្ទឹងហាវក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតជាតិអះអាងថា មាស មុត មិនដែលមកពិនិត្យទីតាំងឧក្រិដ្ឋកម្មនោះឡើយ និង ថាគ្រាន់តែបញ្ជូនបទបញ្ជាពី សុន សេន ឱ្យវរសេនាតូចដើម្បីចាប់មនុស្សនិងបញ្ជូនទៅការដ្ឋាននោះប៉ុណ្ណោះ[718]។ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទថា ត្រូវបានប្រព្រឹត្តដោយកងទ័ពជើងទឹក[719] សហចៅក្រមស៊ើបអង្កេតរកឃើញថា មាស មុត ចូលសម្រាកនៅមន្ទីរពេទ្យក្នុងអំឡុងពេលនៃឧប្បត្តិហេតុកប៉ាល់ម៉ៃយ៉ាហ្គេស[720] ដែលមិនអាចធ្វើការសម្រេចដោយគ្មានការអនុញ្ញាតពីថ្នាក់លើឡើយពាក់ព័ន្ធនឹងការចាប់និងការសម្លាប់ អ្នកនេសាទ[721]និងមានតែជនរងគ្រោះមួយចំនួនតូចប៉ុណ្ណោះត្រូវបានរាយការណ៍[722]។ ជាងនេះ ទៀត មាស មុត អាចមិនមានការពាក់ព័ន្ធនឹងជម្លោះជាមួយវៀតណាម[723]និងឧក្រិដ្ឋកម្មទាក់ទិន នឹងជម្លោះនេះ[724]។

---

[711] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៧៩-២៨០។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៦៣-២៨៧ (ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទាក់ទងនឹងស-២១)។

[712] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៨១-២៨៣។

[713] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៨៥។

[714] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៨៦។

[715] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៨២។

[716] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៨៨-២៩៧។

[717] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៩៧។

[718] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣០៥។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៩៨-៣០៥ (ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅការដ្ឋានវាយថ្មស្ទឹងហាវ)។

[719] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣០៦, ៣២២។

[720] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣១១។

[721] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣១៦, ៣២១។

[722] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣១៣-៣១៥។

[723] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣២៧។

[724] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣២៣-៣២៩។

មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតជាតិអះអាងថា មាស មុត ពុំមាន ទំនាក់ទំនងតាមផ្លូវច្បាប់និងភាពជាក់ស្តែងជាមួយកងពលធំលេខ៨០១ឡើយ[725]ឬក៏មិនពាក់ព័ន្ធ ទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទថាត្រូវបានប្រព្រឹត្តដោយកងពលនោះដែរ[726]ផ្អែកលើរចនា សម្ព័ន្ធនិងតួនាទីរបស់កងពលនោះ[727]។ ចំណុចចុងក្រោយ គឺថាពុំមានភស្តុតាងបង្ហាញថា មាស មុត ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខរបស់កងទ័ពបដិវត្តកម្ពុជាទេ[728]។

៣០៧. ពាក់ព័ន្ធនឹងតួនាទីរបស់ មាស មុត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចៅក្រមអន្តរជាតិសង្កេតឃើញថា ទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិទទួលស្គាល់ថា មាស មុត "មានតួនាទីជាច្រើនក៏ដោយ"[729] ឧទាហរណ៍ដូចជា មេបញ្ជាការកងពលធំលេខ១៦៤[730] និង ជំនួយការនៃគណៈកម្មាធិការមជ្ឈិម[731] ក៏គាត់សន្និដ្ឋានថា មាស មុត មិនមែនជាបុគ្គលមួយរូប ក្នុងចំណោមបុគ្គល១៣រូបដែលមានសិទ្ធិបញ្ជាចាប់ខ្លួននិងសម្លាប់ឡើយ[732]។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតជាតិ បានសន្និដ្ឋានថា មាស មុត ""គ្មានសិទ្ធិអំណាចច្រើនទេ"[733] ដោយសារតែគាត់ស្ថិតនៅក្រោមកម្មាភិបាលប្រហែល ៥០រូបទៀត[734] និងគ្រាន់តែអនុវត្តបញ្ជាពីថ្នាក់លើ និងរាយការណ៍ជូនថ្នាក់លើប៉ុណ្ណោះ[735]។

៣០៨. សហចៅក្រមស៊ើបអង្កេតជាតិសន្និដ្ឋានថា មាស មុត មិនមែនជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ[736]ផ្អែកលើការពិភាក្សាអង្គហេតុខាងលើ។ តាមទស្សនៈរបស់សហចៅក្រមជាតិ ពុំមានភស្តុតាងបង្ហាញអំពីគំនិតផ្តួចផ្តើមរបស់មាស មុត និងលទ្ធភាពក្នុងការបញ្ជាការចាប់ខ្លួន

---

[725] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥១។

[726] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៣០-៣៥១។

[727] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥១។

[728] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៥២។

[729] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២៨។

[730] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤១៦-៤១៧។

[731] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤១៨-៤១៩។

[732] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤១៨ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ១៦៩។

[733] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២៨។

[734] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤១៩។

[735] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២១-៤២៥, ៤២៨។

[736] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២៧-៤២៩។

និងសម្លាប់ឡើយ[737] ក្នុងអំឡុងពេលនៃការបោសសម្អាត កងពលធំលេខ១៦៤ ដែលគាត់មានការពាក់ព័ន្ធ[738] ។ ផ្ទុយទៅវិញ ភស្តុតាងបង្ហាញអំពីភវនីយភាពកាន់តែតិចដែលថា មាស មុត មានអំណាចតាមលក្ខខណ្ឌតម្រូវក្នុងការសម្របសម្រួលឬរៀបចំផ្ទេរអ្នកទោសទៅ ស២១ និង បង្ក្រាបខ្មាំងក្នុងដែនទឹក[739]។

ខ. ពិភាក្សា

*i. សាវតារនិងតួនាទីរបស់ មាស មុត*

៣០៩. ចៅក្រមអន្តរជាតិយល់ឃើញថាជាការចាំបាច់ក្នុងការរម្លឹកអំពីសាវតាររបស់ មាស មុត មុននឹងកំណត់អំពីតួនាទីនានារបស់គាត់នៅក្នុង ប.ក.ក ពេញរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

៣១០. មាស មុត បានបញ្ជាក់ថាគាត់ចូលខ្មែរក្រហមដំបូងនៅឆ្នាំ១៩៧០[740]។ គាត់មានតួនាទីជាពេទ្យនៅក្នុងភូមិពោធិ៍ ក្រោយមកនៅក្នុងស្រុកអង្គរជ័យ (ស្រុក១០២) តំបន់១៣[741]។ នៅចុងឆ្នាំ១៩៧០ ឬដើមឆ្នាំ១៩៧១ មាស មុត ក្លាយជាអនុមេបញ្ជាការយោធាស្រុក១០២ គ្រប់គ្រង ទ័ពចំនួន ប្រមាណ ២០០នាក់[742]។ បន្ទាប់មកគាត់ត្រូវបានតែងតាំងជាគណៈតំបន់១៣ ភូមិភាគនិរតី ទទួល បន្ទុកយោធារហូតដល់យ៉ាងហោចណាស់ឆ្នាំ១៩៧៣[743]។ នៅក្នុងអំឡុងពេលមុនបែកភ្នំពេញឆ្នាំ ១៩៧៥ មាស មុត ក្លាយជាសមាជិកពេញសិទ្ធិ

---

[737] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៥៨, ៤២៣។

[738] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៥៨, ៤២២-៤២៣។

[739] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ២៥៨, ៤២៥។

[740] បទសម្ភាសន៍ជាមួយ មាស មុត (POW/MIA) ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០១ D22.2.181 ("បទសម្ភាសន៍ជាមួយ មាស មុត (D22.2.181)") KH ERN 00741996 ទំព័រ៣។

[741] បទសម្ភាសន៍ជាមួយ មាស មុត (D22.2.181) KH ERN 00741996 ទំព័រ៣។ បទសម្ភាសន៍ជាមួយ មាស មុត (POW/MIA) ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២ D22.2.182 ("បទសម្ភាសន៍ជាមួយ មាស មុត (D22.2.182)") KH ERN 00741989 ។

[742] បទសម្ភាសន៍ជាមួយ មាស មុត (D22.2.182) KH ERN 00741989។

[743] បទសម្ភាសន៍ជាមួយ មាស មុត (D22.2.181) KH ERN 00741996។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ D54/62 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/62)") KH ERN 00975781 (ឆ.១៥)។ សៀវភៅនិពន្ធដោយ Ben KIERNAN មានចំណងជើង *របបប៉ុល ពត ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍នៅ កម្ពុជា ក្រោមការដឹកនាំរបស់ខ្មែរក្រហម ឆ្នាំ១៩៧៥-១៩៧៩* D114/29.1.4 EN ERN 00678538។

នៃ ប.ក.ក[744]។

៣១១. មាស មុត បានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ តាម៉ុក ដែលជាលេខាភូមិភាគខ្មែរក្រហម និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍។ ជាការពិត មាស មុត បានរៀបការជាមួយ កូនស្រីរបស់ តាម៉ុក[745] និងជាលេខាស្រុកត្រាំកក់(ស្រុក១០៥)[746]មុនឆ្នាំ១៩៧៣ ធ្វើឱ្យគាត់ក្លាយជាកូនប្រសាររបស់មេដឹកនាំជាន់ខ្ពស់បំផុតរបស់ខ្មែរក្រហមមួយរូប។ មាស មុត នៅតែមាន ភក្តីភាពជាមួយ តាម៉ុក ទទួលបញ្ជាពីគាត់ ប្រមាណ១៨ឆ្នាំក្រោយពីរបបខ្មែរក្រហមដួលរលំ[747]។ មាស មុត ត្រូវបានអ្នកនៅក្រោមបង្គាប់ពិពណ៌នាថា ជា "មនុស្សសាហាវ"[748]និង អ្នកថ្នាក់លើខ្លាចគាត់[749]។

---

[744] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ D54/110 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង (D54/110)") KH ERN 00997259 (ឆ.២៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ D54/54 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន (D54/54)") KH ERN 00970657 (ឆ.៥)។

[745] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ ឯកសារ D54/70 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ (D54/70)") KH ERN 00979226 (ឆ.១៥)។

[746] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ (D54/70) KH ERN 00979223-00979226 (ឆ.១៣, ឆ.១៨)។

[747] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ D114/158 ("កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច (D114/158)") KH ERN 01202336 (ឆ.២០)។

[748] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D114/65 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា (D114/65)") KH ERN 01096732 (ឆ.២០)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ D54/37 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី (D54/37)") KH ERN 00964279 ។ *សូមមើលផងដែរ* បទសម្ភាសន៍របស់ ស៊ឹម នី ជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D54/30.1 ("បទសម្ភាសន៍របស់ ស៊ឹម នី ជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា (D54/30.1)"), KH ERN 00964130 ("[ស]: សម្លឹងម៉េចទៅ? [ឆ]: សម្លឹងមិនព្រិចហ្នឹង ខ្ញុំមិនអីទេ ហើយខ្ញុំទៅកាត់សក់ ហើយគាត់ធ្វើកន្លែងផ្ទះទទួលភ្ញៀវនៅជិតផ្ទះប្រពន្ធគាត់ខ្មោច ខំ ហ្នឹង ដល់ពេលជាងខ្ញុំមិនដឹងថាភិនភាគយ៉ាងម៉េចទេ ដល់ពេលធ្វើឃើញប្រក់អីខុស ខុសបំណងបន្តិច ដល់ពេលខុសបំណងចិត្តគាត់លែងហៅជាងឡើចុះមកពីលើដំបូលផ្ទះដីលែងកាប់ក្បាលត្រឹមហ្នឹង ទាញកូនប្រចៅពីដៃជាងហ្នឹងមក ទក្បាលត្រឹមហ្នឹងដោះដួលស្រុច។ [ស]: ស្លាប់ដែរ? [ឆ]: ស្លាប់ [É] [ស]: ឮឃើញផ្ទាល់នឹងភ្នែក? [ឆ]: ឃើញផ្ទាល់ភ្នែក។")។

[749] ប្រតិចារឹកសំណុំរឿង០០២/២ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ D234/2.1.95 KH ERN 01394556 ទំព័រ ២១ ("លោកសាក្សីលោកធ្លាប់ឮទេ ដែលនៅពេលនោះគឺថា តាសោម និងតាមុតនេះ ត្រូវបាន តាម៉ុក ស្តីបន្ទោសឲ្យថា "ជាមនុស្សកាចសហាវ"។ លោកចាំទេ? [É] ខ្ញុំចងចាំនោះ ពេលនោះគាត់និយាយអំពីលក្ខណៈឲ្យកម្មាភិបាលបង្កបង្កើត [É] ហើយគាត់ងាកពេលហ្នឹងគាត់

៣១២. ចៅក្រមអន្តរជាតិកត់សម្គាល់ថា តួនាទីរបស់ មាស មុត នៅក្នុង ប.ក.ក មានលក្ខណៈ ផ្សេងៗគ្នា ហើយជាការចាំបាច់គឺត្រូវលើកឡើងអំពីតួនាទីនីមួយៗដើម្បីវាយតម្លៃការទទួលខុសត្រូវរបស់គាត់ឲ្យបានគ្រប់ជ្រុងជ្រោយ។

(ក) សមាជិកគណៈកម្មាធិការមជ្ឈិម

៣១៣. ពាក់ព័ន្ធនឹងសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម ចៅក្រមអន្តរជាតិរកឃើញភស្តុតាងដែលបង្ហាញថា មាស មុត បានក្លាយជាផ្នែកមួយនៃគណៈកម្មាធិការ មជ្ឈិមនៅដើមឆ្នាំ១៩៧៥[750]។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ទាំង ខៀវ សំផន ទាំង ឌុច គឺ សុទ្ធតែកំណត់ មាស មុត ថាជា "សមាជិក"ឬ "ជំនួយការ"គណៈកម្មាធិការមជ្ឈិម[751]។ ក្រោយ ពីទទួលបានឋានៈជាមេបញ្ជាការកងពលធំលេខ១៦៤ក្នុងឆ្នាំ១៩៧៥[752] មាស មុត ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ[753] ដែលជារចនាសម្ព័ន្ធខ្ពស់ជាងគេបង្អស់នៃកងទ័ពបដិវត្តកម្ពុជា ទទួលបន្ទុកកងពលមជ្ឈិម និងការងារយោធាក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម[754]។ ជាងនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថាគិត

---

អង្គុយកណ្ដាល ហើយ តាមសោម និងតាមុត អង្គុយខាង។ គាត់ថា អ៊ីចឹងដូចជាសូមធ្វើការប្រាប់ផង គ្រូសោម គ្រូមុត ប្រជាជនឮថាប្រជាជនខ្លាច ខ្ញុំដើរមកគេប្រាប់។ អ៊ីចឹងធ្វើម៉េចលោកចុះទៅឲ្យប្រជាជនស្រឡាញ់ ធ្វើម៉េចកុំឲ្យគេ ខ្លាច។")។

[750] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ D4.1.405, KH ERN 00244235 ("[ណាត] បង្ហាញពីការច្រណែន នៅពេលដែលមាស មុត និងសំ ប៊ិត ត្រូវបានតែងតាំងជាសមាជិកគណៈមជ្ឈិមក្នុងឆ្នាំ ១៩៧៥")។

[751] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ D1.3.33.15 KH ERN 00156751។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ D12 KH ERN 00680802 ។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ D1.3.33.13 KH ERN 00154911។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លុន សេង (D54/110) KH ERN 00997258 (ឆ.២០, ឆ.២២, ឆ.២៣) (សាក្សីនេះលើកឡើងអំពី "គណៈកម្មាធិការជំនួស" សម្រាប់ជួយគណៈមជ្ឈិម ហើយមាស មុត ស្ថិតក្នុងគណៈកម្មាធិការជំនួសនេះ)។

[752] *សូមមើល ខាងក្រោម* កថាខណ្ឌ ៣១៥-៣១៦។

[753] *សូមមើល ខាងក្រោម* កថាខណ្ឌ ៣២៥-៣២៧ ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លុន សេង (D54/110) KH ERN 00997256 (ឆ.៩)។

[754] សាលក្រមសំណុំរឿង ០០២/០១ (E313), កថាខណ្ឌ ២៤២។

ត្រឹមឆ្នាំ១៩៧៨ មាស មុត ក្លាយជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម[755]។ ជាលទ្ធផល និងដោយផ្អែកលើភស្តុតាង ដែលមាន ចៅក្រមអន្តរជាតិសន្និដ្ឋានថា បុព្វសិទ្ធិរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិមចេះតែរីកវឌ្ឍទៅមុខ ពីជំនួយការនៅក្នុងឆ្នាំ១៩៧៥ រហូតដល់សមាជិកបម្រុងនៅក្នុងឆ្នាំ១៩៧៨ ដែលត្រូវបានគេចាត់ទុកជាតំណាងរបស់គណៈកម្មាធិការមជ្ឈិមនៅក្នុងអំឡុងបេសកកម្មនានា ក្រៅតំបន់ស្វយ័តកំពង់សោម[756]។

៣១៤. អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិ ដែលគ្រាន់តែពិចារណាលើតួនាទីរបស់ មាស មុត ជាជំនួយការគណៈកម្មាធិការមជ្ឈិម[757] និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលគ្រាន់តែសន្និដ្ឋានអំពីតួនាទីរបស់ មាស មុត ជាសមាជិកបម្រុងចាប់ពីឆ្នាំ១៩៧៨ ឡើងទៅ[758] សុទ្ធតែខកខានមិនបានពិពណ៌នាឲ្យបានត្រឹមត្រូវ លើទំហំពេញលេញនៃការចូលរួមរបស់ មាស មុត និងសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម។

(ខ) មេបញ្ជាការកងពលធំលេខ១៦៤

(i) ចាប់ផ្ដើមពីមេបញ្ជាការកងពលធំលេខ៣

៣១៥. កាលពីដំបូង ចៅក្រមអន្តរជាតិសន្និដ្ឋានដោយផ្អែកលើភស្តុតាងស៊ីសង្វាក់ថា មាស មុត កាន់តួ

---

[755] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ D114/159 ("កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច (D114/159)") KH ERN 01202353 (ឆ.១៨)។

[756] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥ D114/52 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ (D114/52") KH ERN 01071601 (ឆ.40), 01071604 (ឆ.៥៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ D4.1.810 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន (D4.1.810)") KH ERN 00402509 (ឆ.២៦, ឆ.២៧)។

[757] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266), កថាខណ្ឌ១១១-១២១, ៤១៨។

[758] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267), កថាខណ្ឌ ១៥០, ៤៥៩។ ចៅក្រមអន្តរជាតិ យល់ឃើញថាវាជាការសំខាន់ក្នុងការបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលស្គាល់ក្នុងកថាខណ្ឌ១៥០នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន អំពីតួនាទីរបស់មាស មុត ជាជំនួយការគណៈកម្មាធិការកងទ័ព ដែលដឹកនាំដោយប៉ុល ពត ដែលជួយដល់គណៈកម្មាធិការមជ្ឈិម ក្នុងចំណោមគណៈកម្មាធិការផ្សេងទៀត។ តាមរយៈការអានដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនធ្វើការសន្និដ្ឋានថា ជនដែលត្រូវចោទ មានតួនាទីស្រដៀងគ្នាជាជំនួយការ ឬសមាជិកគណៈកម្មាធិការមជ្ឈិមឡើយ មុនពេលក្លាយជាសមាជិកបម្រុងនៃគណៈកម្មាធិការនេះក្នុងឆ្នាំ១៩៧៨។

នាទីជាមេបញ្ជាការកងពលធំលេខ៣[759] ចាប់តាំងពីការបង្កើតកងពលនោះនៅចុងឆ្នាំ១៩៧៣ ឬដើមឆ្នាំ ១៩៧៤[760]។

៣១៦. ភស្តុតាងនៅក្នុងសំណុំរឿងបញ្ជាក់ច្បាស់ថា មាស មុត គឺជាមេបញ្ជាការកងពលធំលេខ៣ ក្នុងឆ្នាំ១៩៧៥ ក្នុងអំឡុងពេលនៃការវាយលុកចូលទីក្រុងភ្នំពេញ[761]និងនៅពេលដែលកងពលធំលេខ៣ ត្រូវបាន

---

[759] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា (D114/65) KH ERN 01096732-01096733 (ឆ.៦, ឆ.៩)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ D2/8 KH ERN 00607068 (ឆ.២៧), 00607069 (ឆ.៣២)។

[760] យោងលើចម្លើយដែលមានការបញ្ជាក់ពីមាស មុត គាត់បានក្លាយមេបញ្ជាការកងពលធំលេខ៣ ចុងក្រោយបង្អស់ក្នុងអំឡុងឆ្នាំ១៩៧៤។ *សូមមើល* បទសម្ភាសន៍ជាមួយមាស មុត (D22.2.181) KH ERN 00741996 ("ក្នុងឆ្នាំ១៩៧៤ គាត់ត្រូវបានតែងតាំងធ្វើជាមន្ត្រីនយោបាយទទួលបន្ទុកកងពលធំលេខដែលត្រូវបានបង្កើតឡើងថ្មីរបស់កងទ័ពកុម្មុយនីស្ត" (គូសបញ្ជាក់បន្ថែម) [កែតម្រូវ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ រ៉ាន់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ D114/132 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ រ៉ាន់ (D114/132)") KH ERN 01154111 (ឆ.១៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា (D114/65) KH ERN 01096732 (ឆ.៥-ឆ.៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ង៉ុន ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ D114/48 KH ERN 01071534 (ឆ.៨, ឆ.៩, ឆ.១០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ថ្ងៃទី១៤ ខែមីនាឆ្នាំ២០១៦ D114/186 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ (D114/186)") KH ERN 01214202-01214203 (ឆ.៨-ឆ.៩, ឆ.១៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ូង ជ្រោង ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ D2/6 KH ERN 00598402 (ឆ.១០)។ សាក្សីមួយចំនួន រៀបរាប់ថាមាស មុត កាន់តំណែងនៅក្នុងកងពលធំលេខ៣ ចាប់តាំងពីចុងឆ្នាំ១៩៧៣ នៅពេលដែលកងពលធំនោះត្រូវបានបង្កើត។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ D54/98 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត (D54/98)") KH ERN 00990389 (ឆ.៣៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉េន ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥ D114/113 KH ERN 01138458 (ឆ.១៥, ឆ.១៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម កុល ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ D114/181 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម កុល (D114/181)") KH ERN 01211916 (ឆ.៦, ឆ.៧, ឆ.៨, ឆ.៩)។

[761] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ D54/43 KH ERN 00967503-00967504 (ឆ.១, ឆ.៦-ឆ.៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជី ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ D114/261 KH ERN 01335468 (ឆ.២៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ D114/18 KH ERN 01034003 (ឆ.២-ឆ.៣)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ រ៉ាន់ (D114/132) KH ERN 01154111 (ឆ.១៥-ឆ.១៦)។ កិច្ច សម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់ សុខា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១ D54/35.1 ("កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់ សុខា (D54/35.1)") EN ERN 00971209។ ប្រតិចារឹកសំណុំរឿង០០២/២ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ (ព្រំ សារ៉ាត់) D234/2.1.91 KH ERN 01198893 ("ស. អរគុណ។ តើលោកស្គាល់មេបញ្ជាការកងពលលេខ៣ ឈ្មោះអ្វី? ឆ.មេបញ្ជាការកងពលលេខ៣ គាត់ឈ្មោះមាស មុត។ ស. ខ្ញុំនឹងនិយាយពីមេ

បញ្ជូនទៅកំពង់សោមភ្លាមៗក្រោយពីកាន់កាប់រដ្ឋធានីបាន[762]។

(ii) ការបង្កើតកងពលធំលេខ១៦៤ និងតួនាទីរបស់ មាស មុត

៣១៧. ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា មាស មុត នៅតែទទួលបន្ទុកដដែលនៅពេលដែល កងពលធំលេខ៣ ក្លាយជាកងពលធំលេខ១៦៤[763]។ ចៅក្រមកត់សម្គាល់ថា កងពលធំលេខ៤ បង្កើតឡើងដំបូងពីការផ្គុំគ្នានៃកងពលធំលេខ៣របស់ភូមិភាគនីរតី និង យោធានានា ពីតំបន់៣៧[764]។ យោងតាមសហចៅក្រមស៊ើបអង្កេតជាតិ កងពលធំលេខ១៦៤ ត្រូវបានបង្កើត ឡើងនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥[765]និងនាំដល់ការបង្កើតកងទ័ពជើងទឹកកម្ពុជាប្រជា ធិបតេយ្យ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ នៅក្នុងអំឡុងពេលនៃការប្រជុំមួយរបស់គណៈកម្មា ធិការអចិន្ត្រៃយ៍[766]។ ក៏ប៉ុន្តែ ចៅក្រមអន្តរជាតិបានពិនិត្យភស្តុតាងយ៉ាងហ្មត់ចត់ដែលបញ្ជាក់ថា កងពលធំលេខ១៦៤ ត្រូវបានបង្កើតឡើងនិងប្រតិបត្តិការជាកងទ័ពជើងទឹកកម្ពុជា

---

បញ្ជាការផ្សេងទៀត ក្នុងពេលខាងមុខ។ ឥឡូវនេះ ខ្ញុំត្រឡប់មកពេលវេលាជាក់លាក់មួយ។ តើលោកនៅចាំឬទេថា កងពលរបស់លោកហ្នឹងចូលពាក់ព័ន្ធនៅក្នុងការវាយប្រហារទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ឬទេ? ឆ. បាទ កងពលរបស់ខ្ញុំមានការជាប់ពាក់ព័ន្ធវាយប្រហារប្រយុទ្ធនៅសមរភូមិភ្នំពេញនៅឆ្នាំ១៩៧៥។ វាជាការពិត។" (គូសបញ្ជាក់បន្ថែម)។

[762] បទសម្ភាសន៍ជាមួយ មាស មុត (D22.2.181) KH ERN 00741997 ("នៅម៉ោង៤ល្ងាច ថ្ងៃទី១៧ ខែមសា ឆ្នាំ១៩៧៥ កងពលធំលេខ៣ បានទទួលបញ្ជាឲ្យទៅកាន់កំពង់សោម")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ (D114/186) KH ERN 01214203 (ឆ.១៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ (D114/132) KH ERN 01154111 (ឆ.១៨-១៩)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ D54/77 ("កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក (D54/77)") KH ERN 00982522 (ឆ.៦)។

[763] បទសម្ភាសន៍ជាមួយ មាស មុត (D22.2.181) KH ERN 00742002 ("នៅចុងឆ្នាំ១៩៧៥ កងពលធំលេខ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធជាកងពលធំលេខ១៦៤ [É]. សមាសភាពនៃគណៈបញ្ជាការកងពលធំនេះ ស្ថិតនៅដដែល")។ កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី ឯក នី ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ D114/282 KH ERN 01353846 (ឆ.១០)។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់ សុខា (D54/35.1) EN ERN 00971209។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ (D114/186) KH ERN 01214203 (ឆ.១៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជី ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ D114/281 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជី (D114/281)") KH ERN 01348833 (ឆ.១១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម កុល (D114/181) KH ERN 01211922 (ឆ.៤៤)។

[764] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជី (D114/281) KH ERN 01348833 (ឆ.១០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ D54/51 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក") KH ERN 00970619 (ឆ.១០)។

[765] *សូមមើល* ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ១៨៧ និងជើងទំព័រ ៥៦៣។

[766] *សូមមើល* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៧ និងជើងទំព័រ ៥៦៤។

ប្រជាធិបតេយ្យនៅក្នុងរយៈកាល ២ខែក្រោយពីទីក្រុងភ្នំពេញបានដួលរលំ[767] ដូចនេះ គឺប្រហែល ក្រោយកិច្ចប្រជុំនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ នៅស្តាតអូឡាំពិក ទីក្រុងភ្នំពេញ។ ភស្តុតាង បន្ថែមបង្ហាញថា មាស មុត ត្រូវបានឧទ្ទេសនាមថាជាមេបញ្ជាការកងទ័ពជើងទឹក ទទួលបន្ទុក ការពារដែនទឹកនិងបណ្តាកោះរបស់កម្ពុជាប្រជាធិបតេយ្យ នៅក្នុងកិច្ចប្រជុំដែលដែលរៀបចំ នៅក្នុងឆ្នាំ១៩៧៥[768]។ ចៅក្រមអន្តរជាតិកត់សម្គាល់ទៀតថា សហចៅក្រមស៊ើបអង្កេតជាតិ នៅក្នុងការគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា កងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅក្នុង ខែតុលា ឆ្នាំ១៩៧៥ បង្ហាញនូវកំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ដែលរៀបរាប់អំពី "ការរៀបចំកងទ័ពជើងទឹកថ្មី"[769] មិនមែនជាការបង្កើតកងពលធំនេះឡើយ។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិផ្អែកលើភស្តុតាងមិនបានការ (ប្រសិនជាពាក់ព័ន្ធ) ក្នុងការផ្តល់ ភាពលម្អិតនៃការបង្កើតកងពលធំលេខ១៦៤ និង សន្និដ្ឋានថា កងពលធំនោះ ដែលបញ្ជាដោយ មាស មុត គឺត្រូវបានបង្កើតឡើងយ៉ាងយូរបំផុតត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ ១៩៧៥ និងបញ្ចូលគ្នាជាមួយកងទ័ពជើងទឹករួចស្រេចទៅហើយ។

៣១៨. ធាតុផ្សំមួយទៀតដែលបង្ហាញអំពីឋានៈដោយឡែករបស់ មាស មុត នៅក្នុងឋានានុក្រមនៃ កងទ័ពបដិវត្តកម្ពុជាគឺការណ៍ដែលថា ក្នុងឋានៈជាមេបញ្ជាការកងពលមជ្ឈិម គាត់រាយការណ៍ ដោយផ្ទាល់ទៅមជ្ឈិមបក្ស។ ជាការផ្ទុយទៅនឹងការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលថាលេខាទាំងអស់

---

[767] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ិក (D54/77) KH ERN 00982522 (ឆ.៦)។ ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ (ទាំងស្រុង) D4.1.861 ("ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ (D4.1.861)") EN ERN 00401488។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ D54/47 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន (D54/47)") KH ERN 00969426 (ឆ.១៨)។ ចំពោះភស្តុតាងប្រហោលដែលកងពលធំផ្សេងទៀត ត្រូវបានបង្កើតនៅពេលនោះ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សែ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ D4.1.801 EN ERN 00406211។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សែ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៩ D4.1.805 KH ERN 00401315 (ឆ.៣)។

[768] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ D54/50 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន (D54/50)") KH ERN 00970613 (ឆ.២៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន (D54/51) KH ERN 00970617 (ឆ.១), 00970619 (ឆ.៧) *ប្រៀបធៀបជាមួយទង់បដិវត្ត* ខែសីហា ឆ្នាំ១៩៧៥ (D4.1.861) EN ERN 00401500-00401503 (ចំពោះព័ត៌មានលម្អិតស្តីពីសុន្ទរកថារបស់ ប៉ុល ពត ដែលស្របគ្នាទាំងស្រុងទៅនឹងចម្លើយរបស់ សាក្សី)។

[769] ដីកាលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ១៨៧ និងជើងទំព័រ ៥៦៤ ដែលយោងទៅកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ ប.ក.ក ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ D1.3.27.1 ត្រង់ ERN 00019114។

រាយការណ៍ទៅមជ្ឈិមបក្ស[770] មានតែមេបញ្ជាការកងពលមជ្ឈិម ប៉ុណ្ណោះដែលអនុវត្តតាមរបបរាយការណ៍នេះ[771] ដោយហេតុថាកងពលធំដទៃទៀតចំណុះឲ្យ ថ្នាក់ភូមិភាគ ដូចជាកងពលធំលេខ៣ (កងពលភូមិភាគនិរតី)[772] ឬកងពលធំលេខ១(កងពល ភូមិភាគបស្ចិម)[773]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិចាត់ទុកថាមុខតំណែងតាមឋានានុក្រមរបស់ មាស មុត ក្នុងឋានៈជាមេបញ្ជាការកងពលធំ១៦៤ របស់មជ្ឈិម គឺខ្ពស់ជាងឋានៈរបស់ មេបញ្ជាការ កងពលដទៃទៀត[774]។ ជាងនេះទៀត ក្នុងឆ្នាំ១៩៧៨ មាស មុត មិនត្រឹមតែជាមេបញ្ជាការកងពលមជ្ឈិមនោះទេ ប៉ុន្តែថែមទាំងជាអ្នកដឹកនាំការបោសសម្អាតនៅក្នុងកងពលធំលេខ៥០២ និងកងពលធំលេខ៣១០របស់មជ្ឈិមទៀតផង[775]។ នេះបង្ហាញឋានៈជាមេដឹកនាំជាន់ខ្ពស់នៅក្នុងកងទ័ព ក្នុងរយៈកាលនៃរបបខ្មែរក្រហម។

៣១៩. លើសពីនេះ លោក មាស មុត បានក្លាយជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨[776] ហើយត្រូវបានបញ្ជូនទៅខេត្តក្រចេះយ៉ាងហោចណាស់រហូតដល់ចុងឆ្នាំ១៩៧៨[777]។ ផ្ទុយពីការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[778] ភ័ស្តុតាងដែលបានពិនិត្យឡើងវិញដោយចៅក្រមអន្តរជាតិបង្ហាញថា មុខតំណែងជាមេបញ្ជាការកងពលធំលេខ ១៦៤ *តាមផ្លូវច្បាប់* បានបញ្ចប់នៅ

---

[770] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266), កថាខណ្ឌ ១៨៨។

[771] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ D114/103 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន (D114/103)") KH ERN 01127742 (ឆ.៣១-៣២)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ D114/286 KH ERN 01357547 (ឆ.៣០)។

[772] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា (D114/65) KH ERN 01096733 (ឆ.៩)។

[773] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ D54/52 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/52)") KH ERN 00970630-00970631 (ឆ.២, ឆ.៤, ឆ.៥, ឆ.៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/54) KH ERN 00970657 (ឆ.៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន KH ERN 00970609 (ឆ.៦)។

[774] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/52) KH ERN 00970630-00970631 (ឆ.៤, ឆ.៥, ឆ.៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/54) KH ERN 00970657 (ឆ.៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/50) KH ERN 00970609 (ឆ.៦)។

[775] *សូមមើល ខាងក្រោម* កថាខណ្ឌ ៣២៨។

[776] *សូមមើល ខាងលើ* កថាខណ្ឌ ៣១៣។

[777] *សូមមើល ខាងក្រោម* កថាខណ្ឌ ៣២៨-៣២៩។

[778] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៦៣។

01667458



ក្នុងអំឡុងពេលនោះ[779] ដោយសារ ទីម សេង បានមកកាន់មុខតំណែងនេះ[780]។ ទោះជាយ៉ាងណាក្តី ចៅក្រមអន្តរជាតិយល់ឃើញថា *តាមស្ថានភាពជាក់ស្តែង* លោក មាស[781] មុត នៅតែសកម្មក្នុងមានជាថ្នាក់លើនៅក្នុងកងពលធំលេខ ១៦៤ រហូតដល់ ខែមករា ឆ្នាំ១៩៧៩ ដែលនៅពេលនោះ លោកនៅបន្តទទួលរបាយការណ៍ពី ទីម សេង ហើយនៅតែមានអំណាចគ្រប់គ្រាន់ដើម្បីបញ្ជាឲ្យជម្លៀសខេត្តកំពង់សោម នៅពេលដែលកងទ័ពវៀតណាមបានមកដល់នៅឆ្នាំ១៩៧៩[782]។

៣២០. ទាក់ទងនឹងការទទួលខុសត្រូវរបស់លោក មាស មុត ក្នុងកងពលធំលេខ ១៦៤ ឬ កងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានរៀបចំឡើងដើម្បីការពារដែនទឹកកម្ពុជា[783] ចៅក្រមអន្តរជាតិបានពិនិត្យភ័ស្តុតាងសល់ពីសម័យនោះ ដែលបង្ហាញអំពីការចូលរួមរបស់លោកនៅក្នុងសកម្មភាព

---

[779] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត់ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ D54/87 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត់ (D54/87)") KH ERN 0985318 (ឆ.៤៥), 00985323 (ឆ.៧៣, ឆ.៧៥, ឆ.៧៦)។ [កែតម្រូវ ២] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង (ទីកសាប, មន្ទីរសន្តិសុខវត្តអង្គឥន្ទញាណ, ការដ្ឋាន និងការដ្ឋានទំនប់បិតត្រាង, តំបន់កំពង់សោម ការដ្ឋាននានាផ្សេងទៀតពាក់ព័ន្ធនឹងកងពល១៦៤, កោះរុងសន្លឹម ៩ បញ្ចាការដ្ឋានកងវរសេនាតូច៣៨៦ និងការកាប់សម្លាប់) ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ D114/54 KH ERN 01353018 ទំព័រ១៥។

[780] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៧ D54/99.1 ("កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ (D54/99.1)") EN ERN 01115988។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត (D54/98) KH ERN 00990389 (ឆ.៣៥-៣៦)។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៉ាង រ៉េត ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៧ D59/1/1.11a (" កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៉ាង រ៉េត (D59/1/1.11a)") EN ERN 00974098។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ D54/81 KH ERN 00984375 (ឆ.១៤-១៥)។

[781] *សូមមើល ឧទាហរណ៍* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រុំ សារ៉ាត់ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៨ ឯកសារ D59/1/1.8a ("កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រុំ សារ៉ាត់ (D59/1/1.8a)") នៅត្រង់ ERN 00926404 ("[ស.]៖ ទោះទៅខាងមេមត់អីនឹង នៅតែនៅគ្រប់គ្រងកងពលដែលបញ្ជា នៅតែ? [ឆ.]៖ជាសារទូរលេខអី ឆ្លងឆ្លើយ។ [ស.]៖ ជាសារទូរលេខអី ឆ្លងឆ្លើយងនៅតែគាត់ទទួលអញ្ចឹង? [ឆ.]៖ បាទ! [ស.]៖ ដូចថាមានបញ្ហានៅដែនសមុទ្រដីបញ្ហាមានព្រឹត្តិការណ៍អីប្លែក? [ឆ.]៖ អានឹងសារទូរលេខមានហើយ។ [ស.]៖ សារទូរលេខ ប៉ុន្តែគាត់នៅតែបញ្ជាផ្ទាល់ ពីសារទូរលេខ? [ឆ.]៖ បាទ! បញ្ជាបាន")។

[782] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ (D54/99.1) EN ERN 01115988។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៉ាង រ៉េត (D59/1/1.11a) EN ERN 00974119។

[783] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/51) KH ERN 00970619 (ឆ.៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន (D54/52) KH ERN 00970632 (ឆ.១២)។

ឃោសនា[784] និងរបាយការណ៍នយោបាយ[785]របស់កងពលធំលេខ ១៦៤ ក៏ដូចជាការត្រួតពិនិត្យរបស់លោកលើកិច្ចការរដ្ឋ បាលទាក់ទងនឹងកងពលធំលេខ ១៦៤ (ខ. កម្រិតនៃការប្រើប្រាស់អង្ករ) [786]។ លោក មាស មុត ទទួលខុសត្រូវជាមេបញ្ជាការ ដែលបានបញ្ជាឱ្យអ្នកក្រោមបង្គាប់ចាប់នាវាបរទេស និងខ្មាំងនៅក្នុងដែនទឹក និងកោះនៃកម្ពុជាប្រជាធិបតេយ្យ[787]។ លើសពីនេះ លោក មាស មុត បានផ្ដល់ការណែនាំដោយផ្ទាល់ដល់អង្គភាពវរសេនាតូច ជាពិសេស កងវរសេនាតូចលេខ ៤៥០ ក្រោយមកប្ដូរឈ្មោះទៅជាកងវរសេនាតូចលេខ ១៦៥[788] ដែលទទួលបន្ទុកការពារ និងសន្តិសុខ រួមទាំងការគ្រប់គ្រងមន្ទីរសន្តិសុខវត្តឥន្ទ្រញ្ញាណ ស៊ើបអង្កេត និងចាប់ខ្លួនយុទ្ធជន នៃកងពលធំលេខ ១៦៤ ស្ទើរតែទាំងអស់ ដែលសង្ស័យថាជា "សមាសធាតុមិនល្អ" ឬ

---

[784] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ D54/105.1 EN ERN 01147560-01147583។ ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ D1.3.34.10 EN ERN 00233647-00233648។ ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ D1.3.30.2 EN ERN 00231824។

[785] ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៦ D1.3.14.1 EN ERN 00233960-00233961។ សារតាមទូរស័ព្ទសម្ងាត់ ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ D54/11.1 EN ERN 01147584-01147585។ ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៧ D4.1.636 EN ERN 00143509-00143513។ "ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ D4.1.639 KH ERN 00143520។

[786] គម្រោងចំណាយស្រូវក្នុងឆ្នាំ១៩៧៦ តាមអង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦ D1.3.12.1 KH ERN 00160081។

[787] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដាវ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ D114/24 KH ERN 01043297 (ឆ.៨១)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មួល ឈិន ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ D114/31 KH ERN 01049864-01049865 (ឆ.១៥៣-ឆ.១៥៤) (សាក្សី លើកឡើងអំពីបទបញ្ជាពីកងពលធំ១៦៤ ឱ្យចាប់ទូក និងមនុស្ស។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម សុខុន ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ D114/112 KH ERN 01136623 (ឆ.៣៩)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាក សុខ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ D54/25 KH ERN 00955535 (ឆ.៦)។

[788] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សុន ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ D54/46 ("កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សុន (D54/46)") KH ERN 00969417 (ឆ.៣៨)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទួច សឿលី ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ D2/15 ("កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទួច សឿលី (D2/15)") KH ERN 00623901 (ឆ.២២-ឆ.២៤)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌុល សុង ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ D54/7 KH ERN (EN) 00936670 (ឆ.១០-១១, ឆ.១៣)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ី រ៉េត ថ្ងៃ២២ ខែមិថុនា ឆ្នាំ២០១៣ D54/10 KH ERN 00936701 (ឆ.២៧)។

01667460



ជនក្បត់[789]។

(គ) លេខាតំបន់ស្វយ័តកំពង់សោម

៣២១. ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា បន្ថែមលើមុខងារយោធារបស់គាត់ជាមេបញ្ជាការកងពលធំលេខ ១៦៤ លោក មាស មុត បានបំពេញមុខងារនយោបាយជាលេខាគណៈកម្មាធិការ ប.ក.ក នៅក្នុងតំបន់ស្វយ័តកំពង់សោម[790] ទើបអាចបានរក្សាការគ្រប់គ្រងលើតំបន់នោះទាំងមូលបាន[791]។ បន្ទាប់ពីបានពិនិត្យសក្ខីកម្មសាក្សីដែលពាក់ព័ន្ធ ចៅក្រមអន្តរជាតិពិចារណាឃើញថា តំបន់ស្វយ័តកំពង់សោមបានលាតសន្ធឹងយ៉ាងហោចណាស់ពីទឹកសាបផ្លូងកាត់កេងកង រាម កំពង់សោម និងកោះនៃរបបកម្ពុជាប្រជាធិបតេយ្យ[792]។ លើសពីនេះទៀត តំបន់នោះមិនស្ថិតនៅក្រោមការដឹកនាំរបស់ភូមិភាគនោះទេ ហើយបានទទួល

[789] កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (D2/15), ERN 00623900-00623901 (ឆ.១៤, ឆ.២០, ឆ.២៣-ឆ២៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ, ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤, ឯកសារ D54/71, ERN 00979265-00979266 (ឆ.៣៩-ឆ.៤០, ឆ.៤២, ឆ.៤៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤, ឯកសារ D54/101, ERN 00992740 (ឆ.១០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ D54/105, ERN 00992813-00992814, 00992818-00992819 (ឆ.៦, ឆ.១៨)។

[790] លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជាៈ មាត្រា ៨, ចុះខែមករា ឆ្នាំ២០៧៦, ឯកសារ D1.3.22.1, ERN 00053026។ កំណត់ហេតុស្តាប់ចម្លើយ ឌុច (D114/159), ERN 01202350-01202351 (ឆ.១០)។ គណៈប្រតិភូចិនធ្វើទស្សនកិច្ចនៅតំបន់កំពង់សោមកាលពីថ្ងៃទី១២ ខែធ្នូ, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៧, ឯកសារ D54/47.3 ("ទស្សនកិច្ចរបស់ប្រតិភូចិន (D54/47.3"), ERN 01509279-01509282។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់, ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤, ឯកសារ D54/100 ("កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (D54/100)"), ERN 00990724-00990725 (ឆ.២៨-ឆ.២៩, ឆ.៣៣)។ មេដឹកនាំភូមិភាគរបស់បក្សកុម្មុយនីស្តកម្ពុជា និងគណៈប្រជាជន, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧៨, ឯកសារ D114/266.1.2 ("មេដឹកនាំភូមិភាគ (D114/266.1.2)"), ERN 01509098។ កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ ប្រាក់ សុខា (D54/35.1), ERN 00964251។

[791] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង, ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥, ឯកសារ D114/95 ("កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង (D114/95)"), ERN 01121894 (ឆ.១៩៥, ឆ.១៩៦, ឆ.១០៧, ឆ.១៩៨, ឆ.១៩៩)។ កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ សាន់ កាន, ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧, ឯកសារ D54/106.2 ("កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ សាន់ កាន (D54/106.2)"), ERN 00993440។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង, ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥, ឯកសារ D54/106.2, ERN 01125438 (ឆ.១០-១១)។ កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយឈ្មោះ សៀង, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨, ឯកសារ D1.3.13.11, ERN (EN) 00217564។

[792] កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា (D114/65), ERN 01096733 (ឆ.៩)។ កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង (D114/95), ERN 01121894 (ឆ.១៩៤, ឆ.១៩៧)។

ការណែនាំពី និងរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិម[793]។

៣២២. លើសពីនេះទៀត ចៅក្រមអន្តរជាតិបានរកឃើញថា មាស មុត គឺជាមន្ត្រីជាន់ខ្ពស់បំផុតនៅក្នុង គណៈកម្មាធិការ ប.ក.ក នៅកំពង់សោម និងកាន់កាប់ការងារគ្រប់គ្រងផ្នែកនយោបាយទាំងមូលនៅក្នុង តំបន់នោះ[794]។ ភស្តុតាងបង្ហាញថា មាស មុត បានគ្រប់គ្រងលើជនស៊ីវិល និងកំពង់ផែកំពង់សោម[795] ក៏ដូច ជាកំពង់ផែកងទ័ពជើងទឹករាម[796] ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម[797]។

---

[793] កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (D54/100)"), ERN 00990724 (ឆ.២៨-ឆ.២៩)។

[794] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣, ឯកសារ D54/24 ("កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ (D54/24)"), ERN 00955529-00955530 (ឆ.២០)។ កំណត់ហេតុស្តាប់ចម្លើយ អែម សុន (D54/47), ERN 00969429 (ឆ.៣២)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ស៊ឹម នី, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១, ឯកសារ D59/2/2.16a ("បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី (D59/2/2.16a)"), ERN 00735605។ កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី (D54/31), ERN 00964166 (ឆ.១១-១២)។ កំណត់ហេតុស្តាប់ចម្លើយ អែម សុន (D54/46), ERN 00969414 (ឆ.២៥)។

[795] កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ (D54/23), ERN 00955484 (ឆ.១៥)។ កំណត់ហេតុស្តាប់ចម្លើយ ខុច (D114/159), ERN 01202350-01202351 (ឆ.១០)។ កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា (D114/65), ERN 01096733 (ឆ.៩-១០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦, ឯកសារ D114/194, ERN 01221872-01221873 (ឆ.៤០, ឆ.៤១, ឆ.៤១, ឆ.៤៣)។ កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ (D54/24)"), ERN 00955529-00955530 (ឆ.២០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ D54/104 ("កំណត់ហេតុស្តាប់ចម្លើយ ឯក នី (D54/104)"), ERN 00992792 (ឆ.១៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង, ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤, ឯកសារ D114/6, ERN 01029811 (ឆ.១៥១, ឆ.១៥៣, ឆ.១៥៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤, ឯកសារ D114/16, ERN 01033972 (ឆ.១៤-១៥)។

[796] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៦, ឯកសារ D114/241, ERN 01318547 (ឆ.៩៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ, ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤, ឯកសារ D114/25, ឯកសារ D114/25, ERN 01043316 (ឆ.៧)។

[797] កិច្ចសម្ភាសន៍របស់ ឡាយ ប៊ុនហាក់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D54/99.1), ERN 00990768-00990771។ កិច្ចសម្ភាសន៍របស់ ហៀង រ៉េត ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D59/1/1.11a), ERN 00926544-00926545។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ព្រំ សារ៉ាត់, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៧, ឯកសារ D59/1/1.8a ("កិច្ចសម្ភាសន៍របស់ ព្រំ សារ៉ាត់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D59/1/1.8a)"), ERN 00926391។ D54/104

លោក មាស មុតមានអនុលេខាចំនួន០២ ទទួលខុសត្រូវលើកិច្ចការជនស៊ីវិលៈ លោក គ្រិន[798] អនុលេខានៃគណៈកម្មាធិការ ប.ក.ក នៅកំពង់សោម[799] និងលោក ឡូញ[800] សមាជិកគណៈកម្មាធិការដូចបានលើកឡើងខាងលើ[801]។

៣២៣. ក្នុងនាមជាលេខាតំបន់ស្វយ័តកំពង់សោម លោក មាស មុត មានវត្តមាននៅតាមកន្លែងផ្សេងៗដែលបានប្រព្រឹត្តបទឧក្រិដ្ឋដូចបានចោទប្រកាន់។ ឧទាហរណ៍ គេបានឃើញគាត់ជាច្រើនដងនៅការដ្ឋានវាយថ្មស្ទឹងហាវ[802] និងនៅព្រលានយន្តហោះកងកេង[803] ជាកន្លែងដែលគេឃើញគាត់ថ្លែងសុន្ទរកថាអំពីជន

---

[798] កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី (D54/31), ERN 00964166 (ឆ.១០-១២) *ដែលបាននិយាយឡើងវិញនៅក្នុង*កិច្ចសម្ភាសន៍របស់ ស៊ឹម នី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D54/30.1), ERN 00964128។ កំណត់ហេតុស្តាប់ចម្លើយ អែម សុន (D54/47), ERN 00969429 (ឆ.៣៣)។

[799] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦, ឯកសារ D114/195, ERN 01221887 (ឆ.៥)។ កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី (D54/31), ERN 00964166 (ឆ.១០)។ កំណត់ហេតុស្តាប់ចម្លើយ អែម សុន (D54/47), ERN 00969429 (ឆ.៣៣)។ កិច្ចសម្ភាសន៍របស់ ព្រំ សារ៉ាត់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D59/1/1.8a)"), ERN 00926391។

[800] កិច្ចសម្ភាសន៍របស់ ស៊ឹម នី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D54/30.1), ERN 00964128 ("តាឡូញ ប្រធាននេសាទ")។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី (D59/2/2.16a)"), ERN 00735605 (" [É]*តាឡូញ* នោះគាត់ខាងនេសាទផ្គត់ផ្គង់សម្រាប់អង្គភាពរដ្ឋ")។

[801] ("ទស្សនកិច្ចរបស់ប្រតិភូចិន (D54/47.3"), ERN 01509279-01509280។ មេដឹកនាំភូមិភាគ (D114/266.1.2), ERN 01509098។ កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី (D54/31), ERN 00964166 (ឆ.១០-១២)។ កំណត់ហេតុស្តាប់ចម្លើយ អែម សុន (D54/47), ERN 00969429 (ឆ.៣៣)។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី (D59/2/2.16a), ERN 00735566។

[802] មាស មុត បានមកទស្សនកិច្ចនៅការដ្ឋានស្ទឹងហាវជាញឹកញាប់ អាស្រ័យទៅតាមពេលវេលា (*សូមមើល ឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី, ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D114/208, ERN 01247428 (ឆ.២៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម, ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦, ឯកសារ D114/215 ("កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម (D114/215)"), ERN 01301432 (ឆ.១២), 01301438 (ឆ.៤៣)។

[803] *សូមមើល ឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤, ឯកសារ D54/102 ("កំណត់ហេតុស្តាប់ចម្លើយ ឯក នី (D54/102)"), ERN 00992745-00992746 (ឆ.១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ, ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៥, ឯកសារ D114/68, ERN 01096701-01096702 (ឆ.៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ D114/89 ("កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន (D114/89)"), ERN 01111036-01111037 (ឆ.៥៦, ឆ.៦០-ឆ.៦៣)។

ក្បត់ និងខ្លឹមសារនៃចម្លើយសារភាពរបស់ពួកគេ[804]។ គាត់បានដឹកនាំការប្រជុំ និងការបណ្តុះបណ្តាលស្តីពីគោលនយោបាយ ប.ក.ក[805] ហើយសាក្សីបានរៀបរាប់ឡើងវិញអំពីតួនាទីរបស់ មាស មុត ក្នុងការលើកកម្ពស់គោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[806] និងណែនាំដល់អ្នកក្រោមបង្គាប់ឱ្យរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ[807]។ លោក មាស មុត បានចេញបញ្ជាដល់កងទ័ពរបស់លោកទាក់ទងនឹងការគ្រប់គ្រងទីតាំងពលកម្មដោយបង្ខំ (ឧទាហរណ៍ នៅការដ្ឋានវាយថ្មស្ទឹងហាវ)[808] និងបានចេញសេចក្តីណែនាំឱ្យចាប់ខ្លួន និងសម្លាប់អ្នកដែលត្រូវបានចាត់ទុកជាខ្មាំងនៅតំបន់រាម[809] និងជាទូទៅនៅតាមគ្រប់តំបន់ក្រោមការទទួលខុសត្រូវរបស់គាត់នៅកំពង់សោម[810]។ គេជឿថា លោក មាស មុត បានបញ្ជាដោយផ្ទាល់ឱ្យយកសាកសពរបស់ខ្មាំងដែលត្រូវបានសម្លាប់ រួមមាន ជនស៊ីវិល ទៅធ្វើជាជីនៅការដ្ឋានកាប់សម្លាប់ចំការទុរេន[811]។ លោក មាស មុត នៅបន្តកាន់កាប់តំបន់ស្វយ័តកំពង់សោមរហូតដល់ឆ្នាំ១៩៧៩[812]។

៣២៤. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសដោយសារមិនបានពិចារណាត្រឹមត្រូវលើតួនាទីរបស់ លោក មាស មុត ក្នុងនាមជាលេខាតំបន់ស្វយ័តកំពង់

---

804 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន (D114/89), ERN 01111036-01111037 (ឆ.៥៦, ឆ.៦០-ឆ.៦៣)។ កំណត់ហេតុស្តាប់ចម្លើយ ឯក នី (D54/102)"), ERN 00992745-00992746 (ឆ.១)។

805 *សូមមើល ឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន, ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ D54/33, ERN 00964187 (ឆ.១៥, ឆ.១៦, ឆ.១៧)។

806 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន, ERN 01127765 (ឆ.២០៤)។

807 *សូមមើល ឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន, ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣, ឯកសារ D54/29, ERN 00955650-00955652 (ឆ.៣, ឆ.៦)។ កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង (D114/95), ERN 01121899 (ឆ.២៤៨, ឆ.២៥៣)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វុន ប៊ុនណា, ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧, ឯកសារ D114/304, ERN 01404242 (ឆ.៦៨, ឆ.៧០), 01404243-01404245 (ឆ.៨៦, ឆ.៩៦, ឆ.៩៨, ឆ.១០០, ឆ.១០៧)។ កំណត់ហេតុ ស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥, ឯកសារ D114/78, ERN 01101724 (ឆ.២៩)។

808 *សូមមើល ឧទា.* កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម (D114/215), ERN 01301444 (ស និង ឆ.៧០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦, ឯកសារ D114/178, ERN 01211388 (ឆ.១០)។

809 ទូរលេខកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦, ឯកសារ D4.1.699, ERN 00092628។

810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា (D114/65), ERN 01096733 (ឆ.៩)។ កំណត់ហេតុស្តាប់ចម្លើយ ឌុច (D114/159), ERN 01202357-01202358 (ឆ.៣០)។ កំណត់ហេតុស្តាប់ចម្លើយ ឯក នី (D54/104), ERN 00992791-00992792 (ឆ.១៤, ឆ.១៦)។

811 កំណត់ហេតុស្តាប់ចម្លើយ ឯក នី (D54/102), ERN 00992752 (ឆ.២៩), 00992755-00992756 (ឆ.៤៣-ឆ.៤៤)។

812 *សូមមើល ផងដែរ*, កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ សាន់ កាន (D54/106.2), ERN 00993441។

សោមនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់របស់ខ្លួន ដែលមុខងារនេះគឺជាកត្តាដែលមិនអាចខ្វះបានត្រូវយកមកវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត។ ចៅក្រមអន្តរជាតិក៏យល់ឃើញថាលោក មាស មុត ក្រៅពីកាន់កាប់មុខតំណែងយោធាកំពូល ក៏មានតួនាទីដឹកនាំកិច្ចការជនស៊ីវិលនិងនយោបាយសម្រាប់តំបន់ទាំងមូលចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដែលអនុញ្ញាតឱ្យគាត់មានទំនាក់ទំនងផ្ទាល់ជាមួយមេដឹកនាំនយោបាយនៅថ្នាក់ជាតិក្នុងគណៈកម្មាធិការមជ្ឈិម។

(ឃ) តួនាទីនៅក្នុងគណៈកម្មាធិការនៃអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា

៣២៥. ចៅក្រមអន្តរជាតិកត់សំគាល់ថា ក្រៅពីតួនាទីទាំងនោះ លោក មាស មុត ក្នុងនាមជាមេបញ្ជាការកងពលធំមជ្ឈិម[813] ក៏បានក្លាយជាសមាជិកគណៈកម្មាធិការនៃអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា នៅដើមឆ្នាំ១៩៧៥ ក្រោយពេលបង្កើតគណៈកម្មាធិការនេះឡើង និងបានបម្រើការងារនៅទីនោះក្នុងមុខតំណែងជាមេបញ្ជាការកងទ័ពជើងទឹក[814]។ យ៉ាងយូរបំផុតចាប់ពីឆ្នាំ១៩៧៦ លោក មាស មុត បានចូលរួមកិច្ចប្រជុំអគ្គសេនាធិការយ៉ាងទៀងទាត់នៅក្រុងភ្នំពេញ[815] ជាកន្លែងដែលគាត់បានធ្វើរបាយការណ៍ បានដឹងអំពីការរៀបរាប់របស់សហសេរីក និងបានឃើញ សុន សេន ថ្លែងសុន្ទរកថា[816]។ ទោះបីជាសមាជិកនៃគ

---

[813] កំណត់ហេតុស្តាប់ចម្លើយសាក្សី លុន សេង (D54/110), ERN 00997256-0997257 (ឆ.៩, ឆ.១៨)។

[814] *សូមមើល ឧទា.* របាយការណ៍វិភាគរបស់អ្នកជំនាញការ, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, ឯកសារ D234/2.1.52, ERN 00314822។ កំណត់ហេតុស្តាប់ចម្លើយសាក្សី លុន សេង (D54/110), ERN 00997256 (ឆ.១០)។ កំណត់ហេតុស្តាប់ចម្លើយ ឌុច (D114/158), ERN 01202337-01202338 (ឆ.២៤)។ កំណត់ហេតុស្តាប់ចម្លើយ ឌុច (D114/159), ERN 01202354-01202355 (ឆ.២៣)។ ប្រតិចារឹកនៃសវនាការលើសំណុំរឿង ០០២, ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ (កាំងហ្គេកអ៊ាវ ហៅ ឌុច), ឯកសារ D53/2.1.42, ERN 00797625, បន្ទាត់ទី ៨-១៣។ ចៅអន្តរជាតិបញ្ជាក់បំភ្លឺត្រង់ចំណុចនេះថា ខណៈ ឌុច បានបញ្ជាក់លម្អិតនៅក្នុងចម្លើយមួយថា មាស មុត ជាសមាជិកបម្រុងនៃគណៈកម្មាធិការអគ្គសេនាធិការ សាក្សីភាគច្រើនផ្សេងទៀតពុំបានបញ្ជាក់ទេ និងគ្រាន់តែលើកឡើងថា មាស មុត ជាសមាជិកនៃគណៈកម្មាធិការនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចយកតាមគុណវុឌ្ឍិរបស់ ឌុច និងសម្រេចថា ឌុច ជាសមាជិកបម្រុង ចៅក្រមអន្តរជាតិទាំងអស់បែរជាចាត់ទុកថាជាសមាជិកពេញសិទ្ធិតាំងពីឆ្នាំ ១៩៧៥ និង អនុប្រធានរបស់ SON Sen តាំងពីអំឡុងឆ្នាំ ១៩៧៨។

[815] កំណត់ហេតុស្តាប់ចម្លើយសាក្សី ស៊ឹម នី (D54/37), ERN 00964282-00964283 (ឆ.៣០, ឆ.៣១)។

[816] *សូមមើល* កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦, ឯកសារ D1.3.8.2, ERN 00162484។ កំណត់ហេតុនៃអង្គប្រជុំការងារយោធារបស់កម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦, ឯកសារ D1.3.8.3, ERN 00021496-00021498។ កំណត់ហេតុនៃការប្រជុំការងារយោធារបស់កម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.18, ERN 00052389-00052390។ *សូមមើល ផងដែរ,* សៀវភៅរៀបរៀង

01667465



ណៈកម្មាធិការអគ្គសេនាធិការក៏ដោយ លោក មាស មុត មិនបានស្នាក់នៅក្នុងក្រុងភ្នំពេញនោះទេ[817]។

៣២៦. ចៅក្រមអន្តរជាតិយល់ឃើញបន្ថែមទៀតថា ផ្ទុយពីការអះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[818] លោក មាស មុត ត្រូវបានតម្លើងឋានៈជាអនុប្រធានអគ្គសេនាធិការរបស់ សុន សេន នៅឆ្នាំ ១៩៧៨[819] បន្ទាប់ពីអនុប្រធានទាំងអស់របស់ សុន សេន ត្រូវបានដកចេញកាលពីប៉ុន្មានឆ្នាំមុន[820]។ ចាប់ពីឆ្នាំ១៩៧៨ លោក មាស មុត បានផ្លាស់មកក្រុងភ្នំពេញ[821] និងមានបុព្វសិទ្ធិថ្មីៗ[822]។ ក្រោយពីក្លាយជាអនុប្រធានកងទ័ព លោក មាស មុត បានអនុវត្តការគ្រប់គ្រងលើសាខាទាំងបីនៃកងកម្លាំងយោធា[823]។ ចៅក្រមអន្តរជាតិកត់សំគាល់ថា លោក មាស មុត តាមស្ថានភាពជាក់ស្តែងទំនងបានក្លាយជាអគ្គសេនាធិការរួមជាមួយ លោក ស៊ូ ម៉េត នៅចុងឆ្នាំ១៩៧៨ បន្ទាប់ពី លោក សុន សេន បានបាត់បង់ការទុកចិត្តពីមេដឹកនាំ

---

ដោយ Stephen HEDER និង Brian TITTEMORE: *បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវកាត់ទោស៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម*, at ERN (EN) 00393604។

[817] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦, ឯកសារ D114/160, ERN 01202374 (ឆ.៨)។

[818] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267), កថាខណ្ឌ ១៦២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជាក់ថា មាស មុត បានក្លាយជាអនុប្រធានរបស់ សុន សេន តាំងពីពេលបង្កើតកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ *មានន័យថា* តាំងពីឆ្នាំ ១៩៧៥ មក)។

[819] [កែតម្រូវលើកទី ១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន សារ៉ាត់, ឯកសារ D114/285, ERN 01354328-01354329 (ឆ.២០៦-២០៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/62), ERN 00975783 (ឆ.២២-២៣)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា (D114/65), ERN 01096733-01096735 (ឆ.៩, ឆ.១២-១៣)។

[820] កំណត់ហេតុស្តាប់ចម្លើយ ឌុច (D114/159), ERN 01202354-01202355 (ឆ.២៣)។

[821] កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ (D114/186), KH ERN 01214220 (ឆ.១២៦, ១២៩)។ កំណត់ហេតុស្តាប់ចម្លើយ វ៉េត ប៉ាង (D54/98), KH ERN 00990387 (ឆ.២៨)។ កិច្ចសម្ភាសន៍របស់ ព្រំ សារ៉ាត់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D59/1/1.8a), ERN 00926402-00926403។ កិច្ចសម្ភាសន៍របស់ ឡាយ ប៊ុនហាក់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (D54/99.1), ERN 00990786។ *សូមមើល ផងដែរ*, កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (D54/100), ERN 00990733-00990734។

[822] *សូមមើល ឧទា.* កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត (D54/62), ERN 00975783-00975784 (ឆ.២២, ឆ.២៥)។

[823] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D54/63 ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/63)") ERN 00975795 (ឆ.១១)។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D114/169 ("កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង សឿន (D114/169)") ERN 01203859 (ឆ.២៥)។

នយោបាយ[824]។ ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិកត់សម្គាល់ថា តួនាទីរបស់គាត់នៅខេត្តក្រចេះបង្ហាញអំពីការឡើងតំណែងរបស់គាត់នៅក្នុងឋានានុក្រមកងទ័ពបដិវត្តន៍ និងគណៈកម្មាធិការនៃអគ្គសេនាធិការ[825]។

៣២៧. ហេតុនេះ ចៅក្រមអន្តរជាតិយល់ស្របជាមួយនឹងការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា លោក មាស មុត ជាសមាជិកគណៈកម្មាធិការនៃអគ្គសេនាធិការ[826] ដែលជាកម្រិតជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥ ។ ចៅក្រមអន្តរជាតិបញ្ជាក់ថា ការឡើងតួនាទីរបស់ លោក មាស មុត ដល់មុខតំណែងជាអនុប្រធានអគ្គសេនាធិការនៅឆ្នាំ១៩៧៨ ដែលអាចបញ្ជាសាខាទាំងបីនៃកងទ័ព និងទំនងជាឡើងកាន់កាប់មុខតំណែងជាក់ស្ដែងជានាយអគ្គសេនាធិការ ដោយគ្មានការសង្ស័យនោះ ជាលក្ខខណ្ឌធ្វើឱ្យគាត់ក្លាយជាមេដឹកនាំជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

(ង) តួនាទីនៅភូមិភាគបូព៌ា និងខេត្តក្រចេះ

៣២៨. ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ឋានៈជាន់ខ្ពស់របស់ លោក មាស មុត នៅក្នុងជួរកង

---

[824] ប្រតិចារិកនៃបទសម្ភាសន៍ជាមួយ អៀង សារី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ D4.1.964 EN ERN 00417616 (“បញ្ហាវាមានរឿងរ៉ាវច្រើនដែរក្នុងបដិវត្តហ្នឹង។ ដូច្នេះ ប៉ុល ពត ហ្នឹង លែងទុកចិត្តនរណាទាំងអស់ហើយ។ នៅតែនួន ជា ហ្នឹងទេ ដែលពីរនាក់ហ្នឹង។ ដូច្នេះធ្វើការងារផ្ទាល់ជាមួយខុច ហ្នឹងហ្នង។ អត់ឆ្លងតាមវន វេត អត់ឆ្លងតាមសុន សេន អីទៀតទេ” (គូសបញ្ជាក់បន្ថែម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/62) EN ERN 00982740-00982741 (ឆ.៣១) (“ស. នៅក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាភាសាអង់គ្លេស ត្រង់ទំព័រទី២២ លោកបាននិយាយថា “<u>គេមិនមានទំនុកចិត្តលើ សុន សេន ទៀតទេ</u>។ <u>សុន សេន ពេលនោះមានតែងារប៉ុណ្ណោះនៅនឹងសេនាធិការ</u> <u>តែតាមពិត តា មុត និង តា ម៉េត ជាអ្នកទទួលខុសត្រូវ</u>”។ នៅខាងក្រោមបន្តិចលោកបាននិយាយបន្ថែមថា “តាខៀវ គឺមិនមានអំណាចអ្វីលើ កងទ័ពទៀតទេ នៅពេលនោះ គឺមានតែ តា ម៉េត និងតា មុត”។ សូមពន្យល់ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឆ.៣១ ពីព្រោះ<u>នៅចុងឆ្នាំ ១៩៧៨ សុន សេន ត្រូវបានគេបញ្ជូនទៅនៅស្នួង ដោយមិនប្រគល់ការងារអ្វីច្បាស់លាស់ឱ្យគាត់ទេ</u>។ ក្នុងពេលនោះ <u>រាល់សំណើសុំទាំងឡាយដែលស្នើទៅអគ្គសេនាធិការ គឺមានការឆ្លើយតបមកវិញដោយ តា ម៉េត និង តា មុត</u>។ ខ្ញុំដឹងរឿងនេះតាមរយៈសារទូរលេខ។”) (គូសបញ្ជាក់បន្ថែម)។ លើសពីនេះ ចៅក្រមអន្តរជាតិ រំឭកឡើងវិញថាការវាយតម្លៃលើយុត្តាធិការបុគ្គល ត្រូវធ្វើឡើងតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ដូច្នេះ ទោះបីជាមាស មុត អាចធ្លាប់កាន់តំណែងអនុប្រធានសេនាធិការ រយៈពេលខ្លីក៏ដោយ ដូចបានកត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេតជាតិ ដើម្បីកំណត់យុត្តាធិការបុគ្គល វាជាការសំខាន់ដែលត្រូវពិចារណារយៈពេលដែលគាត់កាន់តំណែងនោះ ឋានៈខ្ពស់នៃមុខតំណែង ព្រមទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងតំណែងនោះ។ ចៅក្រមអន្តរជាតិ គូសបញ្ជាក់ថា ការបោសសម្អាតនៅក្នុងភូមិភាគបូព៌ា បានធ្វើឡើងក្នុងរយៈពេលខ្លី ហើយ មាស មុត ត្រូវបានចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មនោះ។

[825] *សូមមើលខាងក្រោម* កថាខណ្ឌ ៣២៨-៣២៩ ។

[826] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ១៦២។

ទ័ពបដិវត្តន៍កម្ពុជា បានបង្ហាញឱ្យឃើញតាមរយៈភស្តុតាងនៃការទទួលខុសត្រូវរបស់គាត់នៅភូមិភាគបូព៌ា និងកកាន់តែច្បាស់ទៀតនោះគឺនៅក្នុងខេត្តក្រចេះ។ លោក មាស មុត ត្រូវបានបញ្ជូនទៅតំបន់នោះ ដើម្បី បំពេញបេសកកម្មពីរប្រភេទ។ បេសកកម្មទី១ លោក មាស មុត បានដឹកនាំការបោសសំអាតកម្មាភិបាលភូមិ ភាគបូព៌ានៅក្នុងកងពលធំលេខ ១១៧ ក្នុងខេត្តក្រចេះ បន្ទាប់ពីមានសេចក្តីសម្រេចក្នុងមហាសន្និបាតបក្ស ដែលបានប្រារព្ធធ្វើឡើងនៅក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៨ និងនៅក្នុងកិច្ចប្រជុំមួយនៅទីបញ្ជាការដ្ឋាន យោធាក្បែរបឹងត្របែក ដែលនៅទីនោះ លោក មាស មុត បានចូលរួមជាមួយ "មេបញ្ជាការយោធាជាន់ ខ្ពស់" ដទៃទៀត[827]។ យោងតាមសេចក្តីថ្លែងការណ៍របស់គាត់ លោក មាស មុត ត្រូវបានបញ្ជូនទៅខេត្ត ក្រចេះភ្លាមៗនៅខែកុម្ភៈឆ្នាំ១៩៧៨ ហើយបន្តស្ថិតនៅទីនោះជាមេបញ្ជាការកងពលធំលេខ ១៦៤[828]។ ទោះបីមិនមានការរៀបរាប់ជាក់លាក់អំពីការខិតខំប្រឹងប្រែងរបស់គាត់នៅខេត្តក្រចេះនៅដើមឆ្នាំ១៩៧៨ ក៏ ដោយ ក៏ចៅក្រមអន្តរជាតិរកឃើញថា លោក មាស មុត ក្នុងនោះជាប់ទាក់ទងដោយផ្ទាល់ក្នុងការផ្ទេរកម្មា ភិបាលចំនួន ១១ នាក់ ពីកងពលធំលេខ ១១៧ ទៅ ស-២១[829] ហើយបានកោះប្រជុំយ៉ាងហោចណាស់មួយ លើកនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨[830] ដើម្បីរៀបចំកងពលធំលេខ ១១៧[831] ដែលគាត់បានតែងតាំងផ្លាស់ប្តូរជំ ប្រធាននៃកងពលនោះ។

៣២៩. បេសកកម្មលើកទី២ របស់ លោក មាស មុត រួមមាន ការធ្វើដំណើរទៅកាន់ភូមិភាគបូព៌ានៅខែ តុលាឆ្នាំ១៩៧៨ ដើម្បី "ពិនិត្យស្ថានភាពនៅជួរមុខ" នៅពេលដែលវៀតណាមកំពុងដឹកនាំការវាយលុកខ្លាំង

---

[827] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ D4.1.408 EN ERN 00268871-00268872។

[828] ខ្សែអាត់សំឡេងនៃបទសម្ភាសន៍ជាមួយ មាស មុត ខែមេសា ឆ្នាំ២០០៩ D54/16/1R, 34:37-35:28 ("ខ្ញុំត្រូវបានចាត់ឱ្យធ្វើការនៅខេត្តក្រចេះ ជិតព្រំដែនឡាវ។ ស. ដូច្នេះតើគាត់បានចាកចេញពីកងពល១៦៤ទាំងស្រុង ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ មែនទេ? ឆ. ទេ ខ្ញុំនៅកាន់តំណែងរបស់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវបានចាត់តាំងបេសកកម្មមួយទៀតនៅខេត្តក្រចេះ។ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ (D54/87) ERN 00985323 (ឆ.៧៥)។

[829] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន (D4.1.810) ERN 00402510 (ឆ.៣៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/63) ERN 00975792-00975793 (ឆ.២)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/62) ERN 00975787 (ឆ.៣៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៦ D114/193 ERN 01221859 (ឆ.៦៤)។

[830] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ (D114/52) ERN 01071601 (ឆ.៥២)។

[831] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/63) ERN 00975792 (ឆ.១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ (D114/52) ERN 01071601 (ឆ.៤០, ឆ.៤១)។

ក្លា[832]។ ដើម្បីបំពេញបេសកកម្មនេះ គាត់បាននាំកងទ័ពជាច្រើននាក់ទៅជាមួយគាត់យ៉ាងតិច ០១ ឬ អាច ០៣ កងវរសេនាធំ (១៦១ ១៦២ និង១៦៣) នៃកងពលធំលេខ ១៦៤[833]។ លោក មាស មុត នៅបន្តមានវត្តមាននៅខេត្តក្រចេះនៅខែធ្នូ ឆ្នាំ១៩៧៨ មុនពេលចាកចេញទៅក្រុងភ្នំពេញ[834] និងរត់គេចខ្លួនឆ្លងកាត់ព្រៃ[835]។

ii. សេចក្តីសន្និដ្ឋានអំពីកម្រិតនៃការទទួលខុសត្រូវរបស់ លោក មាស មុត

៣៣០. ដោយពិនិត្យលើមុខតំណែង និងតួនាទីផ្សេងៗដែលលោក មាស មុត កាន់កាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចៅក្រមអន្តរជាតិនឹងពិនិត្យឡើងវិញលើការយល់ឃើញនីមួយៗរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។

៣៣១. ទីមួយ ចៅក្រមអន្តរជាតិស្របជាមួយនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីកម្រិតនៃការទទួលខុសត្រូវរបស់ លោក មាស មុត ចំពោះការចូលរួមនៅក្នុងឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់។ ជាពិសេស ចៅក្រមអន្តរជាតិរកឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីការចូលរួមរបស់ លោក មាស មុត នៅក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក ចំនួន ៤ ដែលជាសហឧក្រិដ្ឋកម្មរួម តាមរយៈការប្រព្រឹត្តក្នុងគោលបំណងសម្រេចផែនការរួម ឧក្រិដ្ឋកម្មអន្តរជាតិ និងអន្តរជាតិជាច្រើនផ្សេងទៀត។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ការចូលរួមរបស់ជនត្រូវចោទ ជាមួយមេដឹកនាំជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ ក្នុងក្រុមឧក្រិដ្ឋមួយ ដែលមានផលវិបាកកាប់សម្លាប់ និងបំផ្លាញដល់ប្រជាជនគឺជាការបង្ហាញនូវកម្រិតនៃការទទួលខុសត្រូវដ៏ធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការដាក់បញ្ចូលរូបគាត់ក្នុងចំណោមអ្នកទទួលខុសត្រូវបំផុ

[832] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/63) ERN 00975793 (ឆ.៣)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ (D114/52) ERN 01071598 (ឆ.២៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/62) ERN 00975783 (ឆ.២២)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង (D54/110) ERN 00997255 (ឆ.៦)។

[833] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត (D54/63) ERN 00975797 (ឆ.២១, ឆ.២៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង (D54/110) ERN 00997255 (ឆ.៧)។

[834] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន (D4.1.810) ERN 00402509 (ឆ.២៥, ឆ.២៦, ឆ.២៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន (D114/169) ERN 01203859 (ឆ.២៨)។

[835] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ D54/73 ERN 00979291 (ឆ.១៧)។

ត។ លើសពីនេះទៀត ការចូលរួមចំណែករបស់ លោក មាស មុត មានសារសំខាន់ដល់ការអនុវត្ត ប្រកបដោយជោគជ័យនូវគោលនយោបាយទាំងនោះក្នុងការងារទទួលខុសត្រូវរបស់គាត់។ ចៅក្រមអន្តរជាតិយល់ឃើញថា ប្រសិនបើគ្មានការចូលរួមចំណែករបស់លោក មាស មុត ក្នុងការអនុវត្តគោលនយោបាយ ប.ក.ក នោះទេ ការស្លាប់ និងជនរងគ្រោះដែលបណ្តាលមកពីឧក្រិដ្ឋកម្មនៅកំពង់សោម នៅតំបន់សមុទ្រ និងនៅភូមិភាគបូព៌ានឹងមានចំនួនទាបជាងនេះច្រើន។ ជាងនេះទៅទៀត ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញយ៉ាងត្រឹមត្រូវថា ដោយសារតួនាទីខុសៗគ្នារបស់គាត់ លោក មាស មុត បានរួមដៃប្រព្រឹត្តអំពើមនុស្សឃាត រៀបចំផែនការ និងចេញបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាច្រើន ដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់។

៣៣២. លើសពីនេះទៀត ចៅក្រមអន្តរជាតិយល់ឃើញដូចសហចៅក្រមស៊ើបអង្កេតអន្តរជាតិលើតួនាទីរបស់ លោក មាស មុត ទោះបីជាមានការសន្និដ្ឋានផ្ទុយពីតួនាទីរបស់ជនត្រូវចោទនៅក្នុងគណៈកម្មាធិការមជ្ឈិម[836] និងគណៈកម្មាធិការនៃអគ្គសេនាធិការក៏ដោយ[837]។ តាមការយល់ឃើញរបស់ចៅក្រមអន្តរជាតិ មុខតំណែង និងតួនាទីជាមេបញ្ជាការកងពលធំលេខ ១៦៤ តែមួយ ឬ រួមជាមួយមុខតំណែង និងតួនាទីជាលេខាតំបន់ស្វយ័តកំពង់សោម គឺគ្រប់គ្រាន់ដើម្បីដាក់បញ្ចូលគាត់ទៅក្នុងប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។

៣៣៣. ទាក់ទងនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតជាតិស្តីពីកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ចៅក្រមអន្តរជាតិបញ្ជាក់សាជាថ្មីថា ការបដិសេធរបស់លោកក្នុងការសន្និដ្ឋានលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ គឺជាកំហុសអង្គច្បាប់ពីព្រោះការរកឃើញបែបនេះគឺជាធាតុផ្សំមួយដែលមិនអាចខ្វះបានចំពោះការកំណត់យុត្តាធិការបុគ្គលទាក់ទងនឹងលោក មាស មុត[838]។ ចៅក្រមអន្តរជាតិកត់សំគាល់លើសេចក្តីថ្លែងការណ៍របស់គាត់ដែលថា "អ្នកដែលមានឋានៈទាបអាចត្រូវបានចាត់ទុកថាជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតអាស្រ័យលើ*ការចូលរួមផ្ទាល់ខ្លួនរបស់*ពួក*គេ*នៅក្នុងអំពើឃោរឃៅ"។ វិសាលភាពនៃសកម្មភាពផ្ទាល់របស់មនុស្សម្នាក់ និងសិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាពនៃអំពើទាំងនោះគឺចំណុចត្រូវពិចារណាឲ្យបានត្រឹមត្រូវ"[839]។ សហចៅក្រមស៊ើបអង្កេតជាតិបានឈាន

[836] *សូមមើលខាងលើ* កថាខណ្ឌ ៣១៣-៣១៤។

[837] *សូមមើលខាងលើ* កថាខណ្ឌ ៣២៥-៣២៧។

[838] *សូមមើលខាងលើ* កថាខណ្ឌ ២៩៨-២៩៩ ។

[839] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៦៨ (គូសបញ្ជាក់បន្ថែម)។

ដល់ការសន្និដ្ឋានបែបនេះ ដោយផ្អែកលើគំរូរបស់ ឌុច ដែលតាមការអះអាងគឺជាហេតុផលសម្រាប់ការដាក់បញ្ចូលប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងច្បាប់ អ.វ.ត.ក[840]។ ចំណុចចុងក្រោយ សហចៅក្រមស៊ើបអង្កេតជាតិបានកំណត់ថា បើប្រៀបធៀបជាមួយ ឌុច "ការចូលរួមរបស់ មាស មុត មិនមានភាពសកម្ម មិនដុំកំភួន និងមិនកៀកកិតនឹងការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ"[841]។

៣៣៤. នៅពេលពិនិត្យមើលទឡ្ហីករណ៍ដាក់ជូនដោយសហចៅក្រមស៊ើបអង្កេតជាតិ ចៅក្រមអន្តរជាតិសូមរំលឹកថា កត្តានានាដែលត្រូវពិចារណានៅពេលវាយតម្លៃកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានកំណត់រួចហើយនៅក្នុងសេចក្ដីសម្រេច និងសាលក្រមតុលាការ[842]។ កត្តាបែបនេះ រួមមានកម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម មុខតំណែង និងឋានៈតាមឋានានុក្រមរួមទាំងចំនួនអ្នកក្រោមបង្គាប់ និងឋានានុក្រមខាងលើ និងភាពអចិន្ត្រៃយ៍នៃមុខតំណែង។

៣៣៥. ទាក់ទងនឹងកម្រិតនៃការចូលរួម សហចៅក្រមស៊ើបអង្កេតជាតិបានសង្កត់ធ្ងន់ស្ទើរតែទាំងស្រុងលើការចូលរួមដោយផ្ទាល់នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដូចបានចោទប្រកាន់ ដែលតាមការយល់ឃើញរបស់ចៅក្រមអន្តរជាតិ គឺជាការបញ្ជាក់ថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវតែធ្វើសកម្មភាព និងប្រព្រឹត្តដោយផ្ទាល់ចំពោះអំពើដែលចាត់ទុកជាឧក្រិដ្ឋកម្ម។ ការវិភាគបែបនេះមានកំហុស និងមិនត្រឹមត្រូវ ព្រោះយុត្តិសាស្ត្រអន្តរជាតិទទួលស្គាល់ទម្រង់នៃការចូលរួមចំណែក និងសកម្មភាពផ្សេងៗគ្នា ដែលអាចបង្ហាញពីការចូលរួមក្នុងឧក្រិដ្ឋកម្ម[843] បន្ថែមលើការចូលរួមជារូបវន្ត ឬ ដោយផ្ទាល់[844]។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណី

---

[840] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៣៩៦-៣៩៧។

[841] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266) កថាខណ្ឌ ៤២៨។

[842] *សូមមើលជាឧទាហរណ៍* សាលក្រមសំណុំរឿង០០១ (E188) កថាខណ្ឌ ២២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET, កថាខណ្ឌ ៣៣២។

[843] *សូមមើលជាឧទាហរណ៍* តុលាការ ICTY, រដ្ឋអាជ្ញា តទល់នឹង *Tadić*, IT-94-1-T, Opinion and Judgment, យោបល់ និងសាលក្រម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦៧៩, ៦៩១។ តុលាការ ICTR, រដ្ឋអាជ្ញា តទល់នឹង *Kayishema និងRuzindana*, ICTR-95-1-A, សាលដីកាលើបណ្ដឹងឧទ្ធរណ៍ (សំអាងហេតុ), អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ១៨៥។

[844] *សូមមើលជាឧទាហរណ៍* តុលាការ ICTY, រដ្ឋអាជ្ញា តទល់នឹង *Ademi និង Norac*, IT-04-78-PT, សេចក្តីសម្រេចលើការផ្ទេរទៅអាជ្ញាធរនៃសាធារណរដ្ឋក្រូអាត អនុលោមតាមវិធាន១១ស្ទួន, ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥ កថាខណ្ឌ៣០។

លោក មាស មុត ការដឹកនាំរបស់គាត់នៅក្នុងការធ្វើប្រតិបត្តិការយោធានានា ដែលធ្វើឡើងដោយកងពលធំរបស់គាត់ រួមទាំងវត្តមានរបស់គាត់នៅទីតាំងឧក្រិដ្ឋកម្មជាក់លាក់[845] និងការចូលរួមក្នុងប្រតិបត្តិការមួយចំនួន[846] ក៏ដូចជាតួនាទីរបស់គាត់នៅក្នុងជម្រុញគោលនយោបាយ ប.ក.ក ដោយរួមបញ្ចូលការលើកទឹកចិត្តឱ្យមានការរៀបអាពាហ៍ពិពាហ៍នៅក្នុងការទទួលខុសត្រូវចំបងរបស់គាត់ បង្ហាញដល់កម្រិតគ្រប់គ្រាន់ថាគាត់ពិតជាបានចូលរួមពិតប្រាកដនៅក្នុងឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានចោទប្រកាន់។

៣៣៦. ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុសអង្គច្បាប់និងអង្គហេតុ ដោយផ្អែកលើការវាយតម្លៃរបស់គាត់អំពីកម្រិតនៃការទទួលខុសត្រូវរបស់ លោក មាស មុតចំពោះអវត្តមាននៃ "សកម្មភាពផ្ទាល់ និងសិទ្ធិអំណាចនៃអំពើទាំងនោះ" ដោយមិនពិចារណាលើការចូលរួមចំណែករបស់គាត់ ក៏ដូចជាតួនាទីរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ការខកខានធ្វើដូច្នេះមានបញ្ហាច្រើនជាងនេះទៅទៀត គឺជាសក្ខីកម្មមួយបញ្ជាក់អំពីមុខតំណែងជាន់ខ្ពស់ ដែលកាន់កាប់ដោយ មាស មុត នៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា និង ប.ក.ក។

៣៣៧. ចំណុចទីពីរ ទាក់ទងទៅនឹងការអះអាងរបស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលថា ប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានបង្កើតឡើងសម្រាប់តែ ឌុច នោះ ចៅក្រមអន្តរជាតិសូមលើកឡើងជាបឋមថា ការអះអាងនេះផ្ទុយពីការយល់ឃើញរបស់គាត់ទាំងស្រុងដែលថា អៀង ធីរិទ្ធ ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយសារហេតុផលតែមួយគត់គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម[847]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិ យោងតាមការយល់ឃើញមុនៗរបស់ខ្លួនអំពីប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" កត់សំគាល់ឃើញថា សេចក្តីថ្លែងការណ៍បែបនេះមិនអាចលុបចោលការវិភាគយ៉ាងប្រុងប្រយ័ត្នលើភាសា ដែលបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក និងអភិក្រមផ្លូវច្បាប់ ដែលបានបង្កើតឡើងត្រឹមត្រូវនៅក្នុងសាលាក្តីអន្តរជាតិ រួមទាំងនៅចំពោះមុខតុលាការនេះ ដើម្បីកំណត់ខ្លឹមសារ

---

[845] *សូមមើលខាងលើ* កថាខណ្ឌ ៣២១-៣២៤ ។

[846] *សូមមើលខាងលើ* កថាខណ្ឌ ៣២៨ ។

[847] ចៅក្រមអន្តរជាតិសូមរំឭកឡើងវិញថា សហចៅក្រមស៊ើបអង្កេតជាតិ បានរកឃើញថា អៀង ធីរិទ្ធ ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យដោយសារតែគាត់ជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម។ សហចៅក្រមស៊ើបអង្កេតជាតិ មិនបានរកឃើញថា អៀង ធីរិទ្ធ ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មាធិការមជ្ឈិម ហើយសហចៅក្រមស៊ើបអង្កេតជាតិ ក៏មិនបានរកឃើញជាក់លាក់ណាមួយនូវការចូលរួមដោយផ្ទាល់របស់អៀង ធីរិទ្ធ ទៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានស៊ើបអង្កេតឡើយ (ដីកាដំណោះស្រាយ សំណុំរឿង០០២ (D427) កថាខណ្ឌ១២០៧-១២៩៥, ១៣២៨) ។

នៃពាក្យបែបនេះទេ[848]។

៣៣៨. យោងតាមហេតុផលខាងលើ ដោយពិចារណាលើកំហុសអង្គច្បាប់ និងអង្គហេតុ ដែលបានប្រព្រឹត្តដោយសហចៅក្រមស៊ើបអង្កេតជាតិ ចៅក្រមអន្តរជាតិយល់ឃើញថា មិនចាំបាច់ត្រូវលើកឡើងលម្អិតបន្ថែមទៀតនូវការយល់ឃើញ និងសេចក្តីសន្និដ្ឋានរបស់គាត់ ទាក់ទងនឹងកម្រិតនៃការទទួលខុសត្រូវរបស់ លោក មាស មុត ឡើយ។

## ៣. សេចក្តីសន្និដ្ឋាន

៣៣៩. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃយ៉ាងត្រឹម

[848] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣៦, ៣៥០-៣៥២។ ក្រៅពីនេះ ចៅក្រមអន្តរជាតិបានពិនិត្យទៅលើធាតុផ្សំមួយចំនួនដែលបង្ហាញថា នៅពេលចរចាលើកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ទាំងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានព្រមព្រៀងគ្នាថា ប្រភេទបុគ្គលដែលត្រូវបានពិភាក្សា មិនផ្តោតទៅលើតែបុគ្គលម្នាក់ទេ (*សូមមើល* សេចក្តីថ្លែងហេតុរបស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីកម្ពុជានៅចំពោះមុខរដ្ឋសភាកម្ពុជា ប្រតិចារិកនៃសម័យប្រជុំលើកទីមួយ នីតិកាលទីបី នៃរដ្ឋសភាកម្ពុជា៖ ការពិភាក្សាដេញដោល និងការអនុម័យលើវិសោធនកម្មច្បាប់ស្តីពីការកាត់សេចក្តីមេដឹលនាំខ្មែរក្រហម ថ្ងៃទី០៤-០៥ ខែតុលា ឆ្នាំ២០០៤ អាចរកបាននៅលើគេហទំព័រ៖ http://law.scu.edu/wp-content/uploads/krt_law_debate.pdf (ចូលមើល ៧ មេសា 2021) ("ប្រសិនបើយើងសួរសំណួរថា "តើត្រូវចោទប្រកាន់អ្នកណាខ្លះ?" ទាំងអង្គការសហប្រជាជាតិ ទាំងក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាមិនអាចផ្តល់ចម្លើយបានទេ។ ដោយសារនេះជាកាតព្វកិច្ចរបស់តុលាការគឺ៖ អង្គជំនុំជម្រះវិសាមញ្ញ។ ប្រសិនបើយើងរៀបរាប់ឈ្មោះមនុស្សដែលត្រូវចោទប្រកាន់ជំនួសតុលាការ យើងរំលោភអំណាចរបស់តុលាការ។ ហេតុនេះ យើងមិនអាចកំណត់អត្តសញ្ញាណ ក, ខ, គ ឬ ឃ ថាត្រូវយកទៅជំនុំជម្រះបានទេ។ ជាដំណោះស្រាយ យើងបានកំណត់គោលដៅពីរគឺ៖ *មេដឹកនាំជាន់ខ្ពស់* និងអ្នក *ទទួលខុសត្រូវខ្ពស់បំផុត*។ [..] ទោះជាយ៉ាងណាក្តី នៅមានគោលដៅទីពីរទៀត។ ពួកគាត់មិនមែនជាមេដឹកនាំទេ តែជាអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងឃោរឃៅ។ ហេតុនេះហើយបានយើងប្រើពាក្យថា អ្នកទទួលខុសត្រូវខ្ពស់បំផុត។ *ពុំមានចំនួនមនុស្សជាក់លាក់នៅក្នុងក្រុមទីពីរដែលត្រូវយកមកជំនុំជម្រះទេ*។ អ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មខុសពីគ្នា និងយ៉ាងឃោរឃៅ អាចត្រូវបានយកមកជំនុំជម្រះ" (គូសបញ្ជាក់បន្ថែម))។ របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់កម្ពុជា ដែលត្រូវបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប លេខ A53/850 និង S/1999/231 ឧបសម្ព័ន្ធ កថាខណ្ឌ ១០៩-១១០ ("[គោលដៅសម្រាប់ស៊ើបអង្កេត] រាប់បញ្ចូលមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវចំពោះការរំលោភបំពាននានា ព្រមទាំងអ្នកនៅថ្នាក់ក្រោមបន្ទាប់ដែលបានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត។ [ក្រុមអ្នកជំនាញ] *ពុំមានបំណងផ្តល់នូវការកំណត់អំពីចំនួនបុគ្គលទាំងនេះ* ដែលអាចក្លាយជាគោលដៅនៃការស៊ើបអង្កេតទេ។ [..] បុគ្គលដែលត្រូវយកមកកាត់សេចក្តីអាចមាន*ក្នុងចន្លោះពី ២០ ទៅ ៣០ នាក់*") (គូសបញ្ជាក់បន្ថែម)។

01667473



ត្រូវអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់ មុខតំណែង និងការទទួលខុសត្រូវរបស់លោក មាស មុត ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្តឆន្ទានុសិទ្ធិក្នុងនាមចៅក្រម ដើម្បីកំណត់ថា លោក មាស មុត ស្ថិតនៅក្នុងប្រភេទនៃអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ ម្យ៉ាងវិញទៀត តាមការពិចារណាចំណុចខាងលើ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិមានំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការវាយតម្លៃចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់លើ មាស មុត និងនៅក្នុងការពិនិត្យឡើងវិញលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

៣៤០. អាស្រ័យហេតុនេះ ដោយបានពិនិត្យឡើងវិញលើវិសាលភាពនៃការចោទប្រកាន់ព្រហ្មទណ្ឌនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ភ័ស្តុតាងពាក់ព័ន្ធដែលត្រូវបានរកឃើញក្នុងអំឡុងពេលនៃការស៊ើបសួរ និងដោយពិចារណាលើឋានៈ និងការទទួលខុសត្រូវរបស់ លោក មាស មុត នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ចៅក្រមអន្តរជាតិតម្កល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា លោក មាស មុត ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដូច្នេះហើយគាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

## ង. សេចក្តីសន្និដ្ឋានចុងក្រោយ

### ១. ការយល់ឃើញនានាលើបណ្តឹងឧទ្ធរណ៍ និងអានុភាពនៃសេចក្តីពិចារណានេះ

៣៤១. យោងតាមសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិ ច្រានចោលភ្លាមៗនូវបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ។ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទោះបីជាចៅក្រមអន្តរជាតិតម្កល់មូលដ្ឋាន ខ និង គ នៃបណ្តឹងឧទ្ធរណ៍នេះក៏ដោយ ក៏ចៅក្រមអន្តរជាតិយល់ឃើញថា មូលដ្ឋាន ផ្សេងៗទៀតនៃបណ្តឹងឧទ្ធរណ៍នេះ លែងជាការចាំបាច់ទៀតហើយ ដោយសារតែដីកាលើកលែងចោទប្រកាន់ត្រូវបានទុកជាមោឃៈ ហើយពុំមានអានុភាពគតិយុត្តិឡើយ។

៣៤២. ពាក់ព័ន្ធនឹងផលវិបាកផ្នែកច្បាប់នៃសេចក្តីពិចារណានេះ ចៅក្រមអន្តរជាតិសូមលើកឡើងនូវចំណុចខាងក្រោម ដែលជាគោលការណ៍ណែនាំខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋាន នៅក្នុងរឿងក្តីនេះ។ ដូចបានពិភាក្សាខាងលើ[849] ទីមួយ ដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវបានចាត់ទុកជាមោ

[849] *សូមមើលខាងលើ* កថាខណ្ឌ ២២៨-២៥០, ២៨៤ ។

យៈ និងគ្មានសុពលភាព ដោយហេតុថាជាឯកសារគតិយុត្តិមិនពេញលេញ និងដោយគេចវេះទាំងស្រុងពីក្របខណ្ឌគតិយុត្តិដ៏សំខាន់ និងចាំបាច់របស់ អ.វ.ត.ក។ ហេតុនេះ ដីកានេះមិនអាចត្រូវបានពិចារណាឲ្យបានសមហេតុផលថាមានអានុភាពគតិយុត្តិឡើយ។ ទីពីរ មានការសម្រេចជាឯកច្ឆ័ន្ទ*តាមព្រឹត្តន័យ* ដោយអង្គបុរេជំនុំជម្រះលើករណីនេះថា៖ ទោះបីជាមានសំអាងហេតុខុសគ្នា ដូចបានពន្យល់នៅក្នុងមតិយោបល់ដោយឡែកដែលភ្ជាប់ទៅនឹងសេចក្តីពិចារណានេះក៏ដោយ ក៏ចៅក្រមជាតិ និងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានសម្រេចស្របគ្នាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាព[850]។

៣៨៣. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សំឡេងភាគច្រើនដែលតម្រូវ គឺសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤ (បួន) រូបយ៉ាងតិច អាចរកបាននៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ទាំងនេះ ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា ហើយថា ជាបញ្ហាអង្គហេតុ អង្គបុរេជំនុំជម្រះតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆន្ទ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកសំណុំរឿងមកពិនិត្យ ដោយឈរលើមូលដ្ឋានដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ចៅក្រមអន្តរជាតិ បញ្ជាក់ថា យោងតាមវិធាន ៧៧ (១៤) នៃវិធានផ្ទៃក្នុង សេចក្តីពិចារណាដែលមានភ្ជាប់ជាមួយនឹងមតិយោបល់នេះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេត ត្រូវបន្តកិច្ចនីតិវិធីជាបន្ទាន់ ស្របតាមសេចក្តីពិចារណានេះ ពោលគឺសេចក្តីសម្រេចតាមសំឡេងជាឯកច្ឆន្ទដោយអង្គបុរេជំនុំជម្រះ[851]។

៣៨៤. លើសពីនេះទៀត ពុំមានអង្គភាពតុលាការណាមួយនៃ អ.វ.ត.ក រកឃើញថា មិនមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងសំណុំរឿងនេះទេ ឬអង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួរ មិនពាក់ព័ន្ធជាមួយនឹង មាស មុត នោះឡើយ។ ប្រសិនបើសំណុំរឿងនេះ មិនបន្តទៅអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ទេនោះ អាជ្ញាធរកម្ពុជា ត្រូវពិចារណាបន្តយកមកកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនោះនៅចំពោះមុខតុលាការជាតិ ហើយជារួម ត្រូវធ្វើការចោទប្រកាន់ជនសង្ស័យទាំងអស់ចំពោះឧក្រិដ្ឋ

850 *សូមមើលខាងលើ* កថាខណ្ឌ ១១៥ (យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី)។ ខាងលើ កថាខណ្ឌ ២៨៤ ខាងក្រោម ទំព័រ ២០៨ (យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK)។

851 *សូមមើល* វិធាន ៧៧ (៤) នៃវិធានផ្ទៃក្នុង។

កម្មក្នុងរបបខ្មែរក្រហម ដែល អ.វ.ត.ក មិនត្រូវបានប្តឹងឲ្យយកមកធ្វើការជំនុំជម្រះ[852]។

២. វិធានការសន្តិសុខ

៣៤៥. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាថា ការឃុំខ្លួន មាស មុត បណ្តោះអាសន្ន រង់ចាំការជំនុំជម្រះមិនមែនជាវិធានការចាំបាច់ ដើម្បីបញ្ចៀសនូវកត្តាហានិភ័យនានាអនុលោមតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង[853] ឡើយ ហើយថា "ភាពមិនច្បាស់លាស់ផ្នែកនីតិវិធី ដោយសារមានដីកាដំណោះស្រាយផ្ទុយគ្នា" គឺជាសំអាងហេតុមួយទៀតដែលជំទាស់ទៅនឹងការបង្គាប់ឲ្យឃុំខ្លួន[854]។ សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាដល់វិធានការសន្តិសុខណាផ្សេងទៀត ដែលគាត់អាចប្រើប្រាស់បានទេ។

៣៤៦. ចៅក្រមអន្តរជាតិយល់ឃើញថា ការផ្តល់សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត បង្ហាញពីកំហុសឆ្គងយ៉ាងធ្ងន់ធ្ងរ។

ក. ច្បាប់ជាធរមាន

៣៤៧. ចៅក្រមអន្តរជាតិសង្កេតឃើញថា វិធាន ៦៣ នៃវិធានផ្ទៃក្នុង បញ្ញត្តិអំពីការឃុំខ្លួនបណ្តោះអាសន្ន។ ជាពិសេស វិធាន ៦៣(៣)(ខ) ចែងដូចខាងក្រោម៖

> ៣. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បាន តែក្នុង លក្ខខណ្ឌដូចខាងក្រោម៖
>
> ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

---

[852] *សូមមើលខាងលើ* កថាខណ្ឌ ១៧៦ ពាក់ព័ន្ធនឹងយុត្តាធិការរបស់តុលាការកម្ពុជាសម្រាប់ឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/០២ (D359/24 និង D360/33) កថាខណ្ឌ ៥៩។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៤/០១ កថាខណ្ឌ ៧៩។

[853] ដីកាដំណោះស្រាយ (D267) កថាខណ្ឌ ៥៧៨។

[854] ដីកាដំណោះស្រាយ (D267) កថាខណ្ឌ ៥៧៩។

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ។ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

៣៤៨. វិធាន ៦៥ នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

១. តាមការយល់ឃើញរបស់ខ្លួន ឬ តាមសំណើរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតអាចចេញបង្គាប់ឱ្យជនត្រូវចោទមានសេរីភាពឡើងវិញ ឬ ត្រូវដោះលែងពីការឃុំខ្លួន។ [..] ដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេតនេះត្រូវ [..] មានលក្ខខណ្ឌមួយចំនួន ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និង ដើម្បីការពារអ្នកដទៃទៀត [..]។

[..]

៦. បើជនត្រូវចោទរំលោភលក្ខខណ្ឌដែលមានចែងក្នុងដីកានេះ សហចៅក្រមស៊ើបអង្កេតអាចចេញសេចក្តីព្រមាន ឬ ចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះបាន [..]។

៣៤៩. វិធាន ៦៨ នៃវិធានផ្ទៃក្នុងចែងបន្ថែមទៀតដូចខាងក្រោម៖

១. ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាលក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬ ឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥ នៅតែតម្រូវ សហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀតឬ រក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែលនៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក នៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះ ត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង។

ខ. ការពិភាក្សា

៣៥០. ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅពេលចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតត្រូវតែពិនិត្យថាតើ មានលក្ខខណ្ឌសម្រាប់បង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ឬដោះលែងពីការឃុំខ្លួន អនុលោមតាមវិធាន ៦៣(៣)(ខ) និង ៦៥ នៃវិធានផ្ទៃក្នុង ដែរឬយ៉ាងណា ហើយត្រូវសម្រេចទៅតាមនោះ ថាតើពួកគេអាចបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នឬដោះលែងពីការឃុំខ្លួនឬបង្គាប់ឲ្យជនត្រូវចោទមានសេរីភាពឡើងវិញ[855]។

៣៥១. ទោះជាយ៉ាងណាក្តី ក្នុងករណីនៅចំពោះមុខនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ពិសេស *(sui generis)* ហើយដែលចៅក្រមអន្តរជាតិយល់ឃើញថា ជាដីកាបង្គាប់ដែលមានបញ្ហា ("ដីកាស្តីពីការអនុវត្តតាមការធានាអះអាងដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្ត")[856] ដែល មាស មុត មានកាតព្វកិច្ច "ក្នុងករណីដែលគាត់ទទួលបានលិខិតឆ្លងដែនដែលមានសុពលភាព គាត់ត្រូវប្រគល់លិខិតឆ្លងដែននេះជូនទៅមេប៉ុស្តិ៍នគរបាលឃុំតាសាញ ដែលមានទីតាំងនៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង មិនឲ្យហួសពីរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលដីកានេះ ឬបន្ទាប់ពីទទួលបានលិខិតឆ្លងដែន"[857] និង "ជូនដំណឹងដល់ [សហចៅក្រមស៊ើបអង្កេត] នៅពេលគាត់ត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយសារមូលហេតុសុខភាព និងនៅពេលគាត់វិលត្រឡប់មកវិញ"[858]។

៣៥២. ក្នុងការឆ្លើយតបទៅនឹងការតាំងសំណួរពីចៅក្រម ក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ សហមេធាវីអន្តរជាតិការពារក្តី មាស មុត លោក Michael KARNAVAS[859] បានលើកឡើងដោយមានការសោក

[855] វិធាន ៦៥ នៃវិធានផ្ទៃក្នុង។

[856] ដីកាស្តីពីការអនុវត្តតាមការធានាអះអាងដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្ត នៅពេលបង្ហាញខ្លួនលើកដំបូងចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៥ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D174/2។

[857] ដីកាស្តីពីការអនុវត្តតាមការធានាអះអាងដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្ត នៅពេលបង្ហាញខ្លួនលើកដំបូងចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៥ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D174/2 ទំព័រ ២។

[858] ដីកាស្តីពីការអនុវត្តតាមការធានាអះអាងដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្ត នៅពេលបង្ហាញខ្លួនលើកដំបូងចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៥ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D174/2 ទំព័រ ១១។

[859] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ (CS) ឯកសារ D266/18.2 និង ឯកសារ D267/13.2 ERN (ភាសាអង់គ្លេស) 01639993 ទំព័រ ២២ បន្ទាត់ ០៦ ដល់ ទំព័រ ២២ បន្ទាត់ ១៦ *យោងទៅ* សំណើរបស់ មាស មុត សុំអនុញ្ញាតមិនចូលបង្ហាញខ្លួនផ្ទាល់ក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/13 និង ឯកសារ D267/18 កថាខណ្ឌ ២។

ស្តាយថា៖

លោកចៅក្រមជាទីគោរព និយាយស្មោះត្រង់ ករណីថាតើ [មាស មុត] មាន ឬមិនមានលិខិតឆ្លងដែននោះ គ្មានអ្វីខុសប្លែកគ្នាទេ។ គាត់អាចចាកចេញទៅប្រទេសថៃ [នៅជិតស្រុកសំឡូត មានច្រកព្រំដែនជាច្រើនទៅប្រទេសថៃ ហើយងាយស្រួលឆ្លងទៅទីនោះ ដោយគ្រាន់តែមានលិខិតបញ្ជាក់អត្តសញ្ញាណជាការស្រេច] ក្នុងគោលបំណងពិនិត្យសុខភាពបាន។ [..] ខ្ញុំបានដឹងកាលពីព្រឹកម៉ិញនេះថា គាត់មានលិខិតឆ្លងដែនថ្មី ហើយមានតាំងពីឆ្នាំ២០១៦ មក។ ហើយវានៅនឹងគាត់ស្រាប់។ [..] [គាត់] មិនបានប្រគល់លិខិតឆ្លងដែនឱ្យទៅនគរបាលទេ។ [..] [គាត់] នៅមានវានៅឡើយ[860] ។

៣៥៣. ចៅក្រមអន្តរជាតិសង្កេតឃើញថា មាស មុត ទទួលបានលិខិតឆ្លងដែននៅឆ្នាំ២០១៦ និងបានធ្វើដំណើរទៅបរទេសចាប់តាំងពីពេលនោះមក ដោយមិនបានជូនដំណឹងដល់អាជ្ញាធរ អ.វ.ត.ក ឡើយ។ ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា មាស មុត មិនបានគោរពតាមការធានា ដែលគាត់បានសន្យាដោយផ្ទាល់ និងដោយស្ម័គ្រចិត្តចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិចាប់តាំងពីឆ្នាំ២០១៦។

៣៥៤. យោងតាមហេតុផលខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមុនពេលចេញដីកាដំណោះស្រាយរបស់ខ្លួន ខកខានមិនបានពិនិត្យពិចារណាថាតើ ការធានាដោយស្ម័គ្រចិត្ត ដែល មាស មុត បានសន្យា បានគោរពយ៉ាងត្រឹមត្រូវដែរឬទេ ជាហេតុខកខានមិនបានពិចារណាឱ្យបានត្រឹមត្រូវលើដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬ ឱ្យនៅក្រៅឃុំ១៣៧មានលក្ខខណ្ឌចាំបាច់ ដើម្បីធានាវត្តមានរបស់ មាស មុត ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី និងការការពារអ្នកដទៃទៀតស្របតាមវិធានផ្ទៃ ៦៣ និង៦៥។

៣៥៥. សំខាន់ជាងនេះ ចៅក្រមអន្តរជាតិយល់ឃើញថា នៅពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបង្ហាញក្របខ័ណ្ឌច្បាប់ច្បាស់លាស់ ស្របតាមវិធានផ្ទៃក្នុង។

៣៥៦. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានដោយមាន

[860] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ (CS) ឯកសារ D266/18.2 និង ឯកសារ D267/13.2 ERN (ភាសាអង់គ្លេស) 01639993-01639994 ទំព័រ ២២ បន្ទាត់ ២៥ ដល់ ទំព័រ ២៣ បន្ទាត់ ២៣។

កំហុសថា គ្មានវិធានការសន្តិសុខចាំបាច់ទេ។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា មាស មុត ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមនុស្សឃាត ដែលគាត់ប្រឈមការជាប់ពន្ធនាគារអស់មួយជីវិត ហើយពិចារណាថា ចាំបាច់ត្រូវនាំ មាស មុត មកជំនុំជម្រះ។ សហចៅក្រមអន្តរជាតិសូមរំលឹកថា មិនត្រូវដាក់បន្ទុកមិនសមស្របលើសាក្សីនោះទេ ជាពិសេសអ្នកដែលទទួលបានលិខិតធានាពីសហចៅក្រមស៊ើបអង្កេត យោងតាមវិធាន ២៨ នៃវិធានផ្ទៃ[861]។ ដោយមើលឃើញអំពីលក្ខណៈធ្ងន់ធ្ងរនៃអំពើអន្តរាយដល់មនុស្សជាតិ ដែលអាជ្ញាយុកាលមិនមានកំណត់ ហើយការប៉ះពាល់ដ៏ធ្ងន់ធ្ងរលើសណ្ដាប់ធ្នាប់សាធារណៈទាំងក្នុងសង្គមជាតិ និងអន្តរជាតិ ចៅក្រមអន្តរជាតិយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន ឬ វិធានការសន្តិសុខផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចអនុវត្តប្រឆាំង មាស មុត ត្រូវធ្វើឡើងឱ្យបានសមស្រប។

៣៥៧. ចំណុចទី២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានវាយតម្លៃកត្តាហានិភ័យឱ្យបានត្រឹមត្រូវអនុលោមតាមវិធានផ្ទៃ ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង។ ក្នុងករណីនេះ ចៅក្រមអន្តរជាតិកត់សម្គាល់អង្គហេតុដែលថា មាស មុតទទួលបានលិខិតឆ្លងដែនថ្មីមួយច្បាប់ក្នុងឆ្នាំ២០១៦ និងបានធ្វើដំណើរទៅប្រទេសថៃ ចាប់តាំងពីពេលនោះមកដោយមិនបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត[862] ផ្ទុយពីការប្ដេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់គាត់ថានឹងត្រៀមខ្លួនធ្វើតាម អ.វ.ត.ក ក៏ដូចជាការធានាដោយស្ម័គ្រចិត្តរបស់គាត់ចំពោះបញ្ហានេះ ដែលបានសន្យាចំពោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[863]។

៣៥៨. អាស្រ័យហេតុនេះ យោងតាមវិធាន ៤៤ និងអង្គហេតុនៅក្នុងសំណុំរឿង ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយសារខកខានមិនបានពិចារណាឱ្យបាន

---

[861] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ (D359/24 និង D360/33) កថាខណ្ឌ ៦៩១។ ពាក់ព័ន្ធនឹងលិខិតធានាអះអាងដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះសាក្សីនានា សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៤៧។

[862] សំណុំរឿង ០០៣ ប្រតិចារឹក ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ (CS) ឯកសារ D266/18.2 និង D267/13.2 ERN (ភាសាអង់គ្លេស) 01639994 ទំព័រ 23:20 ដល់ 23:21។ សំណើរបស់ មាស មុត សុំអនុញ្ញាតមិនចូលបង្ហាញខ្លួនផ្ទាល់ក្នុងសវនាការលើបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/13 និង D267/18 កថាខណ្ឌ ២។

[863] *សូមមើល* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ឯកសារ D174 ទំព័រ ១១។ ដីកាស្ដីពីការអនុវត្តតាមការធានាអះអាង ដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្តនៅពេលបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D174/2 ទំព័រ ២។

01667480



ត្រឹមត្រូវក្នុងការចេញដីកាបង្គាប់ឲ្យនាំខ្លួន។ ការគេចវេសដោយចេតនាក្នុងការចាត់វិធានការបណ្ដោះអាសន្ន បង្ហាញពីចេតនារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបន្ថយអត្ថន័យ និងប្រសិទ្ធភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់។

**យោងតាមសំអាងហេតុខាងនេះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ÷**

- បដិសេធ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ។
- យល់ឃើញ ថា មូលដ្ឋាន ខ និង គ នៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានតម្កល់ និងប្រកាស ថា មូលដ្ឋានផ្សេងៗទៀតនៃបណ្ដឹងឧទ្ធរណ៍នេះលែងជាការចាំបាច់ទៀតហើយ។
- យល់ឃើញ ថា ដីកាលើកលែងចោទប្រកាន់ត្រូវទុកជាមោឃៈ។
- តម្កល់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។
- យល់ឃើញ ថា អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកសំណុំរឿង ០០៣ មកពិនិត្យ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២១

**ចៅក្រម** **Olivier BEAUVALLET**

**ចៅក្រម Kang Jin BAIK**